


សង្ខេបរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកល ២០១៧/៨

# គណនេយ្យភាព ក្នុងវិស័យអប់រំ៖

## គោរពតាមអ្វីដែលយើងបានសន្យា

United Nations Educational, Scientific and Cultural Organization
Sustainable Development Goals

KH/2017/RP/78
Phnom Penh, November 2017
Original: English

Global Education Monitoring Report

សង្ខេបរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកល

២០១៧/៨

# គណនេយ្យភាព ក្នុងវិស័យអប់រំ៖

## គោរពតាមអ្វីដែលយើងបានសន្យា

*សេចក្តីប្រកាសអ៊ីនឈ័ននិងក្របខ័ណ្ឌសកម្មភាពវិស័យអប់រំឆ្នាំ២០៣០*ចែងថារបាយការណ៍ពិនិត្យតាមដានការអប់រំជាសកលមានតួនាទីជា "យន្តការសម្រាប់ពិនិត្យតាមដាន និងរាយការណ៍ពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤ និងពីការអប់រំដែលត្រូវបានបញ្ចូលទៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពផ្សេងទៀត" និង "រាយការណ៍ពីការអនុវត្តយុទ្ធសាស្ត្រជាតិ និងអន្តរជាតិ ដើម្បីទាមទារឱ្យគ្រប់ដៃគូពាក់ព័ន្ធទាំងអស់មានគណនេយ្យភាពចំពោះអ្វីដែលពួកគេបានសន្យាជាផ្នែកមួយនៃការតាមដានបន្តនិងការពិនិត្យលើគោលដៅអភិវឌ្ឍន៍ដោយចីរភាពជារួម។របាយការណ៍នេះត្រូវបានរៀបចំឡើងដោយអ្នកជំនាញឯករាជ្យមួយក្រុម ក្រោមការដឹកនាំរបស់យូណេស្កូ។

ឈ្មោះតួនាទី ដែលត្រូវបានប្រើប្រាស់ និងព័ត៌មានដែលបង្ហាញក្នុងឯកសារបោះពុម្ពផ្សាយនេះ មិនមែនជាការបញ្ចេញមតិរបស់យូណេស្កូ ពាក់ព័ន្ធនឹងស្ថានភាពស្របច្បាប់របស់ប្រទេស ដែនដីទីក្រុង ឬតំបន់ណាមួយ ឬសមត្ថកិច្ចរបស់ប្រទេស ដែនដីទីក្រុង ឬតំបន់នេះ ឬពាក់ព័ន្ធនឹងការកំណត់ព្រំប្រទល់ដែនរបស់ប្រទេស ដែនដីទីក្រុង ឬតំបន់ទាំងនេះឡើយ។

ក្រុមការងាររៀបចំរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកលនេះ គឺជាអ្នកទទួលខុសត្រូវលើការជ្រើសរើស និងការបង្ហាញអង្គហេតុ ក្នុងឯកសារបោះពុម្ពផ្សាយនេះ និងលើទស្សនៈដែលត្រូវបានបញ្ចេញក្នុងឯកសារនេះ។ ទស្សនៈទាំងនេះមិនមែនជាទស្សនៈយូណេស្កូ ហើយមិនតម្រូវឲ្យយូណេស្កូជាប់កាតព្វកិច្ចអ្វីមួយឡើយ។ ប្រធានក្រុមការងារនេះ ជាអ្នកទទួលខុសត្រូវជារួមលើគំនិតយោបល់ និងទស្សនៈយល់ឃើញ ដែលត្រូវបានលើកឡើងក្នុងរបាយការណ៍នេះ។

## ក្រុមការងាររៀបចំរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកល

*ប្រធានក្រុម៖* Manos Antoninis

Madeleine Barry, Nicole Bella, Nihan Köseleci Blanchy, Anna D'Addio, Priyadarshani Joshi, Katarzyna Kubacka, Leila Loupis, Kassiani Lythrangomitis, Alasdair McWilliam, Anissa Mechtar, Branwen Millar, Claudine Mukizwa, Yuki Murakami, Taya Louise Owens, Judith Randrianatoavina, Kate Redman, Maria Rojnov, Will Smith និង Rosa Vidarte។

*ក្រុមការងាររៀបចំរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកលនេះ សូមថ្លែងអំណរគុណដល់ Aaron Benavot ប្រធានក្រុមការងារមុន ដែលបានដឹកនាំការស្រាវជ្រាវ និងការរៀបចំរបាយការណ៍នេះឡើង។*

*របាយការណ៍ពិនិត្យតាមដានការអប់រំជាសកលនេះ*គឺជាឯកសារបោះពុម្ពផ្សាយឯករាជ្យប្រចាំឆ្នាំ។ របាយការណ៍ GEM នេះ ត្រូវបានរៀបចំឡើង ក្រោមការឧបត្ថម្ភថវិកាពីរដ្ឋាភិបាល ទីភ្នាក់ងារពហុភាគី និងមូលនិធិឯកជន និងមានការសម្របសម្រួល និងការគាំទ្រពីយូណេស្កូ។

ឯកសារបោះពុម្ពផ្សាយនេះត្រូវបានផ្សព្វផ្សាយ ឱ្យមានការប្រើប្រាស់ជាចំហ ក្រោមអាជ្ញាប័ណ្ណ Attribution-ShareAlike 3.0 IGO (CC-BY-SA 3.0 IGO) license (http://creativecommons.org/licenses/by-sa/3.0/igo/)។ តាមរយៈការដកស្រង់ខ្លឹមសារពីឯកសារបោះពុម្ពផ្សាយនេះទៅប្រើប្រាស់ អ្នកប្រើប្រាស់ទទួលថាខ្លួននឹងជាប់កាតព្វកិច្ចគោរពតាមលក្ខខណ្ឌនៃការប្រើប្រាស់ ដែលកំណត់ដោយបណ្ណាល័យដែលអាចចូលប្រើប្រាស់ដោយសេរីរបស់យូណេស្កូ (http://www. unesco.org/open-access/terms-use-ccbysa-en)។

ចំណងជើងដើមជាភាសាអង់គ្លេស៖ Global Education Monitoring Report Summary 2017/8: Accountability in education: Meeting our commitments

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖**
ក្រុមរៀបចំរបាយការណ៍ពិនិត្យតាមដានស្ថានភាព នៃការអប់រំទូទាំងសកលលោក
អង្គការយូណេស្កូ អាសយដ្ឋាន 7, place de Fontenoy
75352 Paris 07 SP, France
អ៊ីមែល៖ gemreport@unesco.org
ទូរស័ព្ទ៖ +33 1 45 68 07 41
www.unesco.org/gemreport
https://gemreportunesco.wordpress.com

រាល់កំហុស ឬការខ្វះព័ត៌មាន ដែលរកឃើញក្រោយពេលបោះពុម្ពនឹងត្រូវកែតម្រូវក្នុងសំណៅអនឡាញនៃឯកសារនេះ ដែលអាចរកបានតាមរយៈគេហទំព័រ www.unesco.org/gemreport

© UNESCO, ២០១៧
រក្សាសិទ្ធិគ្រប់បែបយ៉ាង
កំណែទីមួយ
បោះពុម្ពផ្សាយក្នុងឆ្នាំ ២០១៧ ដោយអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃសហប្រជាជាតិ
7, Place de Fontenoy, 75352
Paris 07 SP, France

វាយអត្ថបទដោយយូណេស្កូ
រចនាក្រាហ្វិចដោយ FHI 360
រចនាសម្រាប់បោះពុម្ពដោយ FHI 360
គំនូរជីវចលដោយ Toby Morris

**របាយការណ៍ពិនិត្យតាមដានស្ថានភាពនៃការអប់រំទូទាំងសកលលោកចុងក្រោយ**

២០១៧/៨ គណនេយ្យភាពក្នុងវិស័យអប់រំ៖ គោរពតាមអ្វីដែលយើងបានសន្យា
២០១៦ ការអប់រំសម្រាប់មនុស្សនិងផែនដី៖បង្កើតអនាគតប្រកបដោយនិរន្តរភាព សម្រាប់ទាំងអស់គ្នា

**របាយការណ៍ពិនិត្យ តាមដានទូទាំងសកលលោកសម្រាប់ការអប់រំសម្រាប់ទាំងអស់គ្នា**

២០១៥ ការអប់រំសម្រាប់ទាំងអស់គ្នា២០០០-២០១៥៖ សមិទ្ធផលសម្រេចបាន និងបញ្ហាប្រឈម
២០១៣/៤ ការបង្រៀន និងរៀន៖ សម្រេចឲ្យបាននូវគុណភាពសម្រាប់ទាំងអស់គ្នា
២០១២ យុវជន និងជំនាញ៖ ប្រែក្លាយការអប់រំជាការបំពេញការងារ
២០១១ វិបត្តិលាក់មុខ៖ ជម្លោះប្រដាប់អាវុធ និងការអប់រំ
២០១០ ការផ្តល់សេវាដល់ក្រុមដែលពុំមានឱកាស
២០០៩ ការជំនះវិសមភាព៖ ហេតុអ្វីបានជាអភិបាលកិច្ចមានសារៈសំខាន់
២០០៨ ការអប់រំសម្រាប់ទាំងអស់គ្នាត្រឹមឆ្នាំ ២០១៥៖ តើយើងអាចសម្រេចវាបានដែរឬទេ?
២០០៧ មូលដ្ឋានរឹងមាំ៖ ការគាំពារ និងអប់រំកុមារតូច
២០០៦ អក្ខរកម្ម ដើម្បីជីវិត
២០០៥ ការអប់រំសម្រាប់ទាំងអស់គ្នា៖ គុណភាពដែលចាំបាច់ត្រូវមាន
២០០៣/៤ យេនឌ័រ និងការអប់រំសម្រាប់ទាំងអស់គ្នា៖ ការបោះជំហានទៅរកសមភាព
២០០២ ការអប់រំសម្រាប់ទាំងអស់គ្នា៖ តើពិភពលោកស្ថិតតាមផែនការដែលបានគ្រោងទុកដែរឬទេ?

រូបថតគ្របមុខ និងគ្របក្រោយ៖ David Tett
រូបជីវចលដោយ Godfrey Mwampembwa (GADO)
រូបភាពដោយ Housatonic Design Network

រូបថតគ្របមុខជាការតវ៉ានៅសាលាបឋមសិក្សាវិនដេល ក្នុងប្រទេសអង់គ្លេស (ចក្រភពអង់គ្លេស) ប្រឆាំងនឹងការកាត់ថវិកាសាលារៀនរបាយការណ៍សង្ខេប និងឯកសារពាក់ព័ន្ធនានា អាចដោនឡូតពី៖ bitly.com/CountOnME និង gem-report-2017.unesco.org។

# អារម្ភកថា

បច្ចុប្បន្ននេះ មានកុមារ និងយុវជនចំនួន ២៦៤ លាននាក់ពុំបានទៅរៀន - នេះគឺជាបរាជ័យមួយដែលយើងចាំបាច់ត្រូវរួមគ្នាឆ្លើយតប នោះគឺដោយសារតែការអប់រំគឺជាការទទួលខុសត្រូវរួមរបស់យើងទាំងអស់គ្នា ហើយវឌ្ឍនភាពអាចសម្រេចទៅបានប្រកបដោយចីរភាព លុះត្រាតែមានកិច្ចខិតខំប្រឹងប្រែងរួមគ្នាពីយើងទាំងអស់គ្នាតែប៉ុណ្ណោះ។ នេះគឺជាអ្វីដែលសំខាន់ចាំបាច់ ដើម្បីសម្រេចទៅតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសម្រាប់ការអប់រំ (គោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាពទី ៤) ដែលជាផ្នែកមួយ នៃរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០។ រដ្ឋាភិបាល សាលារៀន និងគ្រូ គឺជាអ្នកបំពេញតួនាទីជួរមុខ ដែលត្រូវធ្វើការរួមគ្នាជាមួយសិស្សផង និងមាតាបិតារបស់ពួកគេផង។

ការបោះជំហានទៅមុខ ទាមទារឱ្យមានការកំណត់ការទទួលខុសត្រូវឱ្យបានច្បាស់លាស់ត្រូវដឹងពីពេល និង ទីកន្លែងដែលមាន ការខកខាន ពុំបាន បំពេញ ទៅតាម ការទទួលខុសត្រូវ ទាំងនេះ និង ពី សកម្មភាព ដែលចាំបាច់សម្រាប់ឆ្លើយតប - នេះគឺជាអត្ថន័យនៃពាក្យថាគណនេយ្យភាព ដែលជាប្រធានបទនៃរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកលនេះ។ របាយការណ៍នេះបានទាញចេញនូវសេចក្តីសន្និដ្ឋានយ៉ាងជាក់ច្បាស់ថា - កង្វះគណនេយ្យភាពអាចធ្វើឱ្យវឌ្ឍនភាពដែលសម្រេចបានកន្លងមក ត្រូវរលាយបាត់ទៅវិញ ជាហេតុនាំឱ្យការអនុវត្តមិនល្អអាចបង្កឱ្យមានគ្រោះថ្នាក់ កប់ចូលជ្រៅទៅក្នុងប្រព័ន្ធអប់រំ។ ការពុំមានការរៀបចំផែនការអប់រំឱ្យបានច្បាស់លាស់ពីសំណាក់រដ្ឋាភិបាល អាចនាំឱ្យមានការកំណត់តួនាទីពុំបានច្បាស់លាស់ មានន័យថាការសន្យា នានា នៅត្រឹមតែជាការសន្យា ហើយគោលនយោបាយផ្សេងៗពុំមានថវិកាសម្រាប់អនុវត្តឡើយ។ នៅពេលដែល ប្រព័ន្ធ សាធារណៈ ពុំបាន ផ្តល់ ការអប់រំ ដែលមាន គុណភាព គ្រប់គ្រាន់ ហើយ តួអង្គ រកប្រាក់ចំណេញចូលមកបំពេញចន្លោះខ្វះខាតនេះ ប៉ុន្តែពួកគេដំណើរការដោយពុំមានការគ្រប់គ្រង ឱ្យបានត្រឹមត្រូវ ពេលនោះក្រុមដែលពុំមានឱកាសគឺជាក្រុមដែលត្រូវខាតបង់។ រដ្ឋាភិបាលគឺជាអ្នកដែលមានភារកិច្ចចម្បងក្នុងការបំពេញសិទ្ធិទទួលបានការអប់រំប៉ុន្តែនៅក្នុងប្រទេសប្រមាណជាជិតពាក់កណ្តាលក្នុងចំណោមប្រទេសសរុបក្នុងពិភពលោក សិទ្ធិមួយនេះគឺជាសិទ្ធិដែលគេមិនអាចយកមកកាត់សេចក្តីកេយុត្តិធម៌ក្នុងប្រព័ន្ធតុលាការបានឡើយ ដូច្នេះគេត្រូវបាត់ច្រកដ៏សំខាន់មួយ ដើម្បីស្វែងរកយុត្តិធម៌ដល់អ្នកដែលពុំបានទទួលសិទ្ធិនេះ។

គ្រប់គ្នាសុទ្ធតែមានតួនាទីត្រូវបំពេញ ដើម្បីធ្វើឱ្យការអប់រំកាន់តែមានភាពប្រសើរជាងមុន។ កិច្ចខិតខំប្រឹងប្រែងនេះត្រូវចាប់ផ្តើមចេញពីប្រជាពលរដ្ឋទៅ ដោយត្រូវមានការគាំទ្រពីអង្គការសង្គមស៊ីវិល និងស្ថាប័នសិក្សាស្រាវជ្រាវ ដែលជាអ្នកគូសបង្ហាញឱ្យឃើញពីចំណុចខ្វះខាត ដើម្បីឱ្យមានការផ្តល់ការអប់រំដែលមានគុណភាពខ្ពស់ និងមានសមធម៌។ នៅបណ្តាប្រទេសជាច្រើន ជារឿយៗចលនារបស់សិស្សនិស្សិតធ្វើឱ្យមានការប្រែប្រួល ដល់ការរៀបចំគោលនយោបាយអប់រំដែលមានសមធម៌ និងអស់ចំណាយសមរម្យដែលនេះបង្ហាញឱ្យឃើញពីអំណាចដែលយើងទាំងអស់គ្នាមានរួមគ្នា និងដែលយើងត្រូវយកមកប្រើប្រាស់ ដើម្បីជំរុញឱ្យមានការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤។ អង្គការអន្តរជាតិក៏បានបំពេញតួនាទីនាំមុខក្នុងការសម្រួចគោលដៅ និងចំណុចដៅថ្មីៗ ដើម្បីដោះស្រាយបញ្ហាប្រឈមដ៏សែនស្មុគស្មាញ ដែលយើងកំពុងជួបប្រទះនាពេលបច្ចុប្បន្ននេះផងដែរ។

របាយការណ៍នេះបង្ហាញថា មិនមែនគ្រប់វិធីសាស្ត្រទាមទារគណនេយ្យភាពទាំងអស់ សុទ្ធតែកំពុងអាចជួយឱ្យយើងសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤នោះទេ។ ឧទាហរណ៍នៅតាមតំបន់មួយចំនួនក្នុងពិភពលោក វាក្លាយទៅជាការអនុវត្តធម្មតា ដែលគ្រូ និងសាលារៀនត្រូវទទួលទណ្ឌកម្ម នៅពេលលទ្ធផលតេស្តមិនបានល្អ ដោយគេលើកហេតុផលថា នេះជាកិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើនគុណភាពនៃការបង្រៀន និង រៀន។ របាយការណ៍ នេះ សន្និដ្ឋានថា ការដាក់ទណ្ឌកម្មបែបនេះ ត្រូវតែ ធ្វើឡើង ដោយមានការប្រុងប្រយ័ត្នខ្ពស់ ដើម្បីបញ្ចៀសមិនឱ្យមានផលវិបាកផ្ទុយទៅនឹងអ្វីដែលគេចង់បាន។

មានភស្តុតាងជាច្រើនបង្ហាញថា ការធ្វើតេស្តក្នុងទ្រង់ទ្រាយធំ ដោយប្រើរង្វាស់លទ្ធផលសិក្សាដែលមានលក្ខណៈចង្អៀតអាចលើកទឹកចិត្តឱ្យគេ "លេងល្បែងជាមួយនឹងប្រព័ន្ធនេះទៅវិញ" ដែលអាចបង្កផលប៉ះពាល់ជាអវិជ្ជមានលើការរៀនសូត្រ និងជាការដាក់ទណ្ឌកម្មលើសលុបលើក្រុមដែលពុំមានឱកាស។ ជាការសំខាន់ណាស់ដែលគេត្រូវប្រមូលទិន្នន័យអំពីលទ្ធផលនៃការរៀនសូត្រ ដើម្បីបង្ហាញឱ្យឃើញពីកត្តានានា ដែលនាំឱ្យមានវិសមភាពក្នុងការអប់រំ។ ប៉ុន្តែការ ទាញ ចេញ នូវ សេចក្តីសន្និដ្ឋាន ឱ្យបាន ច្បាស់លាស់ ត្រូវការ ពេលវេលា ធនធាន និងជំនាញ ដែលមានតែប្រទេសមួយចំនួនតូចតែប៉ុណ្ណោះដែលមាន ហើយការទាញចេញនូវសេចក្តីសន្និដ្ឋានខុស ក៏ជាអ្វីដែលគេងាយស្រួលធ្វើផងដែរ។

គណនេយ្យភាពដែលមានន័យថា ជាការអាចធ្វើសកម្មភាព នៅពេលដែលអ្វីមួយកើតឡើងពុំបានត្រឹមត្រូវតាមរយៈការដាក់ចេញនូវគោលនយោបាយច្បាប់និងការធ្វើការតស៊ូមតិដូចជាតាមរយៈការិយាល័យតំណាងប្រជាពលរដ្ឋ ដើម្បីការពារសិទ្ធិរបស់ប្រជាពលរដ្ឋជាដើម។ យើងត្រូវការ យន្តការរឹងមាំជាងមុន ដើម្បីគោរព និងអនុវត្តសិទ្ធិទទួលបានការអប់រំ និងទាមទារឱ្យរដ្ឋាភិបាលទាំងអស់ រាប់បញ្ចូលទាំងអ្នកជំនួយ ផងដែរ មានគណនេយ្យភាព ចំពោះអ្វីដែលពួកគេបានសន្យា។

ពាក្យថា "គណនេយ្យភាព" បានលេចចេញនៅគ្រប់កន្លែងក្នុងក្របខ័ណ្ឌសកម្មភាពសម្រាប់ការអប់រំ *ឆ្នាំ ២០៣០* ដែលបង្ហាញពីសារៈសំខាន់ ដែលយូណេស្កូ និងសហគមន៍អន្តរជាតិផ្តល់ដល់ការតាមដាន និងពិនិត្យឡើងវិញលើមុខងារនានា ដើម្បីពិនិត្យតាមដានវឌ្ឍនភាពដែលសម្រេចបាន។ នេះក៏មានន័យផងដែរថា គ្រប់ប្រទេសទាំងអស់គួររៀបចំរបាយការណ៍ពិនិត្យតាមដានការអប់រំក្នុងប្រទេសរបស់ខ្លួន ដោយត្រូវពន្យល់ពីវឌ្ឍភាពសម្រេចបាន ធៀបនឹងអ្វីដែលខ្លួនបានសន្យា ដែលបច្ចុប្បន្ននេះមានប្រទេសប្រមាណជាពាក់កណ្តាលប៉ុណ្ណោះ ដែលបានរៀបចំរបាយការណ៍បែបនេះ ហើយប្រទេសភាគច្រើនពុំបានរៀបចំរបាយការណ៍បែបនេះឱ្យបានទៀងទាត់ឡើយ។ គណនេយ្យភាពសំដៅលើការបកស្រាយភស្តុតាង ការកំណត់បញ្ហា និងការធ្វើការងាររួមគ្នា ដើម្បីកំណត់ពីរបៀបដោះស្រាយបញ្ហាទាំងនេះ។ ដើម្បីសម្រេចឱ្យបាននូវការអប់រំ ប្រកបដោយសមធម៌ និងគុណភាពខ្ពស់សម្រាប់ទាំងអស់គ្នា គណនេយ្យភាពត្រូវតែជាមូលដ្ឋានគ្រឹះនៃគ្រប់កិច្ចខិតខំប្រឹងប្រែងទាំងអស់របស់យើង។

Irina Bokova

អគ្គនាយកនៃអង្គការយូណេស្កូ



# គណនេយ្យភាពក្នុងវិស័យអប់រំ

របាយការណ៍ពិនិត្យតាមដានការអប់រំជាសកលឆ្នាំ ២០១៧-២០១៨ នេះ ធ្វើការវាយតម្លៃលើតួនាទីនៃគណនេយ្យភាព ក្នុងប្រព័ន្ធអប់រំសកល សំដៅឈានទៅសម្រេចចក្ខុវិស័យដាក់ចេញក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) ទី ៤ របស់អង្គការសហប្រជាជាតិ៖ ការធានានូវការអប់រំបរិយាប័ន្នប្រកបដោយគុណភាព និងសមធម៌ និងការរៀនសូត្រពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

ប្រជាជនដែលទទួលបានការអប់រំកាន់តែមានចំនួនច្រើនឡើង ប៉ុន្តែទន្ទឹមគ្នានេះ ក៏មានភស្តុតាងដែលបង្ហាញពីការទទួលបានលទ្ធផលសិក្សាទាបផងដែរ។ ប្រការនេះឱ្យមានការផ្តោតការយកចិត្តទុកដាក់ខ្លាំងលើចំណុចខ្វះខាតដែលបន្តកើតមានជុំវិញការផ្តល់ការអប់រំ និងគុណភាពការអប់រំ។ បញ្ហាទាំងនេះ ផ្ទួបផ្សំនឹងការផ្តល់ថវិកាតិចតួចសម្រាប់វិស័យអប់រំ និងការចង់បានផលឱ្យបានច្រើនពីថវិកាចំណាយនៅទូទាំងពិភពលោកផងដែរនោះ នាំឱ្យបណ្តាប្រទេសនានាត្រូវខិតខំស្វែងរកដំណោះស្រាយចំពោះបញ្ហាទាំងនេះ។ ការបង្កើនគណនេយ្យភាព តែងតែជាអាទិភាពមួយ ក្នុងចំណោមអាទិភាពចំពោះមុខនានា។

គណនេយ្យភាពអាចជាគុណធម៌មួយ។ គណនេយ្យភាពសំដៅលើភាពអាចឆ្លើយបាន នៅពេលគេសួរសំណួរអ្វីមួយ និងភាពអាចជឿទុកចិត្តបាន។ ក្នុងរបាយការណ៍នេះ គណនេយ្យភាពត្រូវបានឱ្យនិយមន័យថាជាយន្តការមួយប្រភេទ។ បើគិតតាមហេតុផលច្បាប់ នយោបាយ សង្គម ឬសីលធម៌រដ្ឋាភិបាល និងតួអង្គដទៃទៀត ដែលបំពេញតួនាទីក្នុងវិស័យអប់រំ មានកាតព្វកិច្ចរាយការណ៍ពីអ្វីដែលខ្លួនបានធ្វើ ដើម្បីបំពេញទៅតាមការទទួលខុសត្រូវរបស់ខ្លួន។

ដោយហេតុថាដើម្បីសម្រេចនូវលទ្ធផលនៃការអប់រំដែលជាលទ្ធផលប្រកបដោយមហិច្ឆតាគេត្រូវពឹងអាស្រ័យលើតួអង្គពាក់ព័ន្ធជាច្រើនដែលមានទំនួលខុសត្រូវរួមគ្នាមួយចំនួន ការសម្រេចនូវគណនេយ្យភាពមិនអាចពឹងតែលើតួអង្គពាក់ព័ន្ធនីមួយៗនោះឡើយ។ ដូចដែរបង្ហាញក្នុងរបាយការណ៍នេះ ការសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤និងការធានានូវការអប់រំបរិយាប័ន្នប្រកបដោយគុណភាពនិងសមធម៌គឺជាកិច្ចខិតខំប្រឹងប្រែងរួមគ្នា ពោលគឺតួអង្គទាំងអស់ត្រូវរួមគ្នាបំពេញទៅតាមទំនួលខុសត្រូវរបស់ខ្លួន **(រូបភាពទី ១)**។ ដើម្បីឱ្យមានការខិតខំប្រឹងប្រែងរួមគ្នាបែបនេះ គេត្រូវតម្រឹមផលប្រយោជន៍ផ្នែកនយោបាយ និងផ្នែកសេដ្ឋកិច្ចឱ្យស្របគ្នា។ គោលនយោបាយអប់រំ និងតួអង្គពាក់ព័ន្ធក្នុងវិស័យអប់រំ មិនអាចធ្វើការងារដាច់ដោយឡែកពីពិភពលោកដែលនៅជុំវិញខ្លួនរបស់ពួកគេបានឡើយ។

> “ការធានានូវការអប់រំបរិយាប័ន្នប្រកបដោយគុណភាព និងសមធម៌ជាកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់គ្រប់តួអង្គពាក់ព័ន្ធទាំងអស់ត្រូវ ដើម្បីបំពេញតាមទំនួលខុសត្រូវរបស់ខ្លួន”

ចំណុចដែលសំខាន់ដូចគ្នានេះផងដែរ គឺថាពុំមានអភិក្រមគណនេយ្យភាពណា អាចទទួលបាន ជោគជ័យឡើយប្រសិនបើតួអង្គពាក់ព័ន្ធពុំមានបរិយាកាសអំណោយផល ឬពុំបានទទួលការបំពាក់ធនធានឱ្យបានគ្រប់គ្រាន់ដើម្បីបំពេញទំនួលខុសត្រូវរបស់ខ្លួននោះ។ នៅពេលដែល

ពុំមានព័ត៌មានច្បាស់លាស់ ក៏ដូចជាធនធាន និងសមត្ថភាពឱ្យបានគ្រប់គ្រាន់កិច្ចខិតខំប្រឹងប្រែង របស់ពួកគេនឹងជួបការបន្ទុចបង្អាក់ជាមិនខាន។ គោលនយោបាយ សម្រាប់កែលំអការអនុវត្តបច្ចុប្បន្ន ដែលផ្តោតលើការជួយកសាងជាជាងការស្តីបន្ទោស ទំនងជាអាចបង្កើតនូវប្រព័ន្ធអប់រំបរិយាប័ន្នមួយប្រកបដោយ ដោយគុណភាព និងសមធម៌។




ការសម្រេចគោលដៅនៃការអប់រំដែលមានលក្ខណៈទូលំទូលាយ ទាមទារឱ្យតួអង្គពាក់ព័ន្ធនានាធ្វើការសហការ និងប្រាស្រ័យទាក់ទងជាមួយគ្នា ។ ដើម្បីទទួលបានការជឿទុកចិត្ត និងការគាំទ្រពីសាធារណជន គេត្រូវធ្វើយ៉ាងណាឱ្យដំណើរការ និងគោលដៅដែលត្រូវបានដាក់ចេញ ក្លាយជាដំណើរការ និងគោលដៅសមស្រប និងអាចសម្រេចទៅបានជាមួយនឹងធនធានបច្ចុប្បន្ន ដែលកំពុងតែមានកម្រិតនៅឡើយ។ ចុងក្រោយកង្វះការជឿទុកចិត្តពីសាធារណជន អាចធ្វើឱ្យប្រជាពលរដ្ឋលែងចូលរួម និងធ្វើឱ្យមាតាបិតាមួយចំនួនបាត់បង់សិទ្ធិចូលរួមជាមួយនឹងការងារអប់រំ។ ក្នុងប្រព័ន្ធដែលមានការជឿទុកចិត្តតិចតួច កំណែទម្រង់វិស័យអប់រំទំនងជាមានល្បឿនយឺតយ៉ាវ និងកើតមានតែលើក្រដាសតែប៉ុណ្ណោះ។ ការកសាងការជឿទុកចិត្ត តម្រូវឱ្យតួអង្គពាក់ព័ន្ធចូលរួមកំណត់ពីគោលបំណងនិងទទួលស្គាល់ថាការពឹងពាក់គ្នាទៅវិញទៅមករបស់តួអង្គនានាអាចសម្រេចទៅបាន តាមរយៈការមានគណនេយ្យភាពចំពោះគ្នាទៅវិញទៅមក។

ដោយសារតែនិន្នាការសង្គមនយោបាយ គណនេយ្យភាពបានទទួលការយកចិត្តទុកដាក់កាន់តែខ្ពស់ក្នុង គោលនយោបាយអប់រំនានា។ ការពង្រីកវិស័យអប់រំយ៉ាងឆាប់រហ័សក្នុងរយៈពេល ៥០ ឆ្នាំចុងក្រោយនៃសតវត្សរ៍ទី ២០ ដែលធ្វើឱ្យប្រព័ន្ធអប់រំកាន់តែពិបាកគ្រប់គ្រង។ ក្នុងប្រទេសដែលមានចំណូលខ្ពស់ ការឆ្លើយតបមួយរបស់អាជ្ញាធររដ្ឋាភិបាលចំពោះបញ្ហាប្រឈមនានា មិនត្រឹមតែនៅក្នុងវិស័យអប់រំប៉ុណ្ណោះទេ ថែមទាំងវិស័យដទៃទៀតផងដែរនោះ គឺការផ្លាស់ប្តូរពីការគ្រប់គ្រងធាតុចូល ទៅការគ្រប់គ្រងលទ្ធផលវិញម្តង។ ការបង្កើតរង្វាស់រង្វាល់ និងឧបករណ៍ដែលមានលក្ខណៈស្តង់ដា ដើម្បីផ្តល់លទ្ធភាពឱ្យគេអាចធ្វើការប្រៀបធៀបរដ្ឋបាលមូលដ្ឋានមួយ និងរដ្ឋបាលមូលដ្ឋានមួយទៀត និងរវាងសាលារៀនមួយ និងសាលារៀនមួយទៀត គឺជាអ្វីដែលគេបានធ្វើឡើង ដើម្បីបង្កើនការយកចិត្តទុកដាក់លើលទ្ធផល។

ការវិវឌ្ឍន៍មួយទៀត គឺការធ្វើវិមជ្ឈការដើម្បីផ្ដល់អំណាចកាន់តែច្រើនជាងមុនដល់ថ្នាក់មូលដ្ឋានក្នុងការផ្ដល់សេវាអប់រំ ខណៈពេលរដ្ឋាភិបាលនៅថ្នាក់កណ្ដាលនៅរក្សាការទទួលខុសត្រូវ ពាក់ព័ន្ធនឹងការផ្ដល់មូលនិធិ ការពិនិត្យតាមដាន និងការធ្វើនិយ័តកម្ម។ លើសពីនេះ នៅតាមបណ្ដាប្រទេសមួយចំនួន ការមិនពេញចិត្តជាមួយនឹងសេវាអប់រំសាធារណៈ បានរួមចំណែកធ្វើឱ្យមានការបង្កើតនូវគោលនយោបាយធ្វើពិពិធកម្មសេវាអប់រំ និងការបង្កើតនូវ "ទីផ្សារ" អប់រំមួយ ដែលមាតាបិតាអាចជ្រើសរើសសាលារៀនឱ្យកូនរបស់ខ្លួនផ្អែកទៅតាមចំណាត់ថ្នាក់សាលារៀន ដែលត្រូវបានបោះពុម្ពផ្សាយជាសាធារណៈ ក្នុងគោលបំណងជម្រុញឱ្យមានការប្រកួតប្រជែង និងបង្កើនគុណភាពឱ្យកាន់តែខ្ពស់ជាងមុន។ លើសពីនេះព័ត៌មានដែលអាចរកបានទាំងនេះ ក៏បានលើកទឹកចិត្តឱ្យប្រជាពលរដ្ឋទាមទារគណនេយ្យភាពកាន់តែច្រើនជាងមុនផងដែរ។

នៅតាមបណ្ដាប្រទេស ដែលមានចំណូលខ្ពស់មួយចំនួន ក៏មាននិន្នាការរៀបចំគោលនយោបាយគណនេយ្យភាព ដោយប្រើប្រាស់ពិន្ទុតេស្តរបស់សិស្សសម្រាប់វាស់វែង និងវាយតម្លៃលទ្ធផលសិក្សាផងដែរ។ លទ្ធផលសិក្សារបស់សិស្សកាន់តែត្រូវបានគេភ្ជាប់ជាមួយនឹងការដាក់ទោសទណ្ឌ និងការផ្ដល់រង្វាន់ដល់សាលារៀន និងត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់វាយតម្លៃលទ្ធផលការងាររបស់គ្រូ និងគុណភាពរបស់សាលារៀន។

**រូបភាពទី ១៖**

**របៀបដែលតួអង្គទាំងអស់ក្នុងវិស័យអប់រំត្រូវបានគេទាមទារឱ្យមានគណនេយ្យភាពនាពេលបច្ចុប្បន្ននេះ**




ប្រភព៖ របាយការណ៍ពិនិត្យតាមដានការអប់រំជាសកល

ប៉ុន្តែប្រសិនបើយើងចង់ប្រើគណនេយ្យភាព ដើម្បីជួយឱ្យប្រព័ន្ធអប់រំកាន់តែមានបរិយាប័ន្ន សមធម៌ និងគុណភាព នោះគេចាំបាច់ត្រូវប្រើប្រាស់អភិក្រមដែលមានភាពបត់បែន ដើម្បីឱ្យគេអាចយកព័ត៌មានដែលមានទៅប្រើប្រាស់ឱ្យបានត្រឹមត្រូវ។ យន្តការគណនេយ្យភាពអាចមានប្រសិទ្ធភាពនៅក្នុងបរិបទមួយចំនួន និងសម្រាប់តែផ្នែកមួយចំនួននៃការអប់រំតែប៉ុណ្ណោះ និងអាចនាំមកនូវអន្តរាយក្នុងបរិបទ ឬផ្នែកផ្សេងទៀតទៅវិញ។

គណនេយ្យភាពដែលមានសារៈសំខាន់យ៉ាងធំធេងក្នុងការធ្វើយ៉ាងណាឱ្យប្រព័ន្ធអប់រំកាន់តែមានភាពល្អប្រសើរជាងមុន ប៉ុន្តែគេចាំបាច់ត្រូវស្វះស្វែងដោយការសន្ទតមួយចំនួន។ ការទទូចស្តុះដើម្បីឱ្យមានគណនេយ្យភាពដើម្បីតែគោលបំណងគណនេយ្យភាពតែមួយមុខគត់ គឺជាការគិតមិនត្រឹមត្រូវឡើយ។ គេគួរចាត់ទុកគណនេយ្យភាពថាជាមធ្យោបាយ ដើម្បីសម្រេចគោលដៅអ្វីមួយ ពោលគឺជាឧបករណ៍ដើម្បីសម្រេចចំណុចដៅ ដែលត្រូវបានដាក់ចេញក្នុងគោលដៅ SDG ទី ៤ ពោលគឺគណនេយ្យភាពមិនមែនជាគោលដៅមួយ ដែលប្រព័ន្ធអប់រំត្រូវសម្រេចឱ្យបាននោះទេ។

> “គេគួរចាត់ទុក គណនេយ្យភាពថាជាមធ្យោបាយ ដើម្បីសម្រេចគោលដៅ អ្វីមួយពោល គឺជាឧបករណ៍ដើម្បីសម្រេចចំណុចដៅ ដែលត្រូវបានដាក់ចេញ ក្នុងគោលដៅ SDG ទី ៤ ពោលគឺគណនេយ្យភាពមិនមែនជាគោលដៅមួយ ដែលប្រព័ន្ធអប់រំត្រូវសម្រេចឱ្យបាននោះទេ”

របាយការណ៍ពិនិត្យតាមដាន ការអប់រំជាសកល ឆ្នាំ២០១៧-២០១៨ នេះធ្វើការពិនិត្យលើភស្តុតាងដែលប្រមូលបានពីបណ្តាប្រទេសនានាក្នុងសកលលោកទាំងមូល អំពីយន្តការដែលប្រទាក់ក្រឡាគ្នាគ្នាទៅវិញទៅមក ដើម្បីទាមទារឱ្យតួអង្គសំខាន់ៗក្នុងវិស័យអប់រំមានគណនេយ្យភាព ប្រសិទ្ធភាពនៃយន្តការទាំងនេះក្នុងការឆ្លើយតបចំពោះគោលដៅSDGទី៤ និងបរិយាកាសគាំទ្រដែលចាំបាច់ ដែលផ្តល់លទ្ធភាពឱ្យតួអង្គពាក់ព័ន្ធនានាអាចបំពេញទៅតាមការទទួលខុសត្រូវរៀងៗខ្លួនរបស់ពួកគេ។

## គណនេយ្យភាពរបស់រដ្ឋាភិបាល

រដ្ឋាភិបាលគឺជាអ្នកដែលទទួលខុសត្រូវចុងក្រោយ ចំពោះវឌ្ឍនភាព ក្នុងការឈានទៅសម្រេចគោលដៅអប់រំជាសកល។ មិនថាក្នុងប្រទេសអ្នកក្រ ឬប្រទេសអ្នកមាននោះទេ រដ្ឋាភិបាលត្រូវតែមានគណនេយ្យភាពចំពោះអ្វីដែលខ្លួនបានសន្យាក្នុងវិស័យអប់រំ ក៏ដូចជាផែនការអនុវត្ត និងលទ្ធផលដែលត្រូវសម្រេចឱ្យបានក្នុងវិស័យនេះ។

### រដ្ឋាភិបាលមានការទទួលខុសត្រូវផ្នែកច្បាប់ចំពោះការអប់រំ

ប្រទេសទាំងអស់បានផ្តល់សច្ចាប័នសន្ធិសញ្ញាអន្តរជាតិ ដែលចងកាតព្វកិច្ចតាមផ្លូវច្បាប់យ៉ាងហោចណាស់ក៏មួយដែរដែលផ្តោតលើសិទ្ធិទទួលបានការអប់រំ។រដ្ឋាភិបាលមានការទទួលខុសត្រូវគោរព ការពារ និង

សម្រេចឱ្យបាននូវសិទ្ធិនេះ។ បច្ចុប្បន្ននេះ ក្នុងចំណោមរដ្ឋធម្មនុញ្ញរបស់បណ្តាប្រទេសនានាក្នុងសកលលោក មានរដ្ឋធម្មនុញ្ញ ៨២ ភាគរយ បានបញ្ចូលបញ្ញត្តិស្តីពីសិទ្ធិទទួលបានការអប់រំ។ ប៉ុន្តែក្នុងចំណោមប្រទេសទាំងអស់ក្នុងពិភពលោក មានប្រទេសជាងពាក់កណ្តាលតែប៉ុណ្ណោះ ដែលចាត់ទុកសិទ្ធិនេះថាជាសិទ្ធិដែលអាចទទួលបាន យុត្តិធម៌តាមផ្លូវតុលាការ បាន ពោលគឺផ្តល់លទ្ធភាពតាមផ្លូវច្បាប់ ឱ្យប្រជាពលរដ្ឋប្តឹងរដ្ឋាភិបាលទៅតុលាការ ក្នុងករណីមានការបំពានសិទ្ធិនេះ **(រូបភាពទី ២)**។

## ដំណើរការនៃការរាយការណ៍ជាលក្ខណៈអន្តរជាតិ មានឥទ្ធិពលខុសៗគ្នាលើគណនេយ្យភាពរបស់រដ្ឋាភិបាល

ប្រទេសនានាដែលបានផ្តល់សច្ចាប័នសន្ធិសញ្ញាមួយ ក្នុងចំណោមសិទ្ធិមនុស្សស្នូលទាំង ៧ របស់អង្គការសហប្រជាជាតិពាក់ព័ន្ធនឹងការអប់រំត្រូវដាក់របាយការណ៍តាមកាលកំណត់អំពីវិធានការដែលត្រូវបានអនុវត្តដើម្បីបំពេញកាតព្វកិច្ច ដូចមានចែងក្នុងសន្ធិសញ្ញាទាំងនេះ។ សន្ធិសញ្ញាមួយក្នុងចំណោមសន្ធិសញ្ញាស្នូលទាំង ៧ គឺអនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិជនពិការ ដែលស្នើឱ្យមានការបង្កើតប្រព័ន្ធអប់រំបរិយាប័ន្ននៅគ្រប់ភូមិសិក្សាទាំងអស់។ អនុសញ្ញានេះជម្រុញឱ្យមានការប្រើប្រាស់អភិក្រមយកសិទ្ធិជាគោល ដើម្បីផ្តល់ការអប់រំដល់ជនពិការ ដែលជាមូលដ្ឋានរឹងមាំសម្រាប់ទាមទារឱ្យរដ្ឋាភិបាលមានគណនេយ្យភាព។ អនុសញ្ញាស្តីពីសិទ្ធិជនពិការ ចែងឱ្យមានការបង្កើតនូវយន្តការអនុវត្ត និងពិនិត្យតាមដាន នៅថ្នាក់ជាតិ និងអន្តរជាតិ។ ប្រទេសនានាត្រូវធ្វើការប្រមូលទិន្នន័យ និងរាយការណ៍ជូនគណៈកម្មាធិការទទួលបានបន្ទុកសិទ្ធិជនពិការរបស់អង្គការសហប្រជាជាតិ។

ខណៈពេលដែលរបាយការណ៍ភាគច្រើនក្នុងចំណោមរបាយការណ៍របស់ប្រទេសចំនួន ៨៦ ដែលដាក់ជូនគណៈកម្មាធិការនេះ គិតរហូតដល់ពេលបច្ចុប្បន្ននេះ រាយការណ៍ថារដ្ឋធម្មនុញ្ញ ច្បាប់ ឬគោលនយោបាយនានា បានចែងយ៉ាងច្បាស់ពីសិទ្ធិជនពិការក្នុងការទទួលបានការអប់រំ មានរបាយការណ៍តែមួយចំនួនតូចតែប៉ុណ្ណោះ ដែលកំណត់និយមន័យពិការភាព។ កង្វះនិយមន័យឱ្យបានច្បាស់លាស់ជាលក្ខណៈអន្តរជាតិ ធ្វើឱ្យគេមានការពិបាកក្នុងការរៀបចំកម្មវិធី និងអនុលោមទៅតាមបទដ្ឋានអន្តរជាតិ។ ស្រដៀងគ្នានេះដែររដ្ឋធម្មនុញ្ញច្បាប់ គោលនយោបាយរបស់ប្រទេស ចំនួន ៤២ បានលើកឡើង យ៉ាងជាក់ច្បាស់អំពីការអប់រំបរិយាប័ន្ន ដោយបង្ហាញឱ្យឃើញពីនិន្នាការងាកចេញពីសាលារៀនពិសេស ទៅរកការរៀបចំកម្មវិធីបរិយាប័ន្នតាមសាលារៀនទូទៅវិញ។ ប៉ុន្តែការអនុវត្តជាក់ស្តែងមិនមែនចេះតែកើតមានដូចគ្នាទៅនឹងគោលនយោបាយនោះឡើយ។

របាយការណ៍ដែលដាក់ដោយអង្គការមិនមែនរដ្ឋាភិបាល ទន្ទឹមគ្នានឹងរបាយការណ៍របស់រដ្ឋាភិបាល អាចមានឥទ្ធិពលលើការទាញសេចក្តីសន្និដ្ឋានរបស់គណៈកម្មាធិការទទួលបន្ទុកសន្ធិសញ្ញាសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ។ ឧទាហរណ៍ ការរាយការណ៍របស់អង្គការមិនមែនរដ្ឋាភិបាល អំពីការផ្តល់ថវិកាមិនបានគ្រប់គ្រាន់ដល់ការអប់រំសាធារណៈ និងការពុំមានការត្រួតពិនិត្យត្រឹមត្រូវ លើសាលារៀនឯកជនក្នុងប្រទេសហ្វីលីពីន ត្រូវបានឆ្លុះបញ្ចាំងក្នុងអនុសាសន៍របស់គណៈកម្មាធិការនេះ។

**រូបភាពទី ២៖**

ប្រជាពលរដ្ឋគួរអាចប្តឹងរដ្ឋាភិបាលរបស់ពួកគេទៅកាន់តុលាការ ក្នុងករណីដែលរដ្ឋាភិបាលបំពានសិទ្ធិទទួលបានការអប់រំរបស់ពួកគេ។




> “ក្នុងចំណោមប្រទេសចំនួន ៨៦ មានប្រទេសចំនួន៤២ដែលរដ្ឋធម្មនុញ្ញច្បាប់ ឬ គោលនយោបាយ បានលើកឡើងយ៉ាងជាក់ច្បាស់ពីការអប់រំបរិយាប័ន្ន”

ប្រទេសនានា ក៏បានរាយការណ៍ពីវឌ្ឍនភាព ក្នុងការឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពផងដែរ បើទោះបីជាការរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពបែបនេះធ្វើឡើងដោយស្ម័គចិត្ត យ៉ាងណាក៏ដោយ។ គិតរហូតមកដល់បច្ចុប្បន្ននេះមានប្រទេសចំនួន ៤៤ បានដាក់របាយការណ៍បង្ហាញពីវឌ្ឍនភាពដែលសម្រេចបាន។ ការពិនិត្យឡើងវិញតាមប្រធានបទជាសកលដែលធ្វើឡើង ដោយអង្គការសហប្រជាជាតិក្នុងឆ្នាំ២០១៩ ក្រោមប្រធានបទ “ផ្តល់សិទ្ធិអំណាចដល់ប្រជាពលរដ្ឋ និងធានាឱ្យមានបរិយាប័ន្ន” និងធ្វើការពិនិត្យដោយប្រុងប្រយ័ត្នលើគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤។ គេចាំបាច់ត្រូវបន្តពិនិត្យមើលដើម្បីឱ្យដឹងថាតើអភិក្រមស្ម័គ្រចិត្តដឹកនាំដោយប្រទេសរៀងៗខ្លួន ដើម្បីឈានទៅសម្រេចការផ្លាស់ប្តូរទាំងនេះ និងមានប្រសិទ្ធភាពកម្រិតណា។ ប៉ុន្តែកង្វះយន្តការពង្រឹកការអនុវត្តពីខាងក្រៅ អាចធ្វើឱ្យមានភាពយឺតយ៉ាវដល់ការសម្រេចវឌ្ឍនភាពនេះ។

## ប្រជាពលរដ្ឋអាចដាក់សម្ពាធឱ្យរដ្ឋាភិបាល គោរពទៅតាមអ្វីដែលបានសន្យា តាមរយៈដំណើរការនយោបាយ។

ដំណើរការនយោបាយលើកទឹកចិត្តឱ្យមន្ត្រី ធ្វើការឆ្លើយតបចំពោះការទាមទារជាសាធារណៈរបស់ប្រជាពលរដ្ឋ។ យន្តការមួយដើម្បីធ្វើការទាមទារបែបនេះ គឺការបោះឆ្នោតដោយសេរី និងយុត្តិធម៌។ ចាប់ពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ២០១១ ក្នុងចំណោមការបោះឆ្នោតជ្រើសរើសអ្នកដឹកនាំនៅថ្នាក់ជាតិចំនួន ៨៩០ លើកក្នុងប្រទេសចំនួន ១៦៩ មានការបោះឆ្នោតចំនួន ៤៦៩ លើកត្រូវបានចាត់ទុកថាជាការបោះឆ្នោតសេរី និងយុត្តិធម៌។ ភាគរយនេះត្រូវចុះពី ៧០ ភាគរយ ក្នុងឆ្នាំ ១៩៧៥-១៩៨៥ ដល់ ៤៥ ភាគរយ ក្នុងឆ្នាំ ២០០១-២០១០ ដែលមូលហេតុមួយ គឺដោយសារតែការរៀបចំការបោះឆ្នោតក្នុងប្រទេស ដែលលទ្ធិប្រជាធិតេយ្យនៅក្មេងខ្ចីនៅឡើយ **(រូបភាពទី ៣)**។

ការចំណាយលើការអប់រំសាធារណៈ មានការកើនឡើងនៅពេលដែលប្រទេសមួយ ងាកទៅរកលិទ្ធិប្រជាធិតេយ្យ និងការបើកចំហ។ បើទោះបីជាយ៉ាងណាក៏ដោយ អ្នកបោះឆ្នោតនៅតែមានការលំបាកក្នុងការកំណត់ និងទាមទារគណនេយ្យភាពពីមន្ត្រីដែលជាប់ឆ្នោត ក្នុងករណីដែលគោលនយោបាយអប់រំបរាជ័យ ឬអនុវត្ត ពុំមានប្រសិទ្ធភាពនោះ។ ការសន្យាងាយៗក្នុងកំឡុងពេលយុទ្ធនាការបោះឆ្នោត អាចបង្វែរចំណាប់អារម្មណ៍ និងការវិនិយោគចេញពីបញ្ហាអប់រំសំខាន់។ រដ្ឋាភិបាលច្រើនតែផ្តោតការយកចិត្តទុកដាក់ និងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តអប់រំ ដែលគេអាចមើលឃើញផ្ទាល់ភ្នែក ជាជាងផ្តោតលើការផ្តល់ធាតុចូលសម្រាប់វិស័យអប់រំ ដែលមិនសូវមានលក្ខណៈរូបី ដូចជាការអភិវឌ្ឍសមត្ថភាពជាដើម។

អ្នកខ្លះលើកឡើងថាការប្រកួតប្រជែងគ្នា ក្នុងកំឡុងពេលបោះឆ្នោតជម្រុញឱ្យមានការអនុវត្តសកម្មភាពប្រកបដោយការទទួលខុសត្រូវ ក៏ប៉ុន្តែភស្តុតាងកន្លងមកមិនបង្ហាញបែបនេះរហូតនោះទេ។ ក្នុងប្រទេសប្រេស៊ីល ការចាយវាយធនធានមិនត្រឹមត្រូវរបស់អភិបាលក្រុងដែលត្រូវឆ្លងកាត់ការបោះឆ្នោតសារជាថ្មី ដើម្បីរក្សាតំណែងរបស់ខ្លួន មានកម្រិតតិចជាងអភិបាលក្រុង ដែលមានការកំណត់អាណត្តិ អត្រា ២៧ ភាគរយ ។ ផ្ទុយទៅវិញក្នុងរដ្ឋកូរ៉េ ការប្តូរទៅរកការបោះឆ្នោតជ្រើសរើសអ្នកគ្រប់គ្រងស្ថាប័នអប់រំដោយផ្ទាល់ ពុំបានធ្វើឱ្យមានការផ្លាស់ប្តូរចំណាយអប់រំឬអត្រាបញ្ចប់ការសិក្សាឬអត្រាចុះឈ្មោះចូលរៀនគួរឱ្យកត់សម្គាល់ឡើយ។

## ប្រជាពលរដ្ឋក៏អាចដាក់សម្ពាធដល់រដ្ឋាភិបាល តាមរយៈចលនាសង្គមផងដែរ

ការបោះឆ្នោតមិនមែនជាយន្តការនយោបាយតែមួយគត់ដើម្បីទាមទារឱ្យរដ្ឋាភិបាលមានគណនេយ្យភាពនោះឡើយ។ សកម្មភាពរបស់ប្រជាពលរដ្ឋក៏អាចដាក់សម្ពាធលើរដ្ឋាភិបាលផងដែរ ដូចជានៅក្នុងករណីដែលចលនានិស្សិតទាមទារឱ្យមានការបញ្ចុះថ្លៃសិក្សានៅសកលវិទ្យាល័យ ដែលទទួលបានជោគជ័យនៅក្នុងប្រទេសឈីលលី អាហ្វ្រិកខាងត្បូងជាដើម។

**រូបភាពទី ៣៖**

ជារឿយៗ គេមិនអាចបោះឆ្នោតទម្លាក់រដ្ឋាភិបាលបានឡើយ ប្រសិនបើរដ្ឋាភិបាលពុំបានគោរពទៅតាមអ្វីដែលខ្លួនបានសន្យានោះ




អង្គការសង្គមស៊ីវិលប្រើប្រាស់យុទ្ធសាស្ត្រជាច្រើន ដូចជាយន្តការច្បាប់ការអង្កេត និងការស្រាវជ្រាវផ្សេងទៀត ទិន្នន័យចំហរ ការកសាងសម្ព័ន្ធភាព និងយុទ្ធនាការតាមប្រព័ន្ធផ្សព្វផ្សាយជាដើម។ សមាគមពលរដ្ឋដើម្បីសកម្មភាពយុត្តិធម៌របស់អាហ្សង់ទីន បានដាក់ពាក្យបណ្តឹងប្តឹងរដ្ឋបាលទីក្រុង Buenos Aires ទៅកាន់តុលាការ ដោយសារតែរដ្ឋបាលទីក្រុងនេះពុំបានឆ្លើយតបចំពោះសំណើសុំព័ត៌មានពាក់ព័ន្ធនឹងការអប់រំកុមារតូច។

ការអង្កេត អាចជួយ ប្រមូល ព័ត៌មាន បង្ហាញឱ្យឃើញ ពី ចំណុច ខ្វះខាត ក្នុង គោលនយោបាយ និងជម្រុញឱ្យមានការផ្លាស់ប្តូរ។ នៅតាមប្រទេសជាច្រើនដូចជាកេនយ៉ា ប៉ាគីស្ថាន និងសេណេហ្កាល់ជាដើម ការអង្កេត ដែល ធ្វើឡើង ដោយ ប្រជាពលរដ្ឋ ដើម្បី វាយតម្លៃ លើសមត្ថភាព អំ ណាន និង លេខនព្វន្ត កម្រិតមូលដ្ឋានរបស់កុមារត្រូវបានប្រើប្រាស់ ដើម្បីដាក់សម្ពាធឱ្យរដ្ឋាភិបាលធ្វើកែលំអការផ្តល់សេវាអប់រំរបស់ខ្លួន។

សម្ព័ន្ធភាពសង្គមស៊ីវិល ដូចជា យុទ្ធនាការដើម្បីការអប់រំពលរដ្ឋ ក្នុងប្រទេសបង់ក្លាដេស ជាដើម បានកៀរគរកម្លាំង ដើម្បីបង្កើនសម្ពាធឱ្យរដ្ឋាភិបាល បង្កើនការវិភាជន៍ធនធាន សម្រាប់វិស័យអប់រំ។ ប័ណ្ណរាយការណ៍របស់ប្រជាពលរដ្ឋ ដែលដំបូងត្រូវបានប្រើប្រាស់ក្នុងទីក្រុងបង់ហ្គាល់កាលពីឆ្នាំ ១៩៩៤ ត្រូវបានយកទៅប្រើប្រាស់នៅតាមបណ្តាប្រទេសដទៃទៀតផងដែរ ដូចជា ប្រទេសរវ៉ាន់ដា ជាដើម។

នៅតាមប្រទេសមួយចំនួនដូចជាឥណ្ឌា និងសាធារណរដ្ឋតង់ហ្សានៀ ជាដើមអង្គការសង្គមស៊ីវិលបំពេញតួនាទី យ៉ាងសំខាន់ ក្នុងការ ប្រយុទ្ធប្រឆាំង នឹង ការប្រព្រឹត្ត អំពើពុករលួយ ដោយបាន ប្រើប្រាស់ ការតាមដាននូវការវិភាជន៍ថវិកា ដើម្បីតាមដានការទម្លាក់ថវិកា និងចំណាយរបស់រដ្ឋាភិបាល និងវាយតម្លៃថាតើមានការបែងចែក និងចំណាយធនធានស្របទៅតាមថវិកា និងផែនការដែរឬទេ។

អង្គការជនពិការក៏អាចជម្រុញឱ្យរដ្ឋាភិបាលធ្វើការផ្លាស់ប្តូរផងដែរ។ អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នសិទ្ធិមនុស្សឯករាជ្យ អាចផ្តល់ព័ត៌មាន និងបង្កើនការយល់ដឹង។ អង្គការជនពិការបានជួយពិនិត្យតាមដានការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការក្នុងប្រទេសចំនួន ៥០ ក្នុងចំណោមប្រទេសទាំង ៨៦ ដែលបានធ្វើរបាយការណ៍ប៉ុន្តែអង្គការជនពិការទាំងនេះបានចូលរួមក្នុងការពិនិត្យឡើងវិញនៅថ្នាក់ជាតិតែក្នុងប្រទេសចំនួន២៩ប៉ុណ្ណោះ។ កង្វះ សមត្ថភាព គឺជា ឧបសគ្គ ដែល រារាំង ដល់ ការចូលរួមរបស់អង្គការទាំងនេះ។

> “អង្គការជនពិការបានជួយពិនិត្យតាមដានការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិជនពិការក្នុងប្រទេសចំនួន ៥០ ក្នុងចំណោមប្រទេសទាំង ៨៦ ដែលបានធ្វើរបាយការណ៍”

សមាគមគ្រូបង្រៀន គឺជាផ្នែកមួយនៃសង្គមស៊ីវិល ប៉ុន្តែមានសំលេង និងតួនាទីពិសេស។ សមាគមគ្រូបង្រៀនអាចជួយទាមទារឱ្យរដ្ឋាភិបាលមានគណនេយ្យភាព តាមរយៈ ការគាំទ្រ ឬ ការប្រឆាំងតបតនឹង កំណែទម្រង់វិស័យអប់រំ និងជម្រុញឱ្យមានកិច្ចសន្ទនា អំពីបញ្ហារសើបនានា ដែលរដ្ឋាភិបាល មានការ ស្ទាក់ស្ទើរ ក្នុងការ ឆ្លើយតប។ ការផ្តល់ ឱកាស ឱ្យ សមាគម គ្រូបង្រៀន អាច ចូលរួម ក្នុងការតាក់តែងគោលនយោបាយជាផ្លូវការ ជួយបង្កើនគណនេយ្យភាព និងការគាំទ្រពីគ្រូ ហើយក្នុងពេលជាមួយគ្នាអាចកែលំអទំនាក់ទំនងរវាងសមាគមគ្រូបង្រៀន និងរដ្ឋាភិបាលបន្ថែមទៀត។ ប៉ុន្តែគួរឱ្យសោកស្តាយ តែនៅពេលដែលមានកំណែទម្រង់អ្វីមួយ គេពុំបានពិគ្រោះយោបល់ជាមួយសមាគមគ្រូបង្រៀមឱ្យបានជាប្រចាំឡើយ។ ក្នុងចំណោមសមាគម គ្រូបង្រៀនចំនួន ៧០ ក្នុងប្រទេសជាង ៥០ មានសមាគមគ្រូបង្រៀនជាង ៦០ ភាគរយដែលមិនដែល ឬកម្រត្រូវបានគេពិគ្រោះយោបល់ជាមួយ ពាក់ព័ន្ធនឹងការរៀបចំ និងការជ្រើសរើសឯកសារបង្រៀនឡើយ។

> “ក្នុងចំណោម សមាគម គ្រូបង្រៀន ចំនួន ៧០ក្នុងប្រទេសជាង៥០មានសមាគមគ្រូបង្រៀនជាង ៦០ ភាគរយដែលមិនដែល ឬកម្រត្រូវបានគេពិគ្រោះយោបល់ ជាមួយពាក់ព័ន្ធនឹងការរៀបចំ និងការជ្រើសរើសឯកសារបង្រៀនឡើយ”

## ប្រព័ន្ធផ្សព្វផ្សាយមានតួនាទីសំខាន់ក្នុងការលើកឡើងពីបញ្ហាសំខាន់ៗពាក់ព័ន្ធនឹងការអប់រំ

ប្រជាពលរដ្ឋត្រូវការព័ត៌មានត្រឹមត្រូវ ដើម្បីទាមទារឱ្យរដ្ឋាភិបាលមានគណនេយ្យភាព។ ប្រព័ន្ធផ្សព្វផ្សាយអាចបំពេញតួនាទីជាអ្នកឃ្លាំមើលការបំពេញការងាររបស់រដ្ឋាភិបាល និងជួយប្រជាពលរដ្ឋវាយតម្លៃលទ្ធផលការងាររបស់រដ្ឋាភិបាល។ ប្រព័ន្ធផ្សព្វផ្សាយក៏អាចបំពេញតួនាទីជាច្រកសម្រាប់ឱ្យអង្គការសង្គមស៊ីវិលធ្វើការផ្សព្វផ្សាយការងាររបស់ខ្លួន និងពាំនាំបញ្ហានានា ដូចជា បញ្ហាសមធម៌ ជាដើម ទៅដាក់បញ្ចូលក្នុងរបៀបវារៈរបស់រដ្ឋ។ ប្រព័ន្ធផ្សព្វផ្សាយអន្តរជាតិ ប្រព័ន្ធផ្សព្វផ្សាយជាតិ និងប្រព័ន្ធផ្សព្វផ្សាយមូលដ្ឋានបានបោះពុម្ពផ្សាយនូវលទ្ធផលនៃការវាយតម្លៃ ដែលធ្វើឡើងដោយប្រជាពលរដ្ឋ ដើម្បីបង្ហាញឱ្យឃើញពីបញ្ហាប្រឈមក្នុងការធានាឱ្យកុមារគ្រប់រូបទទួលបានបំណិនជាមូលដ្ឋាន។

ប្រព័ន្ធផ្សព្វផ្សាយក៏អាចរាយការណ៍ពីរបកគំហើញនៃការស្រាវជ្រាវ ដែលធ្វើឡើងដោយក្រុមអ្នកសិក្សាស្រាវជ្រាវ សកលវិទ្យាល័យ និងស្ថាប័នរដ្ឋាភិបាលផងដែរ។ ការបង្កើនការផ្សព្វផ្សាយព័ត៌មានអំពីការចាយវាយថវិការដ្ឋអាចផ្តល់សិទ្ធិអំណាចបន្ថែមដល់ប្រជាពលរដ្ឋនិងជាការដាក់សម្ពាធឱ្យមន្ត្រីអប់រំធ្វើសកម្មភាពការងាររបស់ខ្លួន ប្រកបដោយការទទួលខុសត្រូវ (នៅក្នុងប្រទេស Uganda)។ ការថយចុះចំណាយទៅកាន់កន្លែងលក់កាសែត ២,២ គីឡូម៉ែត្រ នាំឱ្យភាគរយនៃថវិកាដែលបានដល់សាលារៀន កើនឡើងជិត ១០ ភាគរយចំណុច។

ខណៈពេលដែលប្រព័ន្ធផ្សព្វផ្សាយជាប្រពៃណី នៅតែបំពេញតួនាទីដ៏សំខាន់ក្នុងការបកស្រាយពន្យល់ពីបញ្ហាស្មុគស្មាញនានាទៅកាន់សាធារណជនទូទៅ បណ្តាញទំនាក់ទំនងសង្គម ជួយឱ្យអ្នកប្រើប្រាស់ចែករំលែកព័ត៌មានកាន់តែទូលំទូលាយ ដោយមិនចាំបាច់មាននិពន្ធនាយកពិនិត្យមើលឡើងវិញ ការមិនចាំបាច់ឱ្យអ្នកសារព័ត៌មានជ្រើសរើសប្រភេទព័ត៌មានយកទៅផ្សព្វផ្សាយឬក្នុងករណីមួយចំនួនមិនចាំបាច់មានការហាមឃាត់ពីរដ្ឋាភិបាលឡើយ។ ក្នុងកំឡុងពេលដែលគោលនយោបាយអប់រំមានការផ្លាស់ប្តូរយ៉ាងឆាប់រហ័សបែបនេះមុខងារដែលអាចបំពេញដោយបណ្តាញទំនាក់ទំនងសង្គមនៅតែមានសារៈសំខាន់។

ទោះបីជាយ៉ាងណាក៏ដោយ ប្រព័ន្ធផ្សព្វផ្សាយចាំបាច់ត្រូវតែឯករាជ្យ មានគណនេយ្យភាព និងអាចផ្តល់ព័ត៌មានដែលពាក់ព័ន្ធនិងឆ្លុះបញ្ចាំងពីទស្សនៈខុសៗគ្នាក្នុងសង្គម។បុគ្គលិករបស់ប្រព័ន្ធផ្សព្វផ្សាយដែលធ្វើការសិក្សាស្រាវជ្រាវវិភាគចងក្រងសរសេរឬផ្សព្វផ្សាយព័ត៌ដោយផ្ទាល់គួរមានសមត្ថភាពបច្ចេកទេសដើម្បីអាចរាយការណ៍ពីបញ្ហា ដែលកើតមានក្នុងវិស័យអប់រំ ដើម្បីឱ្យខ្លឹមសារដែលពួកគេសរសេរអាចជឿទុកចិត្តបាន។

## ផែនការអប់រំ ដែលអាចជឿជាក់បាន ដោយមានការកំណត់ច្បាស់លាស់ពីការទទួលខុសត្រូវ គឺជាឧបករណ៍ដ៏សំខាន់

បន្ទាប់ពីរដ្ឋាភិបាលបានស្បថចូលកាន់អំណាច ឯកសាររៀបចំផែនការវិស័យអប់រំ ជាមធ្យោបាយដើម្បីសម្រួលឱ្យមានការទាមទារគណនេយ្យភាពតាមរយៈការដាក់ចេញនូវការប្តេជ្ញាចិត្តជាផ្លូវការ និងការកំណត់ឱ្យបានច្បាស់លាស់ពីការទទួលខុសត្រូវ។ ជារឿយៗរដ្ឋាភិបាលរៀបចំផែនការយុទ្ធសាស្ត្រច្រើនឆ្នាំសម្រាប់វិស័យអប់រំ ប៉ុន្តែផែនការប្រតិបត្តិប្រចាំឆ្នាំ ជាធម្មតាគឺជាគន្លឹះសម្រាប់ការរៀបចំផែនការ និងការសម្របសម្រួល។

យន្តការស្ថាប័នដែលផ្តល់អំណាចផ្លូវការបន្ថែមដល់តួអង្គពាក់ព័ន្ធនានា ក៏អាចជួយពង្រឹងគណនេយ្យភាពផងដែរ។ គណៈកម្មាធិការដឹកនាំ ដែលមានសមាសភាពចំរុះជាតួអង្គពាក់ព័ន្ធមកពីរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលដែលមានអំណាចផ្លូវការក្នុងការវាយតម្លៃនិងអនុម័តលើផែនការសម្រាប់វិស័យនេះគួរត្រូវបានបង្កើតឡើង។ ប៉ុន្តែ ក្នុងករណី ដែលមាន ការខ្វះខាត សមត្ថភាព តួអង្គ ពាក់ព័ន្ធ ទាំងនេះ ប្រហែលជា មិនអាចតំណាងឱ្យ ប្រជាពលរដ្ឋ គ្រប់ ស្រទាប់វណ្ណៈ ឡើយ។ ការរៀបចំ ផែនការ អប់រំដែលមាន ការចូលរួម ពិតប្រាកដ អាចត្រូវការពេលវេលាច្រើន។ រដ្ឋាភិបាលច្រើនតែចង់ឱ្យអ្នកជំនាញ ទីប្រឹក្សា អ្នកផ្តល់ជំនួយ រៀបចំផែនការឱ្យខ្លួនឱ្យបានលឿន ដោយមិនចង់ធ្វើការពិគ្រោះយោបល់ច្រើនឡើយ។ ការប្រើប្រាស់ផ្លូវកាត់បែបនេះ អាចធ្វើឱ្យប៉ះពាល់ដល់ភាពជាម្ចាស់ និងការប្តេជ្ញាចិត្តពីតួអង្គពាក់ព័ន្ធនានានៅក្នុងប្រទេស។ ប្រទេសទទួលជំនួយគួរមានការប្រុងប្រយ័ត្ន ដើម្បីបង្ការមិនឱ្យការផែនការនានាទទួលរងឥទ្ធិពលទាំងស្រុងពីអ្នកផ្តល់ជំនួយ។

ការបែងចែកការទទួលខុសត្រូវឱ្យបានច្បាស់មានសារៈសំខាន់យ៉ាងខ្លាំង ជាពិសេសនៅក្នុងប្រព័ន្ធបែបវិមជ្ឈការ ដែលធ្វើឱ្យមានភាពមិនច្បាស់លាស់ពាក់ព័ន្ធជាមួយនឹងអ្នកដែលត្រូវទទួលខុសត្រូវ។ រដ្ឋបាលបែបវិមជ្ឈការជាពិសេសនៅតាមបណ្តាប្រទេសដែលមានចំណូលទាប និងប្រទេសដែលស្ថានភាពមានភាពផុយស្រួយ ជារឿយៗមាន សមត្ថភាព រៀបចំ ផែនការ ជាយុទ្ធសាស្ត្រនៅមានកម្រិតនៅឡើយ។

> “រដ្ឋាភិបាលដែលចាត់តាំងឱ្យអ្នកជំនាញ ទីប្រឹក្សា ឬអ្នកផ្តល់ជំនួយ រៀបចំផែនការលឿនអាចធ្វើឱ្យបាត់បង់ភាពជាម្ចាស់ក្នុងការប្តេជ្ញាចិត្តពីតួអង្គពាក់ព័ន្ធនានានៅក្នុងប្រទេស”

ការប្រើប្រាស់ជំនួយ ដែលកំណត់លទ្ធផលការងារជាលក្ខខណ្ឌ ដើម្បីបង្កើនសមត្ថភាព និងតម្លាភាព របស់រដ្ឋបាលថ្នាក់មូលដ្ឋាន បានជួយកែលំអ ការគ្រប់គ្រងហិរញ្ញវត្ថុនៅតាមប្រទេសដែលមានចំណូលទាប និងមធ្យមជាច្រើន។ នៅសាធារណរដ្ឋតង់ហ្សានៀ អាជ្ញាធរ ដែលអាចបំពេញទៅតាមលក្ខខណ្ឌអប្បបរមា ដើម្បីទទួលជំនួយបែបនេះ កើនឡើងពី ៥០ ភាគរយ ទៅ ៩០ ភាគរយ ក្នុងរយៈពេល ៣ ឆ្នាំ។




ប៉ុន្តែការតម្រូវឱ្យរដ្ឋបាល ថ្នាក់មូលដ្ឋានមានគណនេយ្យភាពចំពោះលទ្ធផល ដែលកំណត់ដោយថ្នាក់ជាតិ ក៏អាចមានផលប៉ះពាល់អវិជ្ជមានផងដែរ។ វប្បធម៌នៃការធ្វើការសវនកម្មច្រើនលើសលុប អាចធ្វើឱ្យមានការបែងចែកការទទួលខុសត្រូវមិនបានច្បាស់លាស់ ធ្វើឱ្យការសហការមានការថយចុះ រារាំងមិនឱ្យមានការច្នៃប្រឌិតថ្មី និងធ្វើឱ្យអ្នកផ្តល់សេវាផ្តោតតែលើចំណុចដៅ ជាជាងធ្វើការកែលំអ។

## ការបង្កើនការត្រួតពិនិត្យក្នុងកំឡុងពេលរៀបចំថវិកា អាចធានាឱ្យមានការបែងចែកធនធាន ចំពោះការអប់រំជាអាទិភាព

ការផ្តល់សិទ្ធិអំណាចឱ្យអ្នកពាក់ព័ន្ធចូលរួមក្នុងការរៀបចំថវិកា និងពិនិត្យឡើងវិញលើចំណាយដែលបានគ្រោងទុក អាចជួយបង្កើនសមធម៌ក្នុងការវិភាជន៍ធនធាន។

ការត្រួតពិនិត្យថវិកាគឺជាមុខងារដ៏សំខាន់នៃអង្គនីតិបញ្ញត្តិ ដែលតម្រូវឱ្យមានពេលវេលា និងការផ្តល់ធាតុចូលពីអ្នកជំនាញ។ អង្គការសង្គមស៊ីវិលអាចជួយដល់អង្គនីតិបញ្ញត្តិ វាយតម្លៃថវិកាដែលបានស្នើឡើង និងផ្តល់ព័ត៌មានមួយចំនួនសម្រាប់ការជជែកពិភាក្សាអំពីថវិកា ដូចជាអ្វីដែលបានធ្វើឡើងនៅក្នុងប្រទេសឥណ្ឌូនេស៊ី និងកេនយ៉ាជាដើម។ ការរៀបចំថវិកាកម្មវិធី ជាជាងការរៀបចំថវិកាដែលផ្តោតលើខ្ទង់ថវិកា អាចជួយឱ្យអ្នកតាក់តែងច្បាប់ធ្វើការវាយតម្លៃចំណាយនានាកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត។

## គណនេយ្យភាពតាមខ្សែទទឹង អាចមានប្រសិទ្ធភាព

គណៈកម្មាធិការរបស់ស្ថាប័ននីតិបញ្ញត្តិ ការិយាល័យប្រជាពលរដ្ឋ និងតុលាការ គឺជាឧទាហរណ៍ដែលបង្ហាញពីឧបករណ៍គណនេយ្យភាពតាមខ្សែទទឹង ដែលតំណាងឱ្យសំលេងរបស់សាធារណជន និងសម្រាប់ដេញដោលការបំពេញការងាររបស់អង្គនីតិប្រតិបត្តិ។ សវនកម្មផ្ទៃក្នុង និងសវនកម្មខាងក្រៅ គឺជាឧបករណ៍ដ៏មានប្រសិទ្ធភាព ដើម្បីធានាឱ្យមានការអនុវត្តថវិកាប្រកបដោយគណនេយ្យភាព កាត់បន្ថយការខ្ជះខ្ជាយ ការវិភាជន៍ថវិកាខុសគោលដៅ និងអំពើពុករលួយ។ ប៉ុន្តែ សវនកម្មទាំងនេះ ត្រូវការអ្នកដែលមានសមត្ថភាពគ្រប់គ្រាន់។

គណៈកម្មាធិការរបស់ស្ថាប័ននីតិបញ្ញត្តិ គឺជាស្ថាប័នដែលបំពេញមុខងារពិនិត្យតាមដានដ៏សំខាន់មួយនេះ។ កង្វះឯករាជ្យភាព សមត្ថភាព ឬសមត្ថកិច្ច អាចជាកត្តាដាក់កំហិតមិនឱ្យគណៈកម្មាធិការទាំងនេះ អាចដឹកនាំការផ្លាស់ប្តូរបាន ប៉ុន្តែការជជែកពិភាក្សារបស់អ្នកតាក់តែងច្បាប់ ដែលមានឯកទេសខាងការអប់រំ អាចធ្វើឱ្យសំណើ គោលនយោបាយ នានា ជុំវិញ បញ្ហា ដែល មិនសូវមាន ភាព ប្រទាំង ប្រទើស កាន់តែ ល្អ ជាងមុន។ អង្គនីតិបញ្ញត្តិនៅប្រទេសញ៉ូហ្ស៊ីលែន ណរវ៉េ ពេរូ សហរដ្ឋអាមេរិច និងតង់ហ្សានី មានគណៈកម្មាធិការអចិន្ត្រៃយ៍ ទទួលបន្ទុកវិស័យអប់រំ ដែលមានតួនាទីត្រួតពិនិត្យលើសកម្មភាពដែលអនុវត្តដោយរដ្ឋាភិបាល ពិនិត្យឡើងវិញលើច្បាប់ និងផ្តល់អនុសាសន៍អំពីការផ្លាស់ប្តូរនានា។ នៅចក្រភពអង់គ្លេស អនុសាសន៍របស់គណៈកម្មាធិការបែបនេះ មានលក្ខណៈដូចគ្នា ឬស្រដៀងគ្នាជាមួយនឹងវិធានការគោលនយោបាយ ដែលនៅក្នុងករណីចំនួន ២០ ក្នុងចំណោមករណីចំនួន ៨៦ ជាពិសេសនៅក្នុងការរៀបចំតាក់តែងច្បាប់ ដើម្បីធ្វើកំណែទម្រង់ប្រព័ន្ធអធិការកិច្ច។ ការិយាល័យប្រជាពលរដ្ឋបើកទ្វារទទួលប្រជាពលរដ្ឋដែលមានបំណងចង់ដាក់ពាក្យបណ្តឹងប្រឆាំងនឹងរដ្ឋាភិបាល។ ការិយាល័យទាំងនេះមានសារៈសំខាន់ជាពិសេស នៅពេលដែលប្រជាពលរដ្ឋពុំមានភាពងាយស្រួលក្នុងការចូលរួមសហការណ៍ជាមួយនឹងមន្ត្រីរដ្ឋាភិបាល។ ក្នុងឆ្នាំ ២០១០ មានប្រទេសចំនួន ១១៨ ដែលមានការិយាល័យប្រជាពលរដ្ឋ។ ជារឿយៗ ការិយាល័យនេះដោះស្រាយបញ្ហា ដែលមានភាពចំរូងចំរាស់ផ្នែកនយោបាយ ដែលអាចធ្វើឱ្យការិយាល័យនេះមានទំនាស់ជាមួយនឹងរដ្ឋាភិបាល។ នៅអាមេរិចឡាទីន វត្តមាននៃការិយាល័យប្រជាពលរដ្ឋ បានជួយលើកកម្ពស់លទ្ធភាពទទួលបានសេវាអប់រំ សុខភាព និងលំនៅដ្ឋាន ពីឆ្នាំ ១៩៩២ ដល់ឆ្នាំ ២០០៦ បើទោះបីជាការិយាល័យនេះពុំមានអំណាចដាក់ទោសយ៉ាងណាក៏ដោយ។ នៅប្រទេសឥណ្ឌូនេស៊ី ការិយាល័យប្រជាពលរដ្ឋបំពេញតួនាទីយ៉ាងសំខាន់ក្នុងការរើកមុខអ្នកដែលប្រព្រឹត្តអំពើគៃបន្លំ លួចលក់វិញ្ញាសារទៅឱ្យសិស្ស និងផ្តល់ចម្លើយសម្រាប់វិញ្ញាសារទាំងនេះ តាមរយៈទូរស័ព្ទដៃ។

អង្គការសង្គមស៊ីវិល និងប្រជាពលរដ្ឋ អាចជួយពង្រឹងសវនកម្មខាងក្រៅ។ នៅប្រទេសឈីលី និងសាធារណរដ្ឋកូរ៉េ ប្រព័ន្ធសម្រាប់ឱ្យប្រជាពលរដ្ឋដាក់ពាក្យបណ្តឹងនិងសំណូមពរតាមអនឡាញជួយរំលេចឱ្យឃើញពីបញ្ហាដែលសវនករត្រូវផ្តោតការយកចិត្តទុកដាក់។ ការអង្កេតតាមដានចំណាយសាធារណៈផ្តល់លទ្ធភាពឱ្យអង្គការសង្គមស៊ីវិល ធ្វើសវនកម្មសង្គម លើចំណាយថវិការបស់រដ្ឋាភិបាល។ ប៉ុន្តែជារឿយៗ ការអង្កេតទាំងនេះ គឺជាអន្តរាគមន៍ដែលធ្វើតែម្តងចប់ ដោយសារមានការជម្រុញពីអ្នកផ្តល់ជំនួយ ហើយកម្រនឹងនាំឱ្យមានការផ្លាស់ប្តូរជាដុំកំភួនយូរអង្វែងណាស់។

> "អង្គនីតិបញ្ញត្តិនៅ ប្រទេសញ៉ូហ្ស៊ីលែន ណរវ៉េ ពេរូ សហរដ្ឋអាមេរិច និងតង់ហ្សានី មាន គណៈកម្មាធិការ អចិន្ត្រៃយ៍ ទទួលបន្ទុកវិស័យអប់រំ ដែលមាន តួនាទី ត្រួតពិនិត្យលើសកម្មភាពដែលអនុវត្តដោយរដ្ឋាភិបាល ពិនិត្យឡើងវិញលើច្បាប់ និងផ្តល់អនុសាសន៍អំពីការផ្លាស់ប្តូរនានា"

## ការកសាងវប្បធម៌ សុចរិតភាពក្នុងស្ថាប័ន គឺជាគន្លឹះដើម្បីឆ្លើយតបចំពោះករណីពុករលួយ

អំពើពុករលួយអាចកើតឡើងនៅក្នុងគ្រប់ផ្នែកទាំងអស់នៃការផ្តល់សេវាអប់រំ ចាប់ពីហិរញ្ញវត្ថុ និងការធ្វើលទ្ធកម្មសេវាកម្មរហូតដល់ការបញ្ជាក់គុណភាពស្ថាប័នការគ្រប់គ្រងគ្រូការប្រឡងការផ្តល់អាហារូបករណ៍ ការស្រាវជ្រាវ និងសៀវភៅសិក្សា។ មិនថាអំពើពុករលួយជាការគែបន្លំប្រាក់ក្នុងទ្រង់ទ្រាយធំ ដែលទាក់ទាញឱ្យមានការចុះផ្សាយក្នុងសារព័ត៌មាន ឬជាការប្រព្រឹត្តអំពើពុករលួយតូចតាចនោះទេ ផលវិបាកដែលកើតចេញពីអំពើពុករលួយសាយភាយលើសពីការខាតបង់ប្រាក់ទៅទៀត ដោយវាអាចបង្កផលប៉ះពាល់ដល់លទ្ធភាពទទួលបានការអប់រំ និងគុណភាពនៃសេវាអប់រំ។ អំពើពុករលួយនាំឱ្យមានភាពលំអៀងក្នុងការធ្វើការសេចក្តីសម្រេចចិត្តអំពីការបែងចែកធនធានរបស់រដ្ឋាភិបាលកាត់បន្ថយផលិតភាព និងធ្វើឱ្យចំណូលរបស់រដ្ឋមានការថយចុះ។

ស្របពេលដែលការសិក្សារបស់ធនាគារ ពិភពលោកអំពីការលេចធ្លាយថវិកា ដែលផ្ទេរពីរដ្ឋាភិបាលនៅថ្នាក់ជាតិ ទៅរដ្ឋបាលមូលដ្ឋាន និងបន្ទាប់មកទៅកាន់សាលារៀន បានជម្រុញឱ្យមានការធ្វើការងារជាច្រើនពាក់ព័ន្ធជាមួយនឹងបញ្ហានេះ ការតាមដានថវិការហូតដល់កន្លែងដែលទទួលថវិកាសម្រាប់យកទៅផ្តល់សេវានៅតែជាការលំបាក ជាពិសេស ក្នុងស្ថានភាពដែលពុំមានការកំណត់វិធានឱ្យបានច្បាស់លាស់ សម្រាប់ការវិភាជន៍ថវិកា។ គ្រូ និងសាលារៀន "ខ្មោច" ពោលគឺគ្រូ និងសាលារៀនដែលមានតែឈ្មោះក្នុងបញ្ជី ប៉ុន្តែពុំមានវត្តមានជាក់ស្តែង គឺជាប្រធានបទដែលមានលក្ខណៈស្មុគស្មាញ និងចំរូងចំរាស់។ នៅក្នុងឆមាសទី ១ នៃឆ្នាំ ២០១៦ តែឯង មានគ្រូខ្មោច ឬគ្រូដែលបើកប្រាក់បៀវត្សរ៍របស់ខ្លួនលើសពីចំនួនដែលត្រូវបាន រហូតទៅដល់ ៨០០០ នាក់។

បន្ទាប់ពីមានការអនុវត្តកំណែទម្រង់ ដើម្បីកែលំអយន្តការវិភាជន៍ថវិកា សម្រាប់វិស័យអប់រំក្នុងប្រទេសប្រេស៊ីល ការធ្វើអធិការកិច្ចដោយអគ្គសវនករក្នុងក្រុងចំនួន ១២០ និងរដ្ឋចំនួន ៤ នៅរកឃើញថា មានក្រុងចំនួន៤៩មានករណីមិនប្រក្រតីនៅក្នុងដំណើរការដេញថ្លៃក្រុងចំនួន២៨មានករណីមិនប្រក្រតីក្នុងការអនុវត្តកិច្ចសន្យា និងក្រុងចំនួន ២១ មានករណី "ដកសាច់ប្រាក់" ចេញពីគណនីធនាគារ។ ការអនុវត្តទាំងនេះអាចមិនត្រូវបានអ្នកសង្កេតពីខាងក្រៅមើលឃើញឡើយ ហើយគេក៏មានការពិបាកក្នុងការផ្ទៀងផ្ទាត់ឱ្យដឹងថាតើមានការប្រព្រឹត្តអំពើពុករលួយកម្រិតណាដែរ ជាពិសេសក្នុងស្ថានភាពពិបាកៗដូចជាក្នុងប្រទេសដែលមានជម្លោះជាដើម។ នៅក្នុងខេត្តហ្គ័រ សាលារៀន ៨០ ភាគរយ ក្នុងចំណោមសាលារៀន ៧៤០ កន្លែង ពុំបានដំណើរការឡើយ បើទោះបីជាក្រសួងអប់រំផ្តល់បៀវត្សរ៍ដល់គ្រូនៅតាមសាលារៀនទាំងនោះយ៉ាងណាក៏ដោយ។

ករណីពុករលួយមួយចំនួនចាក់ឫសគល់កប់យ៉ាងជ្រៅ ដែលធ្វើឱ្យគេមិនអាចកំណត់ដឹងបាន។ នៅក្នុងការអង្កេតតាមដានចំណាយសាធារណៈក្នុងប្រទេសបង់ក្លាដែស មន្ត្រីអប់រំនៅថ្នាក់ស្រុក និងថ្នាក់ឃុំចំនួន ៤០ភាគរយសារភាពថាធ្លាប់"ផ្តល់ប្រាក់"ទៅឱ្យមន្ត្រីគណនេយ្យដើម្បីទទួលបានការទូទាត់ចំណាយរបស់ពួកគេឱ្យបានលឿន។ ការទូទាត់ទាំងនេះអាចមិនពាក់ព័ន្ធជាមួយនឹងការលេចធ្លាយថវិកាជាក់ស្តែង ឬពាក់ព័ន្ធ

ផ្ទាល់ជាមួយថវិការដ្ឋឡើយ ប៉ុន្តែការអនុវត្តបែបនេះលើកទឹកចិត្ត ឱ្យមន្ត្រីទាំងនេះប្រព្រឹត្តអំពើអ្វីមួយ ដើម្បីរកប្រាក់មករ៉ាប់រងចំណាយចាយវាយបែបនេះ។

ការបង្ហាញឱ្យឃើញពីភាពមិនប្រក្រតី គឺមិនទាន់គ្រប់គ្រាន់ឡើយ។ ចាំបាច់ត្រូវតែមានបទដ្ឋានរចនាសម្ព័ន្ធច្បាប់ អមជាមួយដោយយន្តការពិនិត្យតាមដាន ដែលមានភាពល្អប្រសើរជាងមុន ក៏ដូចជាស្ថាប័នសវនកម្មដែលរឹងមាំនិងមានឯករាជ្យភាពប្រព័ន្ធព័ត៌មានបើកចំហនិងការបង្កើតនូវបរិយាកាសអំណោយផលដើម្បីឱ្យមានការត្រួតពិនិត្យពីប្រព័ន្ធផ្សព្វផ្សាយ និងការចូលរួមពីអង្គការមិនមែនរដ្ឋាភិបាល។ នៅក្នុងករណីដែលមានការរកឃើញករណីអំពើពុករលួយ មន្ត្រីនគរបាល និងតុលាការ បំពេញតួនាទីយ៉ាងសំខាន់ ក្នុងការចាត់វិធានការបន្តទៀត។

## ការពិនិត្យតាមដាន និងការវាយតម្លៃការអប់រំ គួរធ្វើឡើងជាប្រព័ន្ធ

ការពិនិត្យតាមដាន និងការវាយតម្លៃ អាចជម្រុញការលើកកម្ពស់គណនេយ្យភាពរបស់រដ្ឋាភិបាល។ ដើម្បីឱ្យការពិនិត្យតាមដានអាចធ្វើទៅបានដោយមានប្រយោជន៍ការពិនិត្យតាមដានត្រូវរាយការណ៍ពីលទ្ធផលដែលចង់បាន ហើយទិន្នន័យនានា ត្រូវតែមានភាពសុក្រឹត និងត្រូវមានការប្រមូលទិន្នន័យឱ្យបានជាប្រចាំ ប៉ុន្តែជារឿយៗ ប្រព័ន្ធពិនិត្យតាមដាន និងវាយតម្លៃមានលក្ខណៈបែកខ្ញែកពីគ្នា។ ស្ថាប័នផ្សេងៗប្រើប្រាស់វិធីសាស្ត្រខុសគ្នា និងមានភាពញឹកញាប់ក្នុងការប្រមូលទិន្នន័យខុសៗគ្នា។ អាចពុំមានការចងក្រងទិន្នន័យនៅថ្នាក់ជាតិ និងទិន្នន័យអាចមិនយកធ្វើការប្រៀបធៀបជាមួយគ្នាបាន ឬគេពុំអាចចូលទៅមើលទិន្នន័យទាំងនោះបាន។

វិធីសាស្ត្រមួយដើម្បីប្រមូលទិន្នន័យ គឺរដ្ឋាភិបាលត្រូវរៀបចំរបាយការណ៍ពិនិត្យតាមដានការអប់រំនៅថ្នាក់ជាតិដែលជាផ្នែកមួយនៃការបំពេញកាតព្វកិច្ចចំពោះស្ថាប័នផ្សេងទៀត ដូចជា អង្គនីតិបញ្ញត្តិ ឬអង្គការអន្តរជាតិជាដើម និងត្រូវជួយឱ្យប្រជាពលរដ្ឋទាមទារគណនេយ្យភាពពីរដ្ឋាភិបាល។ ក្នុងចំណោមប្រទេសចំនួន ២០៩ មានប្រទេសចំនួន ១០៨ បានបោះពុម្ពផ្សាយរបាយការណ៍ពិនិត្យតាមដានការអប់រំនៅថ្នាក់ជាតិយ៉ាងហោចណាស់មួយដងចាប់តាំងពីឆ្នាំ ២០១០ មក ប៉ុន្តែមានតែប្រទេសមួយ ក្នុងចំណោមប្រទេស ៦ ទូទាំងសកលលោកតែប៉ុណ្ណោះ ដែលបានរៀបចំរបាយការណ៍បែបនេះជាទៀងទាត់។

> “ក្នុងចំណោមប្រទេសចំនួន ២០៩ មានប្រទេសចំនួន ១០៨ បានបោះពុម្ពផ្សាយរបាយការណ៍ពិនិត្យតាមដានការអប់រំនៅថ្នាក់ជាតិយ៉ាងហោចណាស់មួយដងចាប់តាំងពីឆ្នាំ២០១០មកប៉ុន្តែមានតែប្រទេសមួយ ក្នុងចំណោមប្រទេស ៦ ទូទាំងសកលលោកតែប៉ុណ្ណោះដែលបានរៀបចំរបាយការណ៍បែបនេះជាទៀងទាត់”

> “ក្នុងចំណោម របាយការណ៍ ពិនិត្យ តាមដានការអប់រំនៅថ្នាក់ជាតិ ដែលមាននៅពេលបច្ចុប្បន្ននេះ មានរបាយការណ៍ តែ ១ ភាគ ៣ ប៉ុណ្ណោះដែលបានលើកឡើងពីការអប់រំមនុស្សពេញវ័យ”

របាយការណ៍ពិនិត្យតាមដានការអប់រំថ្នាក់ជាតិច្រើនតែត្រូវបានគេរៀបចំឡើងតែនៅក្នុងប្រទេសអ្នកមាន ប៉ុន្តែប្រទេសចំណូលមធ្យមដូចជាសាធារណរដ្ឋដូមីនិក និងសាធារណរដ្ឋម៉ូដូវ៉ា ក៏ដូចជាប្រទេសចំណូលទាបមួយចំនួន ដូចជា អ៊ូហ្គាន់ដា ក៏រៀបចំរបាយការណ៍នេះផងដែរ។ របាយការណ៍ស្ទើរតែ ទាំងអស់សុទ្ធតែលើកឡើងពីការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា។របាយការណ៍ប្រមាណជា៣ភាគ៤លើកឡើងពីការគាំពារ និងការអប់រំកុមារតូច របាយការណ៍ ២ ភាគ ៣ លើកឡើងពីការអប់រំឧត្តមសិក្សា និងរបាយការណ៍ ១ ភាគ ៣ លើកឡើងពីការអប់រំមនុស្សពេញវ័យ។

របាយការណ៍ទាំងនេះផ្តោតការយកចិត្តទុកដាក់លើចំណុចខុសៗគ្នា។ របាយការណ៍ប្រមាណជា ៦០ ភាគរយ ផ្តោតលើការរៀបរាប់ពីសកម្មភាព ដែលបានធ្វើកន្លងមក និង ២៥ ភាគរយផ្តោតលើការវាយតម្លៃស្ថានភាព ឆ្លុះបញ្ចាំងពីការព្រួយបារម្ភណ៍ពាក់ព័ន្ធនឹងគណនេយ្យភាព តាមបរិបទក្នុងប្រទេសរៀងៗខ្លួន។ របាយការណ៍ខ្លះក៏ផ្តោតការយកចិត្តទុកដាក់លើគណនេយ្យភាពចំពោះចំណាយថវិកាផងដែរ។

របាយការណ៍មួយចំនួនដូចជារបាយការណ៍ Bildungsbericht (របាយការណ៍អប់រំ) របស់ប្រទេសអាល្លឺម៉ង់ គឺជារបាយការណ៍ ដែលច្បាប់ចែងកំណត់ឱ្យរៀបចំ សម្រាប់រាយការណ៍ជូនសាធារណជន ហើយរបាយការណ៍នេះជាទូទៅផ្តោតលើគណនេយ្យភាពចំពោះសកម្មភាព ឬចំណាយថវិកា នានា។ ក្រសួងអប់រំរបស់ប្រទេសប៉ាណាម៉ា បោះពុម្ពផ្សាយរបាយការណ៍ប្រចាំឆ្នាំ ដូចចែងក្នុងច្បាប់ស្តីពីតម្លាភាពក្នុងការគ្រប់គ្រងសាធារណៈ។ នៅក្នុងប្រទេសហ្វីលីពីន បញ្ញត្តិស្តីពី "តម្លាភាព" ក្នុងច្បាប់ថវិកា ដែលមានគោលបំណង "បង្កើនតម្លាភាព និងពង្រឹងគណនេយ្យភាព" ស្នើឱ្យគេហទំព័រផ្លូវការនៃស្ថានប័នរដ្ឋាភិបាលនៅថ្នាក់ជាតិធ្វើការបង្ហោះផ្សព្វផ្សាយរបាយការណ៍ប្រចាំឆ្នាំយ៉ាងហោចណាស់សម្រាប់រយៈពេល ៣ ឆ្នាំ ចុងក្រោយស្របទៅតាមការណែនាំក្នុងសារាចរណែនាំ ស្តីពីថវិកាជាតិ។

ព័ត៌មានមួយចំនួន សម្រាប់គោលបំណងពិនិត្យតាមដាន ប្រហែលជាត្រូវជួលឱ្យស្ថាប័នខាងក្រៅជួយប្រមូល ឬត្រូវផលិតដោយស្ថាប័នណាមួយ ដែលទទួលបានការគោរព និងការទទួលស្គាល់យ៉ាងទូលំទូលាយចំពោះ ស្នាដៃការងារកន្លងមក និងមិនស្ថិតក្រោមឥទ្ធិពលគ្រប់គ្រងរបស់រដ្ឋាភិបាល។ នៅក្នុងទសវត្សរ៍ចុងក្រោយនេះ ស្ថាប័នវាយតម្លៃស្វយ័ត ត្រូវបានបង្កើតឡើងនៅតាមបណ្តាប្រទេសអាមេរិចឡាទីនមួយចំនួន ដូចជាកូឡុំប៊ី អេក្វាឌ័រ និងមិចស៊ិច ហើយការទទួលខុសត្រូវរបស់ស្ថាប័នទាំងនេះ ត្រូវបានពង្រឹងតាមរយៈការធ្វើការងារជាក់ស្តែង ឬតាមរយៈបញ្ញត្តិច្បាប់ថ្មី។ អង្គការផ្តល់មូលនិធិប្រកបដោយចីរភាព គឺជាកត្តាដ៏សំខាន់ដើម្បីឱ្យស្ថាប័នទាំងនេះអាចបំពេញតួនាទីរបស់ខ្លួន ប្រកបដោយប្រសិទ្ធភាព។

នៅតាមបណ្តាប្រទេសទទួលជំនួយ ការពិនិត្យឡើងវិញរួមគ្នាប្រចាំឆ្នាំ តាមវិស័យដែលប្រមូលផ្តុំរដ្ឋាភិបាលអ្នកផ្តល់ជំនួយតួអង្គសង្គមស៊ីវិល និងតួអង្គពាក់ព័ន្ធដទៃទៀត ឱ្យមកធ្វើការងារជុំគ្នា ក៏ជាការអនុវត្ត

ពេញនិយមមួយផងដែរ។ ប៉ុន្តែការពិនិត្យឡើងវិញទាំងនេះមានចំណុចខ្សោយមួយចំនួន ដោយសារតែការចូលរួមពុំមានលក្ខណៈទូលំទូលាយគ្រប់គ្រាន់ពុំមានផែនការសម្រាប់អនុវត្តអនុសាសន៍ហើយរបៀបវារៈច្រើនតែរៀបចំទៅតាមការចង់បានរបស់អ្នកផ្តល់ជំនួយ។

## គណនេយ្យភាពរបស់សាលារៀន

សាលារៀននិងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលដទៃទៀតត្រូវទទួលខុសត្រូវជាផ្លូវការចំពោះរដ្ឋាភិបាល និងទទួលខុសត្រូវមិនផ្លូវការចំពោះមាតាបិតាសិស្ស និងសិស្សានុសិស្ស។ ប្រទេសជាច្រើនដែលបានធ្វើប្រតិភូកម្មសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចចិត្តទៅឱ្យអាជ្ញាធរថ្នាក់តំបន់ និងមន្ត្រីគ្រប់គ្រងសាលារៀនតាមមូលដ្ឋាន ដែលជាការលើកទឹកចិត្តឱ្យមានគណនេយ្យភាពពីក្រោមឡើងលើផង និងពីលើចុះក្រោមផង។ ការផ្តោតការយកចិត្តទុកដាក់លើគណនេយ្យភាព ក៏នាំឱ្យមានការលំបាកជាច្រើនសម្រាប់សាលារៀនផងដែរ។

### លិខិតបទដ្ឋានគតិយុត្តដែលរៀបចំដោយរដ្ឋាភិបាល ជួយដល់ការពិនិត្យតាមដានគុណភាពសាលារៀន

បទបញ្ញត្តិស្តីពីការអប់រំ ដែលរៀបចំដោយរដ្ឋាភិបាល អាចមានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ។ ឧទាហរណ៍ ខណៈពេលដែលក្នុងចំណោមប្រព័ន្ធអប់រំទាំង ៧១ ដែលត្រូវបានពិនិត្យឡើងវិញសម្រាប់រៀបចំរបាយការណ៍ ពិនិត្យតាមដានការអប់រំជាសកលនេះ មានប្រព័ន្ធស្ទើរតែទាំងអស់ ដែលបានកំណត់បទបញ្ញត្តិស្តីពីគុណវឌ្ឍិរបស់គ្រូ មានប្រព័ន្ធតិចជាង ៤០ ភាគរយប៉ុណ្ណោះ ដែលបានកំណត់ផលធៀបសិស្សគ្រូអតិបរមា **(រូបភាពទី ៤)**។ បទបញ្ញត្តិនានាអាចទាមទារឱ្យអ្នកផ្តល់សេវាអប់រំមានគណនេយ្យភាព ប៉ុន្តែអាចពុំមានប្រសិទ្ធភាពក្នុងការអនុវត្តបទបញ្ញត្តិទាំងនេះឡើយ។ នៅតាមបណ្តាប្រទេសក្រីក្រ សាលារៀនជាច្រើនពុំបានគោរពទៅតាមបទបញ្ញត្តិជាធរមានឡើយ ដោយសារមូលហេតុហួសពីអ្វី ដែលសាលារៀនទាំងនេះអាចគ្រប់គ្រងបាន។ ឧទាហរណ៍ ការផ្តល់ថវិកាពុំបានគ្រប់គ្រាន់ ធ្វើឱ្យសាលារៀនជាច្រើនក្នុងប្រទេសតាជីគីស្ថាន ពុំបានទទួលកម្តៅគ្រប់គ្រាន់នៅរដូវរងា បើទោះបីជានេះជាអ្វីដែលត្រូវបានចែងនៅក្នុងច្បាប់យ៉ាងណាក៏ដោយ។

ជាលក្ខណៈប្រពៃណី អធិការកិច្ចសាលារៀន ធ្វើការពិនិត្យតាមដាន លើភាពអនុលោមទៅតាមបទបញ្ញត្តិនានាហើយប្រសិទ្ធភាពនៃការធ្វើអធិការកិច្ចពឹងអាស្រ័យលើជំនាញរបស់មន្ត្រីអធិការ។ការស្រាវជ្រាវមួយចំនួនបានបង្ហាញថានាយកសាលាដែលទទួលរងសម្ពាធខ្ពស់ឱ្យមានគណនេយ្យភាពពីការធ្វើអធិការកិច្ចបានធ្វើសកម្មភាពមួយចំនួន ដើម្បីបង្កើនលទ្ធផលការងារនៃសាលារៀនរបស់ខ្លួន។

## សាលារៀនឯកជនជាច្រើននៅតាមបណ្តាប្រទេសក្រីក្រ ពុំត្រូវបានគ្រប់គ្រងឱ្យបានត្រឹមត្រូវឡើយ

ចំនួនសាលារៀនឯកជនកាន់តែមានការកើនឡើង។ ចំនួនប្រទេសដែលមានអត្រាចុះឈ្មោះចូលរៀនក្នុងសាលាឯកជនលើសពី២០ភាគរយមានការកើនឡើងចន្លោះពីឆ្នាំ២០០៥ដល់ឆ្នាំ២០១៥ **(រូបភាពទី៥)**។ នៅតាមបណ្តាប្រទេសមួយចំនួននៅអាហ្វ្រិចសាប់សាហារ៉ា និងអាស៊ីភាគខាងត្បូង សាលារៀនឯកជនជាច្រើនពុំត្រូវបានគ្រប់គ្រង ឱ្យបានត្រឹមត្រូវឡើយ ជាពិសេសសាលារៀនដែលផ្តល់សេវាអប់រំដល់ប្រជាពលរដ្ឋក្រីក្រដោយយកថ្លៃសេវាទាប ដែលមានការកើនឡើងយ៉ាងឆាប់រហ័សជាងអ្វីដែលរដ្ឋាភិបាលអាចគ្រប់គ្រងបាន។ សាលារៀនមួយចំនួននៅបន្តមិនចុះបញ្ជី ដើម្បីគេចវេះពីការអនុលោមតាមបទបញ្ញត្តិនានាដែលមានលក្ខណៈតឹងរឹងពេក។ ការគ្រប់គ្រងសាលាឯកជន ដើម្បីឱ្យសាលារៀនទាំងនេះ ផ្តោតការយកចិត្តទុកដាក់លើការបង្កើនសមធម៌ ទាមទារឱ្យមានការចាត់វិធានការរួមគ្នា។

### រូបភាពទី ៥៖
បទបញ្ញត្តិស្តីពីការអប់រំរបស់រដ្ឋាភិបាលមានការប្រែប្រួលខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយ




**សម្គាល់៖** ការពិនិត្យឡើងវិញលើបទបញ្ញត្តិនានាត្រូវបានធ្វើឡើងដោយប្រើប្រាស់ព័ត៌មាន ដែលបានពីការស្វែងរកព័ត៌មានដែលអាចរកបានជាសាធារណៈ និងការទំនាក់ទំនងទៅកាន់មន្ត្រីតាមមូលដ្ឋាន។ បញ្ញត្តិអ្វីមួយដែលមិនត្រូវបានលើកឡើងនៅទីនេះ មិនមែនមានន័យថាពុំមានបទបញ្ញត្តិនេះឡើយ លើកលែងតែមានការបញ្ជាក់ថាពុំមានបទបញ្ញត្តិទាំងនេះ។

ប្រភព៖ ការវិភាគដែលធ្វើឡើងដោយក្រុមរៀបចំរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកល។

**រូបភាពទី ៥៖**

ការចុះឈ្មោះចូលរៀនក្នុងវិស័យឯកជន មានការកើនឡើងនៅកម្រិតអប់រំបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ

ភាគរយនៃប្រទេស បែងចែកទៅតាមកម្រិតភាគរយនៃការចុះឈ្មោះចូលរៀនក្នុងសាលាឯកជន កម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ២០០៥ និង ២០១៥




**សម្គាល់៖** ផ្អែកទៅតាមប្រទេសដែលមានទិន្នន័យសម្រាប់ឆ្នាំ ២០០៥ និង ២០១។ ទិន្នន័យឆ្នាំ ២០០៦ និង ២០១៤ ត្រូវបានប្រើប្រាស់ប្រសិនបើពុំមានទិន្នន័យក្នុងឆ្នាំ ២០០៥ ឬ ២០១។ ប្រភព៖ UIS




ភាពកម្សោយនៃការអនុវត្តបទដ្ឋានគតិយុត្តបង្កឱ្យមានបញ្ហាជាច្រើន ជាពិសេសនៅពេលដែលសាលាឯកជន ដែលមានឥទ្ធិពល ពង្រីកខ្លួនយ៉ាងឆាប់រហ័ស។ សាលា Bridge International Academies ដំណើរការ សាលារៀន ជាង ៥០០ កន្លែងក្នុងប្រទេសចំនួន៥។ ការធ្វើអធិការកិច្ចក្នុងប្រទេសកេនយ៉ា និងអ៊ូហ្គានដា បានរាយការណ៍ពីគ្រូដែលពុំមានសមត្ថភាព សម្ភាររូបវន្តពុំគ្រប់គ្រាន់ និងការប្រើប្រាស់កម្មវិធីសិក្សា ដែលគ្មានការអនុញ្ញាត ហើយតុលាការបានតម្កល់សេចក្តីសម្រេច របស់ក្រសួង ក្នុងការបិទសាលារៀនមួយចំនួន។

## ការធ្វើអធិការកិច្ច ដែលផ្តោតលើគុណភាពនៃការអប់រំ គឺជាទិដ្ឋភាពការដែលទទួលបានការស្វាគមន៍ ប៉ុន្តែពិបាកនឹងអនុវត្ត

ការផ្តោតការយកចិត្តទុកដាក់ក្នុងការធ្វើអធិការកិច្ច បានងាកចេញពីការអនុលោមទៅតាមស្តង់ដាដែលមានចែង ក្នុងលិខិតបទដ្ឋានគតិយុត្ត ទៅរកការវាយតម្លៃគុណភាព នៃការបង្រៀន និងរៀននៅតាមសាលារៀនវិញ ជាពិសេសនៅតាមបណ្តាប្រទេសអ្នកមាន ប៉ុន្តែមុខងារគាំទ្រមួយនេះក៏ពិបាកនឹងអនុវត្តផងដែរ។ប្រព័ន្ធអធិការកិច្ចនៅតាមបណ្តាប្រទេសក្រីក្រជួបនឹងបញ្ហាខ្វះធនធាននិងសមត្ថភាព។នៅអាហ្វ្រិចខាងត្បូង មន្ត្រីគ្រប់គ្រងសាលារៀនប្រឆាំងតបតទៅនឹងកំណែទម្រង់ការធ្វើអធិការកិច្ច មូលហេតុមួយដោយសារអនុស្សាវរីយ៍ជូរចត់ពី ការធ្វើអធិការកិច្ចជំនាន់អាផាថេត។ ក្នុងបរិបទជាច្រើន ការកែលំអការងារអធិការកិច្ចត្រូវការពេលវេលា។ ត្រឹមឆ្នាំ ២០១៥ មានមន្ត្រីអធិការតែ ៣៥ ភាគរយក្នុងប្រទេសអង់ហ្គូឡាតែប៉ុណ្ណោះ ដែលបានទទួលការបណ្តុះបណ្តាលអំពីកំណែទម្រង់ បើទោះបីជាកំណែទម្រង់នេះចាប់ផ្តើម តាំងពីឆ្នាំ ២០១០ មកក៏ដោយ។

## ការធានាគុណភាពការអប់រំកុមារតូច ផ្តោតការយកចិត្តទុកដាក់លើចំណុចដែលគេងាយស្រួលសង្កេតឃើញ

បើទោះបីជាការអប់រំកុមារតូចមានសារៈសំខាន់ចំពោះការអភិវឌ្ឍគ្រប់ជ្រុងជ្រោយរបស់កុមារយ៉ាងណាក៏ដោយ អតិក្រមជាប្រព័ន្ធដើម្បីសម្រេចលទ្ធផលនៃការអប់រំកាន់តែប្រសើរជាងមុន ដែលអនុវត្តដោយធនាគារពិភពលោកចន្លោះពី ឆ្នាំ ២០១០ ដល់ឆ្នាំ ២០១៥ បានបង្ហាញថាក្នុងចំណោមប្រទេស ដែលមានចំណូលទាប និងមធ្យមចំនួន ៣៤ មានតែ ១៤ ប្រទេសប៉ុណ្ណោះដែលបានបង្កើតស្តង់ដាអប់រំកុមារតូច និងប្រព័ន្ធពិនិត្យតាមដានភាពអនុលោមទៅតាមស្តង់ដានេះ។

ក្នុងការធានាគុណភាពប្រទេសនានា ច្រើនចង់ប្រើប្រាស់លក្ខណៈវិនិច្ឆ័យដែលងាយស្រួលវាស់វែង និងងាយស្រួលសង្កេតដឹង ដូចជាហេដ្ឋារចនាសម្ព័ន្ធ និងផលធៀបសិស្សគ្រូជាដើម។ បើទោះបីជាបែបនេះយ៉ាងណាក៏ដោយ ប្រទេសមួយចំនួនមានការពិបាកក្នុងការពិនិត្យតាមដានភាពអនុលោមទៅតាមស្តង់ដាដែលបានកំណត់ក្នុងលក្ខណៈជាប្រព័ន្ធ ដូចជាប្រទេសបេលីហ្ស ឥណ្ឌូនេស៊ី នេប៉ាល់ និងស្វាហ្ស៊ីលែន ជាដើម។

> “ក្នុងចំណោមប្រទេសដែលមានចំណូលទាប និងមធ្យមចំនួន ៣៤ មានតែ ១៤ ប្រទេសប៉ុណ្ណោះដែលបានបង្កើតស្តង់ដាអប់រំកុមារតូច និងប្រព័ន្ធពិនិត្យតាមដានធៀបអនុលោមទៅតាមស្តង់ដានេះ”

ប្រព័ន្ធផ្សេងទៀតព្យាយាមវាយតម្លៃ លក្ខណៈវិនិច្ឆ័យតូចៗ ដែលពាក់ព័ន្ធនឹងការបង្រៀន។ ក្នុងប្រទេសឈីលី អ្នកអប់រំនៅតាមសាលាទាំងអស់នៅក្នុងក្រុង ត្រូវឆ្លងកាត់ការវាយតម្លៃរៀងរាល់ ៤ ឆ្នាំម្តង ធៀបនឹងស្តង់ដាក្នុងក្របខ័ណ្ឌស្តីពីការបង្រៀនដែលល្អ ដែលនេះជាដំណើរការមួយដែលមានស្វ័យវាយតម្លៃ ការសង្កេតមើលពីខាងក្រៅ ការវាយតម្លៃគ្នាឯង និងការពិនិត្យលើលទ្ធផលដែលសម្រេចបានកន្លងមក។ គ្រូដែល

ទទួលបានពិន្ទុ "មិនពេញចិត្ត" ត្រូវបានវាយតម្លៃឡើងវិញនៅឆ្នាំបន្ទាប់ និងត្រូវបានហាមឃាត់មិនឱ្យបង្រៀនទៀតឡើយ ប្រសិនបើពុំមានការរីកចម្រើននោះ។

ឧបករណ៍មួយចំនួនដូចជា មាត្រដ្ឋានវាស់វែងបរិយាកាសនៃការអប់រំកុមារតូចជួយវាយតម្លៃគុណភាពនៃអន្តរកម្មរវាងគ្រូ និងកុមារ។ មាត្រាដ្ឋាននេះត្រូវបានបង្កើតឡើង និងប្រើប្រាស់យ៉ាងទូលំទូលាយ នៅសហរដ្ឋអាមេរិច និងត្រូវបានកែសម្រួលប្រើប្រាស់នៅតាមបណ្តាប្រទេសដែលមានចំណូលខ្ពស់ផ្សេងទៀត ដូចជាប្រទេសអាល្លឺម៉ង់ និងអ៊ីតាលីផងដែរ។

ការវាស់វែងការអភិវឌ្ឍកុមារតូចដោយផ្ទាល់ អាចជួយដល់ដំណើរការនៃការធានាគុណភាព។ ការសិក្សាស្រាវជ្រាវរយៈពេលវែងដែលមានឈ្មោះថាការធំឡើងក្នុងប្រទេសស្កុតលែន (Growing Up in Scotland) មានគោលបំណងផ្សារភ្ជាប់ទំនាក់ទំនងបទពិសោធន៍នៅវ័យកុមារតូច ជាមួយនឹងលទ្ធផលដែលសម្រេចក្រោយមកទៀតក្នុងចំណោមកុមារចំនួន១៤០០០នាក់។ កុមារទាំងនេះត្រូវបានបែងចែកជាបីក្រុម។ លទ្ធផលពីការស្រាវជ្រាវនេះត្រូវបានយកទៅ ប្រើប្រាស់សម្រាប់រៀបចំគោលនយោបាយគាំពារ និងអប់រំកុមារតូចឡើងវិញ។

ការរួមចំណែករបស់សហគមន៍ ជាពិសេសរបស់មាតាបិតាសិស្ស មានសារៈសំខាន់យ៉ាងខ្លាំងដើម្បីធានាគុណភាពនៃការគាំពារកុមារតូច។ នៅក្នុងប្រទេសបារាំង បេឡាជាតិសម្រាប់គ្រួសារ (National Family Allocation Fund) បានបង្កើតរង្វាស់មួយ ដោយប្រើប្រាស់ព័ត៌មានដែលបានពីការអង្កេតលើការពេញចិត្តរបស់មាតាបិតាជាគោល ហើយតំណាងមាតាបិតាដែលត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោត ជាអ្នកផ្តល់គំនិតយោបល់ដល់គណៈកម្មការកុមារតូចនៃក្រុមប្រឹក្សាភិបាលនៃបេឡាជាតិនេះ។

## យន្តការធានាគុណភាពនៅឧត្តមសិក្សា ឆ្លុះបញ្ចាំងពីគោលបំណងខុសៗគ្នា

ក្របខ័ណ្ឌច្បាប់របស់ប្រទេសនានា តម្រូវឱ្យមានស្ថាប័នជាតិមួយ ឬស្ថាប័នជាតិច្រើនទទួលខុសត្រូវលើការធានាគុណភាពការអប់រំ និងឧត្តមសិក្សា បើទោះបីជាប្រទេសដែលមានចំណូលទាបជាច្រើន ពុំទាន់បានបង្កើតប្រព័ន្ធបែបនេះនៅថ្នាក់ជាតិយ៉ាងណាក៏ដោយ។ ការរៀបចំនៅថ្នាក់តំបន់ដូចជា អនុសញ្ញាលីស្បូនជាដើម បានជម្រុញឱ្យមានការបង្កើតនូវប្រព័ន្ធធានាគុណភាពនៅថ្នាក់ជាតិ ដោយប្រទេសនៅក្នុងតំបន់នេះត្រូវបញ្ចូលស្តង់ដាតំបន់ទៅក្នុងច្បាប់ជាតិរបស់ខ្លួន។

ការវាយតម្លៃលើការធានាគុណភាពទាមទារឱ្យមានការកំណត់ជាស្តង់ដាស្ថាប័នធ្វើស្វ័យវាយតម្លៃការពិនិត្យឡើងវិញពីអ្នកជំនាញខាងក្រៅ និងការពិនិត្យគ្នាទៅវិញទៅមកដោយស្ថាប័នប្រហាក់ប្រហែលគ្នា ការរៀបចំរបាយការណ៍វាយតម្លៃ និងដំណើរការប្តឹងឧទ្ធរណ៍។ ស្តង់ដា អាចជាស្តង់ដាកំណត់ដែលត្រូវតែធ្វើតាម ឬជាស្តង់ដាដែលមានលក្ខណៈត្រឹមតែជាផ្តល់ប្រឹក្សា។ ស្តង់ដាទាំងនេះគ្របដណ្តប់លើធនធាន សកម្មភាព និងលទ្ធផលដែលត្រូវសម្រេចដោយការអប់រំឧត្តមសិក្សា។ ការវាយតម្លៃលើគុណភាពនៃការអប់រំថ្នាក់បរិញ្ញាបត្រនៅប្រទេសចិន ប្រើប្រាស់សូចនាករចំនួន ១៩ បែងចែកជា ៨ ផ្នែក៖ បេសកម្មរបស់សកលវិទ្យាល័យ បុគ្គលិក

បង្រៀន សម្ភារូបវន្ត កម្មវិធីសិក្សា ការគ្រប់គ្រងបរិយាកាស ខ្លឹមសារនៃការរៀន និងកម្មវិធីពិសេស។

ស្ថាប័នធានាគុណភាព ត្រូវបំពេញគណនេយ្យភាព តាមរយៈរបាយការណ៍ប្រចាំឆ្នាំ ការបង្កើតប្រព័ន្ធព័ត៌មាន ការចុះបញ្ជីជាមួយស្ថាប័ននៅថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មានជាតិ។ ប៉ុន្តែបណ្តាញអន្តរជាតិនៃស្ថាប័នធានាគុណភាពការអប់រំឧត្តមសិក្សា បានបោះពុម្ពផ្សាយសៀវភៅណែនាំស្តីពីឧត្តមានុវត្តន៍ ដើម្បីលើកទឹកចិត្តឱ្យមានគណនេយ្យភាព និងតម្លាភាព។ សមាជិកចំនួន ១៨ នៅក្នុងបណ្តាប្រទេសនានា ចាប់ពីកូស្តារីកា រហូតដល់សាធារណរដ្ឋអារ៉ាប់រួម បានកែសម្រួលគោលការណ៍ណែនាំស្តីពីឧត្តមានុវត្តន៍របស់ខ្លួនឱ្យស្របទៅតាមសៀវភៅណែនាំរបស់បណ្តាញអន្តរជាតិនេះ។ ប៉ុន្តែព័ត៌មានជាច្រើននៅក្នុងរបាយការណ៍គណនេយ្យភាពពុំត្រូវបានគេផ្សព្វផ្សាយឱ្យបានទូលំទូលាយឡើយ ក្រៅតែពីផ្សព្វផ្សាយដល់អ្នកជំនាញកម្រិតឧត្តមសិក្សា។

ក្របខ័ណ្ឌគតិយុត្ត ដែលមានវិសាលភាពចំពោះការអប់រំកម្រិតឧត្តមសិក្សាទូទាំងប្រទេស ផ្តោតការយកចិត្តទុកដាក់សំខាន់លើការគាំទ្រដល់គ្រឹះស្ថានឧត្តមសិក្សា។ និស្សិតអន្តរជាតិ ជារឿយៗ ពុំបានដឹងពីសិទ្ធិរបស់ខ្លួនឡើយ ហើយពេលខ្លះពួកគេអាចមានការលំបាកក្នុងការទទួលព័ត៌មាន។ ប្រទេសទាំងឡាយគួរផ្តល់អាទិភាពដល់ការកំណត់ និងការបង្កើនការយល់ដឹងអំពីអ្នកផ្តល់សេវាដែលមានឈ្មោះអាក្រក់ និងគួរលើកទឹកចិត្តសមាគមនិស្សិតឱ្យធ្វើការផ្សព្វផ្សាយព័ត៌មានអំពីអ្នកផ្តល់សេវាអប់រំដែលមានគុណភាពខ្ពស់។

កម្មវិធីអាហារូបករណ៍ជាច្រើនមានគណនេយ្យភាពចំពោះអ្នកផ្តល់ជំនួយចំពោះធនធានដែលពួកគេបានចំណាយប៉ុន្តែរបាយការណ៍របស់ពួកគេនឹងរឹតតែមានប្រយោជន៍បន្ថែមទៀតប្រសិនបើរបាយការណ៍ទាំងនេះផ្តល់ព័ត៌មានទាន់ពេលវេលាដល់សិស្សនិស្សិត គ្រួសារ និងសកលវិទ្យាល័យនានា។ ការសិក្សារយៈពេលវែងដែលធ្វើការវាស់វែងលទ្ធផលរយៈពេលវែងរបស់កម្មវិធីនិងដែលប្រមូលព័ត៌មានត្រឡប់ពីសកលវិទ្យាល័យនិងអតីតនិស្សិតគឺជាការសិក្សាដែលមានប្រយោជន៍សម្រាប់គោលបំណងនេះ។គណៈកម្មការអាហារូបករណ៍ខមិនវេលស៍នៃចក្រភពអង់គ្លេស ធ្វើការអង្កេតលើអ្នកដែលទទួលបានអាហារូបករណ៍ និងប្រើប្រាស់លទ្ធផលបានពីការអង្កេតនេះ សម្រាប់រៀបចំកម្មវិធីនាពេលអនាគត។

## រដ្ឋាភិបាលចាំបាច់ត្រូវតែមានគណនេយ្យភាព ក្នុងការធានាឱ្យនិស្សិតអាចទទួលបានការអប់រំកម្រិតឧត្តមសិក្សាក្នុងតម្លៃមួយសមរម្យ

ការចុះឈ្មោះចូលរៀននៅកម្រិតឧត្តមសិក្សាមានការកើនឡើងជាបន្តបន្ទាប់ ដោយសារអត្រាបន្តការសិក្សាទៅឆ្នាំបន្ទាប់របស់និស្សិតមានការកើនឡើង ហើយចំនួននិស្សិតសិក្សាក្រៅម៉ោងក៏មានការកើនឡើងផងដែរ។

រដ្ឋាភិបាលបានប្រើប្រាស់ក្របខ័ណ្ឌគតិយុត្តជាតិ ដើម្បីបង្កើនសមធម៌ និងធ្វើឱ្យថ្លៃសិក្សាកម្រិតឧត្តមសិក្សាមានភាពសមរម្យ ប៉ុន្តែមានប្រទេសតែមួយចំនួនតូចតែប៉ុណ្ណោះដែលអាចធានាបាននូវសកលកម្មនៃការអប់រំកម្រិតឧត្តមសិក្សា។ ប្រទេសដែលប្រើប្រាស់ក្របខ័ណ្ឌគតិយុត្តបែបនេះរួមមានប្រទេសអេក្វាឌ័រ ក្រិច

ទុយណេស៊ី។ ប្រទេសជាច្រើន ដូចជា ប្រទេសប្រេស៊ីល ឡាវ មានច្បាប់ដែលធានាលទ្ធភាពទទួលបានការអប់រំឧត្តមសិក្សា។ ប្រទេសទាំងនេះហាមឃាត់ឱ្យមានការរើសអើង និងលើកទឹកចិត្តឱ្យក្រុមជនជាតិភាគតិច និងក្រុមដែលជួបការលំបាកទទួលបានការអប់រំកម្រិតឧត្តមសិក្សា។ខណៈពេលដែលតម្រូវការការអប់រំឧត្តមសិក្សាមានការកើនឡើង រដ្ឋាភិបាលបានបង្វែរបន្ទុកចំណាយមួយចំនួនទៅឱ្យនិស្សិតជាអ្នករ៉ាប់រងដោយខ្លួនឯងវិញ អាចតាមរយៈការបង្កើនថ្លៃសិក្សា និងថ្លៃសេវានានា ឬលើកទឹកចិត្តឱ្យវិស័យឯកជនផ្តល់សេវាអប់រំកម្រិតនេះ។ សូម្បីតែនៅក្នុងករណីដែលពុំមានការយកថ្លៃសេវា យ៉ាងណាក៏ដោយ ការកំណត់បែបនេះគឺមិនទាន់គ្រប់គ្រាន់ ដើម្បីធានាឱ្យថ្លៃសិក្សាមានកម្រិតសមរម្យនៅឡើយ។ ប្រសិនបើពុំមានការគាំទ្របន្ថែមទៀតទេ ការផ្តល់លទ្ធភាពឱ្យនិស្សិតទទួលបានការអប់រំកម្រិតឧត្តមសិក្សាដោយមិនគិតថ្លៃ ទីបំផុត នឹងក្លាយជាការផ្តល់ឧបត្ថម្ភធនដល់និស្សិតមកពីគ្រួសារដែលមានជីវភាពធូរជាទៅវិញ។ ឧទាហរណ៍ ប្រទេសហ្វីលីពីនបានលុបបំបាត់ថ្លៃសេវាចូលរៀននៅមហាវិទ្យាល័យរដ្ឋកាលពីឆ្នាំ ២០១៦ ក៏ប៉ុន្តែការធ្វើបែបនេះបានត្រឹមតែទាក់ទាញនិស្សិតមកពីគ្រួសារអ្នកមានប៉ុណ្ណោះ។

ថ្លៃសិក្សាគួរបញ្ចូលជាមួយនឹងកម្មវិធីផ្តល់ជំនួយហិរញ្ញវត្ថុ ដូចជាការផ្តល់ជាជំនួយកម្ចី និងភាពអនុគ្រោះផ្នែកពន្ធជាដើម។ ជំនួយសម្រាប់សងកម្ចីដល់និស្សិតដែលមានចំណូលទាបអាចជួយបង្កើនជម្រើសដែលមានតម្លៃសមរម្យសម្រាប់ពួកគេ។ ការផ្តោតការយកចិត្តទុកដាក់លើក្រុមដែលមានចំណូលទាប មានសារៈសំខាន់យ៉ាងខ្លាំង ប៉ុន្តែការកំណត់ឱ្យដឹងថា តើអ្នកណាជាអ្នកដែលមានចំណូលទាបជាការលំបាក ក្នុងស្ថានភាពដែលរង្វាស់ចំណូលរបស់គ្រួសារ ពុំអាចជឿទុកចិត្តបាន ដូចជានៅក្នុងប្រទេសដែលមានចំណូលទាបជាដើម។

## អ្នកផ្តល់សេវាបណ្តុះបណ្តាលជំនាញ និងអ្នកចេញវិញ្ញាបនបត្របញ្ជាក់ ត្រូវមានគណនេយ្យភាពចំពោះអ្នកទទួលបានការបណ្តុះបណ្តាល និងនិយោជក

ប្រព័ន្ធធានាគុណភាពដែលរឹងមាំសម្រាប់អភិវឌ្ឍជំនាញវិជ្ជាជីវៈ ជួយទាមទារគណនេយ្យភាពពីអាជ្ញាធរ និងអ្នកផ្តល់សេវា ចំពោះអ្នកដែលមកទទួលសេវាពីពួកគេ ដូចជាកម្មករនិយោជិតនិងនិយោជក និងជួយឱ្យពួកគេមានគណនេយ្យភាពចំពោះគ្នាទៅវិញទៅមក។

> "ការវាយតម្លៃលើការធានាគុណភាព ទាមទារឱ្យមានការកំណត់ជាស្តង់ដា ស្ថាប័នធ្វើស្វ័យវាយតម្លៃការពិនិត្យឡើងវិញពីអ្នកជំនាញខាងក្រៅ និងការពិនិត្យគ្នាទៅវិញទៅមកដោយស្ថាប័នប្រហាក់ប្រហែលគ្នា ការរៀបចំរបាយការណ៍ វាយតម្លៃ និងដំណើរការប្តឹងឧទ្ធរណ៍"

ប្រព័ន្ធអភិវឌ្ឍជំនាញ និងគុណវឌ្ឍិត្រូវការអភិបាលកិច្ចដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា ដោយត្រូវដាក់ចេញនៅក្របខ័ណ្ឌរួមមួយ ដែលត្រូវកំណត់គោលបំណងឱ្យបានច្បាស់លាស់។ វិធីសាស្ត្រមួយ ដើម្បីបន្សុីតម្រូវការទីផ្សារការងារ និងការផ្គត់ផ្គង់របស់អ្នកផ្តល់សេវា គឺត្រូវជម្រុញឱ្យមានការចូលរួមពីនិយោជក និងដៃគូសង្គម ក្នុងការរៀបចំក្របខ័ណ្ឌនានា បើទោះបីជាការធ្វើបែបនេះ មិនមែនចេះតែងាយស្រួល យ៉ាងណាក៏ដោយដូចជាករណីក្នុងប្រទេសប៉ូឡូញ និង ទុយណេស៊ី ជាដើម ។

អ្នកផ្តល់សេវាណ្តុះបណ្តាលដែលមិនមែនរដ្ឋ ដែលបន្តកើនចំនួនជាបន្តបន្ទាប់ គួរគោរពទៅតាមបទដ្ឋានគតិយុត្ត និងនីតិវិធីនានា ដើម្បីទទួលបានការបញ្ជាក់គុណភាព និងដើម្បីអាចដំណើរការប្រតិបត្តិការរបស់ខ្លួនបាន។ ដូចករណីអប់រំឧត្តមសិក្សាដែរ ការបញ្ជាក់គុណភាព គឺជាដំណើរការធានាគុណភាព ដែលជាធម្មតា អាជ្ញាធររដ្ឋាភិបាល ឬអាជ្ញាធរវិជ្ជាជីវៈពីខាងក្រៅ ត្រូវផ្តល់ការបញ្ជាក់ថា អ្នកផ្តល់សេវាពិតជាបានបំពេញទៅតាមស្តង់ដាដែលត្រូវបានដាក់ចេញពិតប្រាកដមែន។

ក្នុងគោលបំណងផ្តល់ការបណ្តុះបណ្តាលដល់ប្រជាពលរដ្ឋ ៤០០ លាននាក់ ត្រឹមឆ្នាំ ២០២២ កម្មវិធីអភិវឌ្ឍន៍ជំនាញដ៏មានមហិច្ឆិតារបស់ប្រទេសឥណ្ឌា ត្រូវធានាថាការចេញវិញ្ញាបនបត្របញ្ជាក់ ត្រូវធ្វើឡើងដោយ តម្លាភាព សិក្ខាកាម ទទួលបាន អត្ថប្រយោជន៍ ពេញលេញ បេក្ខជន ចុះឈ្មោះ ដោយ ប្រើប្រាស់ លេខសម្គាល់អត្តសញ្ញាណតែមួយ និងលែងជួលអ្នកផ្តល់សេវាដែលពុំមានទទួលបានការបញ្ជាក់ត្រឹមត្រូវឱ្យផ្តល់សេវា។ ការជួលអ្នកផ្តល់សេវាបែបនេះ ត្រូវបានចាត់ទុកថាជាទង្វើខុសច្បាប់។ រដ្ឋាភិបាលចាំបាច់ត្រូវការពារសិក្ខាកាមពីការអះអាងក្លែងភូតភរ ដូចជាការអះអាងការសន្យាថានឹងផ្តល់ការងារ ជាថ្នូរនឹងការឱ្យពួកគេបង់ថ្លៃសេវាជាដើម។ ស្រដៀងគ្នានេះដែរ នៅក្នុងប្រទេសអូស្ត្រាលី ការស៊ើបអង្កេតរបស់ព្រឹទ្ធសភា បានធ្វើការពិនិត្យលើ ថា តើ ការផ្សព្វផ្សាយ ពាណិជ្ជកម្មរបស់អ្នកផ្តល់ សេវា បណ្តុះបណ្តាល ឯកជន នាំឱ្យបេក្ខជន មាន ការភាន់ច្រលំពាក់ព័ន្ធនឹងតម្លៃនៃគុណវុឌ្ឍិ ដែលពួកគេនឹងទទួលបានដែរឬទេ ជាពិសេសបេក្ខជនដែលមកពីក្រុមជួបការលំបាក ។

## ការពិនិត្យតាមដានអាចបង្កើនគណនេយ្យភាពក្នុងកម្មវិធីអក្ខរកម្មមនុស្សពេញវ័យ

គណនេយ្យភាពក្នុងកម្មវិធីអក្ខរកម្ម និងលេខនព្វន្តមនុស្សពេញវ័យ គឺជាកិច្ចការដ៏លំបាក ដោយសារកម្មវិធីបែបនេះអ្នកអនុវត្តយ៉ាងច្រើនរបៀបផ្តល់ឱកាសសម្រាប់ការអនុវត្តកម្មវិធីចម្រុះនិងការយល់ឃើញខុសៗគ្នាពីគោលបំណង នៃកម្មវិធីទាំងនេះ។ បើទោះបីជា យ៉ាងណាក៏ដោយប្រទេសនានា កំពុងបន្តដាក់ចេញនូវស្តង់ដាគុណភាពនិងការរំពឹងទុកអំពីលទ្ធផលដែលត្រូវបានសម្រេចឱ្យបាន។ប្រព័ន្ធពិនិត្យតាមដានបានក្លាយជាប្រព័ន្ធ ដែលពេញនិយមនៅតាមបណ្តាប្រទេសទាំងនេះ។ នៅក្នុងប្រព័ន្ធទិន្នន័យរបស់យូណេស្កូ ដែលកត់ត្រាការអនុវត្តផ្នែកអក្ខរកម្មនិងលេខនព្វន្តដែលមានប្រសិទ្ធភាពមានកម្មវិធីអក្ខរកម្មនិងលេខនព្វន្តមនុស្សពេញវ័យជាង ២០០ កម្មវិធី បានធ្វើការពិនិត្យតាមដាន និងវាយតម្លៃដែលជាធម្មតា ធ្វើឡើងជាផ្នែកមួយនៃការគ្រប់គ្រង និងការអនុវត្តកម្មវិធី។

ការប្រមូលទិន្នន័យហិរញ្ញវត្ថុជួយឱ្យរដ្ឋាភិបាលអាចទាមទារគណនេយ្យភាពពីអ្នកផ្តល់សេវាមិនមែនរដ្ឋចំពោះគុណភាពនិងការបែងចែកធនធាន។កម្មវិធីអក្ខរកម្មKha Ri Gude (តោះនាំគ្នារៀន) នៅអាហ្វ្រិចខាងត្បូង បានជួលក្រុមហ៊ុនឯកជនមួយឱ្យរៀបចំរបាយការណ៍គណនេយ្យហិរញ្ញវត្ថុ និងធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យអ្នករៀន និងអ្នកអប់រំ ក្នុងប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់ខ្លួន។ ការផ្តល់បៀវត្សរ៍ឱ្យគ្រូ ធ្វើឡើងទៅតាមការដាក់របាយការណ៍ចំណាយ និងការផ្តល់ទិន្នន័យវត្តមានសិស្ស។ សវនកម្មក្នុងឆ្នាំ ២០១៦ បានរកឃើញថាមានការផ្តល់ប្រាក់ឱ្យអ្នកស្ម័គ្រចិត្ត ដើម្បីឱ្យចំនួនអ្នកចូលរៀនមានការកើនឡើង ក្នុងឯកសារស្នើសុំទូទាត់ចំណាយ។

ការពិនិត្យតាមដានលទ្ធផលកម្មវិធីអក្ខរកម្ម អាចជួយធានាគណនេយ្យភាព។ ការចុះវាយតម្លៃដល់មូលដ្ឋាន គឺជាវិធីសាស្ត្រមួយដែលត្រូវបានប្រើប្រាស់ ដូចជាក្នុងប្រទេសប៉ាគីស្ថានជាដើម។ វិធីសាស្ត្រផ្សេងទៀតរួមមានការរៀបចំយុទ្ធសាស្ត្រវាយតម្លៃក្នុងពេលកំពុងអនុវត្តកម្មវិធី និងវាយតម្លៃពេលបញ្ចប់កម្មវិធីដូចជាការធ្វើតេស្តការធ្វើបទបង្ហាញ និងស្វ័យវាយតម្លៃជាដើម។

ប្រទេសដែលមានចំណូលខ្ពស់ជារឿយៗ ធ្វើការវាយតម្លៃលើលទ្ធផល ដែលសម្រេចបានដោយប្រើប្រាស់ក្របខ័ណ្ឌ និងឧបករណ៍វាយតម្លៃ ដែលត្រូវបានរៀបចំឡើងចេញជាស្តង់ដាថ្នាក់ជាតិ ដែលពេលខ្លះស្តង់ដានេះត្រូវបានភ្ជាប់ទំនាក់ទំនងជាមួយនឹង ការផ្តល់មូលនិធិពីរដ្ឋដូចជាក្នុងសហរដ្ឋអាមេរិចជាដើម។ ប្រទេសចំណូលមធ្យមមួយចំនួនដូចជា សាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ និងម៉ិចស៊ិច បានរៀបចំឱ្យមានការប្រឡងបញ្ចប់តាមប្រព័ន្ធអនឡាញ សម្រាប់ស្រុកនីមួយៗដោយស្វ័យប្រវត្តិ។ ប្រទេសផ្សេងទៀតពឹងអាស្រ័យលើអ្នកសម្របសម្រួលតាមថ្នាក់ ដើម្បីធ្វើការវាយតម្លៃបណ្តើរៗ និងការវាយតម្លៃចុងបញ្ចប់វគ្គ និងពុំបានប្រមូលទិន្នន័យក្នុងលក្ខណៈជាប្រព័ន្ធប់យកមកធ្វើការវិភាគឡើយ។ ហើយកម្មវិធីមួយចំនួនបានធ្វើការវាយតម្លៃលើលទ្ធផលសិក្សារបស់សិស្ស លើសពីបំណិនអក្ខរកម្ម ដែលសិស្សបានទទួល។ កម្មវិធីប្រយុទ្ធប្រឆាំងនឹងគ្រោះអក្ខរកម្មរបស់ប្រទេសបារាំង វាយតម្លៃអ្នកចូលរួមលើសមត្ថភាពស្វ័យភាព ទំនុកចិត្ត ការលើកទឹកចិត្តទំនាក់ទំនងក្នុងការរស់នៅប្រចាំថ្ងៃ និងការអភិវឌ្ឍផ្នែកចំណេះដឹង។

## ប្រើប្រាស់ទិន្នន័យរៀនសូត្ររបស់សិស្ស ដើម្បីទាមទារឱ្យសាលារៀនមានគណនេយ្យភាព ត្រូវការចំណាយច្រើន...

រដ្ឋាភិបាលកាន់តែចាប់អារម្មណ៍ចំពោះការប្រមូលទិន្នន័យអំពីលទ្ធផលដែលសម្រេចបាននៅសាលារៀន និងលទ្ធផលនៃការរៀនសូត្ររបស់សិស្ស។ ជាគោលការណ៍ ព័ត៌មានបែបនេះគួរផ្តល់លទ្ធភាពឱ្យអ្នកដឹកនាំវិស័យអប់រំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងសាលារៀន ធ្វើការសម្រេចចិត្ត ផ្អែកទៅតាមភស្តុតាងត្រឹមត្រូវដរាបណាព័ត៌មាននេះជាព័ត៌មានដែលមានគុណភាពល្អ ហើយអ្នកដឹកនាំទាំងនោះជាអ្នកដែលមានអំណាចធ្វើការសម្រេចចិត្ត ដោយមិនទទួលរងឥទ្ធិពលពីអ្នកនយោបាយ។

លទ្ធផលនៃការវាយតម្លៃបញ្ចប់វគ្គត្រូវបានប្រើប្រាស់ នៅកម្រិតបុគ្គល ដើម្បីធ្វើការសម្រេចចិត្តពី ការចុះឈ្មោះសិស្សឱ្យចូលរៀនក្នុងកម្មវិធីណាមួយ និងធ្វើការសម្រេចថាតើត្រូវឱ្យសិស្សឡើងទៅកម្រិតបន្ទាប់ដែរឬទេ និងត្រូវបានប្រើប្រាស់នៅកម្រិតស្ថាប័ន ដើម្បីប្រៀបធៀបសាលារៀនមួយ និងសាលារៀនមួយទៀតដើម្បីកំណត់ពីចំណុចដែលត្រូវធ្វើការកែលំអ។ លទ្ធផលនៃការវាយតម្លៃបញ្ចប់វគ្គនេះ ក៏ត្រូវបានប្រើប្រាស់នូវកម្រិតប្រព័ន្ធ ដើម្បីជួយពិនិត្យតាមដានការបំពេញទៅតាមស្តង់ដាផងដែរ។

ប្រទេសនានា ប្រើប្រាស់ទិន្នន័យរៀនសូត្ររបស់សិស្សម្នាក់ៗ តាមបែបផែនខុសៗគ្នា។ ប្រព័ន្ធមួយចំនួនដូចជាប្រព័ន្ធរបស់ប្រទេសជប៉ុនជាដើម ផ្តោតការយកចិត្តទុកដាក់លើការប្រឡងថ្នាក់ជាតិ ដើម្បីធ្វើការកំណត់ពីការរីកចម្រើនរបស់សិស្សពីកម្រិតមួយទៅកម្រិតមួយទៀតក្នុងឆ្នាំណាមួយ ប៉ុន្តែប្រព័ន្ធបែបនេះពុំ

អាចឱ្យគេធ្វើការប្រៀបធៀបលទ្ធផលនៃការសិក្សារវាងពេលមួយ និងពេលមួយទៀតនោះឡើយ។

ប្រព័ន្ធផ្សេងទៀតកំណត់ស្តង់ដាអំពីការរៀនសូត្រដែលរំពឹងទុក និងរៀបចំឱ្យមានការវាយតម្លៃ ដើម្បីរាយការណ៍ពីលទ្ធផលរំពឹងទុកទាំងនេះ។ ប្រព័ន្ធវាយតម្លៃលទ្ធផលសិក្សារបស់ប្រទេសអង់គ្លេស ដែលមានលក្ខណៈស្មុគស្មាញ និងមានលក្ខណៈគ្រប់ជ្រុងជ្រោយ ត្រូវបានបង្កើតឡើង ដោយប្រើប្រាស់ស្តង់ដាជាតិជាគោល។ ប្រព័ន្ធនេះជាយន្តការសម្រាប់វាយតម្លៃសិស្ស ហើយក៏ជាប្រព័ន្ធសម្រាប់ធ្វើការវាយតម្លៃពីខាងក្រៅផងដែរ។ ទិន្នន័យដែលប្រមូលបាន ត្រូវបានប្រើប្រាស់ ដើម្បីជួយមន្ត្រីអធិការរៀបចំខ្លួន មុនពេលពួកគេចុះទៅតាមសាលារៀននានា ផ្តល់ព័ត៌មានដល់មាតាបិតាសិស្ស ជួយថ្នាក់គ្រប់គ្រងសាលារៀនក្នុងការកំណត់គោលដៅកំណត់រកសិស្សដែលត្រូវការការគាំទ្របន្ថែម និងផ្តល់ការគាំទ្រដល់អាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរថ្នាក់ជាតិក្នុងការពិនិត្យតាមដានលទ្ធផលការងារ ដើម្បីធានាបាននូវគណនេយ្យភាព។

ប្រទេសផ្សេងគ្នាប្រើប្រាស់លទ្ធផលនៃការសិក្សាតាមបែបផែនខុសៗគ្នា ដោយប្រទេសមួយចំនួនផ្តោតការយកចិត្តទុកដាក់ទាំងស្រុងលើភាសា និងគណិតវិទ្យា និងប្រទេសផ្សេងទៀតក៏ធ្វើការវាយតម្លៃលើមុខវិជ្ជាផ្សេងទៀតផងដែរ។ ប្រទេសនានាក៏មានព័ត៌មានអំពីសិស្សខុសៗគ្នាផងដែរ ដែលព័ត៌មានទាំងនេះត្រូវបានប្រមូល សម្រាប់ធ្វើការប្រៀបធៀប ទៅតាមបរិបទរបស់ប្រទេសនីមួយ។ ក្នុងប្រទេសអូស្ត្រាលី ព័ត៌មានអំពីសាលារៀន ដូចជាព័ត៌មានហិរញ្ញវត្ថុ រចនាសម្ព័ន្ធប្រជាសាស្ត្រ និងព័ត៌មានអំពីភាពអំណោយផលខាងសង្គម និងការអប់រំ ត្រូវបានផ្សព្វផ្សាយ តាមរយៈគេហៈទំព័រសាលារៀនខ្ញុំ (My School website)។ នៅប្រទេសដាណឺម៉ាក ទីភ្នាក់ងារជានាគុណភាពអប់រំ ក៏បានបញ្ចូលសូចនាករស្តីពីសុខមាលភាពរបស់សិស្សផងដែរ។

> “ការគ្រប់គ្រងព័ត៌មានដែលបានពីលទ្ធផលសិក្សាជាការលំបាក សម្រាប់ប្រព័ន្ធអប់រំ។ សូម្បីតែប្រទេសចំណូលខ្ពស់ ក៏ចាំបាច់ត្រូវខិតខំប្រឹងប្រែង ដើម្បីបញ្ចៀសមិនឱ្យមានការយកព័ត៌មាន ទាំងនេះទៅបកស្រាយតាមផ្តេសផ្តាសផងដែរ”

ប៉ុន្តែការគ្រប់គ្រងព័ត៌មានទាំងនេះ អាចជាការលំបាកសម្រាប់ប្រព័ន្ធអប់រំ។ សូម្បីតែប្រទេសចំណូលខ្ពស់ក៏ចាំបាច់ត្រូវប្រឹងប្រែង ដើម្បីបង្ការមិនឱ្យមានការយកព័ត៌មានទាំងនេះទៅ បកស្រាយផ្តេសផ្តាសផងដែរ ដោយបានកែសម្រួលព័ត៌មានទាំងនេះឱ្យស្របតាមស្ថានភាព របស់សាលារៀន និងស្ថានភាពសង្គមសេដ្ឋកិច្ចរបស់សិស្ស ដើម្បីឱ្យដឹងថាតើសាលារៀន និងសិស្សមានការរីកចម្រើនចន្លោះពីពេលមួយទៅពេលមួយទៀតដែរឬទេ។ ប្រទេសនានាកាន់តែដាក់ឱ្យអនុវត្ត នូវវិធានការបន្ថែមគុណតម្លៃទាំងនេះ ប៉ុន្តែវិធានការទាំងនេះអាចមិនគ្រប់គ្រាន់ ហើយគេចាំបាច់ត្រូវទាញជាសេចក្តីសន្និដ្ឋានចេញពីការអនុវត្តវិធានការទាំងនេះ។

បញ្ហាទាំងនេះរឹតតែស្មុគស្មាញបន្ថែមទៀត នៅតាមបណ្តាប្រទេស ដែលមានចំណូលមធ្យម និងប្រទេសដែលមានចំណូលទាប។ ការប្រមូលព័ត៌មានអំពីលទ្ធផល ដែលអាចឱ្យគេយកមកធ្វើការប្រៀបធៀបបានត្រូវការចំណាយថវិកាអស់ច្រើន ហើយចាំបាច់ត្រូវធ្វើការវិនិយោគលើការកសាងសមត្ថភាព ដើម្បីប្រមូល

ព័ត៌មានទាំងនេះ ដែលអាចត្រូវការចំណាយយ៉ាងច្រើនផងដែរ។ ជារឿយៗ ប្រទេសទាំងនេះផ្តោតការយកចិត្តទុកដាក់លើលទ្ធផល នៃការប្រឡងចុងក្រោយ ជាជាងលើការប្រៀបធៀបទៅនឹងស្តង់ដា ដែលមាន។ ឧទាហរណ៍ ការធ្វើតេស្តថ្នាក់ជាតិនៅប្រទេសចរដង់ ធ្វើការវាយតម្លៃលើកម្រិតថ្នាក់នីមួយៗរៀងរាល់បីឆ្នាំម្តង ប៉ុន្តែលទ្ធផលមិនអាចឱ្យគេប្រៀបធៀបរវាងពេលមួយ និងពេលមួយទៀតបានឡើយ ដោយសារតែសំណួរក្នុងតេស្តតែងមានការប្រែប្រួល។ របាយការណ៍ដែលត្រូវបានបោះពុម្ពផ្សាយ ភាគច្រើនបង្ហាញពីតារាងពិពណ៌នា ដោយពុំមានការធ្វើវិភាគគោលនយោបាយឡើយ ហើយក៏ពុំមានការជួយឱ្យគ្រូយល់ពីលទ្ធផលទាំងនេះដែរ បើទោះបីជាគ្រូ គឺជាអ្នកមានតួនាទីផ្តល់ជំនួយផ្នែកគរុកោសល្យយ៉ាងណាក៏ដោយ។

## ...ហើយភស្តុតាងដែលបង្ហាញថាគណនេយ្យភាពផ្អែកទៅតាមលទ្ធផលការងារ ពិតជានាំឱ្យការអប់រំមានគុណភាពល្អ មានច្រើនចំរុះ

ក្នុងចំណោមប្រព័ន្ធអប់រំទាំង ១០១ ដែលត្រូវបានពិនិត្យឡើងវិញ មានប្រព័ន្ធអប់រំចំនួន ៥១ ដែលផ្សព្វផ្សាយពិន្ទុតេស្តរបស់សិស្សជាសាធារណៈ នៅក្នុងនោះមានប្រព័ន្ធអប់រំចំនួន ១៧ ប្រើប្រាស់ពិន្ទុតេស្តនេះដើម្បីដាក់ទោស និងផ្តល់រង្វាន់ដល់សាលារៀន និងអ្នកអប់រំ។ ប៉ុន្តែ ពិន្ទុតេស្តទាំងនេះទទួលរងឥទ្ធិពលយ៉ាងធំធេងពីកត្តាដែលស្ថិតនៅខាងក្រៅការគ្រប់គ្រងរបស់សាលារៀន។ ពុំមានភស្តុតាងជាក់ច្បាស់បង្ហាញថា ការដាក់ទោសសាលារៀនដោយសារតែពិន្ទុតេស្តទាប អាចជួយឱ្យលទ្ធផលនៃការសិក្សាមានភាពល្អប្រសើរជាងមុនឡើយ៖ ជាធម្មតាស្ថិតិពុំបានបង្ហាញពីការរីកចម្រើនជាវិជ្ជមានឡើយ ឬបង្ហាញត្រឹមតែវឌ្ឍនភាពវិជ្ជមានតិចតួចប៉ុណ្ណោះ។ ច្បាប់ស្តីពីការមិនទុកកុមារណាម្នាក់ចោលរបស់សហរដ្ឋអាមេរិច គំរាមបិទសាលារៀនទាំងឡាយណាដែលសម្រេចបានលទ្ធផលទាប។ ច្បាប់នេះមានឥទ្ធិពលវិជ្ជមានតិចតួចតែប៉ុណ្ណោះលើលទ្ធផលសិក្សារបស់សិស្ស ប៉ុន្តែបែរជាធ្វើឱ្យគម្លាតលទ្ធផលសិក្សារវាងសិស្សស្បែកខ្មៅ និងសិស្សស្បែកសកាន់តែឃ្លាតគ្នាឆ្ងាយជាងមុន ហើយធ្វើឱ្យសិស្សមួយចំនួន ជាពិសេស សិស្សដែលកំពុងរៀននៅតាមសាលាដែលបំពេញលទ្ធផលបានទាប ត្រូវរៀនតាមកម្មវិធីសិក្សាដែលមានលក្ខណៈចង្អៀតជាងមុន ព្រោះតែសាលារៀនផ្តល់អាទិភាពតែមុខវិជ្ជាដែលសិស្សត្រូវធ្វើតេស្តតែប៉ុណ្ណោះ។

សាលារៀន អាចសម្របខ្លួន ទៅតាមប្រព័ន្ធគណនេយ្យភាពផ្អែកទៅតាមលទ្ធផលការងារប៉ុន្តែក្នុងលក្ខណៈអវិជ្ជមានដើម្បីជៀសផុតពីការដាក់ទោសមិនឱ្យចូលរួមក្នុងការធ្វើកំណែទម្រង់រយៈពេលវែង។ ការរៀបចំឡើងវិញនូវរបៀបធ្វើតេស្ត ការបង្រួមកម្មវិធីសិក្សា ការបង្រៀនតែមុខវិជ្ជាសម្រាប់ធ្វើតេស្ត និងការលួចចម្លងពេលធ្វើតេស្ត ត្រូវបានរកឃើញថាបានកើតឡើងនៅក្នុងប្រទេសអូស្រ្តាលី ឈីលី សាធារណរដ្ឋកូរ៉េ និងប្រទេសដទៃទៀត ដែលប្រការនេះបង្កផលប៉ះពាល់ដល់សាលា និងសិស្សដែលជួបការលំបាក។

> “សាលារៀន អាចសម្របខ្លួនទៅតាមប្រព័ន្ធគណនេយ្យភាព ផ្អែកទៅតាមលទ្ធផលការងារ ប៉ុន្តែក្នុងលក្ខណៈអវិជ្ជមានដើម្បីជៀសផុតពីការដាក់ទោសមិនឱ្យចូលរួមក្នុងការធ្វើកំណែទម្រង់រយៈពេលវែង”

## ការប្រកួតប្រជែងក្នុងទីផ្សារអប់រំ អាចនាំឱ្យមានការបែកច្រាក់ក្នុងសង្គមកាន់តែជ្រៅ

យន្តការមួយដែលអាចជានាឱ្យមានគណនេយ្យភាព គឺកាប្រកួតប្រជែង។ គំនិតសំខាន់ គឺថាប្រសិនបើឪពុកម្តាយអាចជ្រើសរើសសាលារៀនឱ្យកូនរបស់ខ្លួនបាន វាគឺជាការដាក់សម្ពាធឱ្យសាលារៀនប្រឹងប្រែងបន្ថែមទៀត ដើម្បីទាក់ទាញសិស្ស។




ការផ្សព្វផ្សាយព័ត៌មានសាលារៀន ជាសាធារណៈ ក្នុងទម្រង់ដែលអាចយល់បាន គឺជាលក្ខខណ្ឌដែលចាំបាច់មួយដើម្បីឱ្យមាតាបិតាអាចជ្រើសរើស សាលារៀន សម្រាប់កូនរបស់ខ្លួននិងដើម្បីឱ្យទីផ្សារអប់រំអាចដំណើរការទៅបាន។ ក្នុងប្រព័ន្ធអប់រំតាមប្រទេសដែលមានចំណូលមធ្យមនិងចំណូលខ្ពស់ជាច្រើនលទ្ធផល នៃការធ្វើតេស្តនៅតាមសាលារៀនត្រូវបានបិទផ្សាយ ជាសាធារណៈ ប៉ុន្តែនៅតាមបណ្តាប្រទេសក្រីក្រវិញ ព័ត៌មានទាំងនេះមិនងាយស្រួលរក ឬមិនត្រូវបានបង្ហាញក្នុងទម្រង់ដែលងាយស្រួលយល់ សម្រាប់អ្នកដែលចង់យកព័ត៌មាននេះទៅប្រើប្រាស់ឡើយ។ ឧទាហរណ៍ ប័ណ្ណរបាយការណ៍អនឡាញនៅសាធារណៈតង់ហ្សានី កម្រនឹងត្រូវបានគេចូលទៅមើលណាស់ ជាពិសេសនៅតាមតំបន់ដែលការប្រើប្រាស់អ៊ីនធើណែតមានកម្រិតទាប។ ក្នុងប្រទេសកេនយ៉ា មាតាបិតាសិស្ស ៧២ ភាគរយ ពុំដឹងពីរបៀបប្រើប្រាស់ព័ត៌មានដែលបង្ហាញពីចំណេះដឹងអក្ខរកម្ម និងលេខនព្វន្តឡើយ។

ប្រទេសដែលមានចំណូលមធ្យម និងចំណូលខ្ពស់មួយចំនួនបានផ្តួចផ្តើមគំនិតបង្កើតទីផ្សារសម្រាប់សាលារៀន។ គោលនយោបាយស្តីពីជម្រើសសាលារៀន មានចំនួនច្រើនជាងមុន នៅក្នុងប្រទេសជាសមាជិកអង្គការសហប្រតិបត្តិការ និងអភិវឌ្ឍសេដ្ឋកិច្ច(OECD) ចំនួន ២ ភាគ ៣ នៅក្នុងរយៈពេល ២៥ឆ្នាំចុងក្រោយនេះ។ ប៉ុន្តែភស្តុតាងនានាបានបង្ហាញថា គោលនយោបាយស្តីពីជម្រើសសាលារៀននេះផ្តល់អត្ថប្រយោជន៍ដល់ក្រុមប្រជាពលរដ្ឋពុំជួបការលំបាក ច្រើនជាងទៅវិញ។ ឪពុកម្តាយច្រើនធ្វើការសម្រេចចិត្តផ្អែកទៅតាមកត្តានានា ដូចជា លក្ខណៈប្រជាសាស្ត្រ ដែលនាំឱ្យចំនួនសិស្សដែលមានសាវតារចម្រុះអាចរៀនជាមួយគ្នាមានការថយចុះ និងធ្វើឱ្យកាន់តែមានការបែងចែកវណ្ណៈសង្គមសេដ្ឋកិច្ចបន្ថែមទៀត។ ក្នុងប្រទេសហ្វាំងឡង់ ការជ្រើសរើសសាលារៀនភាគច្រើនត្រូវបានធ្វើឡើងដោយឪពុកម្តាយ ដែលមានកម្រិតវប្បធម៌ខ្ពស់ ដែលមានកូនរៀនពូកែ។ នៅទីក្រុងសាន់ទីអាហ្គោ ប្រទេសឈីលី ក្នុងចំណោមមាតាបិតាសិស្សថ្នាក់ទី ១ បួននាក់ មានតែម្នាក់ប៉ុណ្ណោះ ដែលជ្រើសរើសសាលារៀន ដែលទទួលបានលទ្ធផលខ្ពស់ជាងគេ ចេញពីបញ្ជីរាយនាមសាលារៀន ហើយមានឪពុកម្តាយជិត ៧០ ភាគរយ ជ្រើសរើសសាលារៀនទៅតាមជំនឿសាសនារបស់ពួកគេ។

កម្មវិធីផ្តល់ជំនួយតាមប័ណ្ណអាចជួយ ឱ្យមានសមភាពក្នុងការជ្រើសរើសសាលារៀន ប៉ុន្តែលទ្ធផលដែលកម្មវិធីនេះមានមកលើការអប់រំ មានលក្ខណៈចំរុះ។ កម្មវិធីរបស់ប្រទេសកូឡុំប៊ី ដែលផ្តោតលើសហគមន៍ចំណូលទាប នាំឱ្យការចុះឈ្មោះសិស្សចូលរៀនក្នុងសាលាឯកជនមានការកើនឡើង ហើយក៏ធ្វើឱ្យកម្រិតលទ្ធផលសិក្សា និងអត្រាបញ្ចប់ការសិក្សារបស់អ្នកដែលទទួលប័ណ្ណជំនួយនេះ មានភាពល្អប្រសើរជាងមុនផងដែរ។ ប៉ុន្តែការចែកប័ណ្ណទទួលជំនួយឱ្យបានដល់ប្រជាពលរដ្ឋទូទៅ ដែលជាការជួយឱ្យសាលារៀនបង្កើនថ្លៃសេវារបស់ខ្លួន អាចនាំឱ្យមានការបង្កើនវិសមភាពនៃការចូលរៀនរបស់សិស្សទៅវិញទេ ហើយពុំបានជួយបង្កើនលទ្ធផលសិក្សារបស់សិស្សឡើយ។ កម្មវិធីចែកប័ណ្ណជាសកលរបស់ប្រទេសស៊ុយអែត នាំឱ្យមានការបែងចែកវណ្ណៈកាន់តែច្រើនឡើង។ ប្រទេសឈីលីមានប្រព័ន្ធអប់រំដែលមានការបែងចែកវណ្ណៈខ្ពស់។ កម្មវិធីផ្តល់ជំនួយតាមប័ណ្ណរបស់ប្រទេសឈីលី បានលើកទឹកចិត្តឱ្យមានការទទួលយកតែសិស្សដែលរៀនពូកែ ឬសិស្សជាកូនអ្នកមាន ឱ្យចូលរៀនតាមសាលារៀនពិសេសៗមួយចំនួន។ កំណែទម្រង់ដើម្បីកែលំអការកំណត់ក្រុមគោលដៅសម្រាប់កម្មវិធីនេះ ដែលធ្វើឡើងកាលពីឆ្នាំ ២០០៨ មានលទ្ធផលជាវិជ្ជមានតិចតួចតែប៉ុណ្ណោះចំពោះការបង្កើនសមធម៌។

## សហគមន៍អាចជួយសម្រួច និងពិនិត្យតាមដានគោលនយោបាយ និងការអនុវត្តរបស់សាលារៀន

ការទាមទារគណនេយ្យភាពសង្គមពីសំណាក់សហគមន៍ អាចបង្កើនភាពឆ្លើយតប និងប្រសិទ្ធភាពរបស់សាលារៀន។ ជារឿយៗ ការពិនិត្យតាមដានរបស់សហគមន៍ ច្រើនផ្តោតលើហេដ្ឋារចនាសម្ព័ន្ធ វត្តមានរបស់បុគ្គលិក និងថវិកា ប៉ុន្តែលទ្ធផលដែលទទួលបានពីអន្តរាគមន៍ដែលអនុវត្តតែម្តងចប់បែបនេះ អាចពុំមាននិរន្តរភាពឡើយ។ ក្នុងប្រទេសអេត្យូពី ការសហការក្នុងភាពជាដៃគូរបស់សហគមន៍ជាមួយរដ្ឋាភិបាល ដើម្បីប្រមូលទិន្នន័យសាលារៀន និងពិគ្រោះយោបល់ជាមួយសហគមន៍ បានសម្រេចលទ្ធផលជាវិជ្ជមាន។ ប៉ុន្តែការខ្វះធនធានអាចគំរាមកំហែងដល់និរន្តរភាពនៃគម្រោងបែបនេះ។

អ្នកពាក់ព័ន្ធរបស់សហគមន៍ ចូលរួមក្នុងការគ្រប់គ្រងតាមសាលារៀន ដែលនេះតម្រូវឱ្យមានការផ្ទេរសមត្ថកិច្ចនិងការទទួលខុសត្រូវធ្វើសេចក្តីសម្រេចចិត្តទៅឱ្យអ្នកពាក់ព័ន្ធនៅថ្នាក់មូលដ្ឋាន។ ការគ្រប់គ្រងតាមសាលារៀន បានជួយបង្កើនលទ្ធផលសិក្សារបស់សិស្ស និងវត្តមានរបស់សិស្សនៅតាមបណ្តាប្រទេសមួយចំនួនដូចជាឥណ្ឌូនេស៊ីនិងម៉ិចស៊ិចជាដើម។ ប៉ុន្តែការពុំមានធនធ្វះចែករំលែកការទទួលខុសត្រូវទៅឱ្យសមាជិកសហគមន៍អាចនឹងធ្វើឱ្យប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងគ្រប់គ្រងតាមសាលារៀនមួយចំនួន ដូចជានៅហុងកុង ប្រទេសចិនជាដើម។ ពេលខ្លះតំណាងសហគមន៍ពុំបានបញ្ចូលក្រុម ដែលបាត់បង់ឱកាសឡើយ។ ការផ្តល់ឱកាសឱ្យតែក្រុមអ្នកមានអំណាច គឺជាបញ្ហាដែលកើតមាន នៅក្នុងគណៈកម្មាធិការគ្រប់គ្រងតាមសាលារៀនមួយចំនួននៅក្នុងប្រទេសនេប៉ាល់។

> “ឪពុកម្តាយច្រើនធ្វើការសម្រេចចិត្តផ្អែកទៅតាមកត្តានានា ដូចជា លក្ខណៈប្រជាសាស្ត្រ ដែលនាំឱ្យចំនួនសិស្សដែលមានសាវតារចម្រុះអាចរៀន ជាមួយគ្នាមានការថយចុះនិងធ្វើឱ្យកាន់តែមានការបែងចែកវណ្ណៈសង្គមសេដ្ឋកិច្ចបន្ថែមទៀត”

# គណនេយ្យភាពរបស់គ្រូ

ការទទួលខុសត្រូវចម្បងរបស់គ្រូ គឺផ្តល់ការអប់រំដល់សិស្ស។ នៅតាមប្រទេសជាច្រើនគ្រូកាន់តែទទួលរងសម្ពាធខ្លាំងឡើង។ កិច្ចការដ៏សែនស្មុគស្មាញ និងច្រើនបែបច្រើនយ៉ាង ដែលពួកគេត្រូវបំពេញ អាចដាក់សម្ពាធជាច្រើនមកលើពេលវេលារបស់ពួកគេ ដែលធ្វើឱ្យកិច្ចខិតខំប្រឹងប្រែងទាមទារគណនេយ្យភាពពីពួកគេ កាន់តែពិបាក។

## ការផ្តល់ការបង្រៀនដែលមានគុណភាពខ្ពស់ គឺជាការទទួលខុសត្រូវស្នូលរបស់គ្រូ

ប្រទេសភាគច្រើនបែងចែកពេលវេលាធ្វើការភាគច្រើនលើសលុបរបស់គ្រូ លើការងារបង្រៀន។ ការបង្រៀនជាផ្លូវការនៅតាមប្រទេសមួយចំនួនបានពង្រីកលើសពីមុខវិជ្ជាស្នូលដូចជាគ្រូត្រូវបង្រៀនបំណិនក្រៅកម្មវិធីសិក្សា និងសមត្ថភាពដែលពាក់ព័ន្ធជាមួយនឹងសង្គម ឥរិយាបទ និងការគ្រប់គ្រងអារម្មណ៍បន្ថែមទៀត។ គ្រូដែលបានចូលរួមក្នុងការអង្កេតអំពីការរៀន និងការបង្រៀនអន្តរជាតិ (TALIS) ចំណាយពេលជាមធ្យមប្រមាណជា ២ ម៉ោងក្នុងមួយសប្តាហ៍លើសកម្មភាពក្រៅកម្មវិធីសិក្សា ចាប់ពី ១ ម៉ោងក្នុងប្រទេសស៊ុយអែតរហូតដល់ ៨ ម៉ោងក្នុងប្រទេសជប៉ុន។ គ្រូក៏មានការទទួលខុសត្រូវ ដែលជារឿយៗមិនត្រូវបានគេទទួលស្គាល់ ឬផ្តល់រង្វាន់ផងដែរ ដែលជាកត្តាអាចនាំឱ្យពួកគេមានទឹកចិត្តធ្វើការតិចជាងមុន។

> “គ្រូដែលបានចូលរួម ក្នុងការអង្កេតអំពីការរៀន និងការបង្រៀនអន្តរជាតិ ចំណាយពេលជាមធ្យមប្រមាណជា ២ ម៉ោងក្នុងមួយសប្តាហ៍លើសកម្មភាពក្រៅកម្មវិធីសិក្សា”

ការសិក្សានៅប្រទេស ដែលមានចំណូលទាប និងចំណូលមធ្យមចំនួន ៦ កាលពីដើមទសវត្សរ៍ឆ្នាំ ២០០០ បង្ហាញថា អត្រាអវត្តមានជាមធ្យមរបស់គ្រូគឺ ១៩ ភាគរយ។ ប៉ុន្តែជារឿយៗកម្រិតនៃការទទួលខុសត្រូវរបស់គ្រូលើបញ្ហាអវត្តមាននេះ តែងត្រូវបានគេបំផ្លើសលើសពីកម្រិតជាក់ស្តែង។ ចន្លោះពីឆ្នាំ២០០៧ដល់ឆ្នាំ២០១៤សិស្សនៅក្នុងប្រទេសសេណេហ្គាល់ជាមធ្យមរៀនបាន១០៨ថ្ងៃលើ១៨៨ថ្ងៃដែលជាចំនួនថ្ងៃសិក្សាប្រចាំឆ្នាំជាផ្លូវការ។ មូលហេតុភាគច្រើនដែលនាំឱ្យគ្រូអវត្តមានគឺជាមូលហេតុហួសពីអ្វីដែលគ្រូអាចគ្រប់គ្រងដោយខ្លួនឯងបាន **(រូបភាពទី ៦)**។ នៅប្រទេសឥណ្ឌូនេស៊ីកាលពីឆ្នាំ២០១៣និង២០១៤មានគ្រូបឋមសិក្សា១០ភាគរយអវត្តមាន។ជិតពាក់កណ្តាលនៃអវត្តមាននេះធ្វើឡើងក្រោមលេសថាចំណាយពេលសម្រាប់ទៅបន្តការសិក្សា។

## ការវាយតម្លៃគ្រូ ដើម្បីកំណត់ពីគុណភាពនៃការបង្រៀន អាចជាការលំបាក និងធ្វើឡើងច្រើនទម្រង់

ការជឿទុកចិត្តរបស់រដ្ឋាភិបាល និងសាធារណជនទូទៅលើវិជ្ជាជីវៈបង្រៀន និងការជឿទុកចិត្តរបស់គ្រូលើដំណើរការវាយតម្លៃមានឥទ្ធិពលយ៉ាងធំធេងលើប្រសិទ្ធភាពនៃវិធីសាស្ត្រដែលត្រូវបានប្រើប្រាស់ដើម្បីទាមទារគណនេយ្យភាព។ នៅប្រទេសហ្វាំងឡង់ គ្រូជាអ្នករៀបចំតាក់តែង និងគ្រប់គ្រងការអនុវត្តគោល

នយោបាយគណនេយ្យភាពដោយខ្លួនឯង ដែលនាំឱ្យមានការជឿទុកចិត្តគ្នាទៅវិញទៅមករវាងតួអង្គពាក់ព័ន្ធនានា។ផ្ទុយទៅវិញការជឿទុកចិត្តលើគ្រូក្នុងប្រទេសជប៉ុនថយចុះទាបជាងមុនបន្ទាប់ពីការទទួលបានលទ្ធផលទាបក្នុងការវាយតម្លៃអន្តរជាតិហើយការបង្កើនចំនួនយន្តការគណនេយ្យភាពពីខាងក្រៅបានបន្ថែមការទទួលខុសត្រូវរាយការណ៍ ពីលើបន្ទុកការងាររបស់គ្រូ ដែលក្នុងមួយសប្តាហ៍ គ្រូត្រូវធ្វើការងារជាមធ្យម ៥៤ ម៉ោងរួចទៅហើយនោះ។

**រូបភាពទី ៦៖**

សិស្សសេណាហ្គាល់បាត់បង់ថ្ងៃសិក្សាជាង ៥០ ថ្ងៃជាប្រចាំឆ្នាំ ដោយសារតែការបិទសាលារៀន




ប្រភព៖ Niang (២០១៧)។

ការជួលគ្រូកិច្ចសន្យា ដំបូងឡើយគឺជាវិធានការបំពេញការខ្វះខាតចំនួនគ្រូ ប៉ុន្តែការផ្តល់កិច្ចសន្យារយៈពេលខ្លីដល់គ្រូ ត្រូវបានប្រើប្រាស់កាន់តែច្រើនឡើង ជាយន្តការគណនេយ្យភាពក្នុងបរិបទដែលមានការជឿទុកចិត្តទាបដោយការបន្តកិច្ចសន្យាគឺជាការផ្តល់រង្វាន់សម្រាប់ការបំពេញការងារបានល្អ។ ការផ្តល់ការងារជាប់លាប់ ត្រូវបានធ្វើឡើងអមជាមួយនឹងការបង្កើនបន្ទុកការងារបន្ថែមដល់បុគ្គលិក ការកាត់បន្ថយមូលនិធិសាធារណៈ និងការកាត់បន្ថយសិទ្ធិ របស់បុគ្គលិកក្នុងការចងក្រងបង្កើតសមាគម។ ជារឿយៗគ្រូជាប់កិច្ចសន្យា មានសមត្ថភាពទាប ពុំបានផ្តល់ការគាំទ្រ និងទទួលបានប្រាក់បៀវត្សរ៍ទាប។

> “ការជឿទុកចិត្ត របស់គ្រូលើដំណើរការនៃការវាយតម្លៃ មានឥទ្ធិពលយ៉ាងធំធេងលើប្រសិទ្ធភាពនៃវិធីសាស្ត្រដែលត្រូវបានប្រើប្រាស់ដើម្បីទាមទារគណនេយ្យភាព។ នៅប្រទេសហ្វាំងឡង់ គ្រូជាអ្នករៀបចំតាក់តែង និងគ្រប់គ្រង ការអនុវត្តគោលនយោបាយគណនេយ្យភាព”

## ការវាយតម្លៃជាផ្លូវការ គឺជាយន្តការដែលត្រូវបានគេប្រើប្រាស់ញឹកញាប់ជាងគេ ដើម្បីទាមទារគណនេយ្យភាពពីគ្រូ

ប្រទេសភាគច្រើនវាយតម្លៃគ្រូ ដោយប្រើប្រាស់វិធីសាស្ត្រច្រើនប្រភេទ។ ការចុះសង្កេតតាមថ្នាក់រៀន ត្រូវបានប្រើប្រាស់ ក្នុងការវាយតម្លៃគ្រូ ៩៦% ក្នុងប្រទេសអ្នកមានភាគច្រើន ដែលបានចូលរួមក្នុងការអង្កេតលើការរៀន និងការបង្រៀនជាលក្ខណៈអន្តរជាតិ (TALIS)។ ជាធម្មតា ការសង្កេតមើលថ្នាក់រៀននេះ ធ្វើឡើងដោយនាយកសាលា ឬសមាជិករបស់គណៈគ្រប់គ្រង ហើយលទ្ធផលអាចមានការប្រែប្រួលខុសៗគ្នា។ នៅប្រទេសសិង្ហបុរី ព័ត៌មានដែលទទួលបាន ត្រូវបានប្រើប្រាស់សម្រាប់គោលបំណងដាក់ចេញនូវវិធានការអ្វីមួយ។ នៅក្នុងប្រទេសអ៊ីស្រាអែល ការសង្កេតមើលថ្នាក់រៀនត្រូវបានប្រើប្រាស់សម្រាប់តម្លើងឋានៈដល់គ្រូ។ នៅសហរដ្ឋអាមេរិច ការដាក់ពិន្ទុធ្វើឡើងមិនបានល្អ ដែលនាំឱ្យគេពិបាកនឹងដឹងថាតើគ្រូណាមានសមត្ថភាព គ្រូណាគ្មានសមត្ថភាព។ ការសង្កេតដែលជឿទុកចិត្តបាន ដើម្បីអាចយកទៅប្រើប្រាស់សម្រាប់គោលបំណងអ្វីមួយ តម្រូវឱ្យមានការផ្តល់ព័ត៌មានត្រឡប់ឱ្យបានត្រឹមត្រូវ និងដែលគេអាចយកទៅធ្វើការកែលំអតាមបាន។ អ្នកសង្កេត ដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវអំពីចំណេះដឹងមុខវិជ្ជា និងជំនាញគរុកោសល្យ ក៏ដូចជា គ្រូដែលវាយតម្លៃឱ្យគ្នាទៅវិញទៅមក អាចផ្តល់ព័ត៌មានត្រឡប់កាន់តែមានភាពស៊ីសង្វាក់គ្នាបន្ថែមទៀត។ ក្នុងការអង្កេតលើការបង្រៀន និងការរៀនជាអន្តរជាតិ ដែលធ្វើឡើងកាលពីឆ្នាំ ២០១៣ គ្រូចំនួន ៨៣ ភាគរយបានរាយការណ៍ ថា ការអង្កេតសិស្ស ត្រូវបាន ប្រើប្រាស់ ជាផ្នែកមួយនៃការវាយតម្លៃ។ នៅក្នុងការវាយតម្លៃសិស្សមានការសន្មត់ថា សិស្សអាចដឹងពីការបង្រៀនដែលល្អ និងអាចរាយការណ៍ដោយស្មោះត្រង់។ ភាពអាចជឿទុកចិត្តបាននៃការវាយតម្លៃនេះ ពឹងអាស្រ័យយ៉ាងខ្លាំងលើគោលបំណងនៃការវាយតម្លៃ និងការរៀបចំរបៀបវាយតម្លៃ និងអាចរងផលប៉ះពាល់ដោយសារភាពលំអៀងរបស់សិស្ស។ នៅប្រទេសបារាំង និងអ៊ីតាលី គ្រូដែលផ្តល់ពិន្ទុឱ្យសិស្សខ្ពស់ ទទួលបានការវាយតម្លៃកាន់តែល្អ។ យេនឌ័ររបស់គ្រូក៏អាចមានឥទ្ធិពលលើការយល់ឃើញរបស់សិស្សផងដែរ។

ពិន្ទុតេស្តរបស់សិស្ស គឺជាសមាសភាគដែលត្រូវបានបញ្ចូល ក្នុងការវាយតម្លៃគ្រូញឹកញាប់ជាងគេ ក្នុងការអង្កេតលើការបង្រៀន និងការរៀនអន្តរជាតិ ដែលធ្វើឡើងក្នុងឆ្នាំ ២០១៣ នេះបើតាមការលើកឡើងដោយគ្រូចំនួន ៩៧ ភាគរយដែលបានចូលរួមក្នុងការវាយតម្លៃនេះ។ ប៉ុន្តែពិន្ទុតេស្តទទួលរងឥទ្ធិពល ដោយសារកត្តាច្រើនយ៉ាងដូចជាកម្មវិធីសិក្សាសមត្ថភាពរបស់សិស្សការចូលរួមរបស់មាតាបិតាសិស្ស វប្បធម៌ និងធនធានរបស់សាលារៀន។ ពិន្ទុតែឯងមិនអាចជាសូចនាករដែលអាចជឿទុកចិត្តបានគ្រប់គ្រាន់សម្រាប់កំណត់ដឹងពីប្រសិទ្ធភាពការងាររបស់គ្រូឡើយ។ ការវាយតម្លៃដែលសុក្រឹតត្រូវប្រើប្រាស់ប្រភពព័ត៌មានឱ្យបានច្រើន ដែលអាចជាការលំបាកនៅក្នុងប្រព័ន្ធដែលមានធនធានតិចតួច។

> “ភាពអាចជឿទុកចិត្តបាននៃការវាយតម្លៃរបស់សិស្សលើលទ្ធផលការងាររបស់គ្រូ ពឹងអាស្រ័យយ៉ាងខ្លាំងលើគោលបំណងនៃការវាយតម្លៃ និងការរៀបចំរបៀបវាយតម្លៃ និងអាចរកឥទ្ធិពលដោយសារការលំអៀងរបស់សិស្ស”

ការវាយតម្លៃគ្រូកាន់តែមានសារៈសំខាន់ខ្លាំងឡើង។ អ្នកដែលជឿថាអភិក្រមសម្រាប់ ជានាគណនេយ្យភាពបែបនេះ អាចផ្តល់ការឆ្លើយតបដែលមានប្រសិទ្ធភាព ចំពោះបញ្ហាដែលគេជឿថាកំពុងកើតមានក្នុងវិស័យអប់រំ ជាធម្មតាតែងតែសន្មត់ថា (ក) តួអង្គក្នុងវិស័យអប់រំទាំងអស់សុទ្ធតែបានឯកភាពលើផលដែលគេចង់បាន ដែលគេអាចវាស់វែងយ៉ាងសុក្រឹត (ខ) មានការកំណត់ និងផ្សព្វផ្សាយពីការទទួលខុសត្រូវទាំងនេះយ៉ាងច្បាស់លាស់ហើយតួអង្គដែលមានការទទួលខុសត្រូវជាអ្នកដែលអាចមានឥទ្ធិពលលើលទ្ធផលដែលចង់បានដោយខ្លួនឯង និង (គ) ការលើកទឹកចិត្តដែលត្រូវបានជ្រើសរើស នឹងលើកទឹកចិត្តឱ្យមានការអនុវត្តសកម្មភាព ដែលនាំមកនូវលទ្ធផលដែលគេចង់បាន។

ប៉ុន្តែការផ្តល់បៀវត្សរ៍ផ្អែកទៅតាមលទ្ធផលការងារជះឥទ្ធិពលផលចំរុះលើលទ្ធផលនៃការសិក្សានិងអាចបង្កផលប៉ះពាល់ដល់សមធម៌។ការផ្តល់បៀវត្សរ៍បែបនេះក៏អាចជម្រុញឱ្យមានការប្រកួតប្រជែងដែលជាកត្តាកាត់បន្ថយការលើកទឹកចិត្តរបស់គ្រូ ផ្ទុយទៅនឹងអ្វីដែលគេចង់បាន។ ការសិក្សាមួយចំនួនបង្ហាញថាការផ្តល់បៀវត្សរ៍បែបនេះ បង្កផលប៉ះពាល់ជាអវិជ្ជមានដល់គ្រូជាស្ត្រី ជាងគ្រូជាបុរស។

ការវាយតម្លៃគ្រូក្នុងប្រព័ន្ធអប់រំនៅតាមប្រទេសអ្នកមាន អាចនាំឱ្យមានការកែលំអការបង្រៀនតិចតួចតែប៉ុណ្ណោះ។ កង្វះការផ្តល់ព័ត៌មានត្រឡប់ ដែលគេអាចយកទៅធ្វើការកែលំអតាមបាន និងការផ្តោតការយកចិត្តទុកដាក់លើការពិនិត្យតាមដាន ជាជាងការកែលំអ អាចកាត់បន្ថយការពេញចិត្តរបស់គ្រូ និងធ្វើឱ្យមនុស្សជាច្រើនចាត់ទុកការវាយតម្លៃគ្រាន់តែជាកិច្ចការរដ្ឋបាលតែប៉ុណ្ណោះ។

## ប្រព័ន្ធអប់រំដែលផ្តោតខ្លាំងលើគណនេយ្យភាព ពុំបានត្រៀមរៀបចំគ្រូឱ្យបានគ្រប់គ្រាន់ឡើយ

បច្ចុប្បន្ននេះ ប្រទេសនានាមាននិន្នាការផ្ទេរការទទួលខុសត្រូវលើការបង្រៀន និងការគ្រប់គ្រង ទៅឱ្យសាលារៀនជាអ្នកចាត់ចែង។ ទន្ទឹមគ្នានឹងការដាក់ឱ្យអនុវត្តនូវប្រព័ន្ធគណនេយ្យភាពកាន់តែតឹងរឹងជាងមុន និន្នាការនេះក៏បង្កើនបន្ទុកការងារ និងតម្រូវឱ្យគ្រូនិងអ្នកគ្រប់គ្រងសាលាមានជំនាញបន្ថែមទៀតផងដែរដែលអាចនាំឱ្យមានការកើតទុកមិនសុខចិត្ត។នៅចក្រភពអង់គ្លេសគ្រូ៥៦ភាគរយបានរាយការណ៍ថាការងារប្រមូលទិន្នន័យ និងការគ្រប់គ្រងទិន្នន័យ ធ្វើឱ្យពួកគេត្រូវបំពេញការងារដែលមិនចាំបាច់ជាច្រើន។

គ្រូត្រូវការជំនាញ ដើម្បីវាយតម្លៃលទ្ធផលសិក្សារបស់សិស្សវិភាគទិន្នន័យ និងប្រើប្រាស់ទិន្នន័យទាំងនេះសម្រាប់ការបង្រៀនរបស់ពួកគេ។ ប៉ុន្តែ គ្រូជាច្រើនគិតថា ខ្លួនពុំបានទទួលបានការបណ្តុះបណ្តាលឱ្យបានគ្រប់គ្រាន់អំពីរបៀបប្រើប្រាស់ទិន្នន័យឡើយ។ការសិក្សាមួយនៅសហរដ្ឋអាមេរិចបានរកឃើញថាគ្រូ២ភាគ៣ខ្វះមធ្យោបាយប្រើប្រាស់ទិន្នន័យសម្រាប់កែលំអការបង្រៀនរបស់ពួកគេ ហើយយល់ឃើញថាទិន្នន័យដែលពួកគេទទួលបានគឺច្រើនលើសលុប លើសពីអ្វីដែលពួកគេត្រូវការ។

ប្រទេសចំណូលខ្ពស់ជាច្រើន បានបញ្ចូលចំណេះដឹងអំពីទិន្នន័យទៅក្នុងកម្មវិធីអភិវឌ្ឍន៍វិជ្ជាជីវៈ និងកម្មវិធីត្រៀមរៀបចំគ្រូនិងនាយកសាលា។ប៉ុន្តែកម្មវិធីទាំងនេះច្រើនតែផ្តោតលើការស្វែងយល់ពីរបាយការណ៍ និងមានការផ្តល់ឱកាសឱ្យគរុសិស្សអាចហ្វឹកហាត់របៀបតំរៀបទិន្នន័យបានតិចតួចតែប៉ុណ្ណោះ។ លើសពីនេះ កម្មវិធីទាំងនេះច្រើនផ្តោតលើបច្ចេកវិទ្យា ជាជាងលើបំណិនយល់ដឹងពីទិន្នន័យ។

ការកាត់បន្ថយការប្រមូលទិន្នន័យត្រួតគ្នា ឱ្យបានជាអតិបរមា អាចកាត់បន្ថយបន្ទុកការងាររបស់គ្រូ និងនាយកសាលាបាន។ ប៉ុន្តែ និន្នាការនៃការយកទិន្នន័យមកប្រើប្រាស់សម្រាប់គ្រប់គ្រងការអប់រំ ក៏នាំឱ្យមានសំណួរទូទៅកាន់តែច្រើនផងដែរ។ ទី ១ គំនិតដែលថា គេអាចរៀបចំកម្មវិធី ដើម្បីកែលំអការរៀនសូត្រ មិនបានយកចិត្តទុកដាក់លើទិដ្ឋភាពផ្នែកសង្គម និងវប្បធម៌នៃការអប់រំ។ ទី ២ ការផ្តោតការយកចិត្តទុកដាក់លើលទ្ធផលនៃការរៀនសូត្រដែលអាចពិនិត្យតាមដានដឹងបាន តាមពិតអាចបំពេញតួនាទីជាប្រព័ន្ធគណនេយ្យភាព ផ្អែកតែលើលទ្ធផលនៃការរៀនសូត្រ ដែលមានលក្ខណៈតូចចង្អៀតតែប៉ុណ្ណោះ។ ដូច្នេះ បើទោះបីជាការប្រមូលទិន្នន័យមានប្រយោជន៍យ៉ាងណាក៏ដោយ អ្វីដែលសំខាន់គឺគេមិនត្រូវប្រមូលទិន្នន័យសម្រាប់តែគោលបំណងប្រមូលទិន្នន័យឡើយ។ គួរមានការផ្តោតការយកចិត្តទុកដាក់បន្ថែមទៀត លើការប្រើប្រាស់ទិន្នន័យ សម្រាប់គោលបំណងវិភាគ។

## គណនេយ្យភាពវិជ្ជាជីវៈអាចសម្រួចវប្បធម៌នៃការបង្រៀន




គណនេយ្យភាពវិជ្ជាជីវៈ ត្រូវរៀបចំដោយមានការចូលរួមពីគ្រូ និងត្រូវពឹងអាស្រ័យលើជំនាញ និងវិជ្ជាជីវៈរបស់គ្រូ។ ប្រព័ន្ធដែលបញ្ចូលគណនេយ្យភាពវិជ្ជាជីវៈ ជាទូទៅកើតចេញពីការជឿទុកចិត្ត របស់សាធារណជនលើអាជីពបង្រៀន ថានឹងអាចផ្តល់នូវការអប់រំប្រកបដោយគុណភាពខ្ពស់។

ការរៀនសូត្រពីគ្នាទៅវិញទៅមក អាចជួយឱ្យការបង្រៀនកាន់តែមានលក្ខណៈល្អប្រសើរជាងមុន។ ជាធម្មតា ក្នុងប្រទេសចំណូលមធ្យម និងចំណូលខ្ពស់ សហគមន៍សិក្សារបស់អ្នកជំនាញគឺជាវេទិកាសម្រាប់ឱ្យពួកគេអាចសហការគ្នាក្នុងការរៀនសូត្រ ចែករំលែកមេរៀនជាមួយគ្នាទៅវិញទៅមក។ ម៉ូដែលសិក្សាមេរៀន (Lesson Study model) ដែលត្រូវបានប្រើប្រាស់ក្នុងប្រទេសអូស្ត្រាលី ហុងកុង ចិន ជប៉ុន សិង្ហបុរី ស៊ុយអែត ចក្រភពអង់គ្លេស និងសហរដ្ឋអាមេរិច ប្រើប្រាស់វិធីសាស្ត្រសហការគ្នា សម្រាប់រៀបចំផែនការសង្កេតថ្នាក់រៀនវិភាគ និងកែសម្រួលដើម្បីកែលំអការបង្រៀនមេរៀន និងលើកកំពស់លទ្ធផលនៃការសិក្សារបស់សិស្ស។ នៅក្នុងប្រទេសអង់គ្លេស ម៉ូដែលនេះបានលើកទឹកចិត្តឱ្យគ្រូហ៊ានយកគំនិតថ្មីយកមកប្រើ និងកាត់បន្ថយអារម្មណ៍ឯកការបស់គ្រូ។ ការរៀនសូត្រពីគ្នាទៅវិញទៅមកដែលមានប្រសិទ្ធភាព តម្រូវឱ្យគ្រូមានស្វ័យភាព និងត្រូវមានការផ្តល់ពេលវេលា និងធនធានឱ្យបានច្រើនដល់ពួកគេ។

ប្រទេសភាគច្រើនមានក្រមសីលធម៌ដែលត្រូវបានរៀបចំឡើងដោយគ្រូ ជាគោលការណ៍ណែនាំស្តីពីការគោរពវិន័យសម្រាប់ខ្លួនឯង តាមរយៈបទដ្ឋានវិជ្ជាជីវៈ។ ការពិនិត្យឡើងវិញលើក្រមសីលធម៌ក្នុងប្រទេសចំនួន ២៤ បានរកឃើញថា គ្រូជាច្រើននាក់ពុំបានដឹងពីក្រមសីលធម៌ទាំងនេះឡើយ។ កង្វះយន្តការពង្រឹងការអនុវត្តឱ្យបានច្បាស់លាស់ក៏អាចធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃក្រមសីលធម៌ទាំងនេះផងដែរ។យន្តការសម្រាប់រាយការណ៍ និងសម្រាប់ដាក់ទោស ពុំមែនសុទ្ធតែត្រូវបានរៀបចំឱ្យបានច្បាស់លាស់ឡើយ។ គួរមានការផ្តល់ការបណ្តុះបណ្តាលដល់អ្នកដែលមានតួនាទីវាយតម្លៃលើការប្រព្រឹត្តបំពានក្រមសីលធម៌ទាំងនេះ។

## ប្រជាពលរដ្ឋអាចជួយឱ្យគ្រូមានគណនេយ្យភាព

ការពិនិត្យតាមដានរបស់សហគមន៍អាចមានប្រយោជន៍ ជាពិសេសដើម្បីដោះស្រាយបញ្ហាអវត្តមានរបស់គ្រូ។ នៅក្នុងប្រទេសអ៊ូហ្គាន់ដា ប័ណ្ណរាយការណ៍ដែលត្រូវបានរៀបចំឡើងដោយសហគមន៍ បានជួយកាត់បន្ថយអវត្តមានរបស់គ្រូ។ ប៉ុន្តែការពឹងអាស្រ័យលើមាតាបិតាសិស្ស ជាអ្នកទាមទារគណនេយ្យភាពពីគ្រូ ពុំមាននិរន្តរភាពយូរអង្វែងឡើយ។ ក្នុងប្រទេសកេនយ៉ា វឌ្ឍនភាពជុំវិញលទ្ធផលសិក្សាដែលបានពីការពិនិត្យតាមដាន និងការវាយតម្លៃដែលមាតាបិតារបស់សិស្សធ្វើឡើងចំពោះគ្រូ ត្រូវរលាយបាត់ទៅវិញមួយឆ្នាំក្រោយពេលដែលអន្តរាគមន៍នេះត្រូវបានបញ្ចប់។ ប្រព័ន្ធកាន់តែច្រើន ប្រើប្រាស់បច្ចេកវិទ្យាដើម្បីពិនិត្យតាមដានគ្រូ បើទោះបីជាមានការព្រួយបារម្ភអំពីការជឿទុកចិត្ត និងការរំខានដល់កិច្ចការបង្រៀនរបស់គ្រូយ៉ាងណាក៏ដោយ។ ប្រទេសប៉ាគីស្ថានបានពិនិត្យតាមដានលើអវត្តមានមន្ត្រីអប់រំជាង ២១០០០០ នាក់ ក្នុងសាលារៀនចំនួន ២៦២០០ កន្លែង ដែលប្រើប្រាស់ព័ត៌មានជីវមាត្រ។ គិតត្រឹមខែកុម្ភៈ ឆ្នាំ ២០១៧ គ្រូអវត្តមានចំនួន ៤០០០០ នាក់ និងគ្រូគេចមិនធ្វើការងារ ចំនួន ៦០០០ នាក់ បានទទួលរងការដាក់ពិន័យ។ ថ្នាក់រៀនរាប់ពាន់នៅប្រទេសចិនត្រូវបានផ្សាយបន្តផ្ទាល់ ដែលផ្តល់លទ្ធភាពឱ្យមាតាបិតាសិស្ស និងសាធារណជនទូទាំងអាចពិនិត្យតាមដាន និងផ្តល់យោបល់លើរបៀបបង្រៀន និងឥរិយាបទរបស់សិស្ស។ អ្នករិះគន់ព្រួយបារម្ភថា ការបន្តឃ្លាំមើលបែបនេះ ជាការបំពានសិទ្ធិទទួលបានភាពឯកជនរបស់គ្រូ និងសិស្ស និងអាចបង្កផលប៉ះពាល់ជាអវិជ្ជមានលើការបង្រៀនរបស់គ្រូ។

ការចូលរួមក្នុងការពិនិត្យតាមដានគ្រូ អាចទទួលរងឥទ្ធិពលពីស្ថានភាពសង្គមសេដ្ឋកិច្ច សមត្ថភាពរបស់បុគ្គលម្នាក់ៗ និងឥរិយាបទរបស់គ្រូ។ មាតាបិតាមកពីតំបន់ជួបការលំបាក ច្រើនខ្វះជំនាញចំណេះដឹង ឬទំនុកចិត្តក្នុងការទំនាក់ទំនងជាមួយគ្រូ។ ដើម្បីឱ្យការពិនិត្យតាមដានបែបនេះអាចទទួលបានជោគជ័យ គួរផ្តល់ឱកាសឱ្យសមាជិកសហគមន៍ និងគ្រូបានចូលរួមធ្វើការសម្រេចចិត្តពីលក្ខណៈវិនិច្ឆ័យ និងក្នុងការរៀបចំយន្តការ គណនេយ្យភាពដែលត្រូវមានការកំណត់ពីតួនាទី និងការទទួលខុសត្រូវរបស់ពួកគេឱ្យបានច្បាស់លាស់។

> “ការពិនិត្យឡើងវិញលើក្រមសីលធម៌ក្នុងប្រទេសចំនួន ២៤ បានរកឃើញថា គ្រូជាច្រើននាក់ ពីបានដឹង ពីក្រមសីលធម៌ទាំងនេះឡើយ”

## គណនេយ្យភាពរបស់មាតាបិតាសិស្ស និងរបស់សិស្ស

ជាធម្មតា គោលនយោបាយគណនេយ្យភាពតែងទាមទារឱ្យរដ្ឋាភិបាល សាលារៀន និងគ្រូទទួលខុសត្រូវចំពោះ សិទ្ធិ ទទួលបាន ការអប់រំ សាធារណៈ ប្រកបដោយ គុណភាព ។ ប៉ុន្តែ ដោយសារតែ ការអប់រំ គឺជាកាតព្វកិច្ចរួមរបស់សង្គមទាំងមូល មាតាបិតាសិស្ស និងសិស្សខ្លួនឯងក៏មានតួនាទីសំខាន់ផងដែរ។ មាតាបិតាសិស្សទទួលខុសត្រូវក្នុងការបង្កើតនូវបរិយាកាសអំណោយផលក្នុងគ្រួសារ ក៏ដូចជាជួយឱ្យកូនរបស់ខ្លួនអាចមកសាលារៀនឱ្យបានទៀតទាត់ និងជួយពង្រឹងបន្ថែមដល់ការខិតខំប្រឹងប្រែង និងឥរិយាបទរបស់កូន។ ការទទួលខុសត្រូវទាំងនេះ នឹងត្រូវផ្ទេរទៅឱ្យសិស្សខ្លួនឯង នៅពេលដែលពួកគេមានអាយុកាន់តែច្រើន។

### ច្បាស់ស្តីពីការគេចមិនចូលរៀន ចែងពីការដាក់ទោសដល់មាតាបិតាសិស្ស និងសិស្ស

ការគេចមិនចូលរៀនដែលសំដៅលើអវត្តមានដោយពុំមានការអនុញ្ញាតពីសាលារៀនគឺជាបញ្ហាដែលកើតមានជាទូទៅនៅទូទាំងពិភពលោកទាំងមូល។ ជាមធ្យមក្នុងចំណោមប្រទេសចំនួន ៣៣ដែលបានចូលរួមក្នុងការអង្កេតជាសកលលើសុខភាពសិស្សតាមសាលារៀន ក្នុងចំណោមក្មេងជំទង់អាយុពី ១៣ ដល់ ១៧ ឆ្នាំ ៣នាក់មានម្នាក់បានលើកឡើងថាធ្លាប់គេចសាលាក្នុងរយៈពេល៣០ថ្ងៃចុងក្រោយនេះដោយភាគរយប្រែប្រួលពី ២០ ភាគរយនៅបាហាម៉ាស និងអ៊ុយរុហ្គាយ រហូតដល់ជាង ៤០ ភាគរយនៅប្រទេសគុយវ៉ែត អូម៉ាន និងតុកេឡាវ។ ការគេចសាលាបង្កឱ្យមានផលប៉ះពាល់អវិជ្ជមានរយៈពេលខ្លី និងរយៈពេលវែងមកលើសិស្ស។ បញ្ហានេះក៏មានទំនាក់ទំនងជាមួយការបន្តរៀននៅកម្រិតថ្នាក់ដដែល និងការបោះបង់ចោលការសិក្សា ហើយក៏មានភាពពាក់ព័ន្ធជាមួយប្រព័ន្ធយុត្តិធម៌ផងដែរ។

សិស្សដែលជួបការលំបាកច្រើនគេចសាលា។ ខណៈពេលដែលបញ្ហាគេចសាលាគឺជាបញ្ហាដែលពាក់ព័ន្ធជាមួយនឹងបញ្ហាចំរុះ មាតាបិតាសិស្សមានតួនាទីយ៉ាងសំខាន់ក្នុងការកាត់បន្ថយបញ្ហានេះ។

ប្រទេសជាច្រើនបានរៀបចំច្បាប់ស្តីពីការគេចសាលា ដែលទាមទារឱ្យមាតាបិតាត្រូវទទួលខុសត្រូវចំពោះអវត្តមានរបស់កូនក្នុងសាលារៀន។ ការផាកពិន័យគឺជាទោសដែលគេនិយមប្រើប្រាស់ជាងគេ ហើយមានប្រទេសមួយចំនួនតូចតែប៉ុណ្ណោះ ដែលដាក់ទោសព្រហ្មទណ្ឌ **(រូបភាពទី ៧)**។ ការដាក់ទោសធ្ងន់ធ្ងរអាចបង្កផលប៉ះពាល់លើសលុបដល់គ្រួសារដែលមានចំណូលទាប និងលើស្ត្រីដែលជាមេគ្រួសារ នៅក្នុងករណីដែលពួកគេចិញ្ចឹមកូនតែឯង។

ដូច្នេះ ច្បាប់ស្តីពីការគេចសាលា បើទោះបីជាក្របខ័ណ្ឌមួយយ៉ាងណាក៏ដោយ ចាំបាច់ត្រូវអនុវត្តអមជាមួយដោយយន្តការសម្រាប់ទប់ស្កាត់មិនឱ្យមានបញ្ហាគេចសាលានេះ។ ការបង្កើនគណនេយ្យភាពរបស់មាតាបិតាចាប់ផ្តើមចេញពីការស្វែងយល់ និងការកែលំអទំនាក់ទំនងរវាងសាលារៀន និងមាតាបិតាសិស្ស ដូចជាឧទាហរណ៍ក្នុងប្រទេសអូស្ត្រាលី បារាំង និងអៀឡង់ ជាដើម។

## ការផ្ទេរសាច់ប្រាក់ដោយមានលក្ខខណ្ឌ ផ្តោតលើគ្រួសារដែលមានជីវភាពក្រីក្រ

ការផ្ទេរសាច់ប្រាក់ដែលមានលក្ខខណ្ឌ ផ្តល់ឱ្យគ្រួសារក្រីក្រនូវប្រាក់ឧបត្ថម្ភមួយចំនួន ជាមួយនឹងលក្ខខណ្ឌថា មាតាបិតាត្រូវធានាថា កូនរបស់ខ្លួនពិតជាទៅរៀនពិតប្រាកដមែន។ កម្មវិធីបែបនេះត្រូវបានអនុវត្តដោយប្រទេសមួយចំនួននៅអាមេរិចឡាទីន ដូចជា ប្រេស៊ីល កូឡុំប៊ី និងម៉ិចស៊ិច ជាដើម និងត្រូវបានពង្រីកទៅអនុវត្តនៅតាមបណ្តាប្រទេសអាស៊ី និងប្រទេសអាហ្វ្រិចសាប់សាហារ៉ាដែលមានចំណូលមធ្យម និងចំណូលទាប។ នៅអឺរ៉ុប និងអាមេរិចខាងជើង កម្មវិធីផ្ទេរសាច់ប្រាក់ដោយមានលក្ខខណ្ឌ ប្រើប្រាស់ការលើកទឹកចិត្តដែលមានលក្ខណៈអវិជ្ជមាន ដូចគ្នានឹងការផាកពិន័យដែរ។ ឧទាហរណ៍ ប្រទេសរ៉ូម៉ានីកាត់ ប្រាក់ឧបត្ថម្ភ សម្រាប់កុមារបន្ទាប់ពីពួកគេអវត្តមានជាច្រើនលើក ដោយគ្មានមូលហេតុត្រឹមត្រូវ។

**រូបភាពទី ៧៖**

ការផាកពិន័យគឺជាទោសដែលត្រូវបានគេអនុវត្តញឹកញាប់ជាងគេចំពោះករណីគេចសាលា




ការផ្ទេរសាច់ប្រាក់ ដោយមានលក្ខខណ្ឌ បានបង្កើនវត្តមានរបស់សិស្ស ជាពិសេសសិស្សស្រី ក្នុងប្រទេស បង់ក្លាដេស កម្ពុជា នីការ៉ាគ័រ និងប្រទេសផ្សេងទៀត។ ការពិនិត្យឡើងវិញលើកម្មវិធីផ្ទេរសាច់ប្រាក់ដែលមានលក្ខខណ្ឌនៅក្នុងប្រទេសដែលមានចំណូលខ្ពស់ចំនួន ៣៤ ក៏បង្ហាញឱ្យឃើញពីលទ្ធផលស្រដៀងគ្នានេះផងដែរ។ ប្រសិទ្ធភាពនៃកម្មវិធីទាំងនេះអាស្រ័យលើការកំណត់រកក្រុមគោលដៅ ភាពងាយស្រួលក្នុងការទៅសាលារៀន និងទំហំនៃសាច់ប្រាក់ដែលត្រូវផ្ទេរ ដែលត្រូវតែមានចំនួនគ្រប់គ្រាន់ ដើម្បីរ៉ាប់រងចំណាយឱកាសសម្រាប់ការមករៀននៅសាលា។

## មាតាបិតាសិស្ស និងសិស្សបំពេញតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតនូវបរិយាកាសរៀនសូត្រប្រកបដោយសុវត្ថិភាព

ដើម្បីរៀនចេះកុមារនិងក្មេងជំទង់ចាំបាច់ត្រូវមានភាពកក់ក្តៅនិងទទួលបានការគាំទ្រក្នុងបរិយាកាសរៀនសូត្ររបស់ពួកគេ។ ក្នុងនាមជាដៃគូសកម្ម ក្នុងការបង្កើតនូវបរិយាកាសបែបនេះ សិស្សត្រូវទទួលខុសត្រូវក្នុងការជានាយ៉ាងណាឱ្យឥរិយាបទរបស់ខ្លួនមិនរំខានដល់សិទ្ធិរបស់សិស្សផ្សេងទៀត ក្នុងការទទួលបានសុវត្ថិភាព និងការគាំទ្របែបនេះដែរ។

> "ក្រុមសីលធម៌ ដែលមានគោលបំណងបង្រៀនសិស្ស ពីរបៀបទំនាក់ទំនងគ្នាដែលអាចជឿទុកចិត្តបាន អាចជួយកាត់បន្ថយអំពើហិង្សានៅសាលារៀន យ៉ាងមានប្រសិទ្ធភាព"

សាលារៀនជាច្រើនកំពុងប្រើប្រាស់ក្រុមសីលធម៌ ដើម្បីបង្រៀនសិស្សពីរបៀបទំនាក់ទំនងគ្នាទៅវិញទៅមកដែលអាចទទួលយកបាន។ មានការរកឃើញថា ក្រុមសីលធម៌ទាំងនេះមានប្រសិទ្ធភាព ក្នុងការកាត់បន្ថយករណីអំពើហិង្សា ក្នុងសាលារៀន។ ក្រុមសីលធម៌ភាគច្រើនត្រូវបានប្រើប្រាស់ក្នុងប្រទេសនៅអឺរ៉ុបនិងអាមេរិចខាងជើងហើយត្រូវបានគេយកមកអនុវត្តនៅតាមបណ្តាប្រទេសនៅអាស៊ី ដូចជាប្រទេសសិង្ហបុរីជាដើម។

បន្ថែមពីលើការកំណត់ពីវិធាន និងស្តង់ដាវិន័យឱ្យបានច្បាស់លាស់ ប្រកបដោយសង្គតិភាពសម្រាប់សិស្ស កិច្ចប្រជុំ និងការផ្តល់ការបណ្តុះបណ្តាលដល់មាតាបិតាសិស្ស ក៏ជាផ្នែកមួយដ៏សំខាន់ សម្រាប់កាត់បន្ថយករណីអំពើហិង្សានៅសាលារៀនផងដែរ។ មាតាបិតាសិស្សរួមចំណែកកសាងទំនាក់ទំនងមិត្តភាពរបស់កូនពួកគេដោយផ្ទាល់ (ដូចជាជួយឱ្យកូនរបស់ពួកគេចេះអភិវឌ្ឍបំណិន កសាងទំនាក់ទំនងជាមួយមិត្តភក្តិ) និងដោយប្រយោល (ឧទាហរណ៍ តាមរយៈឥរិយាបទរបស់មាតាបិតាជាដើម)។

នៅសហរដ្ឋអាមេរិចបរិយាកាសក្នុងគ្រួសារពោលគឺនៅក្នុងករណីដែលឪពុកម្តាយរិះគន់កូនរបស់ខ្លួនមិនត្រឹមត្រូវ ដាក់វិន័យតិចតួច ធ្វើបាបកូនរបស់ខ្លួន និងប្រព្រឹត្តអំពើហិង្សាដាក់គ្នាទៅវិញទៅមក មានទំនាក់ទំនងជាមួយនឹងករណីគំរាមកំហែងសិស្សគ្នាឯងក្នុងកម្រិតមួយខ្ពស់នៅសាលារៀន។ នៅប្រទេសអេហ្ស៊ីប ម៉ារ៉ុក និងទុយណេស៊ី នៅពេលដែលឪពុកម្តាយកាន់តែផ្តល់ការលើកទឹកចិត្ត ការគាំទ្រផ្លូវចិត្ត និងកាន់តែមានទំនាក់ទំនងជាមួយកូនរបស់ខ្លួន ករណីអំពើហិង្សារវាងមិត្តភក្តិ និងមិត្តភក្តិរឹតតែមានការថយចុះ។

# គណនេយ្យភាពរបស់អង្គការអន្តរជាតិ

អង្គការអន្តរជាតិ និងអង្គការដែលបំពេញការងារនៅថ្នាក់តំបន់ មានតួនាទីគៀងគរធនធាន និងផ្តល់ការគាំទ្រដល់បណ្តាប្រទេសនានា ដើម្បីអាចបំពេញទៅតាមស្តង់ដាអន្តរជាតិ។ ប៉ុន្តែការទាមទារឱ្យអង្គការទាំងនេះមានគណនេយ្យភាពគឺជាការងារមួយដ៏ពិបាក មូលហេតុមួយគឺដោយសារតែអង្គការទាំងនេះត្រូវទទួលខុសត្រូវចំពោះអ្នកពាក់ព័ន្ធជាច្រើន។ ឧទាហរណ៍អង្គការសហប្រជាជាតិត្រូវទទួលខុសត្រូវចំពោះរដ្ឋជាសមាជិកផង និងចំពោះប្រជាពលរដ្ឋ ដែលសិទ្ធិរបស់ខ្លួនត្រូវបានរដ្ឋជាសមាជិករំលោភបំពានផង។

## អង្គការអន្តរជាតិអាចជួយដាក់ចេញគោលដៅរួម

> "ការបំពេញទៅតាមបំណងប្រាថ្នាខុសៗគ្នា បែបនេះ អាចធ្វើឱ្យ គោលដៅ ពិបាកនឹងសម្រេចការដាក់អាទិភាព ឱ្យបានច្បាស់លាស់ និងការពិនិត្យតាមដានមានកម្រិតខ្សោយ តួយ៉ាងដូចជារបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពជាដើម"

អង្គការអន្តរជាតិគួរជួយរដ្ឋជាសមាជិក និងតួអង្គពាក់ព័ន្ធដទៃទៀតក្នុងការដាក់ចេញនូវគោលដៅអប់រំរួមគ្នានិងបង្កើតយន្តការអនុវត្ត។ អង្គការទាំងនេះគួរមានការទទួលខុសត្រូវក្នុងការធានាយ៉ាងណាឱ្យសំលេងរបស់ក្រុមផ្សេងៗគ្នា ត្រូវបានឆ្លុះបញ្ចាំងទៅក្នុងរបៀបវារៈ និងកិច្ចព្រមព្រៀងអប់រំនានា។ ប៉ុន្តែការបំពេញទៅតាមបំណងប្រាថ្នាខុសៗគ្នាបែបនេះ អាចធ្វើឱ្យគោលដៅពិបាកនឹងសម្រេចការដាក់អាទិភាពពុំបានច្បាស់លាស់ និងការពិនិត្យតាមដានមានកម្រិតខ្សោយ តួយ៉ាងដូចជារបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពជាដើម។ "គណនេយ្យភាព" ត្រូវបានដកចេញពីឯកសារគោលនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។




នៅក្នុងករណីដែលពុំមានការកំណត់ឱ្យបានច្បាស់ពីអ្នកណា ដែលត្រូវទទួលខុសត្រូវទៅលើ អ្វីខ្លះនោះនឹងធ្វើ ឱ្យមានចន្លោះប្រហោងផ្នែកគណនេយ្យភាព ដែលធ្វើឱ្យប្រទេសទាំងឡាយ មិនត្រឹមតែ មិនអាចបំពេញទៅតាមការប្តេជ្ញាចិត្តរបស់ខ្លួនប៉ុណ្ណោះទេ ប៉ុន្តែបញ្ហានេះក៏កើតមានចំពោះអង្គការអន្តរជាតិផងដែរ។ ការវាយតម្លៃលើយន្តការសម្របសម្រួល ការអប់រំសម្រាប់ទាំងអស់គ្នាបាន រកឃើញថា តួនាទី របស់ដៃគូ និងស្ថាប័ននានា ពុំមានភាពច្បាស់លាស់ឡើយ ហើយយន្តការគណនេយ្យភាពក៏នៅខ្វះខាតផងដែរ។ តួនាទីចំរុះ និងរបៀបវារៈប្រជែងគ្នា នាំឱ្យមានការកំណត់ការទទួលខុសត្រូវពុំបានច្បាស់លាស់ ធ្វើឱ្យគេមាន

ការពិបាកក្នុងការទាមទារឱ្យតួអង្គណាមួយមានគណនេយ្យភាពឱ្យប្រាកដ។ ការទាមទារគណនេយ្យភាពពីអង្គការនានា ក៏តម្រូវឱ្យមានការប្រើប្រាស់ធនធាន ដែលអាចពិបាកនឹងកៀងគរផងដែរ។

ខណៈពេលដែលការទទួលខុសត្រូវរបស់អង្គការអន្តរជាតិក្នុងការកំណត់គោលដៅនិងសម្របសម្រួលការសម្រេចគោលដៅទាំងនេះ កាន់តែមានតិចៗទៅនៅកម្រិតពិភពលោក ស្ថានភាពនេះអាចមានលក្ខណៈផ្សេងទៅវិញនៅកម្រិតតំបន់។ នៅអឺរ៉ុប ក្របខ័ណ្ឌយុទ្ធសាស្ត្រ ២០២០ នៃ ET ចាត់ទុកការអប់រំជាផ្នែកមួយនៃយុទ្ធសាស្ត្រកំណើនជារួមរបស់ទ្វីបអឺរ៉ុបទាំងមូល។ សហភាពអឺរ៉ុបបានប្រើប្រាស់រចនាសម្ព័ន្ធស្ថាប័នដ៏ស្មុគស្មាញរបស់ខ្លួន ដើម្បីធ្វើប្រតិភូកម្មភារកិច្ច។ គណៈកម្មការអឺរ៉ុបជាស្ថាប័នរៀបចំរបាយការណ៍ប្រចាំឆ្នាំ ដែលតាមដានវឌ្ឍនភាពសម្រេចបានដោយប្រទេសនានា ធៀបទៅនឹងចំណុចដៅដែលបានដាក់ចេញ ហើយក្រុមប្រឹក្សាអឺរ៉ុបត្រូវដាក់របាយការណ៍រៀងរាល់ ៥ ឆ្នាំម្តង បង្ហាញពីអាទិភាព និងបញ្ហាប្រឈមរួម ដែលអាចដោះស្រាយបានល្អបំផុតតាមរយៈកិច្ចសហប្រតិបត្តិការ។ ប៉ុន្តែបើទោះបីជាសមត្ថភាពស្ថាប័ន និងសមត្ថភាពរៀបចំបែងចែកការងារមានភាពរឹងមាំបែបនេះ យ៉ាងណាក៏ដោយក៏ការទទួលខុសត្រូវចំពោះសកម្មភាព ដែលត្រូវអនុវត្តតាមរយៈការសម្របសម្រួលជាមួយគ្នា នៅមានលក្ខណៈបែកខ្ញែកពីគ្នានៅឡើយ។

## អង្គការអន្តរជាតិត្រូវតែមានតម្លាភាព នៅពេលកំណត់ស្តង់ដានានា

អង្គការអន្តរជាតិដែលជាអ្នកកំណត់ស្តង់ដាសម្រាប់ដំណើរការអប់រំក្នុងប្រព័ន្ធ ដើម្បីគាំទ្រដល់ការសម្របសម្រួល ការស្វែងរកការឯកភាពគ្នា និងសមធម៌។ ការរៀបចំក្របខ័ណ្ឌសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលរៀបចំឡើងដោយមានការពិគ្រោះយោបល់ជាច្រើន គឺជាឧទាហរណ៍មួយដែលបង្ហាញពីដំណើរការបែបនេះ ឧទាហរណ៍មួយទៀតគឺដំណើរការបូឡូញ៉ា ដែលបានបង្កើតនូវតំបន់ឧត្តមសិក្សារបស់អឺរ៉ុបបានផ្សារភ្ជាប់ប្រទេសចំនួន៤៨ជាមួយនឹងក្របខ័ណ្ឌគុណវុឌ្ឍិប្រព័ន្ធក្រេឌីតស្តង់ដាធានាគុណភាព និងឧបករណ៍អនុវត្តរួម ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការផ្លាស់ទីបំពេញការងារពីប្រទេសមួយទៅប្រទេសមួយទៀត។ ដំណើរការនេះបានទទួលការសរសើរ ដោយសារតែវាបានបង្កើតនូវយន្តការគណនេយ្យភាពមួយដែលពុំមានការបង្ខំឱ្យមានការអនុវត្តនៅថ្នាក់ជាតិឡើយ។

អង្គការអន្តរជាតិក៏ជាអ្នកដឹកនាំការផ្សព្វផ្សាយស្តង់ដាអប់រំដែលបង្កើតឡើងនៅខាងក្រៅដំណើរការផ្លូវការ ដូចជាស្តង់ដានៃការរៀនសូត្រជាដើមផងដែរ។ កម្មវិធីវាយតម្លៃសិស្សអន្តរជាតិ (PISA) របស់អង្គការ OECD បានបង្វែរទិសដៅគោលនយោបាយអប់រំ ទៅរកលទ្ធផល ប៉ុន្តែកម្មវិធីនេះទទួលបានការរិះគន់ថាបានជះឥទ្ធិពលលើប្រព័ន្ធអប់រំរបស់ប្រទេស ដែលពុំស្ថិតនៅក្រោមក្របខ័ណ្ឌគណនេយ្យភាពអង្គការមួយនេះ។

## អ្នកផ្តល់ជំនួយគួរមានគណនេយ្យភាពចំពោះការសន្យាផ្តល់ជំនួយរបស់ពួកគេ

បេសកម្មរបស់អង្គការជាច្រើន រួមមានការទទួលខុសត្រូវកែលំអប្រព័ន្ធអប់រំរបស់ប្រទេសក្រីក្រតាមរយៈការផ្តល់ជំនួយហិរញ្ញវត្ថុឬជំនួយបច្ចេកទេស។ ទីភ្នាក់ងារផ្តល់ជំនួយត្រូវទទួលខុសត្រូវចំពោះប្រជាពលរដ្ឋក្នុងប្រទេសផ្តល់ជំនួយផង និងប្រទេសទទួលជំនួយផង ដែលជាការទទួលខុសត្រូវដែលអាចមានភាពប្រទាំងប្រទើសជាមួយគ្នា។

ពុំមានយន្តការសម្រាប់តាមដាន ការទាមទារឱ្យអ្នកផ្តល់ជំនួយទទួលខុសត្រូវចំពោះការប្តេជ្ញាចិត្តផ្តល់ជំនួយរបស់ពួកគេឡើយ។ ក្នុងឆ្នាំ២០១៥ក្នុងចំណោមប្រទេសជាសមាជិកនៃគណៈកម្មាធិការផ្តល់ជំនួយអភិវឌ្ឍ (DAC) របស់ OECD ចំនួន២៨ប្រទេសមានតែ៦ប្រទេសប៉ុណ្ណោះដែលបានបំពេញការសន្យារបស់ខ្លួនក្នុងការវិភាជន៍ថវិកាឱ្យបាន ០,៧ ភាគរយនៃចំណូលរបស់ជាតិ សម្រាប់ផ្តល់ជំនួយដល់ប្រទេសដទៃទៀត។ ការទាមទារឱ្យអង្គការនានា ទទួលខុសត្រូវចំពោះទំហំជំនួយត្រូវបានធ្វើឡើងតាមរយៈដំណើរការផ្លូវការ ដូចជា យន្តការពិនិត្យគ្នាទៅវិញទៅមករបស់ OECD និងច្រកមិនផ្លូវការផ្សេងទៀតដូចជាប្រព័ន្ធផ្សព្វផ្សាយ និងអង្គការមិនមែនរដ្ឋាភិបាលជាដើម។

> “ភាព អាចព្យាករណ៍ដឹងជាមុន បាននូវជំនួយមានការថយចុះចន្លោះពីឆ្នាំ២០១០ ដល់ឆ្នាំ ២០១៥ ហើយលក្ខខណ្ឌគណនេយ្យភាពទ្វេទិស ពាក់ព័ន្ធនឹងបរិយាប័ន្នក៏មិនត្រូវបានបំពេញផងដែរ”

មិនមែនត្រឹមតែទំហំជំនួយប៉ុណ្ណោះទេដែលសំខាន់ ប្រសិទ្ធភាពនៃជំនួយក៏សំខាន់ផងដែរ។ ភាពជាដៃគូ សកល ដើម្បី ប្រសិទ្ធភាព នៃ កិច្ចសហប្រតិបត្តិការ អភិវឌ្ឍ ជា កម្មវិធី ពិនិត្យ តាមដាន សកម្មភាព ដែលអនុវត្ត ដោយ ដៃគូ អភិវឌ្ឍ នានា។ របាយការណ៍ ពិនិត្យ តាមដាន ឆ្នាំ ២០១៦ របស់ កម្មវិធី នេះ បានបង្ហាញឱ្យឃើញពីការកើនឡើងតិចតួចតែប៉ុណ្ណោះនៃតម្លាភាពក្នុងការរាយការណ៍ពីជំនួយ។ ប៉ុន្តែភាពអាចព្យាករណ៍ដឹង ជាមុន អំពី ជំនួយ មានការ ថយចុះ ពី ឆ្នាំ ២០១០ ដល់ ឆ្នាំ ២០១៥ ហើយក៏ ពុំមាន ការបំពេញ ទៅតាមលក្ខខណ្ឌគណនេយ្យភាពទ្វេទិសដែលពាក់ព័ន្ធនឹងបរិយាប័ន្នផងដែរ។ ដំណើរការពិនិត្យតាមដានដែលមានភាពច្បាស់លាស់ ពុំបានបង្កើនទំហំជំនួយ ហើយក៏ពុំបានជួយឱ្យមានការកំណត់គោលដៅនៃការផ្តល់ជំនួយទៅរកប្រទេស ដែលត្រូវការជំនួយច្រើនជាងគេនោះដែរ បើទោះបីជាគេមានការពិបាកក្នុងការប្រាប់អំពីអ្វីដែលសម្រេចបានខុសពីនេះ ប្រសិនបើពុំមានដំណាក់កាលទាំងនេះយ៉ាងណាក៏ដោយ។

ថវិកាជំនួយសម្រាប់វិស័យអប់រំ ១ ភាគ ៣ ក្នុងចំណោមថវិកាជំនួយសម្រាប់វិស័យអប់រំសរុប គឺបានពីអ្នកផ្តល់ជំនួយពហុភាគី។ អង្គការមិនមែនរដ្ឋាភិបាលនានាបានបង្ហាញពីការព្រួយបារម្ភថា ការសម្រេចចិត្ត គោលនយោបាយ ដែលមាន ឥទ្ធិពល លើ ប្រជាពលរដ្ឋ ត្រូវបាន ធ្វើឡើង ក្រៅ ដំណើរការ ប្រជាធិបតេយ្យ។ ធនាគារពិភពលោកគឺជាអ្នកផ្តល់កម្ចីដល់វិស័យអប់រំធំជាងគេរបស់ពិភពលោក។ បន្ទាប់ពីការពិនិត្យឡើងវិញរបស់ម្ចាស់ភាគហ៊ុនកាលពីឆ្នាំ ២០១៥ មានការរំពឹងថាភាគរយនៃសំលេងឆ្នោតរបស់ប្រទេសកំពុងអភិវឌ្ឍនឹងកើនឡើងលើសពី ៥០ ភាគរយ ដែលនេះជាផ្នែកមួយនៃដំណើរការកែទម្រង់ ដើម្បីបង្កើនភាពជាតំណាងនៃប្រទេសកំពុងអភិវឌ្ឍទាំងនោះ។

## ការផ្តល់ ជំនួយ ផ្អែក ទៅតាម លទ្ធផល មិនមែន ចេះតែ នាំឱ្យ សម្រេច នូវ ប្រសិទ្ធភាព និងគណនេយ្យភាពនោះទេ

សេចក្តីប្រកាសទីក្រុងប៉ារីសស្តីពីប្រសិទ្ធភាពហិរញ្ញទានសហប្រតិបត្តិការឆ្នាំ ២០០៥ គឺជាកិច្ចខិតខំប្រឹងប្រែងមួយដើម្បីបង្កើនគណនេយ្យភាពរបស់អ្នកផ្តល់ជំនួយ និងប្រទេសដែលជាដៃគូ ចំពោះប្រជាពលរដ្ឋ

និងអង្គនីតិបញ្ញត្តិ។ ការប្តេជ្ញាចិត្តមួយក្នុងចំណោមការប្តេជ្ញាចិត្ត ដែលត្រូវបានដាក់ចេញក្នុងសេចក្តីប្រកាសនេះ គឺការបង្កើនការគ្រប់គ្រងផ្អែកតាមលទ្ធផល។ "ការទូទាត់ទៅតាមលទ្ធផល" គឺជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងនេះ ដែលអាចផ្តល់ឱ្យប្រទេសទទួលជំនួយនៅស្វ័យភាពបន្ថែមទៀត និងងាកចេញពីដំណើរការដែលធ្លាប់អនុវត្តកន្លងមក។ ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង អ្វីៗដែលជាកាន់តែមានភាពស្មុគស្មាញជាងមុនទៅវិញ។

កម្មវិធីផ្អែកតាមលទ្ធផលផ្តោតសំខាន់លើផលសម្រេច និងផលជះរយៈពេលវែង ខុសពីលក្ខខណ្ឌមុនៗដែលផ្សារភ្ជាប់ការផ្តល់ជំនួយជាមួយនឹងការអនុម័តគោលនយោបាយ។ កម្មវិធីនេះមានច្រើនទម្រង់។ ការផ្តល់ហិរញ្ញប្បទានសម្រាប់ឱ្យកម្មវិធីដើម្បីសម្រេចលទ្ធផល (Program-for-Results) របស់ធនាគារពិភពលោកផ្សារភ្ជាប់ការទម្លាក់សាច់ប្រាក់ជាមួយលទ្ធផលដោយផ្ទាល់។ ឧទាហរណ៍ដែលបង្ហាញពីការប្រើប្រាស់គម្រោងបែបនេះនៅក្នុងវិស័យអប់រំ គឺកម្មវិធីសម្រេចឱ្យបាននូវលទ្ធផលធំដុំក្នុងវិស័យអប់រំនាពេលនេះ (Big Results Now in Education) នៅសាធារណរដ្ឋតង់ហ្សានី ដោយមានការកំណត់សូចនាករផលធៀបសិស្ស/គ្រូផង និងការកែលំអបំណិនអំណានផង។

កម្មវិធីមួយចំនួនជួលអង្គការមិនមែនរដ្ឋាភិបាលឱ្យផ្តល់សេវាអប់រំ។ អ្នកផ្តល់ជំនួយរ៉ាប់រងចំណាយផ្តល់សេវាអប់រំគិតតាមចំនួនសិស្ស ប៉ុន្តែពេលខ្លះក៏មានការផ្តល់ប្រាក់លាភការផងដែរ។ មូលនិធិ Challenge funds ធ្វើឱ្យអង្គការនានាត្រូវប្រកួតប្រជែងដណ្តើមថវិកាជំនួយ។ មូលនិធិបែបនេះ មានគោលបំណងពង្រឹងគណនេយ្យភាពរបស់អ្នកផ្តល់សេវា។ មូលនិធិ Challenge funds សម្រាប់ការអប់រំក្មេងស្រីរបស់ក្រសួងអភិវឌ្ឍន៍អន្តរជាតិនៃចក្រភពអង់គ្លេស គឺជាឧទាហរណ៍មួយដែលបង្ហាញពីមូលនិធិបែបនេះធំជាងគេ ដែលប្រើប្រាស់ក្នុងវិស័យអប់រំ។

កន្លងមកមានការវាយតម្លៃមួយចំនួនលើកម្មវិធីទាំងនេះ។ការវាយតម្លៃពីតម្រូវការបានបញ្ចូលឧបករណ៍ដែលត្រូវបានប្រើប្រាស់ក្នុងកម្មវិធីដើម្បីសម្រេចលទ្ធផល (Program-for-Results)។ ផ្ទុយទៅនឹងការរំពឹងទុក ការវាយតម្លៃទាំងនេះបានរកឃើញថា លទ្ធផលត្រូវបានសម្រេចភាគច្រើននៅកម្រិតស្ថាប័នជាជាងនៅកម្រិតផលសម្រេច។ លើសពីនេះការវាយតម្លៃលើផលជះរយៈពេលវែង ត្រូវប្រឈមនឹងការលំបាកក្នុងការកំណត់ឱ្យដឹងថា តើការផ្លាស់ប្តូរណាខ្លះ ដែលកើតចេញពីកម្មវិធីផ្អែកតាមលទ្ធផល។ មូលហេតុមួយ គឺដោយសារតែអន្តរាគមន៍ភាគច្រើន ផ្តោតលើលទ្ធផលច្រើនពេក ដែលនាំឱ្យគេពិបាកនឹងទាញជាសេចក្តីសន្និដ្ឋានថាតើលទ្ធផលមួយណាកើតចេញពីកម្មវិធីមួយណានោះ។ ចុងក្រោយគេត្រូវការពេលដើម្បីផលិតទិន្នន័យ និងបង្ហាញឱ្យឃើញពីលទ្ធផល។ បច្ចុប្បន្ននេះអ្នកផ្តល់ជំនួយនានាកំពុងចំណាយថវិកា ដើម្បីកែលំអភស្តុតាងបង្ហាញពីលទ្ធផលនៅកម្មវិធីទាំងនេះ។

ភស្តុតាងដែលមានកន្លងមកបង្ហាញពីសំនួរមួយចំនួន។ ការកំណត់លក្ខខណ្ឌពីខាងក្រៅសម្រាប់ផ្តល់ការលើកទឹកចិត្ត អាចធ្វើឱ្យប៉ះពាល់ដល់ទឹកចិត្តបំពេញការងាររបស់អ្នកផ្តល់សេវា។ ដោយសារតែកម្រិតនៃការផ្តល់ជំនួយពុំមានភាពប្រាកដប្រជា អ្នកទទួលជំនួយក៏ត្រូវប្រឈមនឹងហានិភ័យមួយចំនួនផងដែរ ដែល

អាចធ្វើឱ្យប៉ះពាលដល់ការងាររបស់ពួកគេ។ ការផ្តល់ឱ្យអ្នកផ្តល់សេវានូវស្វ័យភាពក្នុងការច្នៃប្រឌិតថ្មី តាមរយៈការអនុវត្តកម្មវិធីផ្អែកតាមលទ្ធផល អាចជួយបង្កើនប្រសិទ្ធភាព ប៉ុន្តែអ្នកផ្តល់សេវាមានភាពស្ទាក់ស្ទើរក្នុងការផ្លាស់ប្តូរវិធីសាស្ត្រ ដែលធ្លាប់ទទួលបានការជឿទុកចិត្តកន្លងមកពោលពួកគេចង់សម្រេចបានលទ្ធផល ដើម្បីអាចទទួលបានជំនួយបន្តទៀត។

> “សូចនាករដែលត្រូវបានប្រើប្រាស់ក្នុងការផ្តល់ហិរញ្ញប្បទានផ្អែកទៅតាមលទ្ធផល ក៏ត្រូវតម្រឹម ឱ្យស្របទៅតាមគោលដៅរយៈពេលវែង និងត្រូវផ្តល់អាទិភាពលើសមធម៌”

សូចនាករដែលអាចវាស់វែងបាន មានប្រសិទ្ធភាពចំណាយ និងអាចផ្ទៀងផ្ទាត់ដឹងបាន គឺជាសូចនាករដែលគេពិបាកបង្កើតឡើង។ សូចនាករនានាក៏ត្រូវតម្រឹមឱ្យស្របទៅតាមគោលដៅរយៈពេលវែងផងដែរ។ សូចនាករមិនសមស្រប ដែលមិនយកចិត្តទុកដាក់លើសមធម៌អាចផ្តល់ការលើកទឹកចិត្តដោយប្រយោល ឱ្យមានការផ្តល់សេវាតែដល់អ្នកដែលទទួលសេវា ដែលគេងាយស្រួលទៅដល់ជាងគេប៉ុណ្ណោះ។

លើសពីនេះការទូទាត់ផ្អែកទៅតាមលទ្ធផល អាចធ្វើឱ្យប៉ះពាល់ដល់ភាពជាម្ចាស់ របស់ប្រទេសដោយសារតែអភិក្រមបែបនេះមានដើមកំណើតពីប្រទេសផ្តល់ជំនួយ ហើយមិនមែនចេះតែស្របទៅតាមប្រព័ន្ធរបស់ប្រទេសទទួលជំនួយឡើយ។ ជារឿយៗ អ្នកផ្តល់ជំនួយមាននិន្នាការទៅរកអ្នកផ្តល់សេវាមិនមែនរដ្ឋាភិបាល ហើយមិនចង់ធ្វើការវិនិយោគ ដើម្បីពង្រឹងសមត្ថភាពវិស័យសាធារណៈឡើយ។ ការកំណត់លក្ខខណ្ឌផ្តល់ជំនួយលើលទ្ធផលដែលសម្រេចបាន ក៏អាចធ្វើឱ្យប៉ះពាល់ដល់ភាពអាចព្យាករណ៍ដឹងជាមុននៃលំហូរធនធានផងដែរ។ ជាការពិត អភិក្រមបែបនេះ អាចមានប្រសិទ្ធភាពបំផុតនៅក្នុងករណីដែលគេត្រូវការវាតិចបំផុតដែរ។ ពោលគឺក្នុងប្រព័ន្ធអប់រំដែលមានការកំណត់គោលបំណងច្បាស់លាស់ និងមានគោលដៅប្រទាក់ក្រឡាគ្នា និងដែលអាចហ៊ានទទួលយកការប្រថុយប្រថានមួយចំនួន។

## គណនេយ្យភាពនៃវិស័យឯកជន ដែលជាតួអង្គរកប្រាក់ចំណេញ

វិស័យឯកជនដែលជាតួអង្គរកប្រាក់ចំណេញជាអ្នកផ្តល់សេវាអប់រំស្នូលផង និងសេវាបន្ថែមនានាផង ដូចជាកម្មវិធីផ្តល់អាហារតាមសាលារៀន និងផលិតសម្ភារឧបទ្ទេស ជាដើម។ ដោយសារតែឥទ្ធិពលរបស់ពួកគេក្នុងវិស័យអប់រំ ក៏ចាំបាច់ត្រូវមានការទាមទារឱ្យពួកគេមានគណនេយ្យភាពផងដែរ។

### កម្មវិធីផ្តល់អាហារតាមសាលារៀនដែលមានប្រសិទ្ធភាព ទាមទារឱ្យមានការត្រួតពិនិត្យពីរដ្ឋាភិបាល

ការផ្តល់អាហារតាមសាលារៀនគឺជាទម្រង់នៃកិច្ចគាំពារសង្គមដែលត្រូវបានអនុវត្តយ៉ាងទូលំទូលាយបំផុតក្នុងពិភពលោកទាំងមូល។ ក្នុងចំណោមកុមារ ៥ នាក់ មានកុមារម្នាក់ញ៉ាំអាហារនៅសាលារៀនជារៀង

រាល់ថ្ងៃ។ ក្នុងប្រទេសជាច្រើន ការផ្តល់អាហារបែបនេះត្រូវបានជួលឱ្យក្រុមហ៊ុនឯកជនផ្តល់ផ្នែកខ្លះ ឬផ្តល់ទាំងស្រុងតែម្តង។ ទោះបីមានប្រសិទ្ធភាពក៏ដោយ ការជួលឱ្យក្រុមហ៊ុនឯកជនទាំងនេះឱ្យសេវាបែបនេះ ទាមទារឱ្យមានការកំណត់ការទទួលខុសត្រូវរបស់រដ្ឋាភិបាល និងរបស់អ្នកផ្តល់សេវាទាំងនេះឱ្យបានច្បាស់លាស់ និងត្រូវកំណត់ពីតម្លាភាព និងមានការផ្តល់ថវិកាឱ្យបានគ្រប់គ្រាន់។

> "ក្នុងប្រទេសជាច្រើន ការផ្តល់អាហារបែបនេះត្រូវបានជួលឱ្យក្រុមហ៊ុនឯកជនផ្តល់ផ្នែកខ្លះ ឬផ្តល់ទាំងស្រុងតែម្តង។"

ការពិនិត្យតាមដានប្រកបដោយប្រសិទ្ធភាព ដែលធ្វើឡើងដោយរដ្ឋាភិបាលអាចជួយធានាឱ្យអ្នកផ្គត់ផ្គង់អាហារទាំងនេះផ្តោតគោលដៅ លើអ្នកដែលជួបនឹងការខ្វះខាត។ ក្នុងប្រទេសឈីលី និងប្រទេសហ្វាណា ការផ្គត់ផ្គង់អាហារដល់គ្រប់សាលារៀនទាំងអស់ ត្រូវបានជួលឱ្យស្ថាប័នឯកជនជាអ្នកធ្វើ។ ប៉ុន្តែខណៈពេលដែលកម្មវិធីអាហារូបត្ថម្ភរបស់ប្រទេសឈីលីមានការពិនិត្យតាមដាន និងផ្តោតគោលដៅលើសិស្សដែលមានជីវភាពក្រីក្រ នៅក្នុងប្រទេសហ្វាណាវិញ ការផ្តល់អាហារទាំងនេះពុំបានផ្តោតលើសហគមន៍ក្រីក្រឡើយ ហើយការជ្រៀតជ្រែកពីអ្នកនយោបាយក៏កើតមានជាទូទៅ។ ថវិកាដែលរដ្ឋាភិបាលផ្តល់សម្រាប់ពិនិត្យតាមដាន ក៏មិនគ្រប់គ្រាន់។

## ការបង្រៀនគួរឯកជន អាចមានបច្ចុផលប៉ះពាល់ដល់សមធម៌នៃការទទួលបានសេវាអប់រំ

ការបង្រៀនគួរឯកជនគឺជាបាតុភូតដែលកើតមានជាសកល ដែលមានសិស្សវិទ្យាល័យយ៉ាងហោចណាស់ពាក់កណ្តាល ក្នុងចំណោម សិស្សវិទ្យាល័យ ដែល ត្រូវបានអង្កេត នៅតាម បណ្តា ប្រទេស នានា ដូចជា



អាហ្សែបៃចាន់ ចិន និង អេស្ប៉ាញ បានចូលរួមរៀនក្នុងថ្នាក់បង្រៀនគួរទាំងនេះ។ នៅសាធារណរដ្ឋកូរ៉េ សិស្សបឋមសិក្សាប្រមាណជា៨១ភាគរយនិងសិស្សវិទ្យាល័យប្រមាណជា៥៦ភាគរយបានទទួលការបង្រៀនគួរក្នុងឆ្នាំ ២០១៤។ គេរំពឹងថាទីផ្សារសម្រាប់ការបង្រៀនគួរជាសកលបែបនេះ នឹងមានតម្លៃលើសពី ២២៧ ពាន់លានដុល្លាត្រឹមឆ្នាំ ២០២២។ ការបង្រៀនគួរឯកជនអាចធ្វើឱ្យសិស្សកាន់តែមានបញ្ហាស្ត្រេស និងធ្វើឱ្យប៉ះពាល់ដល់ថវិការបស់គ្រួសារ។ រដ្ឋាភិបាលអាចលើកទឹកចិត្តឱ្យមានគណនេយ្យភាព តាមរយៈការផ្តល់ព័ត៌មានដល់អ្នកប្រើប្រាស់សេវាទាំងនេះ ធ្វើការសហការជាមួយសាលារៀន និងសមាគមគ្រូដើម្បីកំណត់ស្តង់ដា។ ទីក្រុងហុងកុង ប្រទេសចិន តម្រូវឱ្យមជ្ឈមណ្ឌលបង្រៀនគួរដាក់ពាក្យសុំអាជ្ញាប័ណ្ណ និងត្រូវផ្តល់ព័ត៌មានដល់អតិថិជនរបស់ខ្លួន។ ការធ្វើបែបនេះជម្រុញឱ្យមានតម្លាភាព តាមរយៈការបង្កើតបញ្ជីឈ្មោះមជ្ឈមណ្ឌលដែលបានចុះបញ្ជីត្រឹមត្រូវ និងធ្វើការផ្សព្វផ្សាយតាមប្រព័ន្ធអនឡាញ និងការដាក់ទោសដល់មជ្ឈមណ្ឌលបង្រៀនគួរដែលពុំបានចុះបញ្ជីត្រឹមត្រូវ។

> “មានការរំពឹងទុកថាទីផ្សារសកលនៃការបង្រៀនគួរ និងវាយតម្លៃលើសពី ២២៧ ពាន់លានដុល្លាត្រឹមឆ្នាំ ២០២២។”

ការផ្តល់លទ្ធភាពឱ្យគ្រូបង្រៀនគួរ អាចបង្កើតឱ្យមានទំនាស់ផលប្រយោជន៍។ នៅប្រទេសនេប៉ាល់ គ្រូបង្រៀនតិចតួចតែប៉ុណ្ណោះនៅសាលារៀន ដើម្បីឱ្យសិស្សទៅរៀនគួរ។ ប៉ុន្តែគ្រូជាច្រើនផ្តល់សេវាបង្រៀនគួរនេះ ដើម្បីរកចំណូលបន្ថែមពីលើបៀវត្សរ៍តិចតួចរបស់ពួកគេ និងដោយសារតែពួកគេពុំមានម៉ោងបង្រៀនឱ្យបានគ្រប់គ្រាន់។ ប្រទេសមួយចំនួនបានបង្កើតជាបទបញ្ញត្តិស្តីពីការបង្រៀនគួររបស់គ្រូ។ ក្រមសីលធម៌របស់គ្រូឆ្នាំ ២០១០ របស់ប្រទេសចចា មិនលើកទឹកចិត្តឱ្យគ្រូបង្រៀនគួរសិស្សខ្លួនឯងឡើយ ខណៈពេលដែលប្រទេសជប៉ុនហាមឃាត់មិនឱ្យគ្រូដែលបង្រៀនពេញម៉ោងធ្វើការបង្រៀនគួរឯកជនឡើយ។ ផ្ទុយទៅវិញនៅប្រទេសអ៊ុយប៉េគីស្ថាន គ្រូត្រូវបានអនុញ្ញាតឱ្យបង្រៀនគួរសិស្សខ្លួនឯង។

## រដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលគួរទាមទារគណនេយ្យភាពពីអ្នកផ្គត់ផ្គង់សម្ភារ និងឯកសារបង្រៀន

រដ្ឋាភិបាលជាច្រើនប្រើប្រាស់ក្រុមហ៊ុនឯកជនឱ្យផលិតសៀវភៅសិក្សា ដើម្បីកាត់បន្ថយចំណាយលើការបោះពុម្ព និងការចែកចាយសៀវភៅសិក្សាទាំងនេះ។ ភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជនបានផ្តល់នូវប្រសិទ្ធភាពចំណាយ។ ភាពជាដៃគូបែបនេះក្នុងប្រទេសអ៊ូហ្គាន់ដា ជួយកាត់បន្ថយចំណាយលើសៀវភៅសិក្សា បានរហូតដល់ ២ ភាគ ៣។

ការកំណត់ការទទួលខុសត្រូវឱ្យបានច្បាស់លាស់ ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល និងការធ្វើសកម្មភាពរបស់សង្គមទាំងមូល អាចជួយកែលំអការផ្គត់ផ្គង់ និងការអភិវឌ្ឍសៀវភៅសិក្សា។ ក្នុងប្រទេសហ្វីលីពីន ការធ្វើសកម្មភាពរួមគ្នារវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលជួយឱ្យដំណើរការនៃការដេញថ្លៃផលិតសៀវភៅសិក្សាកាន់តែមានតម្លាភាពជាងមុន កាត់បន្ថយចំណាយជាមធ្យម និងរយៈពេលផលិត និងផ្គត់ផ្គង់សៀវភៅបានរហូតដល់ពាក់កណ្តាល ចន្លោះពីឆ្នាំ ២០០២ ដល់ឆ្នាំ២០០៥។

អង្គការសង្គមស៊ីវិលក៏អាចជួយពិនិត្យតាមដានខ្លឹមសារនៅក្នុងសៀវភៅសិក្សាផងដែរ។ នៅក្នុងរដ្ឋតិចសាស សហរដ្ឋអាមេរិច សកម្មភាពដែលធ្វើឡើងដោយអង្គការនៅមូលដ្ឋានបានជម្រុញឱ្យក្រុមហ៊ុនបោះពុម្ពផ្សាយធ្វើការកែសម្រួលសៀវភៅសិក្សាដែលផ្ដល់ព័ត៌មានមិនត្រឹមត្រូវអំពីការប្រែប្រួលអាកាសធាតុ។

> “សាជីវកម្មឯកជនទទួលខុសត្រូវ តែចំពោះម្ចាស់ភាគហ៊ុនរបស់ខ្លួនតែប៉ុណ្ណោះ ដែលនាំឱ្យមានការព្រួយបារម្ភណ៍ អំពីគណនេយ្យភាពរបស់សាជីវកម្មទាំងនេះ ចំពោះប្រជាពលរដ្ឋទូទៅ នៅពេលដែលសាជីវកម្មទាំងនេះផ្ដល់សេវាសាធារណៈ ដូចជាសេវាអប់រំជាដើម។”

សាជីវកម្មឯកជនទទួលខុសត្រូវ តែចំពោះម្ចាស់ភាគហ៊ុនរបស់ខ្លួនតែប៉ុណ្ណោះ ដែលនាំឱ្យមានការព្រួយបារម្ភណ៍អំពីគណនេយ្យភាពរបស់សាជីវកម្មទាំងនេះ ចំពោះប្រជាពលរដ្ឋទូទៅ នៅពេលដែលសាជីវកម្មទាំងនេះផ្ដល់សេវាសាធារណៈ ដូចជា សេវាអប់រំជាដើម។ បណ្ដឹងមួយត្រូវបានដាក់ ដើម្បីរារាំងមិនឱ្យក្រុមហ៊ុន Pearson ដែលជាក្រុមហ៊ុនផ្ដល់សេវាអប់រំដ៏ធំមួយ មិនឱ្យទទួលបានសិទ្ធិផ្ដាច់មុខក្នុងទីផ្សារអប់រំ។ ជាការឆ្លើយតប ក្រុមហ៊ុននេះបានចាប់ផ្ដើមអនុវត្ត គំនិតផ្ដួចផ្ដើមគណនេយ្យភាពផ្ទៃក្នុង ដែលលទ្ធផលនៃគំនិតផ្ដួចផ្ដើមនេះត្រូវបានគេផ្សព្វផ្សាយជាសាធារណៈ នៅពេលដែលការផ្សព្វផ្សាយរបាយការណ៍ផ្លូវការចាប់ផ្ដើមធ្វើឡើងក្នុងឆ្នាំ ២០១៨។

រដ្ឋាភិបាលបានធ្វើការងារក្នុងភាពជាដៃគូជាមួយក្រុមហ៊ុនផលិតថាប្លេត និងកុំព្យូទ័រយួរដៃឯកជន ដើម្បីដោះស្រាយបញ្ហា “គម្លាតឌីជីថល” រវាងសិស្ស និងសិស្ស និងរវាងសាលារៀនមួយ និងសាលារៀនមួយទៀត។ ប៉ុន្តែគំនិតផ្ដួចផ្ដើមបែបនេះ បែរជាផ្ដល់ប្រយោជន៍ដល់ក្រុមហ៊ុនផ្គត់ផ្គង់ ឧបករណ៍ទាំងនេះទៅវិញ ពោលគឺពុំបានផ្ដល់ប្រយោជន៍ដល់សិស្សឡើយ ដោយសារតែការធ្វើលទ្ធកម្ម និងការអនុវត្តកិច្ចសន្យានៅមានកម្រិតខ្សោយ ដូចជាក្នុងប្រទេសថៃជាដើម។ ប្រទេសឥណ្ឌាលះបង់កម្មវិធី Aakash របស់ខ្លួនក្នុងឆ្នាំ ២០១៥ ដោយសារកម្មវិធីនេះពុំបានសម្រេចគោលបំណងដែលបានដាក់ចេញ។ ក្នុងពេលជាមួយគ្នាក្រុមហ៊ុនដែលផ្គត់ផ្គង់ឱ្យកម្មវិធីនេះឈ្មោះ DataWind បានក្លាយជាក្រុមហ៊ុននាំមុខគេមួយ ខាងផលិតថាប្លេតដែលមានតម្លៃថោក។




**រដ្ឋាភិបាលអាចធ្វើការគ្រប់គ្រងបានតិចតួចប៉ុណ្ណោះ ក្រោយពេលដែលមានការផ្ដាច់មុខក្នុងទីផ្សារ**



សិស្សរៀននៅសាលារៀនមួយ
ជិតតំបន់ម៉ាណូស រដ្ឋអាម៉ាហ្សូណា
ប្រទេសប្រេស៊ីល

CREDIT: GEM Report/Andres Pascoe

## ការពិនិត្យតាមដានវឌ្ឍនភាពគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤

របៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាព បានកំណត់នូវក្របខ័ណ្ឌថ្មីមួយសម្រាប់ពិនិត្យតាមដានវិស័យអប់រំ។ក្របខ័ណ្ឌថ្មីនេះមានគោលបំណងក្លាយខ្លួនជាក្របខ័ណ្ឌដែលមានលក្ខណៈសកលពិតប្រាកដដើម្បីបន្ស៊ីចំណុចដៅនានាជាមួយគ្នា និងពិនិត្យតាមដានលើសពីវិសាលភាពជាប្រពៃណីនៃប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំបច្ចុប្បន្ននេះ។ ទោះជាយ៉ាងនេះក៏ដោយ ដូចដែលត្រូវបានលើកឡើងក្នុងរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកលឆ្នាំ ២០១៦ ក្របខ័ណ្ឌបែបនេះផ្ដោតត្រឹមតែផ្ទៃខាងលើ នៃសំណួរពាក់ព័ន្ធនឹងការអប់រំស្នូល និងការរៀនសូត្រពេញមួយជីវិតតែប៉ុណ្ណោះ ជាពិសេសសំណួរដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ទោះជាបែបនេះក៏ដោយ ការពិនិត្យតាមដានថ្មីនេះ មានគោលដៅប្រកបដោយមហិច្ឆិតាក្នុងកម្រិតមួយគ្រប់គ្រាន់ ដើម្បីទាមទារឱ្យមានការកៀរគរធនធានឱ្យបានច្រើន ដើម្បីកំណត់ស្តង់ដា និងប្រើប្រាស់ឧបករណ៍



ដែលពាក់ព័ន្ធសម្រាប់ប្រមូលព័ត៌មានអំពីសមធម៌គុណភាព និងលទ្ធផលនៃការរៀនសូត្រ។ ការសម្របសម្រួលដែលមានការចូលរួមពិតប្រាកដពីប្រទេសនានា ត្រូវការចំណាយចាយវាយច្រើន។ ក្នុងយុគសម័យដែលថវិកាសម្រាប់សម្រេចគោលបំណងសាធារណៈ មានស្ដួចស្ដើង ដូចជា ថវិកាសម្រាប់ការងារស្ថិតិ និងការស្រាវជ្រាវជាច្រើន នេះមិនមែនជាការងារដែលងាយស្រួលនោះឡើយ។

មូលដ្ឋានស្ថាប័នមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ជាពិសេសក្រុមកិច្ចសហប្រតិបត្តិការបច្ចេកទេសទទួលបន្ទុកសូចនាករសម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤ - ការអប់រំឆ្នាំ ២០៣០ ដែលមានវិទ្យាស្ថានស្ថិតិរបស់យូណេស្កូជាលេខាធិការដ្ឋាន។ គោលបំណងនៃក្រុមនេះ គឺដើម្បីកសាងការឯកភាពជារួមលើការកំណត់សូចនាករ និងជម្រុញឱ្យប្រទេសនានាមានភាពជាម្ចាស់លើដំណើរការនេះ។ បើទោះបីជាយ៉ាងនេះក៏ដោយ ដូចដែលត្រូវបានបង្ហាញនៅក្នុងការពិនិត្យឡើងវិញនេះ សហគមន៍អន្តរជាតិចាំបាច់ត្រូវវិនិយោគបន្ថែមទៀត ដើម្បីធានាយ៉ាងណាឱ្យមានការកំណត់ និងពិនិត្យតាមដានគ្រប់សូចនាករទាំងអស់ឱ្យបានច្បាស់លាស់។




គោលដៅ ៤.១

# ការអប់រំកម្រិតបឋមសិក្សា និងមធ្យមសិក្សា

សូចនាករសកលសម្រាប់ចំណុចដៅ ៤.១ គឺការវាស់វែងភាពស្ទាត់ជំនាញខាងអំណាន និងគណិតវិទ្យានៅកម្រិតថ្នាក់ដំបូងៗ នៅពេលបញ្ចប់ការអប់រំកម្រិតបឋមសិក្សា និងនៅពេលបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ។ បច្ចុប្បន្ននេះនៅមិនទាន់មានស្តង់ដាជាសកលសម្រាប់វាស់វែងកម្រិតស្ទាត់ជំនាញនេះឡើយ បើទោះបីជាកាលពីថ្មីៗនេះមានការអនុវត្តវិធានការជាជំហានៗក្នុងទិសដៅនេះតាមរយៈសម្ព័ន្ធភាពជាសកលដើម្បីពិនិត្យតាមដានការរៀនសូត្រ ( Global Alliance to Monitor Learning ) ក្រោមការសម្របសម្រួលរបស់វិទ្យាស្ថានស្ថិតិរបស់យូណេស្កូយ៉ាងណាក៏ដោយ។

មានប្រទេសប្រមាណជាពាក់កណ្ដាលប៉ុណ្ណោះ បានរៀបចំឱ្យមានការវាយតម្លៃថ្នាក់ជាតិលើការរៀនសូត្រមុខវិជ្ជាអំណាន និងគណិតវិទ្យានៅចុងបញ្ចប់ការអប់រំកម្រិតបឋមសិក្សា និងការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ។ បើទោះបីជាយ៉ាងណាក៏ដោយ គិតត្រឹមឆ្នាំ ២០១៧ មានប្រទេសចន្លោះពី ២៥ ភាគរយទៅ ៣៨ ភាគរយប៉ុណ្ណោះ ក្នុងចំណោមប្រទេសដែលបានចូលរួមក្នុងការវាយតម្លៃការសិក្សានៅថ្នាក់តំបន់ និងនៅថ្នាក់ជាតិបានផ្ដល់ទិន្នន័យសម្រាប់ការរៀបចំសូចនាករសកលនេះ។ លើសពីនេះលទ្ធផលនៃការវាយតម្លៃទាំង

នេះ ត្រូវបានរាយការណ៍ទៅតាមកម្រិតនៃភាពស្ទាត់ជំនាញ ដែលត្រូវបានកំណត់ដោយការអង្កេតនីមួយៗ ដែលធ្វើឱ្យលទ្ធផលទាំងនេះមិនអាចយកមកធ្វើការប្រៀបធៀបគ្នាបាន។

ប្រទេសដែលស្ថិតក្នុងក្រុម E9 ដែលជាវេទិកានៃប្រទេសចំណូលទាប និងចំណូលមធ្យម ដើម្បីជួយសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី៤និងក្តោបលើប្រជាជនជាងពាក់កណ្តាលនៃចំនួនប្រជាជនក្នុងសកលលោកទាំងមូល គឺជាក្រុមដែលមានតួនាទីសំខាន់សម្រាប់ការរៀបចំរបាយការណ៍ជាសកល ស្តីពីលទ្ធផលនៃការសិក្សា។ ប្រទេសប្រេស៊ីល អេហ្ស៊ីប ឥណ្ឌូនេស៊ី និងម៉ិចស៊ិច ស្ថិតនៅក្នុងចំណោមក្រុមប្រទេសទាំងនេះ បានផ្តល់ទិន្នន័យមួយចំនួននៅកម្រិតអប់រំទាំង ៣ ខណៈពេលដែលប្រទេសបង់ក្លាដេស ចិន ឥណ្ឌា នីហ្សេរីយ៉ា និងប៉ាគីស្ថាន ពុំបានដាក់របាយការណ៍អំពីសូចនាករនេះឡើយ ទោះជានៅកម្រិតណាក៏ដោយ។ ដូច្នេះជាការសំខាន់ណាស់ដែលប្រទេសទាំង ៩ ត្រូវចូលរួមក្នុងការអង្កេតប្រៀបធៀបរវាងប្រទេសមួយ និងប្រទេសមួយទៀត ឬប្រើប្រាស់ការវាយតម្លៃរបស់ខ្លួន សម្រាប់រៀបចំរបាយការណ៍ទាំងនេះ ដរាបណាការវាយតម្លៃទាំងនេះអាចបំពេញទៅតាមស្តង់ដាគុណភាពបាន។

**រូបភាពទី ៨៖**

ក្នុងប្រទេសជិតពាក់កណ្តាលក្នុងចំណោមប្រទេសទាំងអស់ ក្នុងចំណោមយុវជន ២ នាក់ មានតិចជាង ១ នាក់ ដែលបានបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សា

*អត្រាបញ្ចប់ការសិក្សា បែងចែកទៅតាមកម្រិតនៃការអប់រំតាមប្រទេសមួយចំនួន ២០១០ - ២០១៥*




Source: GEM Report team analysis using household surveys.

បើទោះបីជាមានបញ្ហាប្រឈមទាំងនេះយ៉ាងណាក៏ដោយ ទិន្នន័យត្រូវបានពីការវាយតម្លៃលើការសិក្សាប្រៀបធៀបរវាងប្រទេសមួយ និងប្រទេសមួយទៀត បង្ហាញថាក្នុងប្រទេសជាច្រើន ជាពិសេសប្រទេសដែលមានចំណូលទាប និងចំណូលមធ្យម សិស្សជាច្រើននាក់ពុំបានសម្រេចដល់កម្រិតស្ទាត់ជំនាញអប្បបរមាឡើយ។ សម្រាប់មុខវិជ្ជាគណិតវិទ្យា សិស្សក្រោម ១ ភាគ ៣ ដែលអាចបំពេញទៅតាមចំណុចដៅអប្បបរមានៅចុងបញ្ចប់នៅការអប់រំកម្រិតបឋមសិក្សាក្នុងប្រទេសឆាត គុយវ៉ែត និងនីការ៉ាហ្គ័រ និងនៅចុងបញ្ចប់នៃការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិនៅប្រទេសអាល់ហ្សេរី ឥណ្ឌូនេស៊ី និងម៉ាសេដូនៀដែលជាអតីតសាធារណរដ្ឋយូហ្គោស្លាវី។ សម្រាប់អំណានវិញ មានសិស្សតិចជាងពាក់កណ្តាលប៉ុណ្ណោះដែលអាចបំពេញទៅតាមចំណុចដៅ នៅចុងបញ្ចប់នៃការអប់រំកម្រិតបឋមសិក្សាក្នុងប្រទេសកាម៉េរូន កុងហ្គោ និងតូហ្គោ និងនៅចុងបញ្ចប់នៃមធ្យមសិក្សាបឋមភូមិនៅប្រទេសអាល់បានី ចចា និងឡេបាណន់។

ចំណុចដៅទាំងនេះវាស់វែងលទ្ធផលសិក្សា របស់សិស្សដែលបានឡើងទៅរៀនដល់កម្រិតថ្នាក់របស់ពួកគេ។ សន្មត់ថាអ្នកដែលបានបោះបង់ចោលការសិក្សា ឬមិនដែលបានចុះឈ្មោះចូលរៀន ពុំអាចបំពេញទៅតាមចំណុចដៅទាំងនេះ នោះភាគរយពិតប្រាកដនៃអ្នកដែលសម្រេចបានភាពស្ទាត់ជំនាញក្នុងកម្រិតអប្បបរមា



ចាំបាច់ត្រូវកែសម្រួលឱ្យកាន់តែតិចជាងនេះទៅទៀត។ ក្នុងឆ្នាំ ២០១៥ កុមារ និងយុវជនដែលគ្រប់អាយុចូលរៀនបឋមសិក្សា និងមធ្យមសិក្សាចំនួន ២៦៤ លាននាក់ ស្ថិតនៅក្រៅសាលានៅឡើយ។ បន្ទាប់ពីចំនួននេះមានការថយចុះពេលគឺចាប់តាំងពី២០០៨មកសម្រាប់កុមារដល់អាយុចូលរៀននៅបឋមសិក្សា,ពីឆ្នាំ២០១២សម្រាប់យុវជនដល់អាយុចូលរៀននៅកម្រិតមធ្យមសិក្សាបឋមភូមិនិងពីឆ្នាំ២០១៣មកសម្រាប់យុវជនដែលដល់អាយុចូលរៀននៅកម្រិតមធ្យមសិក្សាទុតិយភូម។

ការរៀននៅសាលារៀនពុំបានធានាថាសិស្សទាំងអស់ប្រាកដជាអាចបញ្ចប់ការសិក្សាបានឡើយ។បើតាមទិន្នន័យនៃការអង្កេតគ្រួសារឆ្នាំ២០១០-២០១៥អត្រាបញ្ចប់ការសិក្សាជាសកលគឺ៨៣ភាគរយសម្រាប់បឋមសិក្សា ៦៩ ភាគរយសម្រាប់មធ្យមសិក្សាបឋមភូមិ និង ៤៥ ភាគរយសម្រាប់មធ្យមសិក្សាទុតិយភូមិ។ ផ្អែកទៅតាមទិន្នន័យដែលបានពីប្រទេសចំនួន ១២៨ ក្នុងរយៈពេលពីឆ្នាំ ២០១០ ដល់ ២០១៥ ដែលតំណាងឱ្យ ៩០ ភាគរយនៃចំនួនប្រជាជនដែលដល់អាយុចូលរៀននៅកម្រិតមធ្យមសិក្សា ក្នុងចំណោមយុវជន ៤ នាក់មានតិចជាងម្នាក់ប៉ុណ្ណោះដែលបានបញ្ចប់ការសិក្សាពីសាលាមធ្យមសិក្សា ក្នុងប្រទេសចំនួន ៤០ និងតិចជាងម្នាក់ក្នុងចំណោម ២ នាក់ក្នុងប្រទេសចំនួន ៦០។ មានប្រទេសតែ ១៤ ប៉ុណ្ណោះដែលមានអត្រាបញ្ចប់ការសិក្សាតិចបំផុត ៩០ ភាគរយ **(រូបភាពទី ៨)**។

ការធានាយ៉ាងណាឱ្យការអប់រំត្រូវបានផ្តល់ដោយមិនគិតថ្លៃ និងជាកាតព្វកិច្ចដែលតម្រូវដោយច្បាប់គឺជាវិធីមួយដើម្បីទប់ស្កាត់ការបោះបង់ចោលការសិក្សា។មានប្រទេសប្រមាណជា៧០ភាគរយប៉ុន្តែត្រឹមតែ៤០ភាគរយប៉ុណ្ណោះនៃប្រទេសនៅអាហ្វ្រិចសាប់សាហារ៉ាបានកំណត់ការអប់រំកាតព្វកិច្ចយ៉ាងហោចណាស់៩ឆ្នាំ។ នៅក្នុងសកលលោកទាំងមូល ក្នុងចំណោមប្រទេសចំនួន ៥ មានប្រទេសជាង ១ តែប៉ុណ្ណោះដែលធានាឱ្យមានការអប់រំដោយមិនគិតថ្លៃ និងជាកាតព្វកិច្ចរយៈពេល ១២ ឆ្នាំ។ ការធានាបែបនេះច្រើនកើតមានឡើងនៅអាមេរិចឡាទីន និងការីបៀន (ប្រទេស ៤៧ ភាគរយ) និងតំបន់ខៅខាស៊ុស និងអាស៊ីកណ្តាល (ប្រទេស ៣៨ ភាគរយ)។ ខណៈពេលដែលពុំមានប្រទេសចំណូលទាបណាមួយធ្វើការកំណត់បែបនេះឡើយ។




គោលដៅ ៤.២

# ការអប់រំកុមារតូច

ពាក់ព័ន្ធនឹងការអប់រំកុមារតូចវិញ មានប្រទេសត្រឹមតែ ១ ភាគ ៣ តែប៉ុណ្ណោះ ដែលបានចែងនៅក្នុងច្បាប់ពីការផ្តល់សេវាអប់រំកុមារតូចយ៉ាងហោចណាស់ឱ្យបានមួយឆ្នាំ ប្រទេសចំនួន ២១ ភាគរយកំណត់ការអប់រំកុមារតូច ជាការអប់រំកាតព្វកិច្ច និង ១៧ ភាគរយកំណត់ការអប់រំកុមារតូច ជាការអប់រំដែលត្រូវផ្តល់ដោយមិនគិតថ្លៃ និងជាកាតព្វកិច្ចសម្រាប់រយៈពេលមួយឆ្នាំ។

បើទោះបីជាបែបនេះក៏ដោយ នៅក្នុងឆ្នាំ ២០១៥ កុមារដែលមានអាយុក្រោមអាយុចូលរៀននៅបឋមសិក្សាមួយឆ្នាំ៦៩ភាគរយបានចូលរៀនក្នុងកម្មវិធីសិក្សាដែលមានការរៀបចំត្រឹមត្រូវដែលនេះគឺជាសូចនាករសកលដំបូងសម្រាប់ចំណុចដៅ ៤.២។ ភាគរយនៃតំបន់ដែលមានចាប់ពី ៩៥ ភាគរយនៅអឺរ៉ុប និងអាមេរិចភាគខាងជើង អាមេរិចឡាទីន និង ការីបៀន រហូតដល់ ៤២ ភាគរយនៅអាហ្វ្រិចសាប់សាហារ៉ា។ អត្រាចុះឈ្មោះចូលរៀនរបស់កុមារតូចមានការកើនឡើងនៅតាមបណ្តាប្រទេសជាច្រើន ចាប់តាំងពីឆ្នាំ ២០០០ មក **(រូបភាពទី ៩)**។

នៅក្នុងប្រទេសជាច្រើនលើសកលលោក ឱកាសអប់រំកុមារតូចត្រូវបានបែងចែកមិនស្មើគ្នាឡើយ។ ក្នុងចំណោមប្រទេសដែលមានចំណូលទាប និងចំណូលមធ្យមចំនួន ៥២ ចន្លោះពីឆ្នាំ ២០១០ ដល់ ២០១៥ មានកុមារអាយុ ៣ ទៅ ៤ ឆ្នាំត្រឹមតែ ២ នាក់មកពីគ្រួសារក្រីក្រជាងគេលំដាប់ទី ៥ ប៉ុណ្ណោះដែលបានចូលរៀនក្នុងកម្មវិធីអប់រំកុមារតូច ដែលមានការរៀបចំត្រឹមត្រូវ សម្រាប់រៀងរាល់កុមារ ១០ នាក់មកពីគ្រួសារដែលមានជីវភាពធូធារជាងគេលំដាប់ទី ៥។ ក្នុងប្រទេសសែប៊ី និងនីហ្សេរីយ៉ាវិញ អត្រាចូលរៀនគឺ ៨០ ភាគរយសម្រាប់កុមារមកពីគ្រួសារដែលមានជីវភាពធូរជាជាងគេ និងត្រឹមតែជាង ១០ ភាគរយប៉ុណ្ណោះសម្រាប់គ្រួសារដែលមានជីវភាពក្រីក្រជាងគេ។

**រូបភាពទី ៩៖**

ការចូលរួមក្នុងការអប់រំកុមារតូច កើនឡើងយ៉ាងឆាប់រហ័សក្នុងប្រទេសជាច្រើន

អត្រាចូលរួមក្នុងកម្មវិធីសិក្សាដែលមានការរៀបចំត្រឹមត្រូវ (មុនអាយុចូលរៀនផ្លូវការនៅបឋមសិក្សាមួយឆ្នាំ) ប្រទេសមួយចំនួន ២០០០ - ២០១៥




Source: UIS database.

គម្លាតនៃអត្រាចូលរៀនរវាងអ្នកនៅជនបទ និងទីប្រជុំជនលើសពី ៤០ ភាគរយចំណុចនៅប្រទេសទុយណេស៊ី និងទើមិនីស្តាន ខណៈពេលដែលគម្លាតនេះស្ទើរតែគ្មាន ឬមានច្រើនបន្តិចសម្រាប់កុមារជនបទនៅក្នុងប្រទេសបង់ក្លាដេស ចាម៉ៃកា ម៉ិចស៊ិច ប៉ាឡេស្ទីន សាន់លូស្យាំតូម៉េនិងព្រីនស៊ីប៉េ និងថៃ។

សូចនាករសកលទី ២ មានគោលបំណងផ្តោតតែលើការអភិវឌ្ឍកុមារតូច ប៉ុន្តែមានការយល់ឃើញខុសៗគ្នាអំពីអ្វីដែលគួរវាស់វែង ពាក់ព័ន្ធនឹងសុខភាព ស្ថានភាពចិត្តសង្គម និងការរៀនសូត្ររបស់កុមារតូច។ បើតាមសន្ទស្សន៍អភិវឌ្ឍកុមារតូចរបស់យូនីសេហ្វដែលជាប្រភពទិន្នន័យដ៏សំខាន់មានកុមារអាយុពី៣៦ដល់ ៥៩ ខែតិចជាង ២ ភាគ ៣ តែប៉ុណ្ណោះដែលត្រូវបានចាត់ទុកថាមានការអភិវឌ្ឍទៅត្រឹមត្រូវទៅ តាមដំណាក់កាលនៃការអភិវឌ្ឍរបស់កុមារតូច នៅតាមបណ្តាប្រទេសនានា ដូចជាសាធារណរដ្ឋកុងហ្គោ ម៉ារីតានៀ និងនេប៉ាល់ជាដើម។ បច្ចុប្បន្ននេះកំពុងមានកិច្ចខិតខំប្រឹងប្រែងជាច្រើន ដើម្បីបន្តកែសម្រួលវិធីសាស្ត្រនេះប្រើប្រាស់សម្រាប់ធ្វើការវាស់វែងការអភិវឌ្ឍកុមារតូចបែបប្រយោល។

បរិយាកាសក្នុងផ្ទះមានឥទ្ធិពលយ៉ាងធំធេងលើការអភិវឌ្ឍកុមារតូច។ នៅក្នុងប្រទេសដែលមានទិន្នន័យជិតពាក់កណ្តាល ក្នុងចំណោមកុមារអាយុពី ៣៦ ដល់ ៥៩ ខែទាំងអស់ មានកុមារ ១ ភាគ ៤ ដែលរស់នៅក្នុងគ្រួសារដែលអ្នកផ្តល់ការថែទាំពុំបានចូលរួមក្នុងសកម្មភាពចាប់ពី ៤ ឡើងទៅ ដើម្បីលើកកម្ពស់ការរៀនសូត្រ និងការត្រៀមខ្លួនចូលរៀនរបស់កុមារទាំងនេះ ដូចជា ការអាន ឬការមើលសៀវភៅរូបភាព ការច្រៀងចំរៀង ការរាំ ឬការគូសរូបជាដើម។ គ្រួសារដែលមានជីវភាពក្រីក្របំផុត កាន់តែមិនសូវធ្វើសកម្មភាពទាំងនេះទៅទៀត បើធៀបនឹងគ្រួសារដែលមានជីវភាពធូរជាជាងគេ។



គោលដៅ ៤.៣

## ការអប់រំបច្ចេកទេស វិជ្ជាជីវៈ ការអប់រំកម្រិតឧត្តមសិក្សានិងការអប់រំមនុស្សពេញវ័យ

សូចនាករសកលសម្រាប់ចំណុចដៅ ៤.៣ គឺអត្រាចូលរួមរបស់យុវជន និងមនុស្សពេញវ័យ ក្នុងការអប់រំបណ្តុះបណ្តាលក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ។ការអង្កេតកម្លាំងពលកម្មគឺជាប្រភពទិន្នន័យសក្តានុពលមួយ។ឧទាហរណ៍ ការអង្កេតកម្លាំងពលកម្មធ្វើឡើងដោយសហភាពអឺរ៉ុប ដែលគ្របដណ្តប់លើការចូលរួមក្នុងការអប់រំបណ្តុះបណ្តាលក្នុងប្រព័ន្ធផង និងក្រៅប្រព័ន្ធផង បង្ហាញថាស្ត្រី និងយុវជនច្រើនចូលរួមក្នុងកម្មវិធីអប់រំបណ្តុះបណ្តាលទាំងនេះ។ ការរៀបចំការអង្កេតកម្លាំងពលកម្ម ដែលធ្វើឡើងនៅតាមបណ្តាប្រទេសផ្សេងទៀតក្នុងពិភពលោក ចាំបាច់ត្រូវតែប្រើប្រាស់ម៉ូឌុលរួមគ្នាមួយ ផ្តោតលើការអប់រំក្នុងប្រព័ន្ធផង និងក្រៅប្រព័ន្ធផង ទើបគេអាចប្រៀបធៀបទិន្នន័យរវាងប្រទេសមួយ និងប្រទេសមួយបាន ដើម្បីឱ្យការអង្កេតបែបនេះមានលក្ខណៈពេញលេញ។

ក្នុងឆ្នាំ ២០១៥ សិស្សមធ្យមសិក្សា ៦០ លាននាក់ទូទាំងពិភពលោក បានចុះឈ្មោះចូលរៀន ក្នុងកម្មវិធីអប់រំបច្ចេកទេសវិជ្ជាជីវៈ ដែលចំនួននេះស្មើនឹង ១០ ភាគរយនៃសិស្សដែលរៀននៅមធ្យមសិក្សាសរុប ភាគច្រើននៅកម្រិតមធ្យមសិក្សាទុតិយភូមិ។ ចាប់តាំងពីឆ្នាំ ២០០០ មក អត្រានេះមានការប្រែប្រួលតិចតួចតែប៉ុណ្ណោះនៅក្នុងតំបន់ភាគច្រើន បើទោះបីជាការចូលរួមក្នុងកម្មវិធីអប់រំប្រភេទនេះ មានការកើនឡើងនូវតំបន់ ខៅខាស៊ុស និងអាស៊ីកណ្ដាល ប៉ុន្តែបានថយចុះមកនូវតំបន់ប៉ាស៊ីហ្វិចយ៉ាងណាក៏ដោយ។ ការអប់រំបច្ចេកទេសវិជ្ជាជីវៈទទួលបានសិស្សប្រុសចុះឈ្មោះចូលរៀនលើសលុប ខណៈពេលដែលចំនួនសិស្សស្រីចុះឈ្មោះចូលរៀនមានត្រឹមតែ ៤៣ ភាគរយតែប៉ុណ្ណោះ។

> “ក្នុងឆ្នាំ ២០១៥ មានសិស្សមធ្យមសិក្សាចំនួន ៦០ លាននាក់ទូទាំងពិភពលោក បានចុះឈ្មោះចូលរៀន នៅក្នុងកម្មវិធីអប់រំបច្ចេកទេស និងវិជ្ជាជីវៈ និង ២១៣ លាននាក់ចុះឈ្មោះចូលរៀន ក្នុងកម្មវិធីអប់រំកម្រិតឧត្តមសិក្សា។”

ក្នុងឆ្នាំ ២០១៥ សិស្សចំនួន ២១៣ លាននាក់បានចុះឈ្មោះចូលរៀនក្នុងកម្មវិធីអប់រំកម្រិតឧត្តមសិក្សា។ចាប់តាំងពីឆ្នាំ២០០០មកអត្រាសរុបនៃការសិក្សាមានការកើនឡើងជិត៣០ភាគរយចំណុចនៅតាមបណ្ដាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់ពី ១៧ ភាគរយ ដល់ ៤៦ ភាគរយ។ ប៉ុន្តែកំណើននៃការចុះឈ្មោះចូលរៀននៅតំបន់ខៅខាស៊ុសនិងអាស៊ីភាគកណ្ដាលនិងអាហ្វ្រិចសាប់សាហារ៉ាបែរជានៅទ្រឹងទៅវិញ។ ភាគរយនៃការចុះឈ្មោះចូលរៀននៅតាមសាលាឯកជនក៏មានការកើនឡើងផងដែរ។

ចំនួនស្ត្រីដែលបានចុះឈ្មោះចូលរៀននៅកម្រិតឧត្តមសិក្សា កើនឡើងលើសពីចំនួនបុរស ដោយតំបន់អាហ្វ្រិចសាប់សាហារ៉ា គឺជាតំបន់តែមួយគត់មានស្ត្រីចុះឈ្មោះចូលរៀនតិចជាងបុរស។ បើទោះបីជាយ៉ាងណាក៏ដោយចំនួនស្ត្រីដែលរៀនចប់មុខជំនាញវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា នៅមានចំនួនតិចជាងចំនួនបុរស។

គេអាចប្រើប្រាស់ការអង្កេតនៅតាមគ្រួសារ ដើម្បីបង្ហាញឱ្យឃើញពីគម្លាតនៃការចូលរួម និងការបញ្ចប់ការអប់រំក្រោយកម្រិតមធ្យមសិក្សា។ ការប៉ាន់ប្រមាណថ្មីៗដែលធ្វើឡើង សម្រាប់របាយការណ៍នេះបង្ហាញពីអត្រាចូលរៀនរបស់និស្សិតអាយុ ១៨ ទៅ ២២ ឆ្នាំ ថាមានការថយចុះមកពីក្រុមប្រជាជនដែលមានជីវភាពធូរធាជាងគេកម្រិតទី៥នៅតាមបណ្ដាប្រទេសដែលមានចំណូលទាបនិងចំណូលមធ្យមប៉ុន្តែអត្រានេះគៀកទៅរកសូន្យក្នុងចំណោមនិស្សិតមកពីក្រុមដែលមានជីវភាពក្រីក្រជាងគេកម្រិតទី៥។នៅប្រទេសសាលវ៉ាឌ័រ ៥១ ភាគរយនៃនិស្សិតមកពីក្រុមប្រជាជនដែលមានជីវភាពធូរធាជាងគេកម្រិតទី ៥ និងតិចជាង ២ ភាគរយនៃនិស្សិតដែលមកពីក្រុមប្រជាពលរដ្ឋ ដែលមានជីវភាពក្រីក្រជាងគេ បានចូលរៀនក្នុងកម្មវិធីអប់រំ ក្រោយមធ្យមសិក្សាក្នុងទម្រង់ណាមួយ ខណៈពេលដែលតួលេខនៅក្នុងប្រទេសម៉ុងហ្គោលីវិញ គឺ ៦៧ ភាគរយ និង ៣ ភាគរយ បែបនេះបង្ហាញថា ប្រទេសដែលមានចំណូលមធ្យមជាច្រើន ត្រូវអនុវត្តគោលនយោបាយដើម្បីបង្កភាពងាយស្រួលឱ្យមានការចូលរួមក្នុងកម្មវិធីអប់រំក្រោយមធ្យមសិក្សាដែលនេះជាសកម្មភាពដែលចាំបាច់ត្រូវធ្វើបន្ទាន់ (**រូបភាពទី ១០**)។

មានមនុស្សពេញវ័យក្នុងភាគរយមួយខ្ពស់ ដែលពុំបានបញ្ចប់ការអប់រំកម្រិតបឋមសិក្សានៅតាមបណ្តាប្រទេសដែលមានចំណូលទាប និងចំណូលមធ្យម។ បើទោះបីយ៉ាងនេះក៏ដោយ ពួកគេមិនទំនងជាត្រឡប់ទៅរៀននៅតាមសាលាបឋមសិក្សា ដើម្បីបញ្ចប់ការអប់រំកម្រិតមូលដ្ឋានឡើយ។ ក្នុងប្រទេសកេនយ៉ា ក្នុងចំណោមមនុស្សពេញវ័យ២ នាក់មានតែម្នាក់ប៉ុណ្ណោះដែលរៀនចប់សាលាបឋមសិក្សាប៉ុន្តែភាគរយនៃមនុស្សពេញវ័យដែលបានចុះឈ្មោះចូលរៀននៅសាលាបឋមសិក្សាមានត្រឹមតែ៣ភាគរយប៉ុណ្ណោះ។ស្ថិតិនេះពុំបានបង្ហាញលំអិតពីការបន្តការអប់រំនៅខាងក្រៅប្រព័ន្ធរបស់រដ្ឋឡើយ។

**រូបភាពទី ១០៖**

ប្រជាពលរដ្ឋដែលមានជីវភាពក្រីក្រជាងគេ ស្ទើរតែពុំមានឱកាសទទួលបានការអប់រំក្រោយមធ្យមសិក្សានៅតាមបណ្តាប្រទេសដែលមានចំណូលទាប និងចំណូលមធ្យម។

អត្រានៃការចូលរៀនក្នុងកម្មវិធីអប់រំក្រោយមធ្យមសិក្សា បែងចែកទៅតាមទ្រព្យសម្បត្តិក្នុងប្រទេសមួយចំនួន ២០១០ - ២០១៥




ប្រភព៖ ការគណនារបស់ក្រុមរៀបចំរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកល ដោយប្រើប្រាស់ទិន្នន័យដែលបានពីការអង្កេតតាមគ្រួសារជាមូលដ្ឋាន

# បំណិនសម្រាប់ការងារ

គោលដៅ ៤.៤

ការកំណត់ដឹងពីជំនាញការងារដែលនៅតែបន្តមានភាពពាក់ព័ន្ធក្នុងគ្រប់បរិបទទាំងអស់គឺជាការងារស្មុគស្មាញ ដូច្នេះក្របខ័ណ្ឌពិនិត្យតាមដានសម្រាប់ចំណុចដៅ ៤.៤ នេះផ្តោតសំខាន់លើបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ និងបំណិនឌីជីថលតែប៉ុណ្ណោះ។ ការផ្តោតការយកចិត្តទុកដាក់លើលទ្ធផលពាក់ព័ន្ធនឹងជំនាញអ្វីមួយ អាចធ្វើឱ្យអ្នកតាក់តែងគោលនយោបាយ បង្វែរការយកចិត្តទុកដាក់ទៅប្រើប្រាស់វិធីផ្សេងទៅវិញ ដើម្បីសម្រេចលទ្ធផល។ ទាំងនេះជាបញ្ហាដែលតែងតែបានរកឃើញនៅខាងក្រៅប្រព័ន្ធអប់រំក្នុងប្រព័ន្ធ។ ការវាយតម្លៃលើការទទួលបានជំនាញអាចធ្វើឡើងដោយផ្ទាល់ ប៉ុន្តែត្រូវការចំណាយច្រើន ឬអាចធ្វើឡើងដោយប្រយោល ឧទាហរណ៍តាមរយៈទិន្នន័យអង្កេតតាមក្នុងប្រទេសជាដើម។ ការប្រៀបធៀបការវាស់វែងដោយផ្ទាល់ និងដោយប្រយោល ដែលប្រើប្រាស់ទិន្នន័យ Eurostat និងលទ្ធផលនៃកម្មវិធីវាយតម្លៃអន្តរជាតិលើសមត្ថភាពរបស់មនុស្សពេញវ័យ (PIAAC) របស់OECDបានបង្ហាញថាការវាស់វែងទាំង២ប្រភេទនេះមានទំនាក់ទំនងជាវិជ្ជមានជាមួយគ្នាទៅវិញទៅមក បើទោះបីជាទំនាក់ទំនងទៅវិញទៅមកបែបនេះ មានកម្រិតកាន់តែខ្ពស់សម្រាប់ជំនាញនៅកម្រិតទាបយ៉ាងណាក៏ដោយ។

បើតាមទិន្នន័យសូចនាករសកលនៅតាមបណ្តាប្រទេសដែលមានចំណូលទាប និងចំណូលមធ្យម មនុស្សពេញវ័យមិនអាចធ្វើបាន សូម្បីតែកិច្ចការកុំព្យូទ័រងាយៗមួយចំនួន។ឧទាហរណ៍ នៅប្រទេសស៊ូដង់ និងហ្ស៊ីបាវេ មានមនុស្សពេញវ័យតែ ៤ ភាគរយប៉ុណ្ណោះដែលអាចចម្លង (copy and paste ) ឯកសារនានាបាន **(រូបភាពទី ១១)**។

ពាក់ព័ន្ធនឹងជំនាញកម្រិតខ្ពស់ជាងនេះ គម្លាតរវាងប្រទេសមួយ និងប្រទេសមួយទៀត មានកម្រិតខ្ពស់។ក្នុងសហភាពអឺរ៉ុប មនុស្សពេញវ័យនៅប្រទេសប៊ុលហ្គារី ១ ភាគរយ អាចសរសេរកម្មវិធីតាមកុំព្យូទ័របាន បើធៀបនឹង ១៤ ភាគរយនៅក្នុងប្រទេសដាណឺម៉ាក។ គម្លាតយេនឌ័រក៏មានកម្រិតខ្ពស់ផងដែរ។ នៅប្រទេសឆេកឈា និង ហុងហ្គ្រីក្នុងចំណោមបុរស ១០០ នាក់ ដែលមានជំនាញសរសេរកម្មវិធីនេះ មានស្ត្រី ២៥ នាក់។ ប្រទេសមួយចំនួនតូចសម្រេចបាននូវយុគភាព សូម្បីតែសម្រាប់ជំនាញងាយៗ៖ ក្នុងប្រទេសអ៊ីតាលី អាល្លឺម៉ង់ ហុល្លង់ មានស្ត្រីប្រមាណជា ៧៥ នាក់ រៀងរាល់បុរស ១០០ នាក់ ដែលអាចប្រើប្រាស់រូបមន្តពីជគណិតជាមូលដ្ឋានក្នុងតារាងទិន្នន័យបាន។

**រូបភាពទី ១១៖**

ចំណេះដឹងពីជំនាញ ICT នៅមានកម្រិតទាបខ្លាំងនៅតាមបណ្តាប្រទេសដែលមានចំណូលទាប និងចំណូលមធ្យម អត្រានៃការចូលរៀនក្នុងកម្មវិធីអប់រំក្រោយមធ្យមសិក្សា បែងចែកទៅតាមទ្រព្យសម្បត្តិក្នុងប្រទេសមួយចំនួន ២០១០ - ២០១៥




ប្រភព៖ មូលដ្ឋានទិន្នន័យនៃសហព័ន្ធទូរគមនាគមន៍អន្តរជាតិ

**គោលដៅ ៤.៥**

# សមធម៌

របៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាព គូសបញ្ជាក់ពីភាពចាំបាច់ក្នុងការពិនិត្យតាមដានសមធម៌ទៅតាមលក្ខណៈរបស់បុគ្គលម្នាក់ៗ ជាតុចូល និងលទ្ធផលនៃកម្រិតនៃការអប់រំ។

ជាមធ្យម ពិភពលោកទាំងមូលបានសម្រេចទៅតាមចំណុចដៅ យុគភាពយេនឌ័រនៅគ្រប់កម្រិតទាំងអស់នៃការអប់រំ លើកលែងតែកម្រិតឧត្តមសិក្សា។ ប៉ុន្តែនេះមិនមែនជាការពិតសម្រាប់គ្រប់តំបន់ទាំងអស់ និងគ្រប់ក្រុមចំណូលតាមប្រទេសនីមួយៗ ឬនៅកម្រិតប្រទេសនីមួយៗឡើយ។ មានប្រទេសតែ ៦៦ ភាគរយ តែប៉ុណ្ណោះដែលសម្រេចបានយុគភាពយេនឌ័រ ក្នុងការអប់រំកម្រិតបឋមសិក្សា ៤៥ ភាគរយសម្រាប់ការអប់រំមធ្យមសិក្សាបឋមភូមិ និង ២៥ ភាគរយសម្រាប់ការអប់រំមធ្យមសិក្សាទុតិយភូមិ។

គម្លាតយេនឌ័រក្នុងលទ្ធផលនៃការសិក្សា ជារឿយៗ បង្ហាញឱ្យឃើញពីនិន្នាការដែលគេមិនបានរំពឹងទុកជាមុន តាមមុខវិជ្ជាមួយចំនួន ពីពេលមួយទៅពេលមួយទៀត។ ឧទាហរណ៍ នៅតាមបណ្តាប្រទេសដែលមានចំនូលទាប និងចំណូលមធ្យមមួយចំនួន នៅអាមេរិចឡាទីន និងតំបន់ការីប៊ៀន និងអាហ្វ្រិចសាប់សាហារ៉ា សិស្សស្រីទទួលបានលទ្ធផលមិនជាល្អប្រសើរឡើយសម្រាប់មុខវិជ្ជាគណិតវិទ្យា នៅពេលដែលពួកគេបញ្ចប់ការអប់រំកម្រិតបឋមសិក្សា។ នៅកម្រិតមធ្យមសិក្សាបឋមភូមិវិញ បើគិតជាមធ្យម ប្រទេសនានាហាក់បីដូចជាសម្រេចបានយុគភាពយេនឌ័រក្នុងលទ្ធផលនៃការសិក្សា បើទោះបីជាប្រទេសទាំងនេះប្រើប្រាស់ការវាយតម្លៃការរៀនសូត្រខុសៗគ្នាយ៉ាងណាក៏ដោយ។

ចំនួនស្ត្រីដែលកាន់មុខតំណែងជាអ្នកគ្រប់គ្រងក្នុងវិស័យអប់រំ នៅមានភាគរយតិចតួចនៅឡើយ។ នៅក្នុងប្រទេសជប៉ុន មានគ្រូបង្រៀនសាលាមធ្យមសិក្សាបឋមភូមិជាស្ត្រីត្រឹមតែ ៣៩ ភាគរយប៉ុណ្ណោះ និងមាននាយកសាលាតែ ៦ ភាគរយប៉ុណ្ណោះដែលជាស្ត្រី។ នៅក្នុងករណីដែលមានទិន្នន័យសម្រាប់កម្រិតផ្សេងៗគ្នា ភាគរយស្ត្រីដែលកាន់តួនាទីជាអ្នកដឹកនាំ មានការថយចុះ នៅពេលដែលកម្រិតនៃមុខតំណែងដឹកនាំនេះ មានការកើនឡើង។ នៅប្រទេសអូទ្រីស នាយកសាលាបឋមសិក្សា ៧៩ ភាគរយជាស្ត្រី បើធៀបនឹងតួលេខត្រឹមតែ ៣២ ភាគរយប៉ុណ្ណោះ សម្រាប់មុខតំណែងជានាយកសាលាមធ្យមសិក្សាបឋមភូមិ។

**រូបភាពទី ១២៖**

ប្រទេសនានាកាន់តែសម្រេចបានយុគភាពយេនឌ័រ ប៉ុន្តែបញ្ហាប្រឈមនៅតែមានជាពិសេសនៅកម្រិតអប់រំឧត្តមសិក្សា
ភាគរយនៃប្រទេសបែងចែកទៅតាមកម្រិតសន្ទស្សន៍យុគភាពយេនឌ័រនៃអត្រាប្រមូលនៃការសិក្សា បែងចែកទៅតាមកម្រិតនៃការអប់រំ ២០០០ និង ២០១៥




ប្រភព៖ ប្រព័ន្ធទិន្នន័យ UIS

ទីតាំង និងទ្រព្យធនគឺជាកត្តាសំខាន់ៗចំនួន ២ ដែលទាមទារឱ្យមានការពិនិត្យតាមដានឱ្យបានហ្មត់ចត់បន្ថែមទៀត។ ចន្លោះពីឆ្នាំ ២០១០ ដល់ ២០១៥ សម្រាប់រាល់ក្មេងជំទង់ ៧៥ នាក់ក្នុងតំបន់ជនបទដែលបានបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិមានក្មេងជំទង់នៅតំបន់ប្រជុំជន១០០នាក់ដែលបានបញ្ចប់ការសិក្សានៅកម្រិតនេះ។ សន្ទស្សន៍យុគភាពពុំមានភាពល្អប្រសើរសម្រាប់ប្រជាជនក្រីក្រឡើយ។ នៅក្នុងសកលលោកទាំងមូល សម្រាប់រៀងរាល់សិស្ស ១០០ នាក់ ដែលមកពីគ្រួសារដែលមានជីវភាពធូរធាជាងគេ ដែលបានបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ មានតែសិស្ស ៦១ នាក់ប៉ុណ្ណោះ ដែលមកពីក្រុមដែលមានជីវភាពក្រីក្រជាងគេកម្រិតទី ៥ ដែលបានបញ្ចប់ការសិក្សានៅកម្រិតនេះ។ តួលេខដូចគ្នានេះគឺ ៥៤ នាក់សម្រាប់រៀងរាល់ ១០០ នាក់ក្នុងប្រទេសដែលមានចំណូលមធ្យមកម្រិតទាប និង ១៤ នាក់សម្រាប់រៀងរាល់ ១០០ នាក់ក្នុងប្រទេសដែលមានចំណូលទាប។ ខណៈពេលដែលអត្រាបញ្ចប់ការសិក្សាជាសកលគឺ ៦៩ ភាគរយ មានសិស្សប្រុសដែលមានជីវភាពក្រីក្រជាងគេត្រឹមតែ ១២ ភាគរយ និងសិស្សស្រីដែលមានជីវភាពក្រីក្រជាងគេត្រឹមតែ ៨ ភាគរយប៉ុណ្ណោះ ដែលបានបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាបឋមភូមិ។

> "មានមនុស្សប្រមាណជា២៥០លាននាក់ត្រូវបានផាត់ចេញ ដោយសារតែការរៀបចំការអង្កេត និងមានមនុស្សប្រមាណជា ១០០ លាននាក់ ទៀតពុំត្រូវបានគ្របដណ្ដប់ក្នុងការអង្កេតនេះឡើយ។"

លើសពីនេះ ការអង្កេតតាមផ្ទះពុំបានក្ដោបលើក្រុមប្រជាពលរដ្ឋដែលងាយរងគ្រោះជាច្រើននាក់ ដូចជាពលករតាមរដូវ ជនដែលគ្មានផ្ទះសំបែង ជនភៀសខ្លួន និងប្រជាជនដែលរស់នៅក្នុងតំបន់ជំនួយជាដើម។មានការប៉ាន់ប្រមាណថាមានប្រជាជនប្រមាណជា២៥០លាននាក់ទូទាំងសកលលោកទាំងមូលដែលត្រូវបានផាត់ចេញ ដោយសារតែរៀបចំការអង្កេត និងមាន ១០០ លាននាក់ទៀតពុំត្រូវបានបញ្ចូលនៅក្នុងការអង្កេតនេះឡើយ ដូចជាអ្នកដែលរស់នៅតំបន់អណាធិបតេយ្យជាដើម។

ភាសាគឺជាលក្ខណៈមួយដែលគេមិនងាយស្រួលយកមកធ្វើការប្រៀបធៀបរវាងប្រទេសមួយ និងប្រទេសមួយឡើយ ប៉ុន្តែវាមានឥទ្ធិពលយ៉ាងធំធេងលើសមធម៌។ការបង្រៀនដោយប្រើប្រាស់ភាសាទី១របស់សិស្សក្នុងរយៈពេលយ៉ាងហោចណាស់ ៦ ឆ្នាំ អាចជួយបង្កើនលទ្ធផលសិក្សារបស់សិស្ស។ ការពិនិត្យឡើងវិញលើឯកសារគោលនយោបាយនៃប្រទេសចំនួន ២១ នៅអាហ្វ្រិចភាគខាងកើត និងភាគខាងត្បូង បង្ហាញថាប្រទេសភាគច្រើនមានគោលនយោបាយអប់រំ ២ ភាសាអន្តរកាលសម្រាប់ថ្នាក់ដំបូងៗ ដែលកំណត់ពីការបង្រៀនភាសាក្នុងមូលដ្ឋានមួយ ឬច្រើន រហូតដល់ថ្នាក់ទី ៤ ឬទី ៥។ ប៉ុន្តែមិនមែនគោលនយោបាយទាំងអស់សុទ្ធតែត្រូវបានគេអនុវត្តឡើយ ដោយសារកង្វះធនធាន ឬការប្រឆាំងតបតពីតួអង្គសំខាន់ៗ ដូចជាគ្រូ និងមាតាបិតាសិស្សជាដើម។

ការវិភាគធំថ្មី ដែលធ្វើឡើងសម្រាប់រៀបចំរបាយការណ៍នេះ បានបញ្ចូលស្ថិតិប្រជាជនលក្ខណៈប្រជាសាស្ត្រ ភាសា និងគោលនយោបាយភាសាក្នុងវិស័យអប់រំ ដើម្បីធ្វើការចាត់ចំណាត់ថ្នាក់ប្រទេសនៅអាស៊ីប៉ែកភាគខាងកើត និងអាស៊ីអាគ្នេយ៍ ចំនួន ១១ ទៅតាមភាគរយសិស្សដែលនិយាយភាសានៅផ្ទះដូចគ្នានឹងភាសាដែលត្រូវបានប្រើប្រាស់សម្រាប់បង្រៀនពួកគេដែរ។ ការវិភាគនេះ ប៉ាន់ប្រមាណថានៅប្រទេសប្រ៊ុយណេ

ដារូសាឡឹម និងឥណ្ឌូនេស៊ី មានកុមារតិចជាង ២៥ ភាគរយ ដែលអាចទទួលបានការអប់រំដោយប្រើប្រាស់ភាសាកំណើតរបស់ពួកគេ ខណៈពេលដែលនៅក្នុងប្រទេសវៀតណាមវិញ មានកុមាររហូតដល់ ៩០ ភាគរយ ដែលទទួលបានការអប់រំ ដោយប្រើប្រាស់ភាសាដែលពួកគេនិយាយនៅផ្ទះ។

ការវាយតម្លៃការរៀនសូត្រប្រៀបធៀបរវាងប្រទេសមួយ និងប្រទេសមួយ ក៏អាចជួយឱ្យយើងដឹងពីបញ្ហាភាសានេះផងដែរ។ ឧទាហរណ៍ ការសិក្សាពីនិន្នាការរៀនមុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្ត្រជាអន្តរជាតិ (TIMSS) ២០១៥បង្ហាញថាសិស្សរៀនថ្នាក់ទី ៤ ៧៨ភាគរយនៅក្នុងប្រទេសដែលបានចូលរួមក្នុងការសិក្សានេះ ស្ទើរតែជានិច្ចជាកាលនិយាយភាសា ដែលប្រើប្រាស់សម្រាប់ការធ្វើតេស្តនៅផ្ទះរបស់ពួកគេដែរ។ ពាក់ព័ន្ធនឹងពិការភាពវិញ មានបញ្ហាប្រឈមចំនួន២ដែលត្រូវដោះស្រាយ នោះគឺការវាយតម្លៃប្រេវ៉ាឡង់ពិការភាពរបស់ប្រជាពលរដ្ឋ និងការបាត់បង់ឱកាសទទួលបានការអប់រំដែលពាក់ព័ន្ធនូវបញ្ហាពិការភាព។ ក្នុងការអង្កេតប្រជាសាស្ត្រ និងសុខភាពដែលធ្វើឡើងក្នុងប្រទេសចំនួន ២ អត្រាពិការភាពដែលត្រូវបានគេប៉ាន់ប្រមាណមានភាពខុសគ្នាឆ្ងាយ (២,១ ភាគរយនៅកម្ពុជា និង ៩,៧ ភាគរយនៅម៉ាឌីវ) ហើយភាពខុសគ្នាបែបនេះក៏ត្រូវបានឆ្លុះបញ្ចាំងក្នុងការប៉ាន់ប្រមាណដោយឡែកមួយទៀតអំពីផលប៉ះពាល់ ដែលពិការភាពមានលើការរៀនសូត្ររបស់សិស្សនៅតាមសាលារៀនផងដែរ។នៅប្រទេសម៉ាឌីវអត្រាចូលរៀនកម្រិតបឋមសិក្សាគឺ៨៥ភាគរយសម្រាប់សិស្សពិការ និង ៩៤ ភាគរយសម្រាប់សិស្សមិនពិការ ខណៈពេលដែលនៅកម្ពុជាវិញ អត្រាចូលរៀនរបស់សិស្សពិការគឺ ៤៣ ភាគរយ និងអត្រាចូលរៀនរបស់សិស្សមិនពិការគឺ ៩៣ ភាគរយ។

## ការកំណត់រកក្រុមដែលជួបការលំបាក មិនមែនចេះតែងាយស្រួលនោះទេ

ឯកសារគ្រឹះសម្រាប់គោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាពដែលមានចំណងជើងថា ផ្លាស់ប្តូរពិភពលោករបស់យើង៖ របៀបវារៈដើម្បីការអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០៣០ ទទួលស្គាល់ថា "មនុស្សគ្រប់រូបដោយមិនប្រកាន់ភេទ អាយុ ពណ៌ ជាតិសាសន៍ ឬជាតិពន្ធុ និងជនពិការ ជនចំណាកស្រុក ជនជាតិដើមភាគតិច" គួរអាចទទួលបានឱកាសរៀនសូត្រពេញមួយជីវិត។ ប្រទេសនានាត្រូវធ្វើការប្រមូលទិន្នន័យដើម្បីពិនិត្យតាមដានវឌ្ឍនភាពឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព និងគោរពទៅតាមអនុសញ្ញាសិទ្ធិមនុស្សដែលប្រទេសទាំងនោះបានផ្តល់សច្ចាប័ន។ ផ្ទុយទៅវិញក្នុងការអនុវត្តជាក់ស្តែង មានឧបសគ្គជាច្រើនដែលប្រទេសទាំងនេះជួបប្រទះ ហើយមានការព្រួយបារម្ភជាច្រើនដែលត្រូវបានលើកឡើងដោយក្រុមប្រជាជនដែលពុំមានឱកាស។ ការប្រមូលទិន្នន័យអំពីក្រុមដែលពុំមានឱកាស អាចធ្វើឱ្យប៉ះពាល់ដល់ភាពជាឯកជនរបស់ពួកគេ។ ក្នុងច្បាប់ស្តីពីការការពារទិន្នន័យ ព័ត៌មានស្តីពីជាតិពន្ធុ និងជំនឿសាសនា អាចត្រូវបានដាក់ចំណាត់ថ្នាក់ថាជាព័ត៌មានរសើប។ ប្រទេសមួយចំនួនដូចជាប្រទេសស៊ុយអែតជាដើម មិនធ្វើការប្រមូលទិន្នន័យអំពីជាតិពន្ធុឡើយ បើទោះបីជាពុំមានច្បាប់ហាមឃាត់យ៉ាងណាក៏ដោយ។ ប្រទេសដទៃទៀតហាមឃាត់មិនឱ្យប្រមូលទិន្នន័យកំណត់អត្តសញ្ញាណផ្ទាល់ខ្លួនរបស់បុគ្គលឡើយ ប៉ុន្តែអនុញ្ញាតឱ្យប្រមូលទិន្នន័យដែលរក្សាអនាមិកភាព។ជាង ១ភាគ៣នៃកម្រងសំណួរដែលប្រើប្រាស់ក្នុងជំរឿនពុំបានបញ្ចូលការធ្វើចំណាត់ថ្នាក់ជាតិពន្ធុក្នុងទម្រង់អ្វីមួយឡើយ។

ដោយសារតែទិន្នន័យជនជាតិភាគតិចត្រូវបានគេប្រើមិនត្រឹមត្រូវ ក្នុងការកំណត់រកក្រុមណាមួយ ក្រុមដែលពុំមានឱកាសខ្លួនឯង អាចនឹងមានការស្ទាក់ស្ទើរក្នុងការផ្តល់ទិន្នន័យទាំងនេះ ដោយសារភ័យខ្លាចទទួលរងការរើសអើងជនជាតិរ៉ូម៉ានៅអឺរ៉ុបជារឿយៗមិនជឿទុកចិត្តលើការធ្វើជំរឿនឡើយ។ជនពិការអាចមិនរាយការណ៍ថាខ្លួនឯងជាជនពិការឡើយ ដោយពួកគេភ័យខ្លាចទទួលការមាក់ងាយ។ លើសពីនេះ រដ្ឋាភិបាលអាចជៀសវាងមិនធ្វើការប្រមូលទិន្នន័យតែម្តង ដោយសារតែលទ្ធផលនឹងផ្តល់ការឆ្លុះបញ្ចាំងមិនល្អអំពីគោលនយោបាយរបស់ខ្លួន ឬបង្កើនភាពតានតឹងក្នុងចំណោមប្រជាពលរដ្ឋ។

ការវាស់វែង និងការប្រៀបធៀបការជួបការលំបាកមិនងាយស្រួលធ្វើឡើយ ដោយសារតែមានការកំណត់និយមន័យខុសៗគ្នានៃពិការភាព ជាតិពន្ធុ និងប្រភេទដទៃទៀត ដែលបង្ហាញពីការជួបការលំបាករបស់បុគ្គលម្នាក់ៗ។ ប្រភេទនិន្នន័យដែលត្រូវបានបែងចែកជាប្រភេទតូចៗដូចជា បែងចែកជាជាតិពន្ធុ និងជាតិសាសន៍ជាដើម តែងមានការវិវត្តន៍ទៅតាមលក្ខណៈសង្គម និងនយោបាយ ឬការវិវត្តន៍ផ្សេងទៀត ដែលធ្វើឱ្យគេពិបាកធ្វើការប្រៀបធៀប លទ្ធផលពីពេលមួយ និងពេលមួយទៀត។ បើទោះបីជាការកំណត់ពីការលំបាកដោយខ្លួនឯង មានប្រយោជន៍សម្រាប់ដោះស្រាយបញ្ហាក្រមសីលធម៌ក្នុងការប្រមូលទិន្នន័យយ៉ាងណាក៏ដោយបុគ្គលម្នាក់ៗអាចមិនរាយការណ៍ឱ្យបានសុក្រឹតពីការជួបការលំបាករបស់ខ្លួន។ការកំណត់ពីការលំបាកពីខាងក្រៅ ក៏អាចជាបញ្ហាផងដែរ ដោយសារតែវាអាស្រ័យទៅតាមការលំអៀងរបស់អ្នកដែលធ្វើការអង្កេត។



គោលដៅ ៤.៦

# ចំណេះដឹងអក្ខរកម្ម និងចំណេះដឹងលេខនពន្ធ

ចន្លោះពីឆ្នាំ ២០០០ ដល់ឆ្នាំ ២០១៥ អត្រាអក្ខរកម្មមនុស្សពេញវ័យបានកើនឡើងពី ៨១,៥ ភាគរយ ដល់ ៨៦ ភាគរយ បើទោះបីជាអត្រានេះនៅមានត្រឹមកម្រិត ៦៤ ភាគរយនៅអាហ្វ្រិចសាប់សាហារ៉ា និងក្រោម ៦០ ភាគរយនៅតាមបណ្តាប្រទេសចំណូលទាបយ៉ាងណាក៏ដោយ។ ចំនួនមនុស្សពេញវ័យដែលពុំមានបំណិនអក្ខរកម្ម បានថយចុះត្រឹម ៤ ភាគរយប៉ុណ្ណោះ មកនៅត្រឹម ៧៥៣ លាននាក់។

ផ្ទុយទៅវិញ ចំនួនយុវជនដែលពុំមានបំណិនអក្ខរកម្មបានថយចុះ ២៧ ភាគរយ។ បើទោះបីជាយ៉ាងណាក៏ដោយ នៅមានយុវជនជាង ១០០ លាននាក់ដែលពុំចេះអាន នៅក្នុងនោះក្នុងចំណោមយុវជនដែលពុំចេះអាន ៤ នាក់ មានជាង ១ នាក់ទៅហើយ ដែលស្ថិតនៅក្នុងអាហ្វ្រិចសាប់សាហារ៉ា និងប្រទេសដែលមានចំណូលទាប។

"មានយុវជនជាង ១០០ លាននាក់ដែលមិនចេះអាន។"

ការបង្រៀនដោយប្រើប្រាស់ភាសាខុសពីភាសាដែលប្រើនៅផ្ទះ គឺជាមូលហេតុដ៏សំខាន់មួយដែលនាំឱ្យមានការអភិវឌ្ឍបំណិនអក្ខរកម្មយឺតយ៉ាវនៅអាហ្វ្រិចសាប់សាហារ៉ា។ ការវិភាគថ្មីមួយដែលធ្វើឡើងសម្រាប់របាយការណ៍នេះបង្ហាញថានៅប្រទេសចំនួន ៣៦ ដែលស្ថិតក្នុងតំបន់នេះ ក្នុងចំណោមមនុស្សពេញវ័យដែលបានទទួលការអប់រំរយៈពេល ៥ ឆ្នាំ មានត្រឹមតែពាក់កណ្ដាលតែប៉ុណ្ណោះ ដែលអាចអានប្រយោគទាំងមូលដាច់បាន។ ប៉ុន្តែ ៦៩ ភាគរយនៃមនុស្សពេញវ័យដែលបានទទួលការអប់រំរយៈពេល ៥ ឆ្នាំ ដែលទទួលបានការបង្រៀនដោយប្រើប្រាស់ភាសាដែលពួកគេប្រើនៅផ្ទះ អាចអានប្រយោគមួយដាច់បាន បើធៀបនឹងត្រឹមតែ ៤១ ភាគរយនៃអ្នកដែលទទួលបានការអប់រំក្នុងប្រព័ន្ធ ដែលប្រើប្រាស់ភាសារបស់ប្រទេសដាក់នឹមអាណានិគម ឬប្រព័ន្ធអប់រំដែលប្រើប្រាស់ច្រើនភាសា។

បើទោះបីជាមានកិច្ចខិតខំប្រឹងប្រែងជាច្រើនដើម្បីជំនួសការវាស់វែងអក្ខរកម្មបែបប្រពៃណីដែលភាគច្រើនតម្រូវឱ្យអ្នកឆ្លើយតបរាយការណ៍ដោយខ្លួនឯង ជាមួយនឹងការវាយតម្លៃផ្ទាល់លើកម្រិតអក្ខរកម្ម ដែលចាំបាច់សម្រាប់វាយតម្លៃសូចនាករសកល សម្រាប់ចំណុចដៅ ៤.៦ យ៉ាងណាក៏ដោយ ក៏វិធីសាស្ត្រថ្មីនេះនៅពុំទាន់បានអនុវត្តឱ្យបានទូលំទូលាយនៅឡើយ លើកលែងតែក្នុងប្រទេសដែលមានចំណូលខ្ពស់មួយចំនួនតូចតែប៉ុណ្ណោះ។ មនុស្សពេញវ័យប្រមាណជា ១៩ ភាគរយនៅក្នុងប្រទេសដែលបានចូលរួមក្នុងការអង្កេត PIAAC របស់អង្គការ OECD ពុំបានសម្រេចកម្រិតស្ទាត់ជំនាញខាងអក្ខរកម្មដល់កម្រិតអប្បបរមាឡើយ។

វិសមភាពនៃភាពស្ទាត់ជំនាញខាងចំណេះដឹងអក្ខរកម្ម និងលេខ បែងចែកទៅតាមស្ថានភាពសង្គមសេដ្ឋកិច្ច ក៏កើតមានជាទូទៅផងដែរ។ ឧទាហរណ៍ នៅក្នុងប្រទេស OECD ដែលបានចូលរួមនៅក្នុងការអង្កេត PIAAC លទ្ធភាពដែលមនុស្សពេញវ័យមានកម្រិតស្ទាត់ជំនាញខាងចំណេះដឹងអំពីលេខ ទាបជាងកម្រិតអប្បបរមា សម្រាប់អ្នកដែលមានឪពុកម្ដាយពុំបានរៀនចប់កម្រិតមធ្យមសិក្សាទុតិយភូមិ ខ្ពស់ជាងកម្រិតអ្នកដែលយ៉ាងហោចណាស់មានឪពុកម្ដាយម្នាក់ បានរៀនចប់កម្រិតឧត្ដមសិក្សាខ្ពស់ជាង ៣ ដង (៣៣ ភាគរយធៀបនឹង ១០ ភាគរយ)។ នៅសាធារណរដ្ឋឆេក និងស្លូវ៉ាគី ភាពខុសប្លែកគ្នានេះមានដល់ទៅ ១០ ដង (២៩ ភាគរយធៀបនឹង ៣ ភាគរយ)។

គម្លាតប្រភេទមួយចំនួនមានការប្រែប្រួលជាបន្តបន្ទាប់។បើធៀបនឹងការអង្កេតPISAនៅអាយុ១៥ឆ្នាំ និងការអង្កេត PIAAC ដែលធ្វើឡើងនៅ ១២ ឆ្នាំក្រោយមក បានបង្ហាញពីការផ្លាស់ប្ដូរគួរឱ្យភ្ញាក់ផ្អើល នៅមជ្ឈិមវ័យ។ ប្រទេសចំនួន ២០ ដែលត្រូវបានយកមកធ្វើការប្រៀបធៀប មាន ៧៥% ដែលគម្លាតសង្គមសេដ្ឋកិច្ចមានការកើនឡើង ហើយគម្លាតនេះប្រមូលផ្ដុំក្នុងចំណោមអ្នកដែលទទួលបានពិន្ទុទាប ពេលនៅអាយុ ១៥ ឆ្នាំ។ ផ្ទុយទៅវិញគម្លាតយេនឌ័រហាក់បីដូចជាស្ទើរតែលែងមាន។ ប៉ុន្តែការអង្កេត PIAAC បង្ហាញឱ្យឃើញពីគម្លាតយេនឌ័រទាប នៅអាយុ ១៦ ឆ្នាំ ដែលបង្ហាញថា ការប្រែប្រួលនេះអាចកើតឡើងដោយសារតែរបៀបធ្វើការអង្កេតទាំង ២ នេះ **(រូបភាពទី ១៣)**។

**រូបភាពទី ១៣៖**

ខណៈពេលដែលគម្លាតអក្ខរកម្មទៅតាមកត្តាសង្គមសេដ្ឋកិច្ចនៅអាយុ ១៥ ឆ្នាំ មានការកើនឡើងនៅរយៈពេល ១២ ឆ្នាំ បន្ទាប់ គម្លាតយេនឌ័រលែងមានតទៅទៀត

គម្លាតបន្ទុកអក្ខរកម្មស្តង់ដា និងអាយុ ១៥ ឆ្នាំ បើតាមការវាយតម្លៃ PISA និងនៅអាយុ ២៦ ដល់ ២៨ ឆ្នាំ បើតាមការវាយតម្លៃ PIAAC ប្រទេសមួយចំនួន ២០០០ - ២០០៣ រហូតដល់ ២០១១ - ២០១៤




ប្រភព៖ Borgonovi et al. (2017).




គោលដៅ ៤.៧

# ការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងភាពជាពលរដ្ឋសកល

យន្តការរាយការណ៍ពីការអនុវត្តអនុសាសន៍ឆ្នាំ ១៩៧៤ ពាក់ព័ន្ធនឹងការអប់រំដើម្បីការយល់ដឹងជាអន្តរជាតិ កិច្ចសហប្រតិបត្តិការសន្តិភាព និងការអប់រំពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ត្រូវបានស្នើឡើងជាមធ្យោបាយសម្រាប់ពិនិត្យតាមដានវឌ្ឍនភាព ក្នុងការសម្រេចសូចនាករសកលសម្រាប់ចំណុចដៅ ៤.៧។ ប៉ុន្តែស្វ័យវាយតម្លៃលើការអនុវត្តគោលនយោបាយ អាចពុំមានលក្ខណៈសត្យានុម័ត អាចជឿទុកចិត្តបានឬមានភាពសុក្រឹតគ្រប់គ្រាន់សម្រាប់គោលបំណងគោលនយោបាយឡើយហើយស្វ័យតម្លៃបែបនេះអាចនឹងមិនគ្រប់គ្រាន់ដើម្បីកំណត់ឱ្យដឹងថា តើមានការអនុវត្តគោលនយោបាយឬអត់នោះ។ យូណេស្កូទទួលស្គាល់ពីភាពចាំបាច់ក្នុងការបន្តកែសម្រួលគោលការណ៍ណែនាំនានាសម្រាប់រៀបចំរបាយការណ៍ជាតិដើម្បីឱ្យគោលការណ៍ណែនាំទាំងនេះ អាចបំពេញទៅតាមលក្ខខណ្ឌសម្រាប់ពិនិត្យតាមដានសូចនាករសកលនេះ។

ក្នុងកំឡុងពេលពិគ្រោះយោបល់លើកទី ៥ លើអនុសាសន៍ឆ្នាំ ១៩៧៤ នេះ ប្រទេសជាង ៨៥ ភាគរយ បានរាយការណ៍ថា ខ្លួនបានបញ្ចូលសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានទៅក្នុងគោលនយោបាយអប់រំ និងកម្មវិធីសិក្សា ប៉ុន្តែមានប្រទេសត្រឹមតែ ៥១ ភាគរយតែប៉ុណ្ណោះដែលបានបញ្ចូលការអប់រំដើម្បីការអភិវឌ្ឍន៍ប្រកបដោយចីរភាពទៅក្នុងគោលនយោបាយ និង ៣៣ ភាគរយបានបញ្ចូលទៅក្នុងកម្មវិធីសិក្សា។ មានប្រទេសប្រមាណជាពាក់កណ្ដាល បានលើកឡើងពីប្រធានបទសន្តិភាព ភាពអហិង្សា សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ក្នុងការអប់រំគ្រូ ប្រទេស ១៦ ភាគរយបានធ្វើការពិភាក្សាអំពីភាពចំរុះផ្នែកវប្បធម៌ និងការយល់អធ្យាស្រ័យឱ្យគ្នាទៅវិញទៅមក និងមានត្រឹមតែ ៧ ភាគរយប៉ុណ្ណោះដែលបញ្ចូលការអប់រំដើម្បីការអភិវឌ្ឍន៍ប្រកបដោយចីរភាព (រូបភាពទី ១៤)។

នៅតាមបណ្ដាប្រទេសជាច្រើន គ្រូទទួលបានការបំពាក់បំប៉នតិចតួចតែប៉ុណ្ណោះ ដើម្បីបង្រៀនប្រធានបទដែលពាក់ព័ន្ធនឹងចំណុចដៅ៤.៧។ កម្មវិធីអប់រំគ្រូបានចាប់ផ្ដើមកែសម្រួលដើម្បីបញ្ចូលប្រធានបទទាំងនេះ ប៉ុន្តែកិច្ចខិតខំប្រឹងប្រែងនានានៅមានលក្ខណៈបែកខ្ញែកពីគ្នានៅឡើយ។ ប្រទេសអៀរឡង់ និងចាម៉ៃកា បានសម្រេចនូវវឌ្ឍនភាពមួយចំនួន ក្នុងការបញ្ចូលប្រធានបទពាក់ព័ន្ធជាមួយនឹងការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងភាពជាប្រជាពលរដ្ឋសកល ទៅក្នុងការអប់រំគ្រូដំបូងៗ។ ការបន្តអភិវឌ្ឍវិជ្ជាជីវៈគឺជាឧបករណ៍ដែលគេនិយមប្រើប្រាស់ សម្រាប់ជួយគាំទ្រដល់គ្រូ ក៏ប៉ុន្តែកម្រមានការអនុវត្តក្នុងលក្ខណៈជាប្រព័ន្ធណាស់។

**រូបភាពទី ១៤៖**

មានប្រទេសតែ ៧ ភាគរយប៉ុណ្ណោះដែលបានបញ្ចូលការអប់រំ ដើម្បីប្រកបដោយចីរភាពទៅក្នុងការអប់រំគ្រូ

ភាគរយនៃប្រទេសដែលរាយការណ៍ទៅកាន់កិច្ចពិគ្រោះយោបល់លើកទី ៥ ស្ដីពីអនុសាសន៍ឆ្នាំ ១៩៧៤ ដែលបានបញ្ចូលវាក្យស័ព្ទមួយចំនួនទៅក្នុងគោលនយោបាយអប់រំ កម្មវិធីសិក្សា និងការអប់រំគ្រូ ឆ្នាំ ២០១២




ប្រភព៖ McEvoy (២០១៧)។

កម្មវិធីអប់រំផ្លូវភេទតាមសាលារៀនដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ផ្តោតលើទំនាក់ទំនងអំណាចរវាងយេនឌ័រមួយ និងយេនឌ័រមួយទៀត នាំឱ្យមានការកាត់បន្ថយអត្រាឆ្លងជំងឺកាមរោគ និងការមានផ្ទៃពោះដោយគេមិនចង់បាន ៤ ដង។ ការពិនិត្យឡើងវិញឆ្នាំ ២០១៥ លើប្រទេសចំនួន ៤៨ បានរកឃើញថា មានប្រទេស ៨០ ភាគរយមានគោលនយោបាយគាំទ្រឱ្យមានការអប់រំផ្លូវភេទដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ បើទោះបីជាគោលនយោបាយទាំងនេះពុំត្រូវបានអនុវត្តឱ្យបានជាប់លាប់ យ៉ាងណាក៏ដោយ។ ការសិក្សាក្នុងប្រទេសហ្គាណា និងកេនយ៉ា បានរកឃើញថាមានការបង្រៀនដោយប្រើប្រាស់ព័ត៌មានមិនពេញលេញនិងព័ត៌មានដែលមិនសុក្រឹត នៅពេលខ្លះ។

នៅពុំមានការឯកភាពគ្នាជារួមអំពីលទ្ធផល ដែលគួរសម្រេចចេញពីការអប់រំដើម្បីការអភិវឌ្ឍន៍ប្រកបដោយចីរភាព និងការអប់រំភាពជាពលរដ្ឋសកលនោះឡើយ។ ការវាស់វែងចំណេះដឹងវិទ្យាសាស្ត្រអំពីការប្រែប្រួលអាកាសធាតុ និងភពផែនដីគឺជាជម្រើសមួយដែលអាចយកមកអនុវត្តបាន។ ការវាយតម្លៃ PISA ឆ្នាំ ២០១៥ បានបង្ហាញថា មានយុវជនអាយុ ១៥ ឆ្នាំ ២៥ ភាគរយនៅប្រទេស OECD សម្រេចបានលទ្ធផលទាបជាងកម្រិតអប្បបរមា ខាងមុខវិជ្ជា "ផែនដី និងអវកាស"។ ការវាយតម្លៃ TIMSS បានបង្ហាញថា ចំណេះដឹងអំពីផែនដីវិទ្យាក្នុងចំណោមសិស្សបឋមសិក្សាមានការកើនឡើងចន្លោះពីឆ្នាំ២០១១ និង២០១៥នៅក្នុងប្រទេសចំនួន ១៥ ថយចុះក្នុងប្រទេសចំនួន ៩ និងមិនបង្ហាញពីការផ្លាស់ប្តូរអ្វីសោះក្នុងប្រទេសចំនួន ១៦។

ឧបករណ៍ដែលគេធ្លាប់ប្រើប្រាស់កន្លងមក សម្រាប់វាយតម្លៃកម្រិតចំណេះដឹងរបស់សិស្ស តែក្នុងការអប់រំកម្រិតមូលដ្ឋានប៉ុណ្ណោះ។ ការសាកល្បងធ្វើតេស្តចំណេះដឹងអំពីការអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ ២០១៤ - ២០១៦ បានធ្វើការវាយតម្លៃចំណេះដឹងអំពីការអភិវឌ្ឍន៍ប្រកបដោយចីរភាព ក្នុងចំណោមនិស្សិតដែលរៀននៅតាមសកលវិទ្យាល័យនិងមនុស្សពេញវ័យ។អ្នកចូលរួមឆ្លើយសំណួរបានត្រឹមត្រូវចំនួន៥៤ភាគរយនៅក្នុងការវាយតម្លៃបែបប្រឡង និង ៦០ ភាគរយក្នុងការវាយតម្លៃលើការរៀនសូត្រ (នៅតាមផ្ទះ និងពុំមានការត្រួតពិនិត្យ)។ ពួកគេឆ្លើយបានល្អសម្រាប់សំណួរពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និងសេដ្ឋកិច្ច បើធៀបជាមួយនឹងសំណួរពាក់ព័ន្ធនឹងបញ្ហាបរិស្ថាន។

## សៀវភៅសិក្សាមានសារៈសំខាន់សម្រាប់សម្រេចនូវរបៀបវារៈ ភាពចំរុះ ការយល់អធ្យាស្រ័យ និងសន្តិភាព

សៀវភៅសិក្សាបង្ហាញមិនត្រឹមតែពីចំណេះដឹងមុខវិជ្ជាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង ពីគុណតម្លៃសង្គម អត្តសញ្ញាណ នយោបាយ ប្រវត្តិសាស្ត្រ និងការយល់ដឹងពីពិភពលោកថែមទៀតផង។ តែទោះជាយ៉ាងណាក៏ដោយ នៅតាមបណ្តាប្រទេសជាច្រើន សៀវភៅសិក្សានៅពុំទាន់បានផ្តោតការយកចិត្តទុកដាក់ឱ្យបានគ្រប់គ្រាន់លើបញ្ញត្តិសំខាន់ៗ ដែលពាក់ព័ន្ធនឹងភាពចុះសម្រុងក្នុងសង្គម ស្ថិរភាពនយោបាយ និងអនាគតរបស់ភពផែនដីឡើយ។

ការអប់រំភាពជាពលរដ្ឋសកល មានគោលបំណងបណ្តុះការយល់ដឹងអំពីគោលការណ៍នានា ដូចជាសិទ្ធិមនុស្ស ប្រជាធិបតេយ្យ និងយុត្តិធម៌សង្គម។ ក្នុងឆ្នាំ ២០០០ - ២០០៨ ២៥ ភាគរយ នៃសៀវភៅសិក្សា

ទូទាំងសកលលោក បានលើកឡើងពីភាពជាប្រជាពលរដ្ឋសកល ធៀបនឹង ១៣ ភាគរយក្នុងទសវត្ស ៨០។ ដើម្បីជួយកសាងសង្គមមួយឱ្យមានសុខសន្តិភាព សៀវភៅសិក្សាគួរពិភាក្សាពីការបង្ការជម្លោះ ការដោះស្រាយជម្លោះ និងការផ្សះផ្សារ។ មានសៀវភៅសិក្សាតែ ៥ ភាគរយតែប៉ុណ្ណោះ ដែលបានបញ្ចូលខ្លឹមសារពាក់ព័ន្ធនឹងប្រធានបទនេះ។ សៀវភៅសិក្សាជាច្រើននៅអួតអាងពីកម្លាំងយោធា និងការធ្វើសង្គ្រាមនៅឡើយ។

> "ក្នុងឆ្នាំ ២០០០ - ២០០៨ សៀវភៅសិក្សាទូទាំងសកលលោក ២៥ ភាគរយបានលើកឡើងពីភាពជាប្រជាពលរដ្ឋសកល ធៀបនឹង ១៣ ភាគរយក្នុងទសវត្ស ៨០។"

ការលើកឡើងពីភាពចំរុះ គឺជាប្រធានបទដែលគេកម្រលើកឡើង។ ពីឆ្នាំ ២០០០ ដល់ ២០១១ក្នុងចំណោមសៀវភៅសិក្សាមុខវិជ្ជាសិក្សាសង្គមនៅកម្រិតមធ្យមសិក្សាចំនួន៤មានតែ១ប៉ុណ្ណោះដែលបានលើកឡើងពីក្រុមភាគតិចខាងជាតិពន្ធុ វប្បធម៌ សាសនា និងភាសា។ ការលើកឡើងពីសិទ្ធិរបស់ជនអន្តោប្រវេសន៍ និងជនភៀសខ្លួន មានការកើនឡើង ប៉ុន្តែសៀវភៅសិក្សាមួយចំនួននៅបញ្ចូលរូបភាពបង្កប់ផ្នត់គំនិត ពីការធ្វើចំណាកស្រុក និងអ្នកធ្វើចំណាកស្រុកនៅឡើយ។

ពីឆ្នាំ២០០០ដល់ឆ្នាំ២០១១សៀវភៅសិក្សា៣៧ភាគរយបានលើកឡើងពីសិទ្ធិរបស់ស្ត្រីកើនឡើងពី ១៥ ភាគរយក្នុងឆ្នាំ ១៩៤៦ - ១៩៦៩ ខណៈពេលដែលការបង្ហាញពីការរើសអើងលើស្ត្រី កើនឡើងពី ១៦ ភាគរយ ដល់ ៣៨ ភាគរយ។ ប៉ុន្តែសៀវភៅសិក្សាជាច្រើននៅតែបន្តបង្កប់សារ ដែលនាំឱ្យមានវិសមភាពយេនឌ័រ។ សៀវភៅសិក្សាជាច្រើនពុំបានបញ្ចូលស្ត្រី ឬបង្ហាញពីស្ត្រីបំពេញតួនាទីបែបប្រពៃណីចាញ់ប្រៀបអ្នកដទៃ។

តួអង្គពាក់ព័ន្ធនៅកម្រិតអន្តរជាតិនិងតំបន់បានជួយផ្តល់ការគាំទ្រដល់កំណែទម្រង់នានា។យូណេស្កូបានដាក់ចេញនូវបទដ្ឋាន និងស្តង់ដា និងបានផ្តល់ការគាំទ្រដល់ប្រទេសនានា ក្នុងការធ្វើឱ្យមានការផ្លាស់ប្តូរ។ នៅតាមប្រទេសដែលផុតពីជម្លោះ គំនិតផ្តួចផ្តើមយុត្តិធម៌ក្នុងដំណាក់កាលអន្តរកាល ជម្រុញឱ្យមានការផ្លាស់ប្តូរ ដូចជានៅក្នុងប្រទេសពេរូ ជាដើម។ ក្នុងប្រទេសនេះ គណៈកម្មការស្វែងរកការពិត បានលើកទឹកចិត្តឱ្យមានការរៀបចំសៀវភៅសិក្សា ដែលជម្រុញឱ្យមានការគោរពភាពចំរុះរបស់មនុស្ស និងសិទ្ធិមនុស្ស។ តួអង្គសង្គមស៊ីវិលអាចរៀបចំជាមូលដ្ឋានសម្រាប់អនុវត្តគម្រោងដែលទទួលបានការគាំទ្រពីរដ្ឋាភិបាល ប៉ុន្តែតួអង្គនយោបាយនៅតែមានតួនាទីសំខាន់ ក្នុងការជម្រុញលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរ។

គោលដៅ ៤.ក

# សម្ភាររូបវ័ន្តដែលបម្រើដល់ការអប់រំ និងបរិយាកាសនៃការរៀនសូត្រ

ការវាយតម្លៃលើហេដ្ឋារចនាសម្ព័ន្ធសាលារៀន មានលក្ខណៈស្មុគស្មាញ ដោយសារតែកត្តាពាក់ព័ន្ធជាច្រើន។ ប៉ុន្តែការអង្កេតនៅតាមសាលារៀនបានរកឃើញថា ស្ថានភាពហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ជារឿយៗបង្កផលប៉ះពាល់ ដល់ការបង្រៀននៅតាមប្រទេសទាំងអស់ មិនថាប្រទេសទាំងនោះមានចំណូលកម្រិតណានោះឡើយ ជាពិសេសនៅតាមសាលារៀន ដែលជួបការលំបាកផ្នែកសង្គម និងសេដ្ឋកិច្ច។ ការសិក្សាថ្នាក់តំបន់ ដើម្បីធ្វើការប្រៀបធៀប និងពន្យល់ពីភាពខុសប្លែកគ្នារវាងប្រទេសមួយ និងប្រទេសមួយទៀត នៅអាមេរិចឡាទីនឆ្នាំ ២០១៣ បានបង្ហាញថា ក្នុងចំណោមសិស្សថ្នាក់ទី ៣ មកពីគ្រួសារដែលមានជីវភាពធូរជាជាងគេ មានសិស្សជាង ៤ ភាគ ៥ រៀននៅសាលាដែលមានសម្ភាររូបវ័ន្ត ទឹក និងអនាម័យគ្រប់គ្រាន់ ប៉ុន្តែសម្រាប់សិស្សដែលមកពីគ្រួសារមានជីវភាពក្រីក្រជាងគេវិញ មានត្រឹមតែ ១ ភាគ ៣ តែប៉ុណ្ណោះដែលទទួលបានសម្ភាររូបវ័ន្តបែបនេះ។

សាលាបឋមសិក្សានៅតាមប្រទេសក្រីក្រជាច្រើនពុំមានអគ្គិសនីប្រើប្រាស់ឡើយ។ នៅអាហ្វ្រិចសាប់សាហារ៉ា មានសាលាបឋមសិក្សាតែ ២២ ភាគរយតែប៉ុណ្ណោះដែលមានអគ្គិសនីប្រើប្រាស់។ លើសពីនេះ ក៏មានគម្លាតផ្នែកបច្ចេកវិទ្យា និងការប្រើប្រាស់អ៊ីនធឺណិតផងដែរ រវាងប្រទេសមួយ និងប្រទេសមួយទៀត និងរវាងតំបន់មួយនៅក្នុងប្រទេសតែមួយ ដោយសាលារៀននៅតំបន់ជនបទ ពុំមានសេវាទាំងនេះឡើយ បើធៀបនឹងសាលារៀនដែលនៅតាមតំបន់ប្រជុំជន (**រូបភាពទី ១៥**)។

ក្នុងចំណោមប្រទេសទាំង ១៤៨ មានប្រទេស ៧២ ដែលសិស្សនៅសាលាបឋមសិក្សាទទួលបានទឹកសម្រាប់ផឹក នៅក្រោម ៧៥ ភាគរយ។ ការមានសម្ភាររូបវ័ន្តអនាម័យកម្រិតមូលដ្ឋានប្រើប្រាស់ មានកម្រិតទាបជាង ៥០ ភាគរយ ក្នុងប្រទេសចំនួន ២៤ ក្នុងចំណោមប្រទេស ១៣៧ ដែលក្នុងនោះមាន ១៧ ប្រទេសស្ថិតនៅអាហ្វ្រិចសាប់សាហារ៉ា។

សិស្សពិការបន្តជួបឧបសគ្គជាច្រើន ដូចជា ខ្វះឧបករណ៍សម្រាប់ជួយដល់ចលនាបំលាស់ទី អគាររៀបចំពុំបានសមស្រប និងការពុំមានសម្ភារឧបទ្ទេស និងកម្មវិធីសិក្សាសមស្របសម្រាប់ពួកគេជាដើម។ នៅតាមប្រទេសមួយចំនួន ដូចជា សែប៊ី អាហ្វ្រិចខាងត្បូង និងតួគី ជាដើម មានសាលារៀនជាង ៣៥ ភាគរយ ដែលរងផលប៉ះពាល់ដល់សារការខ្វះធនធានទាំងនេះ។

**រូបភាពទី ១៥៖**

សាលារៀនជនបទមានលទ្ធភាពភ្ជាប់អ៊ីនធឺណិតប្រើប្រាស់បានតិចតួច

ភាគរយនៃសាលារៀនដែលមានកុំព្យូទ័រភ្ជាប់ជាមួយអ៊ីនធឺណិត បែងចែកទៅតាមទីតាំងទៅតាមប្រទេសមួយចំនួន ឆ្នាំ ២០១៥




ប្រភព៖ OECD ២០១៦

ចាប់តាំងពីឆ្នាំ ២០០៤ មក ការវាយប្រហារមកលើសាលារៀន បានកើនឡើងគួរឱ្យកត់សម្គាល់ ដែលបង្កផលប៉ះពាល់លើសលុបលើសាលារៀននៅអាស៊ីខាងត្បូង អាហ្វ្រិចខាងជើង និងអាស៊ីខាងលិច។ ចន្លោះពីឆ្នាំ ២០០៥ ដល់ឆ្នាំ ២០១៥ កងកម្លាំងយោធា និងក្រុមប្រដាប់អាវុធនៅក្នុងប្រទេសយ៉ាងហោចណាស់ ២៦ បានប្រើប្រាស់គ្រឹះស្ថានអប់រំ សម្រាប់គោលបំណងយោធារបស់ខ្លួន។

## ការឆ្លើយតបចំពោះករណីអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រតាមសាលារៀន មានសារៈសំខាន់យ៉ាងខ្លាំង

ការឆ្លើយតបចំពោះករណីអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រដែលកើតមាននៅតាមសាលារៀន ទាមទារឱ្យមានការដាក់ចេញនូវច្បាប់ និងគោលនយោបាយដែលមានប្រសិទ្ធភាព ការរៀបចំកម្មវិធីសិក្សា និងឯកសារសិក្សាឱ្យបានសមស្រប ការបណ្តុះបណ្តាល និងការផ្តល់ការគាំទ្រដល់អ្នកអប់រំ និងភាពជាដៃគូរវាងវិស័យអប់រំ និងតួអង្គដទៃទៀត ក៏ដូចជាការពិនិត្យតាមដាន និងការវាយតម្លៃ។

ប្រទេសនានាចាំបាច់ត្រូវអនុម័តលើក្របខ័ណ្ឌច្បាប់ ដែលផ្តល់ការការពារដល់សិស្សពីអំពើហិង្សាដែលប្រព្រឹត្ត រវាងមនុស្សពេញវ័យ និងកុមារ និងអំពើហិង្សាដែលមិត្តភក្តិប្រព្រឹត្តលើគ្នា និងជម្រុញឱ្យមានគណនេយ្យភាព។ ប្រទេសឈីលី ហ្វីជី ហ្វាំងឡង់ ពេរូ និងស៊ុយអែត គឺជាប្រទេសដែលបានដាក់ឱ្យអនុវត្តនូវច្បាប់ប្រឆាំងអំពើហិង្សានៅតាមសាលារៀន។ ក្រមសីលធម៌សម្រាប់គ្រូ ចាំបាច់ត្រូវតែលើកឡើងឱ្យបានច្បាស់លាស់ពីអំពើហិង្សា និងការរំលោភបំពាននានា និងត្រូវចែងឱ្យបានច្បាស់ពីទោសបញ្ញត្តិនានា ស្របទៅតាមក្របខ័ណ្ឌច្បាប់។

ការមានច្បាប់ និងគោលនយោបាយ មិនមែនមានន័យថាសុទ្ធតែមានការអនុវត្តនោះទេ។ ប្រទេសជាច្រើនខកខានពុំបានអនុវត្តគោលនយោបាយវិភាជន៍ធនធានឱ្យបានគ្រប់គ្រាន់ឬធានាឱ្យមានការគាំទ្រពីតួអង្គសំខាន់ៗដូចជា នគរបាល ជាដើម។ ជារឿយៗ តួអង្គនៅតាមមូលដ្ឋានខ្វះការយល់ដឹងអំពីសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន។

យន្តការរាយការណ៍ក៏ត្រូវអាចជឿទុកចិត្តបាន និងធានាការរក្សាការសម្ងាត់ដល់ជនរងគ្រោះផងដែរ។ អ្នកអប់រំគួរទទួលបានការបណ្តុះបណ្តាលពីរបៀបស្តាប់ ផ្តល់ការគាំទ្រ និងជួយឱ្យសិស្សធ្វើការរាយការណ៍ពីករណីនានា។ នៅប្រទេសម៉ាឡាវី ក្រោយពីបានទទួលការបណ្តុះបណ្តាលរួច ការយល់ដឹងរបស់គ្រូអំពីករណីបៀតបៀនផ្លូវភេទចំពោះក្មេងស្រីតាមសាលារៀនមានការកើនឡើងពី៣០ភាគរយរហូតទៅដល់៨០ភាគរយ និងករណីបៀតបៀនផ្លូវភេទចំពោះក្មេងប្រុសពី ២៦ ភាគរយ ទៅ ៦៤ ភាគរយ។ ទោះជាយ៉ាងណាក៏ដោយ បុគ្គលិកសាលារៀន បានទទួលបានការបំពាក់បំប៉នតិចតួចប៉ុណ្ណោះ ដើម្បីអនុវត្តវិធានការប្រឆាំងនឹងការបៀតបៀនផ្លូវភេទបែបនេះ។ នៅសហរដ្ឋអាមេរិច ក្នុងចំណោមសិស្សដែលជាអ្នកស្រលាញ់ភេទដូចគ្នា ដែលរាយការណ៍ពីករណីបំពារបំពានមកលើពួកគេ មានតិចជាង ១ ភាគ ៣ ប៉ុណ្ណោះដែលបាននិយាយថា បុគ្គលិកសាលារៀនបានឆ្លើយតបចំពោះបញ្ហានេះប្រកបដោយប្រសិទ្ធភាព។

ការអប់រំផ្លូវភេទដែលផ្តោតលើលក្ខណៈចំរុះនៃភេទនិងអត្តសញ្ញាណយេនឌ័រ/ការសម្តែងចេញយេនឌ័រ អាចធ្វើឱ្យបរិយាកាសក្នុងសាលារៀនកាន់តែមានភាពល្អប្រសើរជាងមុន ដូចជាក្នុងប្រទេសហុល្លង់ ជាដើម។ ជារឿយៗកម្មវិធីអប់រំភេទពុំបានផ្តោតការយកចិត្តទុកដាក់លើសពីសុខភាពផ្លូវភេទនិងបន្តពូជរហូតដល់លក្ខណៈចំរុះនៃយេនឌ័រឡើយ។

កម្មវិធីអប់រំដែលលើកកម្ពស់ឱ្យមានការឆ្លុះបញ្ចាំង ក្នុងចំណោមក្មេងប្រុស និងយុវជនអំពីឥរិយាបទ និងបទដ្ឋានយេនឌ័រ ដូចជានៅក្នុងប្រទេសឥណ្ឌាជាដើម បានសម្រេចនូវលទ្ធផលល្អប្រសើរច្រើន ក្នុងការបង្កើនការយល់ដឹង និងកែលំអឥរិយាបទនានា ក៏ដូចជាកាត់បន្ថយករណីអំពើហិង្សា។ សកម្មភាពក្រៅកម្មវិធីសិក្សា ដូចជា ក្លឹប និងការលេង និងការប្រគួតកីឡាតាមសាលារៀនជាដើម អាចបំពេញបន្ថែមដល់ការបង្រៀននៅតាមថ្នាក់រៀន ក្នុងការបញ្ជូនសារជាវិជ្ជមានអំពីយេនឌ័រ។

# អាហារូបករណ៍

គោលដៅ ៤.ខ

សូចនាករសកលអំពីអាហារូបករណ៍ប្រើប្រាស់ទិន្នន័យដែលបានពីកម្មវិធីផ្តល់ជំនួយ។ទិន្នន័យនេះពុំមានភាពពេញលេញឡើយ ដោយសារមូលហេតុជាច្រើន និងដោយសារតែកម្មវិធីផ្តល់ជំនួយរបស់អ្នកផ្តល់ជំនួយជាច្រើនពុំបានបញ្ចូលអាហារូបករណ៍ឡើយ។ ក្នុងចំណោមកម្មវិធីដែលបញ្ចូលអាហារូបករណ៍ ការចំណាយថវិកាមានការថយចុះពី ១,២ ពាន់លានដុល្លាក្នុងឆ្នាំ ២០១០ មកនៅ ១,១៥ ពាន់លានដុល្លាក្នុងឆ្នាំ២០១៥ឬ៤ភាគរយស្របគ្នាទៅនឹងការថយចុះនូវថវិកាជំនួយសម្រាប់វិស័យអប់រំទាំងមូល**(រូបភាពទី១៦)**។ ប្រទេសអូស្ត្រាលី(២៣ភាគរយ)បារាំង(១៤ភាគរយ)និងស្ថាប័នសហភាពអឺរ៉ុប(១៥ភាគរយ)គ្រប់ដណ្តប់លើជំនួយអាហារូបករណ៍ជាងពាក់កណ្តាល។ លើសពីនេះ អ្នកផ្តល់ជំនួយបានរាយការណ៍ពីចំណាយយ៉ាងច្រើនមកលើសិស្ស ដែលកំណើននេះកើនឡើងរហូតដល់ ១,៧៦ ពាន់លានដុល្លាក្នុងឆ្នាំ ២០១៥។

មានថវិកាអាហារូបករណ៍ប្រមាណជា៤២៣លានដុល្លា(៣៧ភាគរយ)ពុំអាចបែងចែកទៅឱ្យសិស្សពីប្រទេសណាមួយនោះឡើយ។ ក្នុងចំណោមថវិកាដែលនៅសល់ សិស្សមកពីប្រទេសដែលមានការអភិវឌ្ឍតិចតួចបានទទួល ១៥១ លានដុល្លា។

របាយការណ៍ពិនិត្យតាមការអប់រំជាសកលឆ្នាំ២០១៦ បានរាយការណ៍ថា ពុំមានប្រព័ន្ធសម្រាប់ពិនិត្យតាមដាន និងរាយការណ៍ ពីទិន្នន័យអាហារូបករណ៍ឡើយ ឬមានដែរតែពិបាកទទួលព័ត៌មាន ឬពុំបានព័ត៌មានឬប្រព័ន្ធទាំងនេះពុំបានប្រមូលព័ត៌មាន ដែលចាំបាច់សម្រាប់រាយការណ៍ពីចំណុចដៅ៤.ខ។ ការសិក្សាសាកល្បងលើប្រទេសចំនួន ៥ សម្រាប់របាយការណ៍នេះ បានវាយតម្លៃពីរបៀបប្រមូលទិន្នន័យ ដែលធ្វើឡើងដោយពីភ្នាក់ងារគ្រប់គ្រងកម្មវិធីអាហារូបករណ៍ចំនួន

> “កម្មវិធីសម្រាប់វាស់វែងអាហារូបករណ៍ដោយផ្ទាល់ តម្រូវឱ្យមានការខិតខំប្រឹងប្រែងជាសកល ដើម្បីរៀបចំទិន្នន័យឱ្យមានស្តង់ដាកសាងសមត្ថភាពនិងសម្របសម្រួលកិច្ចសហប្រតិបត្តិការ។”

៣ និងស្ថាប័នផ្តល់ជំនួយចំនួន ១ ក្នុងប្រទេសអូស្ត្រាលី កាណាដា បារាំង អាល្លឺម៉ង់ និងចក្រភពអង់គ្លេស។ ទិន្នន័យនេះហាក់បីដូចជាមាន បើទោះបីជាពុំមានការរាយការណ៍តាមបែបផែនមួយ ដែលជួយឱ្យគេអាចពិនិត្យតាមដានចំណុចដៅ ៤.ខ យ៉ាងណាក៏ដោយ។ កម្មវិធីសម្រាប់វាស់វែងអាហារូបករណ៍ដោយផ្ទាល់ តម្រូវឱ្យមានការខិតខំប្រឹងប្រែងជាសកល ដើម្បីធ្វើឱ្យយ៉ាងណាឱ្យទិន្នន័យនានាមានស្តង់ដាកសាងសមត្ថភាព និងសម្របសម្រួលកិច្ចសហប្រតិបត្តិការ ក្នុងចំណោមអ្នកគ្រប់គ្រងទិន្នន័យ។

**រូបភាពទី ១៦៖**

ការផ្តល់ជំនួយសម្រាប់អាហារូបករណ៍ បន្តនៅកម្រិតដដែលចាប់តាំងពីឆ្នាំ ២០១០ មក

ការទំលាក់ថវិកាសម្រាប់ជំនួយអភិវឌ្ឍន៍ផ្លូវការសម្រាប់អាហារូបករណ៍ និងចំណាយលើសិស្ស ២០១០ - ២០១៥




ប្រភព៖ ការវិភាគរបស់ក្រុមរៀបចំរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកល ផ្អែកទៅតាមទិន្នន័យនៃប្រព័ន្ធរាយការណ៍ព័ត៌មានរបស់ OECD-DAC Creditor។

គោលដៅ ៤.គ

# គ្រូ

ទិន្នន័យដែលបង្ហាញពីចំនួនគ្រូដែលបានទទួលការបណ្តុះបណ្តាលគរុកោសល្យកម្រិតអប្បបរមា ស្របតាមស្តង់ដារបស់ជាតិ នៅមានកម្រិតនៅឡើយ។ ទិន្នន័យដែលអាចរកបានបង្ហាញពីគ្រូក្នុងចំនួនដ៏ច្រើន ដែលទទួលបានការបណ្តុះបណ្តាលពុំបានគ្រប់គ្រាន់នៅតាមតំបន់ជាច្រើន។ ក្នុងសកលលោកទាំងមូល គ្រូបឋមសិក្សា ៨៦ ភាគរយ បានទទួលការបណ្តុះបណ្តាល។ ភាគរយនេះរឹតតែទាបទៅទៀតនៅអាស៊ីភាគខាងត្បូង (៧៧ ភាគរយ) ការីបៀន (៧០ ភាគរយ) និងអាហ្វ្រិចសាប់សាហារ៉ា (៦២ ភាគរយ)។

អ្វីដែលគួរឱ្យភ្ញាក់ផ្អើល ខណៈពេលដែលប្រទេសអាហ្វ្រិចសាប់សាហារ៉ាជាច្រើនមាននិន្នាការជាវិជ្ជមាន ពាក់ព័ន្ធនឹងចំនួនគ្រូដែលបានទទួលការបណ្តុះបណ្តាលនៅតាមបណ្តាប្រទេសមួយចំនួន ដូចជា ប្រទេសអេរីទ្រា ហ្គាណា និងនីហ្សេ ភាគរយគ្រូដែលបានទទួលការបណ្តុះបណ្តាល បែរជាថយចុះទៅវិញចាប់តាំងពីឆ្នាំ ២០០០ មក (**រូបភាពទី ១៧**)។

> “នៅក្នុងសកលលោកទាំងមូល គ្រូបឋមសិក្សា ៨៦ ភាគរយ បានទទួលការបណ្តុះបណ្តាល។”

ចំណុចដៅនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព បានលើកឡើងពី “គ្រូ” ដែល “មានគុណវុឌ្ឍិ” ខណៈពេលសូចនាករសកលលើកឡើងពីគ្រូដែល “បានទទួលការបណ្តុះបណ្តាល” ដែលនាំឱ្យមានការភាន់ច្រលំមួយចំនួន។ គ្រូដែលមានគុណវុឌ្ឍិ សំដៅលើគ្រូដែលទទួលបានគុណវុឌ្ឍិអប្បបរមា តាមរយៈការសិក្សា ខណៈពេលដែលគ្រូដែលបានទទួលការបណ្តុះបណ្តាល សំដៅលើគ្រូដែលបានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ។ នៅតាមបណ្តាប្រទេសមួយចំនួន គ្រូទាំង ២ ប្រភេទនេះមានលក្ខណៈខុសគ្នា ដោយសារតែប្រទេសទាំងនោះមានលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការត្រៀមរៀបចំគ្រូខុសពីគ្នា ដោយគម្លាតមានខ្ពស់បំផុតនៅតាមបណ្តាប្រទេសដែលមានចំណូលទាប និងប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។ ឧទាហរណ៍ ក្នុងប្រទេសចាម៉ៃកា គ្រូមធ្យមសិក្សា ១៥ ភាគរយ មានគុណវុឌ្ឍិ ខណៈពេលដែល ៨៥ ភាគរយទៀតបានទទួលការបណ្តុះបណ្តាល។

ការកំណត់និយមន័យគ្រូ “ដែលបានទទួលការបណ្តុះបណ្តាល” ដើម្បីឱ្យគេអាចយកទៅធ្វើការប្រៀបធៀបគ្នាបាន គឺជាការពិបាកមួយ ហើយប្រភេទអប់រំគ្រូដែលគេប្រើជាសកល មិនទំនងជាត្រូវបានបង្កើតឡើងឱ្យបានដូចៗគ្នាឡើយ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំទៅមុខទៀតនេះ។ ការអង្កេតប្រៀបធៀបរវាងប្រទេសមួយ និងប្រទេសមួយ អាចជាជម្រើសមួយទៀត ដោយសារតែការអង្កេតទាំងនេះកត់ត្រាព័ត៌មានអំពីលក្ខណៈរបស់គ្រូ។ ឧទាហរណ៍ការអង្កេត TIMSS បានបង្ហាញថា ភាគរយសិស្សនៅថ្នាក់ទី ៤ ដែលបង្រៀនដោយគ្រូ

គណិតវិទ្យាដែលមានគុណវុឌ្ឍិ និងបានទទួលការបណ្តុះបណ្តាល មានការថយចុះពី ៨៩ ភាគរយ ក្នុងឆ្នាំ ២០០៧ មក ៥៤ ភាគរយ ក្នុងឆ្នាំ ២០១៥ នៅប្រទេសកាហ្សាកស្ថាន ប៉ុន្តែភាគរយនេះមានការកើនឡើងពី ១៨ ភាគរយ ទៅ ៣៨ ភាគរយក្នុងប្រទេសដាណឺម៉ាកវិញ។

នៅទូទាំងសកលលោកទាំងមូល ផលធៀបសិស្ស/គ្រូ មានកម្រិតខ្ពស់នៅតាមបណ្តាប្រទេសក្រីក្រប៉ុន្តែចំនួនសិស្សបឋមសិក្សាក្នុងគ្រូម្នាក់បែរជាមានការថយចុះទៅវិញ ចាប់តាំងពីឆ្នាំ ២០០០ មក។

ព័ត៌មានអំពីបៀវត្សរ៍គ្រូ ការអភិវឌ្ឍវិជ្ជាជីវៈ អត្រាឈប់របស់គ្រូ គឺជាព័ត៌មានដែលកម្រនឹងអាចរកបាន។ នៅតាមបណ្តាប្រទេស OECD គ្រូទទួលបានបៀវត្សរ៍តិចជាងអ្នកធ្វើការផ្សេងទៀត ដែលមានគុណវុឌ្ឍិប្រហាក់ប្រហែលនឹងពួកគេដែរ។ នៅក្នុងការអង្កេត TALIS គ្រូមធ្យមសិក្សាបឋមភូមិប្រមាណជា ៨៨ភាគរយ បានចូលរួមក្នុងការអភិវឌ្ឍវិជ្ជាជីវៈកាលពីឆ្នាំ ២០១៣។

**រូបភាពទី ១៧៖**

នៅតាមបណ្តាប្រទេសអាហ្វ្រិចសាប់សាហារ៉ាមួយចំនួន ភាគរយគ្រូដែលបានទទួលការបណ្តុះបណ្តាល បានថយចុះ

ភាគរយគ្រូបឋមសិក្សាដែលបានទទួលការបណ្តុះបណ្តាលនៅប្រទេសអាហ្វ្រិចសាប់សាហារ៉ា មួយចំនួន ២០០០-២០១៥




ប្រភព៖ ទិន្នន័យ UIS។

# ការអប់រំ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដទៃទៀត

ការអប់រំគឺជាគន្លឹះដើម្បីសម្រេចលទ្ធផល ដែលត្រូវបានដាក់ចេញក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពជាច្រើន ដូចជាលទ្ធផលពាក់ព័ន្ធនឹងសុខភាព ទឹក និងអនាម័យ និងសន្តិសុខស្បៀងជាដើម។

## ការអប់រំអាចជួយទប់ស្កាត់ជំងឺមិនឆ្លង

គិតត្រឹមឆ្នាំ ២០១២ ជំងឺមិនឆ្លង ដូចជា ជំងឺមហារីក ទឹកនោមផ្អែម ជំងឺផ្លូវដង្ហើមរ៉ាំរ៉ៃ និងជំងឺសរសៃឈាមបេះដូង ជាមូលហេតុដែលនាំឱ្យមានការស្លាប់ប្រមាណជា ៦៨ ភាគរយ ក្នុងចំណោមករណីស្លាប់ទាំងអស់នៅទូទាំងសកលលោក ដែលករណីស្លាប់ដោយសារជំងឺនេះ ៣ ភាគ ៤ កើតឡើងនៅប្រទេសដែលមានចំណូលទាប និងចំណូលមធ្យម។ ការអប់រំអាចជួយធ្វើការផ្លាស់ប្តូរឥរិយាបទ ដើម្បីកាត់បន្ថយការកើតឡើងនូវជំងឺទាំងនេះ។

ការប្រើប្រាស់ថ្នាំជក់ ធ្វើឱ្យមានមនុស្សស្លាប់ ៦,៤ លានករណីក្នុងឆ្នាំ ២០១៥។ អ្នកដែលមានការអប់រំកាន់តែខ្ពស់ មិនសូវជាប្រើប្រាស់ថ្នាំជក់ឡើយ ទាំងក្នុងប្រទេសអ្នកមាន ទាំងក្នុងប្រទេសអ្នកក្រ។ ក្នុងប្រទេសដែលមានចំណូលមធ្យមកម្រិតទាប បុរសដែលពុំបានទទួលការអប់រំក្នុងប្រព័ន្ធ ទំនងជានឹងជក់បារីជាងបុរសដែលទទួលបានការអប់រំយ៉ាងហោចណាស់កម្រិតបឋមសិក្សា ចន្លោះពី ១,៧៥ ទៅ ៦,៥ ដង។ នៅសហរដ្ឋអាមេរិច អ្នកបោះបង់ចោលការសិក្សាពីវិទ្យាល័យ ទំនងជានឹងជក់បារីជាងអ្នកដែលបញ្ចប់ការសិក្សាពីមហាវិទ្យាល័យដល់ទៅ ៣ ដង។

ក្រៅតែពីការអប់រំក្នុងប្រព័ន្ធ យុទ្ធនាការអប់រំតាមរយៈប្រព័ន្ធផ្សព្វផ្សាយ ក៏អាចមានប្រសិទ្ធភាពក្នុងការកាត់បន្ថយការជក់បារីផងដែរ។ ប៉ុន្តែជារឿយៗយុទ្ធនាការបែបនេះ មានប្រសិទ្ធភាពតែសម្រាប់ប្រជាជនដែលមានឋានៈសង្គមសេដ្ឋកិច្ចខ្ពស់តែប៉ុណ្ណោះ ដូច្នេះយុទ្ធនាការនេះអាចបង្កើនវិសមភាពនៃប្រេវ៉ាឡង់នៃការជក់បារីទៅវិញ។ គេចាំបាច់ត្រូវរៀបចំយុទ្ធនាការបែបនេះឱ្យកាន់តែប្រសើរជាងមុន ដើម្បីផ្តោតឱ្យចំក្រុមដែលងាយរងគ្រោះ។

ប្រេវ៉ាឡង់នៃបញ្ហាធាត់ជ្រុលនៅទូទាំងសកលលោកទាំងមូល កើនឡើងទ្វេដងចន្លោះពីឆ្នាំ ១៩៨០ ដល់ឆ្នាំ ២០១៤។ ទំនាក់ទំនងរវាងការទទួលបានការអប់រំ និងបញ្ហាធាត់ជ្រុល អាស្រ័យទៅតាមកម្រិតនៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស និងប្រេវ៉ាឡង់ជារួមនៃបញ្ហាធាត់ជ្រុល។ នៅតាមបណ្តាប្រទេសដែលមានចំណូលទាប ដែលមានប្រេវ៉ាឡង់បញ្ហាធាត់ជ្រុលទាប ស្ត្រីដែលទទួលបានការអប់រំកាន់តែច្រើន កាន់តែធាត់ ខណៈពេលដែលនៅតាមបណ្តាប្រទេសដែលមានចំណូលខ្ពស់វិញ ការអប់រំកម្រិតឧត្តមសិក្សាមានទំនាក់ទំនងជាមួយនឹងលទ្ធភាពមានបញ្ហាធាត់ជ្រុលកាន់តែទាប។

ការអប់រំមាតាបិតាមានឥទ្ធិពលធំធេងលើបញ្ហាជាត់ជ្រុលរបស់កុមារ ដែលដូចករណីដែលរៀបរាប់ពីខាងដើមដែរអាស្រ័យទៅតាមកម្រិតនៃការអភិវឌ្ឍសេដ្ឋកិច្ច។កុមារដែលមានឪពុកម្តាយជាអ្នកទទួលបានការអប់រំ ងាយនឹងលើសទម្ងន់នៅក្នុងប្រទេសកេនយ៉ា ប៉ុន្តែមិនសូវជាលើសទម្ងន់ឡើយនៅប្រទេសប្រេស៊ីល។

ការលើកកម្ពស់អាហារូបត្ថម្ភ ឱ្យបានកាន់តែល្អប្រសើរនៅតាមសាលារៀន ជួយបង្រៀនពីទម្លាប់ល្អពេញមួយជីវិត។ក្នុងទីក្រុងSeinäjokiប្រទេសហ្វាំងឡង់កម្មវិធីបញ្ចូលសុខភាពទៅក្នុងគោលនយោបាយអប់រំបានជួយកាត់បន្ថយបញ្ហាជាត់ជ្រុលក្នុងចំណោមកុមារអាយុ ៥ ឆ្នាំ ពី ១៧ ភាគរយក្នុងឆ្នាំ ២០០៩ មកនៅ ១០ ភាគរយក្នុងឆ្នាំ ២០១៥។

## ការអប់រំជួយកសាងសមត្ថភាពអនុវត្តយុទ្ធសាស្ត្រនានា ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

ចាំបាច់ត្រូវមានអ្នកជំនាញដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ ដើម្បីសម្រេចចំណុចដៅនៅគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៣ នោះគឺគោលដៅលើកកម្ពស់សុខភាព។ អង្គការសុខភាពពិភពលោក បានប៉ាន់ប្រមាណថា ក្នុងឆ្នាំ ២០១៣ ពិភពលោកទាំងមូលខ្វះបុគ្គលិកថែទាំសុខភាព ១៧,៤ លាននាក់ ហើយបានព្យាករថាតួលេខនេះ នឹងនៅបន្តរហូតដល់ ១៤,៥ លាននាក់ក្នុងឆ្នាំ ២០៣០ ដែលបញ្ហាខ្វះអ្នកជំនាញទាំងនេះ រឹតតែអាក្រក់ទៅៗនៅតាមបណ្តាប្រទេសអាហ្វ្រិចសាប់សាហារ៉ា ឬប្រទេសក្រីក្រជាងគេ ដែលជាប្រទេសត្រូវការសេវាសុខភាពជាងគេផងដែរ។ ការបំលាស់ទីជាលក្ខណៈអន្តរជាតិក្នុងកម្រិតមួយខ្ពស់របស់វេជ្ជបណ្ឌិត និងគិលានុបដ្ឋាយិកាអាហ្វ្រិច អាស៊ី និងការីបៀន មានន័យថាប្រទេសដែលមានចំណូលទាប ត្រូវបាត់បង់អ្នកជំនាញទាំងនេះ ហើយត្រូវប្រឈមនឹងបន្ទុកហិរញ្ញវត្ថុដ៏ធ្ងន់ធ្ងរ។ ប្រទេសអ្នកមានគួររ៉ាប់រងចំណាយសម្រាប់ការបណ្តុះបណ្តាលគ្រូពេទ្យ ដែលមកផ្តល់សេវាដល់ប្រជាពលរដ្ឋរបស់ខ្លួន ដោយមិនគិតថាតើគ្រូពេទ្យទាំងនោះទទួលបានការបណ្តុះបណ្តាលនៅទីណានោះទេ។

> “អង្គការសុខភាពពិភពលោកបានព្យាករថា ពិភពលោកទាំងមូលនឹងខ្វះបុគ្គលិកថែទាំសុខភាព ១៤,៥ លាននាក់នៅឆ្នាំ ២០៣០”

ចំណុចខ្វះខាតដែលព័ន្ធនឹងការរៀបចំស្ថាប័ន និងការបង្រៀនធ្វើឱ្យមានបញ្ហាប្រឈមពាក់ព័ន្ធនឹងសមធម៌៖ ប្រទេសចំនួន ២៦ នៅអាហ្វ្រិចសាប់សាហារ៉ា មានសាលាវេជ្ជសាស្ត្រតែមួយ ឬពុំមានសាលាវេជ្ជសាស្ត្រសោះនៅក្នុងឆ្នាំ ២០០៨។ នៅតាមប្រទេសនីមួយៗវិញមានភាពលំអៀងខ្លាំងទៅរកតំបន់ប្រជុំជន ដែលធ្វើឱ្យប្រជាពលរដ្ឋក្នុងតំបន់ជនបទ ពុំបានទទួលសេវាគ្រប់គ្រាន់ឡើយ។ ដើម្បីបង្កើនសមត្ថភាព គេគួរផ្សារភ្ជាប់ការរៀបចំផែនការធនធានមនុស្ស សម្រាប់ប្រព័ន្ធសុខាភិបាលនេះជាមួយនឹងគ្រឹះស្ថានអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ដើម្បីបង្កភាពងាយស្រួលដល់ការធ្វើអន្តរកាលពីសាលារៀនទៅកន្លែងធ្វើការ ការផ្តល់ឱកាសធ្វើកម្មសិក្សាសម្រាប់យុវជន និងការបន្តការអភិវឌ្ឍវិជ្ជាជីវៈ ដែលជាការងាកចេញពីការយកចិត្តទុកដាក់លើការបណ្តុះបណ្តាលតាមមន្ទីរពេទ្យ និងតាមសកលវិទ្យាល័យ។

ការសម្រេចការអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៦ តម្រូវឱ្យមានការបង្កើនជំនាញ ផ្តល់សេវាទឹកស្អាត និងអនាម័យឱ្យបានកាន់តែប្រសើរជាងមុន។ បញ្ហាធនធានមនុស្សត្រូវបានគេយកមកធ្វើការពិនិត្យពិចារណាបន្តិចបន្តួចតែប៉ុណ្ណោះក្នុងវិស័យនេះ។ ក្នុងចំណោមប្រទេសចំនួន ៩៤ ត្រូវបានអង្កេត មានប្រទេសតិចជាង ១៥ ភាគរយប៉ុណ្ណោះដែលបានពិនិត្យឡើងវិញលើយុទ្ធសាស្ត្ររបស់ខ្លួន ឱ្យបានយ៉ាងហោចណាស់រៀងរាល់ ២ ឆ្នាំម្តង។ កង្វះថវិកា និងនិស្សិតបញ្ចប់ការសិក្សាដែលមានជំនាញ និងភាពស្ទាក់ស្ទើររបស់បុគ្គលិកជំនាញក្នុងការទៅធ្វើការងារនៅតាមតំបន់ជនបទ ហើយជាកត្តាដែលប៉ះពាល់ដល់ការអភិវឌ្ឍសមត្ថភាព។

ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ២ ដែលផ្តោតលើសន្តិសុខស្បៀង ចាំបាច់ត្រូវតែមានការអប់រំ និងការកសាងសមត្ថភាព។ កសិករដែលទទួលបានការអប់រំកាន់តែច្រើន និងមានផលិតភាពកាន់តែខ្ពស់ទំនងជានឹងចាត់វិធានការកាន់តែច្រើនដើម្បីកាត់បន្ថយហានិភ័យនៃការប្រែប្រួលអាកាសធាតុនិងប្រើប្រាស់បច្ចេកវិទ្យាថ្មីៗបន្ថែមទៀត។ នៅប្រទេសប៉ាគីស្ថាន កម្មករដែលទទួលបានការអប់រំ ច្រើនតែចង់ស្រោចស្រពដោយប្រើម៉ូទ័របូមទឹក ដែលប្រើប្រាស់ប្រភពថាមពលកកើតឡើងវិញ ដោយសារតែពួកគេធ្វើការស្វែងរកព័ត៌មានបែបនេះយកមកប្រើប្រាស់ ជាងកសិករដែលមានការអប់រំតិចតួច។

វិស័យសុខាភិបាល កសិកម្ម ទឹក និងអនាម័យ ត្រូវផ្តោតការយកចិត្តទុកដាក់លើការបញ្ចប់ការសិក្សាដោយត្រូវចាត់ទុកការបញ្ចប់ការសិក្សានេះ ជាយុទ្ធសាស្ត្រដ៏សំខាន់ ដើម្បីសម្រេចគោលបំណងរបស់ខ្លួន។ វឌ្ឍនភាពក្នុង ការ ឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក៏តម្រូវឱ្យមានការធ្វើសកម្មភាពឱ្យចំគោលដៅ ដែលផ្តល់អាទិភាពដល់សមធម៌ ក្នុងយុទ្ធនាការកសាងសមត្ថភាព ការពង្រាយបុគ្គលិកជំនាញ និងការរៀបចំយុទ្ធនាការបង្កើនការយល់ដឹងជាសាធារណៈ។

# ហិរញ្ញវត្ថុ

អ្នកដែលរួមចំណែកធំៗ ដល់ការផ្តល់ហិរញ្ញប្បទានដល់វិស័យអប់រំ រួមមានរដ្ឋាភិបាល អ្នកផ្តល់ជំនួយ និងប្រជាពលរដ្ឋ។ ថវិកាសម្រាប់វិស័យអប់រំនាពេលបច្ចុប្បន្ននេះ គឺពុំគ្រប់គ្រាន់ឡើយ ប៉ុន្តែមានការយល់ឃើញខុសៗគ្នាពីថាតើអ្នកណាដែលគួរផ្តល់ថវិកាបន្ថែមទៀតសម្រាប់ការអប់រំ។

## ចំណាយសាធារណៈ

ក្នុងឆ្នាំ ២០១៥ ចំណាយលើការអប់រំសាធារណៈជាសកល គិតជាមធ្យមគឺ ៤,៧ ភាគរយនៃ ផសស ស្ថិតនៅចន្លោះ ៤ ភាគរយទៅ ៦ ភាគរយ ដែលត្រូវបានស្នើឡើងដោយក្របខ័ណ្ឌសកម្មភាពសម្រាប់ការអប់រំ ឆ្នាំ ២០៣០។ ចំណាយលើវិស័យអប់រំ មានចាប់ពី ៣,៧ ភាគរយ នៅតាមប្រទេសដែលមានចំណូលទាប រហូតដល់ ៥,១ ភាគរយ នៅប្រទេសដែលមានចំណូលខ្ពស់។ ប៉ុន្តែចំណាយលើការអប់រំសាធារណៈ គឺមាន

កម្រិត ១៤,១ ភាគរយនៃចំណាយសាធារណៈសរុបក្នុងឆ្នាំ ២០១៤ ក្រោមអត្រាពី ១៥ ទៅ ២០ ភាគរយ ដែលត្រូវបានស្នើឡើងដោយក្របខ័ណ្ឌនេះ។ មានប្រទេសយ៉ាងហោចណាស់ចំនួន ៣៣ ទាំងប្រទេសក្រីក្រ ទាំងប្រទេសអ្នកមាន ពុំបានសម្រេចទៅតាមចំណុចដៅនៃការផ្តល់ហិរញ្ញប្បទានសម្រាប់វិស័យអប់រំ ដូចដែលបានកំណត់ទាំងនេះឡើយ (**រូបភាពទី ១៨**)។

## រូបភាពទី ១៨៖

ប្រទេសយ៉ាងហោចណាស់ ៣៣ ពុំបានបំពេញទៅតាមចំណុចដៅនៃការផ្តល់ហិរញ្ញប្បទានដល់វិស័យអប់រំ

ចំណាយលើការអប់រំសាធារណៈគិតជាភាគរយនៃ ផសស និងគិតជាភាគរយនៃចំណាយសាធារណៈសរុបឆ្នាំ ២០១៥ ឬក៏ឆ្នាំចុងក្រោយបំផុត




ប្រភព៖ ប្រព័ន្ធទិន្នន័យ UIS

## ចំណាយហិរញ្ញប្បទានសហប្រតិបត្តិការ

ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤ ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់វិស័យអប់រំ ក្នុងប្រទេសដែលមានចំណូលទាប និងចំណូលមធ្យមកម្រិតទាប ចាំបាច់ត្រូវបង្កើនឱ្យបាន ៦ ដងជាងកម្រិតក្នុងឆ្នាំ ២០១២។ ផ្ទុយទៅវិញ ហិរញ្ញប្បទានសហប្រតិបត្តិការសរុបសម្រាប់វិស័យអប់រំឆ្នាំ ២០១៥ មានកម្រិតទាបជាង ២០១០ ៤ ភាគរយ បើទោះបីជាជំនួយអភិវឌ្ឍន៍ផ្លូវការសរុបកើនឡើង ២៤ ភាគរយនៅក្នុងរយៈពេលនេះយ៉ាងណាក៏ដោយ។ អ្នកផ្តល់ជំនួយបានបង្វែរអាទិភាពរបស់ខ្លួនចេញពីវិស័យអប់រំ។ ភាគរយនៃហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់វិស័យអប់រំ ធៀបនឹងទំហំហិរញ្ញប្បទានសហប្រតិបត្តិការសរុប (ដោយមិនរាប់បញ្ចូលការលើកលែងបំណុល) មានការថយចុះ ៦ ឆ្នាំជាប់ៗគ្នា ពី ១០ ភាគរយក្នុងឆ្នាំ ២០០៩ មកត្រឹម ៦,៩ ភាគរយក្នុងឆ្នាំ ២០១៥។

ចាំបាច់ត្រូវមានការកំណត់ចំណុចដៅឱ្យបានកាន់តែប្រសើរជាងមុន ដើម្បីគ្របដណ្តប់លើគម្លាតហិរញ្ញប្បទាននៅតាមប្រទេសទទួលជំនួយ។ ប្រទេសដែលមានចំណូលទាបទទួលបាន ១៩ ភាគរយនៃហិរញ្ញប្បទានសហប្រតិបត្តិការសរុបសម្រាប់វិស័យអប់រំ និង ២៣ ភាគរយនៃហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ការអប់រំថ្នាក់មូលដ្ឋានក្នុងឆ្នាំ ២០១៥ ថយចុះពី ២១ ភាគរយ និង ២៩ ភាគរយ ក្នុងឆ្នាំ ២០១៤ **(រូបភាពទី ១៩)**។ បើគិតតាមថ្នាក់តំបន់វិញ អាហ្វ្រិចសាប់សាហារ៉ា ដែលមានកុមារក្រៅសាលាជាងពាក់កណ្តាល ក្នុងចំណោមកុមារក្រៅសាលាសរុបរបស់ពិភពលោក បានទទួល ២៦ ភាគរយនូវហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ការអប់រំថ្នាក់មូលដ្ឋានក្នុងឆ្នាំ ២០១៥ ពោលគឺទាបជាងកម្រិតកាលពីឆ្នាំ ២០១២ ដល់ទៅពាក់កណ្តាល។

ជំនួយមនុស្សធម៌សម្រាប់វិស័យអប់រំ មានការកើនឡើងជាង ៥០ ភាគរយក្នុងឆ្នាំ ២០១៦ រហូតដល់ ៣០០លានដុល្លាប៉ុន្តែមូលនិធិសម្រាប់ការអប់រំក្នុងស្ថានភាពអាសន្ននៅពុំទាន់មានគ្រប់គ្រាន់នៅឡើយពោលគឺមានត្រឹមតែ ២,៧ ភាគរយនៃជំនួយមនុស្សធម៌សរុបតែប៉ុណ្ណោះ។

ខណៈពេលដែលកម្រិតបច្ចុប្បន្ននៃហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់វិស័យអប់រំ ថយចុះពីទំហំហិរញ្ញប្បទានសហប្រតិបត្តិការ ដែលចាំបាច់ត្រូវមាន ដើម្បីសម្រេចចំណុចដៅសំខាន់ៗនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព កម្មវិធីដែលកំពុងអនុវត្ត និងកម្មវិធីដែលគ្រោងនឹងអនុវត្ត ដែលមានសក្តានុពលជួយដោះស្រាយបញ្ហាតុល្យភាពបែបនេះ សមនឹងទទួលបានការយកចិត្តទុកដាក់ឱ្យបានកាន់តែជិតស្និទបន្ថែមទៀត។ គេរំពឹងថា ភាពជាដៃគូសកលសម្រាប់ការអប់រំ នឹងបញ្ចប់យុទ្ធនាការផ្តល់មូលនិធិបន្ថែមរបស់ខ្លួន នៅត្រឹមដើមឆ្នាំ ២០១៨ ដែលប្រសិនបើអនុវត្តបានជោគជ័យ នឹងនាំឱ្យចំនួនថវិកាដែលទម្លាក់ជារៀងរាល់ឆ្នាំ កើនឡើង ៤ ដង។

ការបង្កើតកម្មវិធីហិរញ្ញប្បទានអន្តរជាតិសម្រាប់វិស័យអប់រំ ដែលដំបូងឡើយត្រូវបានស្នើឡើងដោយគណៈកម្មការអន្តរជាតិទទួលបន្ទុកហិរញ្ញប្បទានសម្រាប់ឱកាសអប់រំសកលលោក បានទទួលថវិកាបន្ថែមទៀត នៅពេលដែលកម្មវិធីនេះត្រូវបានបញ្ចូលទៅក្នុងសេចក្តីប្រកាសរបស់មេដឹកនាំប្រទេសជាង ២០ ក្នុង

សម័យកិច្ចប្រជុំកំពូល កាលពីខែកក្កដា ឆ្នាំ ២០១៧ នៅក្នុងទីក្រុង Hamburg។ កម្មវិធីនេះមានគោលបំណង ពង្រីកសមត្ថភាពផ្ដល់កម្ចីធនាគារអភិវឌ្ឍន៍ដល់ប្រទេសអ្នកមានចំណូលមធ្យមកម្រិតទាប។

ចុងក្រោយ កម្មវិធីវិស័យអប់រំមិនអាចរង់ចាំបាន (Education Cannot Wait) ដែលបង្កើតឡើង ដោយយូនីសេហ្វ មានគោលបំណងធ្វើឱ្យមានការផ្លាស់ប្ដូរការផ្ដល់សេវាអប់រំ ក្នុងស្ថានភាពអាសន្ន មិនត្រឹម តែតាមរយៈការផ្ដល់ថវិកាឱ្យបានឆាប់រហ័ស នៅពេលដែលវិបត្តិទើបតែនឹងកើតឡើងដំបូងប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងជួយភ្ជាប់នូវគម្លាតរវាងជំនួយមនុស្សធម៌ និងជំនួយអភិវឌ្ឍផងដែរ។ អ្នកផ្ដល់ជំនួយចាំបាច់ត្រូវធ្វើ ការងាររួមគ្នា ដោយមានការសម្របសម្រួលឱ្យបានល្អ ដើម្បីធានាយ៉ាងណាឱ្យគំនិតផ្ដួចផ្ដើមទាំង ៣ នេះអាច បំពេញបន្ថែមឱ្យគ្នាទៅវិញទៅមក និងមិនបន្ថែមចំណាយរដ្ឋបាលដែលមិនចាំបាច់ ឬធ្វើឱ្យមានការអនុវត្ត សកម្មភាពត្រួតគ្នាឡើយ។

**រូបភាពទី ១៩៖**

ភាគរយនៃហិរញ្ញប្បទានសហប្រតិបត្តិសម្រាប់ការអប់រំថ្នាក់មូលដ្ឋាន ដែលផ្ដល់ដល់ប្រទេសដែលមានចំណូលទាប ថយចុះយ៉ាងគំហុកក្នុងឆ្នាំ ២០១៥

ភាគរយនៃប្រទេសចំណូលទាប និងប្រទេសដែលមានការអភិវឌ្ឍតិចតួចនៃទំហំហិរញ្ញប្បទានសហប្រតិបត្តិសរុប សម្រាប់វិស័យអប់រំ និងសម្រាប់ការអប់រំថ្នាក់មូលដ្ឋាន ការទម្លាក់សាច់ប្រាក់ ២០០២ - ២០១៥




ប្រភព៖ ការវិភាគរបស់ក្រុមរៀបចំរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកល ផ្អែកទៅតាមទិន្នន័យនៃប្រព័ន្ធ រាយការណ៍ព័ត៌មានរបស់ OECD-DAC Creditor។

## ចំណាយរបស់គ្រួសារ

ការចំណាយលើការអប់រំ ដែលជាឧបសគ្គដ៏ធំមួយ រារាំងដល់ការទទួលបានការអប់រំរបស់កុមារមកពីប្រទេសដែលមានចំណូលទាប និងចំណូលមធ្យម ពុំទាន់ត្រូវបានគេយកមកពិចារណាឱ្យបានគ្រប់គ្រាន់នៅឡើយទេ។ ក្រសួងជាច្រើនខកខានពុំបានពិនិត្យពិច័យលើចំណាយរបស់វិស័យសាធារណៈ និងវិស័យឯកជនរួមគ្នាឡើយ។ លើសពីនេះ កង្វះការរៀបចំបង្កើតស្តង់ដាសម្រាប់ការធ្វើអង្កេតតាមក្នុងផ្ទះ មានន័យថា ការប៉ាន់ប្រមាណ ដែលធ្វើឡើងដោយការអង្កេតទាំងនេះអាចប៉ាន់ប្រមាណលើស ឬប៉ាន់ប្រមាណខ្វះពីចំណាយសរុបរបស់គ្រួសារនីមួយៗ។ យូណេស្កូ OECD និង Eurostat បានបង្កើតនូវស្តង់ដាមួយ តែស្តង់ដានេះនៅពុំទាន់អាចមានឥទ្ធិពលគ្រប់គ្រាន់លើការរៀបចំការអង្កេតនានាឡើយ។

ការបញ្ចូលចំណាយរបស់គ្រួសារ អាចធ្វើឱ្យមានការផ្លាស់ប្តូរការយល់ដឹង អំពីការវិនិយោគរបស់ប្រទេសនានាក្នុងវិស័យអប់រំ។ ឧទាហរណ៍រដ្ឋាភិបាលរបស់ប្រទេសអេលសាវ៉ាឌ័រចំណាយថវិកាប្រមាណជា២ ភាគរយចំណុចនៃផលិតផលសរុបក្នុងស្រុក (ផសស) លើវិស័យអប់រំ តិចជាងប្រទេសបារាំង។ ប៉ុន្តែចំណាយសរុបនៅក្នុងប្រទេសអេលសាវ៉ាឌ័រ មានចំនួនច្រើនជាង ដោយសារតែប្រជាពលរដ្ឋបានចំណាយប្រាក់ជាង ៣ភាគរយចំណុចនៃផសសលើការអប់រំ។ ជាទូទៅភាគរយនៃចំណាយសរុបលើការអប់រំដែលត្រូវរ៉ាប់រងដោយគ្រួសារ មានទំហំកាន់តែច្រើននៅតាមបណ្តាប្រទេសដែលមានចំណូលទាប បើធៀបនឹងប្រទេសដែលមានចំណូលខ្ពស់។

នៅក្នុងចំណោមប្រទេសនានា ដែលមានទិន្នន័យភាគរយនៃចំណាយគ្រួសារធៀបនឹងចំណាយសរុបលើវិស័យអប់រំ មានចាប់ពី ១៥ ភាគរយនៅក្នុងប្រទេសដែលមានចំណូលខ្ពស់ រហូតដល់ ២៥ ភាគរយក្នុងប្រទេសដែលមានចំណូលមធ្យម និង ៣២ ភាគរយនៅក្នុងប្រទេសដែលមានចំណូលទាប។ បើដករដ្ឋជាសមាជិកសហភាពអឺរ៉ុប និង OECD ចេញ ក្នុងប្រទេសចំនួន ៣ មានប្រទេសជាង ១ ដែលភាគរយនៃចំណាយគ្រួសារ ស្មើនឹងយ៉ាងហោចណាស់ ៣០ ភាគរយនៃចំណាយសរុប។ ក្នុងប្រទេសកម្ពុជា ភាគរយនៃចំណាយរបស់គ្រួសារលើការអប់រំ គឺ ៦៩ ភាគរយ ក្នុងឆ្នាំ ២០១១ (**រូបភាពទី ២០**)។

**រូបភាពទី ២០៖**
នៅក្នុងប្រទេស ១ ភាគ ៣ គ្រួសាររួមចំណែកយ៉ាងហោចណាស់ ១ ភាគ ៣ នៃចំណាយសរុបលើការអប់រំ
របាយនៃចំណាយសរុបលើការអប់រំ បែងចែកទៅតាមប្រភពមូលនិធិប្រទេសមួយចំនួន ២០០៥-២០១៥




**សម្គាល់៖** រូបភាពនេះគ្របដណ្តប់លើគ្រប់ប្រទេសទាំងអស់ដែលមានទិន្នន័យនៅក្នុងរយៈពេលនេះ ដែលមិនរាប់បញ្ចូលប្រទេសដែលជាសមាជិកសហភាពអឺរ៉ុប និង OECD។
ប្រភព៖ ប្រព័ន្ធទិន្នន័យ UIS។

## ការប្រើប្រាស់មេរៀន បទពិសោធន៍ ដែលបានពីទស្សន៍ស្មុខាភិបាល ដើម្បីបង្កើតគណនីអប់រំជាតិ

ក្របខ័ណ្ឌគណនីអប់រំជាតិ ដែលទទួលបានការគាំទ្រពីភាពជាដៃគូ ជាសកលសម្រាប់ការអប់រំ វិទ្យាស្ថានស្ថិតិរបស់យូណេស្កូ និងវិទ្យាស្ថានអន្តរជាតិសម្រាប់ការរៀបចំផែនការរបស់យូណេស្កូ គឺជាឧបករណ៍មួយសម្រាប់ប្រៀបធៀបការចំណាយលើការអប់រំពីប្រភពសាធារណៈ និងប្រភពគ្រួសារនីមួយៗ រវាងប្រទេសមួយ និងប្រទេសមួយទៀត។ ក្របខ័ណ្ឌនេះមានគោលបំណងគ្របដណ្តប់លើគ្រប់កម្រិតនៃការអប់រំទាំងអស់ ចាប់ពីមត្តេយ្យសិក្សា រហូតដល់ឧត្តមសិក្សា រាប់បញ្ចូលទាំងការបណ្តុះបណ្តាលវិជ្ជាជីវៈផងដែរ និងគ្របដណ្តប់លើគ្រប់អ្នកផ្តល់ និងប្រភពថវិកាទាំងអស់។

មេរៀនដែលទទួលបានពីប្រព័ន្ធគណនីសុខាភិបាលជាតិ ដែលជាកម្មវិធីដែលបង្កើតកន្លងមក គួរយកមកអនុវត្ត។ ប្រព័ន្ធគណនីសុខាភិបាលបានទទួលការឯកភាពគ្នាជារួមកាលពីឆ្នាំ ២០០០ ហើយដែលត្រូវបានកែសម្រួលក្នុងឆ្នាំ ២០១១ ហើយមានប្រទេសចំនួន១១២បានបង្កើតគណនីបានប្រើប្រាស់ក្របខ័ណ្ឌនេះជាគោល។ បើទោះបីជាយ៉ាងណាក៏ដោយ មិនទាន់មានប្រទេសឱ្យបានគ្រប់គ្រាន់ បានអនុម័តប្រើប្រាស់ប្រព័ន្ធនេះនៅឡើយ ហើយប្រព័ន្ធនេះបានទទួលការរិះគន់ ដោយគេចាត់ទុកវាថាជាគម្រោងដែលជម្រុញដោយអ្នកផ្តល់ជំនួយ។ កង្វះសមត្ថភាព មានន័យថា ពេលខ្លះគណនីនេះត្រូវពឹងអាស្រ័យលើទីប្រឹក្សាអន្តរជាតិ ហើយគណនីប្រមូលផ្តុំតែលើផ្នែកមួយចំនួននៃវិស័យតែប៉ុណ្ណោះ ដូច្នេះមានន័យថា មិនមែនគ្រប់ប្រទេសទាំងអស់ សុទ្ធតែមានភាពជាម្ចាស់លើដំណើរការនេះឡើយ។ សម្រាប់គណនីអប់រំវិញ ទិន្នន័យចាំបាច់ត្រូវតែផ្តល់ដល់អ្នកតាក់តែងគោលនយោបាយនៅថ្នាក់ជាតិ ជាពិសេសសម្រាប់ការរៀបចំថវិកា ហើយចាំបាច់ត្រូវតែមានការផ្តល់ធនធាន ដើម្បីឱ្យគេអាចធ្វើការផ្សព្វផ្សាយពីសារៈប្រយោជន៍នៃទិន្នន័យទាំងនេះ។

> "ក្រុមការងារអន្តរជាតិមួយ ដែលមានសមាសធាតុជាតួអង្គ ដែលពាក់ព័ន្ធ និងការប្រមូលទិន្នន័យអំពីចំណាយសម្រាប់វិស័យអប់រំ និងត្រូវបង្កើតនូវវេទិកាមួយ ដែលអាចផ្តល់លទ្ធភាពឱ្យប្រទេសនានាធ្វើការចែករំលែកចំណេះដឹង និងបញ្ហាប្រឈមនានាបាន។"

គម្រោងសាកល្បងគណនីអប់រំជាតិ ដែលបានបញ្ចប់ក្នុងឆ្នាំ ២០១៦ បង្ហាញពីសក្តានុពលនៃការប្រើប្រាស់ព័ត៌មាននេះសម្រាប់ធ្វើការវាយតម្លៃនិងការកែសម្រួលយន្តការផ្តល់ហិរញ្ញទាននិងអាចឱ្យគេធ្វើការប្រៀបធៀបជាលក្ខណៈអន្តរជាតិបាន។ ជំហានបន្ទាប់ គឺត្រូវបង្កើតនូវក្រុមការងារអន្តរជាតិមួយ ដែលមានសមាសធាតុជាតួអង្គដែលពាក់ព័ន្ធ និងការប្រមូលទិន្នន័យអំពីចំណាយសម្រាប់វិស័យអប់រំ និងត្រូវបង្កើតនូវវេទិកាមួយ ដែលអាចផ្តល់លទ្ធភាពឱ្យប្រទេសនានា ធ្វើការចែករំលែកចំណេះដឹង និងបញ្ហាប្រឈមនានាបាន។

# អនុសាសន៍

គួរមានការដាក់ឱ្យអនុវត្តនូវយន្តការគណនេយ្យភាពដែលមានភាពច្បាស់លាស់ដើម្បីសម្រេចឱ្យបាននូវការប្តេជ្ញាចិត្តរួមគ្នារបស់សកលលោកទាំងមូល ក្នុងការផ្តល់នូវការអប់រំបរិយាប័ន្នប្រកបដោយគុណភាពខ្ពស់ និងសមធម៌ និងការរៀនសូត្រពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។ របាយការណ៍នេះបានបង្ហាញពីព័ត៌មានជាច្រើន ចាប់ពីប្រទេសដែលពុំមានការយល់ដឹងពីទស្សនទាន គណនេយ្យភាព និងការមិនដេញដោលសួរនាំពីការបំពានសិទ្ធិទទួលបានការអប់រំ រហូតដល់ប្រទេសដែលចាត់ទុកគណនេយ្យភាព គឺជាគោលដៅចុងក្រោយជៀសជាងជាមធ្យោបាយដើម្បីធ្វើការកែលំអការអប់រំ។

គណនេយ្យភាពក្នុងវិស័យអប់រំ ចាប់ផ្តើមចេញដំណើរពីរដ្ឋាភិបាលទៅ ដែលជាអ្នកមានភារកិច្ចចំបងក្នុងការធានាសិទ្ធិទទួលបានការអប់រំ។ ប្រទេសទាំងអស់នៅក្នុងពិភពលោកបានផ្តល់សច្ចាប័នដល់សន្ធិសញ្ញាអន្តរជាតិ យ៉ាងហោចណាស់ ១ ដែលនេះបង្ហាញពីការប្តេជ្ញាចិត្តរបស់ប្រទេសទាំងនោះ ក្នុងការបំពេញសិទ្ធិទទួលបានការអប់រំ។ ប៉ុន្តែនៅក្នុងប្រទេសត្រឹមតែ ៥៥ ភាគរយប៉ុណ្ណោះ ដែលគេអាចស្វែងរកយុត្តិធម៌សម្រាប់ការបំពេញសិទ្ធិទទួលបានការអប់រំបាន មានន័យថាមានច្បាប់ដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋ អាចប្តឹងទៅតុលាការ នៅក្នុងករណីដែលមានការបំពានកើតឡើងក្នុងប្រព័ន្ធអប់រំ។ អង្គការសង្គមស៊ីវិល និងសហគមន៍អន្តរជាតិគួរជម្រុញឱ្យមានការគោរពសិទ្ធិទទួលបានការអប់រំ ដូចជាជម្រុញឱ្យមានការបញ្ចូលលទ្ធភាពប្តឹងទៅតុលាការ ដើម្បីទាមទារយុត្តិធម៌ ក្នុងករណីដែលពុំមានការបំពេញសិទ្ធិដើម្បីទទួលបានការអប់រំទៅក្នុងក្របខ័ណ្ឌច្បាប់ជាតិជាដើម។

ជាការពិត ច្បាប់មានអនុភាព តែនៅពេលមានការអនុវត្តតែប៉ុណ្ណោះ។ គណនេយ្យភាពដែលមានប្រសិទ្ធភាព ទាមទារឱ្យរដ្ឋាភិបាលបង្កើតប្រព័ន្ធកាន់តែរឹងមាំជាងមុន ដើម្បីពង្រឹងការអនុវត្តច្បាប់។ ដូច្នេះរបាយការណ៍នេះសូមដាក់ចេញនូវអនុសាសន៍ដូចតទៅ ដើម្បីជួយដល់រដ្ឋាភិបាលក៏ដូចជាតួអង្គពាក់ព័ន្ធនានា ដែលបំពេញការងារក្នុងវិស័យអប់រំ ក្នុងការរៀបចំ និងអនុវត្តប្រព័ន្ធគណនេយ្យភាពមួយដែលមានភាពរឹងមាំ។

## ការរៀបចំប្រព័ន្ធគណនេយ្យភាព ដែលមានលក្ខណៈរឹងមាំ

១. **រដ្ឋាភិបាលចាំបាច់ត្រូវបង្កើតនូវឱកាស ដើម្បីឱ្យមានការចូលរួមដោយអត្ថន័យ ពីតំណាងអ្នកដែលពាក់ព័ន្ធ ដើម្បីកសាងការជឿទុកចិត្ត និងការយល់ដឹងដូចៗគ្នា ពីការទទួលខុសត្រូវរបស់តួអង្គនីមួយៗ ក្នុងវិស័យអប់រំ** - ពាល់កម្រិតថ្នាក់ និងក្រសួងស្ថាប័នទាំងអស់របស់រដ្ឋាភិបាល អាជ្ញាធរ អង្គនីតិបញ្ញត្តិ និងតុលាការ ស្ថាប័នស្វយ័ត សាលារៀន គ្រូ មាតាបិតាសិស្ស អង្គការសង្គមស៊ីវិល សមាគមគ្រូ វិស័យឯកជន និងអង្គការអន្តរជាតិ។ ជំហានដើម្បីសម្រេចទិសដៅនេះរួមមាន៖

ក. ផ្ដល់ឱកាសផ្លូវការដើម្បីឱ្យមានកិច្ចពិគ្រោះយោបល់ប្រកបដោយអត្ថន័យ រវាងតួអង្គពាក់ព័ន្ធចំរុះ ជាពិសេសអ្នកដែលស្ថិតនៅខាងក្រៅរដ្ឋាភិបាល។

ខ. ពង្រឹងតួនាទីរបស់គណៈកម្មាធិការទទួលបន្ទុកវិស័យអប់រំរបស់អង្គនីតិបញ្ញត្តិ តាមរយៈការដាក់ឱ្យអនុវត្តនូវដំណើរការពិនិត្យឡើងវិញជាទៀងទាត់ និងការកសាងសមត្ថភាពដល់សមាជិករបស់គណៈកម្មាធិការនេះ។

គ. ផ្សព្វផ្សាយរបាយការណ៍ពិនិត្យតាមដានការអប់រំប្រចាំឆ្នាំ ដោយបង្ហាញពីសកម្មភាពដែលបានធ្វើកន្លងមក និងលទ្ធផលដែលសម្រេចបាននៅគ្រប់កម្រិតភូមិសិក្សាទាំងអស់ ដើម្បីជាប្រយោជន៍ដល់សាធារណជនទូទៅ។

២. **រដ្ឋាភិបាលគួររៀបចំផែនការអប់រំ ដែលអាចជឿទុកចិត្តបាន និងថវិកាដែលមានតម្លាភាព ដែលមានការកំណត់ពីការទទួលខុសត្រូវឱ្យបានច្បាស់លាស់ និងត្រូវបង្កើតយន្តការសាវនកម្ម ដែលមានឯករាជ្យភាពពិតប្រាកដ។** គេមិនដែលទាមទារឱ្យតួអង្គនានាក្នុងរដ្ឋាភិបាលមានគណនេយ្យភាពបានឡើយ ប្រសិនបើពុំមានភាពច្បាស់លាស់ ពាក់ព័ន្ធទៅនឹងអ្វីដែលពួកគេត្រូវទទួលខុសត្រូវនោះ។ តម្លាភាពនៃឯកសារថវិកា អាចជួយបញ្ជាក់កាន់តែច្បាស់ថាតើថវិកាត្រូវបានផ្ដល់ទៅស្ថាប័នណាខ្លះ និងនៅពេលណា ដែលនេះជាការផ្ដល់ព័ត៌មានដែលចាំបាច់សម្រាប់ការពិនិត្យពិច័យ ជាពិសេសនៅក្នុងអង្គនីតិបញ្ញត្តិ។

៣. **រដ្ឋាភិបាលគួររៀបចំនូវបទដ្ឋានគតិយុត្ត និងប្រព័ន្ធពិនិត្យតាមដានដែលអាចជឿទុកចិត្តបាន និងមានប្រសិទ្ធភាព និងត្រូវគោរពតាមវិធានការតាមដានបន្ត និងការដាក់ទោសទណ្ឌនៅក្នុងករណីដែលពុំមានការបំពេញទៅតាមស្តង់ដា។** យន្តការទាំងនេះគួរមានវិសាលភាពគ្របដណ្ដប់លើអ្នកផ្ដល់សេវាអប់រំ វិស័យឯកជន និងវិស័យសាធារណៈ និងអ្នកផ្ដល់សេវាបំពេញបន្ថែមទៀត។ ដំណើរការនានាដូចជាការចុះបញ្ជី និងការបញ្ជាក់គុណភាព ឬដំណើរការនៃការដេញថ្លៃ និងការផ្ដល់កិច្ចសន្យាគួរមានភាពច្បាស់លាស់ និងមានតម្លាភាព។ ប៉ុន្តែលិខិតបទដ្ឋានគតិយុត្តទាំងនេះ ក៏គួរផ្ដោតការយកចិត្តទុកដាក់លើសមធម៌ និងគុណភាពនៃវិស័យអប់រំផងដែរ។

៤. **រដ្ឋាភិបាលគួររៀបចំយន្តការគណនេយ្យភាពសម្រាប់សាលារៀន និងគ្រូដែលផ្ដល់ការគាំទ្រដល់ពួកគេ និងជៀសវាងបង្កើតយន្តការដាក់ទោស ជាពិសេសប្រភេទយន្តការដែលផ្អែកទៅតាមការវាស់វែងលទ្ធផលការងារដែលមានលក្ខណៈចង្អៀត។** ការប្រើប្រាស់ពិន្ទុតេស្តសិស្ស ដើម្បីដាក់ទោសសាលារៀន ឬវាយតម្លៃគ្រូ អាចធ្វើឱ្យមានការប្រកួតប្រជែងមិនល្អ នាំឱ្យមានការបង្រួមកម្មវិធីសិក្សា លើកទឹកចិត្តឱ្យបង្រៀនតែមុខវិជ្ជាសម្រាប់ធ្វើតេស្ត ធ្វើឱ្យគ្រូបាក់ទឹកចិត្ត និងធ្វើឱ្យសិស្សដែលរៀនខ្សោយ កាន់តែជួបការលំបាក ដែលកត្តាទាំងនេះអាចប៉ះពាល់ដល់គុណភាពនៃការអប់រំទាំងមូល ក៏ដូចជាដល់ការរៀនសូត្ររបស់សិស្ស។

៥. **រដ្ឋាភិបាលចាំបាច់ត្រូវអនុញ្ញាត ឱ្យមានការបញ្ចេញសំលេងបែបប្រជាធិតេយ្យ ការពារសេរីភាពប្រព័ន្ធផ្សព្វផ្សាយ ក្នុងការពិនិត្យលើវិស័យអប់រំ និងបង្កើតស្ថាប័នឯករាជ្យ ដើម្បីឱ្យប្រជាពលរដ្ឋអាចលើកឡើងពីអ្វីដែលពួកគេមិនពេញចិត្ត។** ការបោះឆ្នោតដោយសេរី និងយុត្តិធម៌ បង្កើនការជឿទុកចិត្តរបស់ប្រជាពលរដ្ឋលើរដ្ឋាភិបាល ហើយការប្រកួតប្រជែងគ្នាតាមរយៈការបោះឆ្នោតអាចធ្វើឱ្យអ្នកដែលកំពុងកាន់អំណាច កាន់តែឆ្លើយតបចំពោះតម្រូវការរបស់ប្រជាពលរដ្ឋ។ ប្រព័ន្ធផ្សព្វផ្សាយអាចជាប្រភពព័ត៌មានងាយស្រួលយល់ដ៏មានតម្លៃ ជាពិសេសសម្រាប់ប្រជាពលរដ្ឋដែលមានលទ្ធភាពតិចតួចក្នុងការទទួលបានព័ត៌មាន។ ការិយាល័យប្រជាពលរដ្ឋអាចជាមធ្យោបាយជាសំខាន់ សម្រាប់ទទួលបណ្តឹងរបស់ប្រជាពលរដ្ឋ ដរាបណាការលើកទឹកចិត្តនៅផ្នែកនយោបាយមានទិសដៅស្របគ្នានឹងភាពចាំបាច់ ដើម្បីឆ្លើយតបទៅនឹងការកើតទុក្ខមិនសុខចិត្តទាំងនេះ។

## ការអនុវត្តដល់ប្រព័ន្ធគណនេយ្យភាពដែលមានលក្ខណៈរឹងមាំ

មិនថាមានការរៀបចំបែបណានោះទេ ប្រសិនបើរដ្ឋាភិបាល និងតួអង្គពាក់ព័ន្ធសំខាន់ៗដទៃទៀតពុំមានការប្តេជ្ញាចិត្តពិតប្រាកដ និងព័ត៌មានធនធានសមត្ថភាពសមស្រប ពេលនោះគេប្រាកដជាមានការលំបាកក្នុងការអនុវត្តយន្តការគណនេយ្យភាពជាមិនខាន។

១. **ព័ត៌មាន៖ គួរមានការផ្តល់ទិន្នន័យដែលមានតម្លាភាព ពាក់ព័ន្ធ និងឱ្យបានទាន់ពេលវេលាដល់អ្នកធ្វើសេចក្តីសម្រេចចិត្ត។**

ក. ជាការសំខាន់ដែលរដ្ឋាភិបាលត្រូវវិនិយោគលើការប្រមូលព័ត៌មាន ដើម្បីបង្កើនការយល់ដឹងអំពីចំណុចខ្លាំង និងចំណុចខ្សោយរបស់ប្រព័ន្ធអប់រំ និងជួយបង្កើតនូវប្រព័ន្ធគណនេយ្យភាពមួយដែលមានប្រសិទ្ធភាព។

ខ. ក្នុងពេលជាមួយគ្នា រដ្ឋាភិបាលក៏ចាំបាច់ត្រូវមានការប្រុងប្រយ័ត្នក្នុងការប្រើប្រាស់ទិន្នន័យនេះផងដែរ។ គួរមានការប្រមូលព័ត៌មានដែលស្របទៅតាមគោលបំណងនៃការប្រើប្រាស់ ហើយចំណាយចាយវាយលើការប្រមូលព័ត៌មាន គួរសមស្របទៅតាមសមត្ថភាពរបស់ប្រទេសដែលយកព័ត៌មាននេះមកប្រើ។

គ. ភារកិច្ចរាយការណ៍របស់គ្រូ និងនាយកសាលា មិនគួរត្រឹមតែមានកម្រិតត្រឹមតែជានីតិវិធីនោះឡើយ តែគួរផ្សារភ្ជាប់ជាមួយនឹងការកែលំអការបង្រៀនផងដែរ។

២. **ធនធាន៖ គួរមានការផ្តល់ធនធានឱ្យបានគ្រប់គ្រាន់ សម្រាប់ប្រព័ន្ធអប់រំ។**

ក. រដ្ឋាភិបាលគួរបំពេញទៅតាមការសន្យាចំណាយរបស់ខ្លួន ឱ្យបានយ៉ាងហោចណាស់៤ភាគរយនៃផសស សម្រាប់វិស័យអប់រំ ឬវិភាជន៍ថវិកាឱ្យបាន ១៥ ភាគរយនៃចំណាយសរុបរបស់រដ្ឋាភិបាល។

ខ. ប្រទេសអ្នកផ្តល់ជំនួយគួរបំពេញទៅតាមអ្វីដែលខ្លួនបានសន្យា ពោលគឺគួរផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការនេះឱ្យបានស្មើនឹង០,៧ភាគរយនៃចំណូលសរុបរបស់ខ្លួនក្នុងនោះ១០ភាគរយ

គួរវិភាជន៍សម្រាប់ការអប់រំ ថ្នាក់មូលដ្ឋាន និងការអប់រំកម្រិតមធ្យមសិក្សា។ ប្រទេសអ្នកផ្ដល់ជំនួយគួរមានការប្រុងប្រយ័ត្ន ក្នុងការផ្ដល់ហិរញ្ញប្បទានសហប្រតិបត្តិការបែបនេះ ដោយត្រូវប្រើប្រាស់យន្តការផ្អែកទៅតាមលទ្ធផល ព្រោះយន្តការ បែបនេះបង្វែរហានិភ័យទៅឱ្យប្រទេសដែលបានត្រៀមខ្លួនតិចតួចទៅវិញ។

៣. **សមត្ថភាព៖ គួរមានការបំពាក់បំប៉នតួអង្គនានានូវជំនាញ និងការបណ្ដុះបណ្ដាលដែលចាំបាច់ ដែលពួកគេអាចបំពេញការទទួលខុសត្រូវរបស់ខ្លួន។**

ក. រដ្ឋាភិបាលគួរធានាឱ្យមានស្ថាប័នដែលរឹងមាំ ដូចជាស្ថាប័នដែលបំពេញតួនាទីអនុវត្តច្បាប់ យុត្តិធម៌ និងសាវនកម្មជាដើម ដែលអាចជួយរកឱ្យឃើញ រារាំង និងស៊ើបអង្កេតករណីអំពើពុករលួយក្នុងវិស័យអប់រំ។

ខ. រដ្ឋាភិបាលគួរចាត់ទុកគ្រូបង្រៀនថាជាអ្នកជំនាញវិជ្ជាជីវៈ។ រដ្ឋាភិបាលគួរជួយកសាងវិជ្ជាជីវៈរបស់គ្រូ តាមរយៈការវិនិយោគលើកម្មវិធីការអប់រំ និងវិក្រឹតការដែលចាំបាច់នានា និងផ្ដល់ស្វ័យភាពដល់គ្រូ។ សមាគមគ្រូដែលមានគោលបំណងពង្រឹងវិជ្ជាជីវៈ របស់គ្រូតាមរយៈក្រមសីលធម៌ គួរជួយកសាងការយល់ដឹងសមាជិករបស់ខ្លួន និងកសាងជំនាញដល់អ្នកដែលមានភារកិច្ច គោរពទៅតាមយន្តការគណនេយ្យភាពផ្ទៃក្នុង។

គ. រដ្ឋាភិបាលចាំបាច់ត្រូវធានាយ៉ាងណាឱ្យអ្នកដែលវាយតម្លៃគ្រូ បានទទួលការបណ្ដុះបណ្ដាលសមស្រប ដើម្បីឱ្យពួកគេអាចយកចិត្តទុកដាក់លើការងារ ផ្ដល់ការគាំទ្រគ្រូ និងផ្ដល់លទ្ធភាពឱ្យគ្រូអាចធ្វើការបង្រៀន ដែលមានលក្ខណៈបរិយាប័ន្ន សមធម៌ ប្រកបដោយគុណភាពខ្ពស់។

ឃ. រដ្ឋាភិបាលគួរបង្កើនសមត្ថភាពតំណាងរបស់ខ្លួន ដើម្បីឱ្យពួកគេអាចចូលរួមយ៉ាងសកម្ម និងពិនិត្យតាមដានការងាររបស់អង្គការអន្តរជាតិនានា។ ដោយឡែក អង្គការអន្តរជាតិវិញ គួរផ្ដល់ឱកាសឱ្យមានការចូលរួមពីសមាជិករបស់ខ្លួន និងត្រូវមានតម្លាភាព ក៏ដូចជាត្រូវរាយការណ៍ព័ត៌មាននានាដល់សមាជិករបស់ខ្លួន។

## កំណត់សម្គាល់

## កំណត់សម្គាល់

## កំណត់សម្គាល់

## កំណត់សម្គាល់

# គណនេយ្យភាពក្នុងវិស័យអប់រំ

## ការបំពេញទៅតាមអ្វីដែលយើងបានសន្យា

កំណែទី ២ នៃ*របាយការណ៍ពិនិត្យតាមដានការអប់រំជាសកល* នេះ បង្ហាញពីភស្តុតាងចុងក្រោយ ដែលបង្ហាញពីវឌ្ឍនភាពសម្រេចបានក្នុងសកលលោកទាំងមូល ក្នុងការឈានទៅសម្រេចចំណុចដៅអប់រំនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ជាមួយនឹងស្ថានភាព ដែលមានមនុស្សរាប់រយលាននាក់ នៅពុំបានទៅរៀននិងជាច្រើននាក់ទៀតពុំបានទទួលជំនាញកម្រិតអប្បបរមាក្នុងសាលារៀន ដែលពួកគេកំពុងរៀននេះជាភស្តុតាងដែលបង្ហាញយ៉ាងច្បាស់ថាប្រព័ន្ធអប់រំនៅមិនទាន់អាចសម្រេចបាន គោលដៅសកលទាំងនេះឡើយ។ អ្នកដែលបាត់បង់ឱកាសបច្ចុប្បន្ននេះ ត្រូវទទួលរងផលប៉ះពាល់ជាងគេ ប៉ុន្តែក៏អាចទទួលបានអត្ថប្រយោជន៍ជាងគេផងដែរ ប្រសិនបើអ្នកតាក់តែងគោលនយោបាយផ្តោតការយកចិត្តទុកដាក់គ្រប់គ្រាន់ លើតម្រូវការរបស់ពួកគេ។ ប្រឈមជាមួយនឹងបញ្ហាទាំងនេះរួមនឹងថវិកាស្ទួចស្ទើងនិងមានការផ្តោតការយកចិត្តទុកដាក់កាន់តែច្រើនលើប្រយោជន៍ដែលបានមកវិញពីប្រាក់ដែលបានចំណាយផងនោះប្រទេសនានាកំពុងស្វែងរកដំណោះស្រាយ។ ការបង្កើនគណនេយ្យភាព តែងតែជាអាទិភាពចំពោះមុខសំខាន់ជាងគេ។

សេចក្តីសង្ខេបនៃរបាយការពិនិត្យតាមដានការអប់រំជាសកល ២០១៧/៨ នេះបង្ហាញពីវិធីសាស្រ្តជារួមដើម្បីធានាឱ្យមានគណនេយ្យភាពក្នុងវិស័យអប់រំ។ វិធីសាស្រ្តទាំងនេះមានចាប់ពីវិធីសាស្រ្ត ដែលប្រើប្រាស់នៅក្នុងប្រទេសដែលការបំពានសិទ្ធិទទួលបានការអប់រំពុំត្រូវបានគេសួរដេញដោលរហូតដល់ប្រទេសដែលចាត់ទុកគណនេយ្យភាព ជាគោលដៅចុងក្រោយជាជាងជាមធ្យោបាយ ដើម្បីសម្រេចការអប់រំបរិយាប័ន្នប្រកបដោយសមធម៌ និងគុណភាពខ្ពស់ និងការរៀនសូត្រពេញមួយជីវិតសម្រាប់ទាំងអស់គ្នា។

របាយការណ៍នេះគូសបញ្ជាក់ថា ការអប់រំគឺជាការទទួលខុសត្រូវរួម។ ខណៈពេលដែររដ្ឋាភិបាល ជាអ្នកមានការទទួលខុសត្រូវសំខាន់ជាងគេ តួអង្គពាក់ព័ន្ធដទៃទៀតដូចជាសាលារៀនគ្រូមាតាបិតាសិស្សអង្គការអន្តរជាតិអ្នកផ្តល់សេវាវិស័យឯកជនសង្គមស៊ីវិលនិងប្រព័ន្ធផ្សព្វផ្សាយសុទ្ធតែមានតួនាទីធ្វើឱ្យប្រព័ន្ធអប់រំនេះ កាន់តែមានភាពល្អប្រសើរជាមុន។ របាយការណ៍នេះគូសបញ្ជាក់ពីសារៈសំខាន់នៃតម្លាភាព និងភាពអាចរកបាននូវព័ត៌មាន ប៉ុន្តែក៏លើកទឹកចិត្តឱ្យមានការប្រុងប្រយ័ត្ន ពាក់ព័ន្ធនឹងរបៀបប្រើប្រាស់ទិន្នន័យផងដែរ។ របាយការណ៍នេះលើកទឹកចិត្តឱ្យមានការជៀសវាងការបង្កើតប្រព័ន្ធគណនេយ្យភាពទាំងឡាយណាដែលផ្តោតការយកចិត្តទុកដាក់លើលទ្ធផលដែលត្រូវបានកំណត់បែបចង្អៀតចង្អល់ និងលើការដាក់ទណ្ឌកម្មនៅក្នុងយុគសម័យដែលមានឧបករណ៍គណនេយ្យភាពចំរុះបែបនេះ របាយការណ៍ក៏បានផ្តល់នូវភស្តុតាង យ៉ាងច្បាស់អំពីឧបករណ៍គណនេយ្យភាពដែលមានប្រសិទ្ធភាព និងឧបករណ៍គណនេយ្យភាពដែលមានពុំមានប្រសិទ្ធភាពផងដែរ។




Global Education Monitoring Report

United Nations Educational, Scientific and Cultural Organization

Sustainable Development Goals

www.unesco.org/publishing • www.unesco.org/gemreport